


# ការធ្វើឲ្យមានតុល្យភាពយេនឌ័រ

## ប្រើប្រាស់សម្រាប់ការវាយតម្លៃហេតុ ប៉ះពាល់ យេនឌ័រក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនី

Australian Government
Department of Foreign Affairs and Trade

Australian Aid

CGIAR Challenge Program on
WATER & FOOD
Andes • Ganges • Limpopo • Mekong • Nile • Volta

OXFAM

**អុកស្វាម អូស្ត្រាលី**
132 Leicester Street
Carlton, Victoria 3053
Australia
Tel +61 3 9289 9444
Fax +61 3 9347 1983
www.oxfam.org.au

**គម្រោងថ្នាក់តំបន់របស់ អុកស្វាម លើផ្នែកអភិបាលកិច្ចទឹក**
អគារលេខ៩៤ មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ : +855 (0) 23885424
ទូរសារ : +855 23 885452

អ្នកនិពន្ធ : លោក ម៉ៃឃើល សាយមីន
អ្នកត្រួតពិនិត្យ : លោក ជេន យុនស៍ផ្ល័រ
អ្នករចនា : លោក ដានីញែល ខតន័រ និង លោក ម៉ាហ្គីន វ៉ាយ
បោះពុម្ពផ្សាយ លើកទី១ ខែតុលា ឆ្នាំ២០១៣
បោះពុម្ពផ្សាយ លើកទី២ ខែតុលា ឆ្នាំ២០១៤
អនុម័តចេញពីសៀវភៅណែនាំលើកទីមួយ ដែលបានបោះផ្សាយក្នុងខែតុលា ឆ្នាំ ២០១៣ ដោយមានផ្លាកសញ្ញាថ្មីរបស់អង្គការឌីហ្វាតនិងអង្គការអុកស្វាម។

**សេចក្តីថ្លែងអំណរគុណ**

អុកស្វាមសូមថ្លែងអំណរគុណដល់អ្នកដែលបានរួមចំណែកក្នុងការរៀបចំសៀវភៅណែនាំនេះ រួមមានសហសេវិករបស់អុកស្វាម មានលោក ប្រីយាជិត សមយ្យា នលិនិ កាស៊ីណាថន ជេស្ស៊ិកា រូសៀន ហ្គារី លី អេលីណា លេដ្រា និង ក្រុមការងាររបស់កម្មវិធីតំបន់ផ្នែកអភិបាលកិច្ចទឹកទន្លេមេគង្គ អុកស្វាម។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះលោកស្រី វាជីនា ស៊ីមសឹន ដែលបានផ្តល់ការរៀបចំការវាយតម្លៃដ៏មានសារៈសំខាន់លើគោលនយោបាយយេនឌ័រថ្នាក់ជាតិទន្លេមេគង្គនិងសិទ្ធិស្ត្រី។

យើងខ្ញុំសូមអរគុណជាពិសេសដល់លោក ជន់ណា ប្រោន លោក វេរីធី ប៉័រ លោកស្រី ខេត ឡាហ្សារុស និង លោកស្រី គ្រីស្ទីណា ហ៊ីល ដែលបានផ្តល់មតិយោបល់ និងការជួយត្រួតពិនិត្យក្នុងលក្ខណៈជាអ្នកជំនាញ។ យើងខ្ញុំសូមថ្លែងអំណរចំពោះការឧបត្ថម្ភនិងការណែនាំរបស់អង្គការជាដៃគូផ្នែកគម្រោង :

Green ID វៀតណាម វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ព្រមទាំង ក្រុមការងារអុកស្វាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះក្រុមការងារ CPWF នៅណាហ្គាហៅស៍ ផងដែរ។

រូបថតក្របមុខ : លោក ជេរី ហ្គែលា/អុកស្វាម អូស្ត្រាលី
កសិករស្ត្រី នៅទីក្រុងវៀងចន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

**អុកស្វាម**

អុកស្វាម គឺជាអង្គការផ្តល់ជំនួយនិងអភិវឌ្ឍន៍ ឯករាជ្យ មិនមែនរដ្ឋាភិបាល។ អង្គការនេះមានកម្មវិធីអភិវឌ្ឍន៍រយៈពេលវែងផ្តល់ការឆ្លើយតបផ្នែកមនុស្សធម៌ក្នុងពេលមានគ្រោះមហន្តរាយនិងជម្លោះក្នុងសង្គម និង គាំទ្រការផ្លាស់ប្តូរគោលនយោបាយនិងការអនុវត្តដែលលើកតម្កើងសិទ្ធិមនុស្សនិងយុត្តិធម៌។ កម្មវិធី ប្រជាជន ហេដ្ឋារចនាសម្ព័ន្ធ និង បរិស្ថាន និង កម្មវិធីអភិបាលកិច្ចទឹកតំបន់ទន្លេមេគង្គរបស់អុកស្វាមធ្វើការដើម្បីធ្វើឲ្យមានឥទ្ធិពលដល់គោលនយោបាយនិងការអនុវត្តរបស់ក្រុមហ៊ុនធ្វើទំនប់វារីអគ្គិសនី និង អ្នកផ្តល់ថវិកា ព្រមទាំងស្ថាប័នទ្វេភាគីឬពហុភាគីដែលគាំទ្រសកម្មភាពទំនប់វារីអគ្គិសនីនិងការគ្រប់គ្រងទឹក។ កម្មវិធីទន្លេមេគង្គរបស់អុកស្វាមធ្វើការជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់ដើម្បីឲ្យពួកគាត់មានការយល់ដឹងពីសិទ្ធិរបស់ខ្លួនក្នុងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។កម្មវិធីនេះផ្តោតលើសិទ្ធិមនុស្សយេនឌ័រ, ទំនាក់ទំនងរវាងសហគមន៍-ក្រុមហ៊ុននិងលើកកម្ពស់ការអនុវត្តល្អក្នុងអភិបាលកិច្ចទឹកឆ្លងព្រំដែន និង ការយល់ព្រម ដោយមិនមានការបង្ខិតបង្ខំ ដោយប្រាប់ជាមុន និង ដោយបានផ្សព្វផ្សាយមានបើកទូលាយ។

---

©Oxfam Australia and CPWF 2013
អុកស្វាម អូស្ត្រាលី គឺជាសមាជិកនក្រុមប្រឹក្សាអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលីដោយស្របច្បាប់និងក្រមសីលធម៌ព្រមទាំងស្របច្បាប់ដោយ ធម្មនុញ្ញរបស់អុកស្វាមអន្តរជាតិរួមទាំងក្រុមប្រឹក្សានៃជនភៀសខ្លួនអូស្ត្រាលីនិងជំនួយរបស់ប្រជាជន។ ឯកសារបោះពុម្ពលើកទី១អាចរកបាន
www.oxfam.org.au/giamanual និង at www.wle-mekong.cgiar.org/gender-impact-manual/

របៀបប្រើប្រាស់សៀវភៅណែនាំ ..... ៤

១ លំនាំដើម ..... ៧

១.១. ផលប៉ះពាល់យេនឌ័រពីវារីអគ្គិសនី ..... ៧

១.២. ភាពលម្អៀងផ្នែកយេនឌ័រក្នុងឧស្សាហកម្មវារីអគ្គិសនី ..... ៧

១.៣ បរិបទ : ហេតុអ្វីបានជាមានបញ្ហាយេនឌ័រ? ..... ៩

២ ហេតុអ្វីបានជាសៀវភៅណែនាំនេះមានសារៈសំខាន់ហើយហេតុអ្វីត្រូវមានពេលនេះ? ..... ១១

២.១ តើអ្នកណាដែលគួរប្រើសៀវភៅណែនាំ ..... ១១

២.២ តើសៀវភៅណែនាំនេះមានសារៈប្រយោជន៍ដូចម្តេចខ្លះ? ..... ១១

២.៣ ការធ្វើច្បាប់ជាតិនិងបរិបទគោលនយោបាយនៅតំបន់ទន្លេមេគង្គក្រោម ..... ១១

៣ ការវាយតម្លៃហេតុប៉ះពាល់ជារឿងល្អ : បរិបទនិងឱកាសនានាដែលកំពុងមាន ..... ១៥

៣.១ យេនឌ័រ : រចនាសម្ព័ន្ធទឹក ការវាយតម្លៃហេតុប៉ះពាល់ទំនប់វារីអគ្គិសនី ភាពងាយរងគ្រោះ និង ផលប៉ះពាល់ ១៧

៣.២ វារីអគ្គិសនីនិងយេនឌ័រ : ឱកាស ..... ២១

៤ ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ ៖ ឧបករណ៍វាយតម្លៃសំខាន់សម្រាប់អ្នកអភិវឌ្ឍ ..... ២៣

៤.១ តើអ្វីជាការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ? ..... ២៣

៤.២ ហេតុអ្វីបានជាធ្វើការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ? ..... ២៣

៤.៣ តើពេលណាគេគួរធ្វើការវាយតម្លៃហេតុប៉ះពាល់? ..... ២៤

៤.៤ អ្វីជាការអនុវត្តល្អនៅពេលមានការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ? ..... ២៦

៤.៥ ការជាប់ទាក់ទងនិងការចូលរួម ..... ២៦

៥ យេនឌ័រក្នុងអាងទន្លេមេគង្គ : មុនគម្រោង ..... ២៨

ដំណាក់កាលមុនគម្រោង : ការយល់ដឹងអំពីបរិបទ - ការប្រមូលទិន្នន័យនិងការបង្កើតមូលដ្ឋានយេនឌ័រ ..... ២៨

យេនឌ័រក្នុងការធ្វើការសម្រេចចិត្ត ..... ៣១

៦ ដំណើរការ ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ ..... ៣៤

៦.១ ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនៅក្នុងដំណាក់ការលទ្ធភាពប្រព្រឹត្តទៅរបស់គម្រោង ដំណាក់កាល កសាងគម្រោង និងដំណាក់កាលធ្វើផែនការ ..... ៣៥

ជំហានទី១ : ការប្រមូលទិន្នន័យ - ការបង្កើតទិន្នន័យបឋមជាក់លាក់ដែលអាចវិភាគយេនឌ័របាន ..... ៣៦

ជំហានទី២ : ការយល់ដឹងអំពីបរិបទ ..... ៣៦

ជំហានទី៣ : ការកំណត់រកបញ្ហាដែលកើតឡើងដោយសារទំនប់ ..... ៤៥

ជំហានទី៤ : ការយល់ដឹងអំពីតម្រូវការនិងសេចក្តីប្រាថ្នារបស់ស្ត្រី (និងបុរស) ..... ៥១

ជំហានទី៥ : យុទ្ធសាស្ត្រយេនឌ័រ និង ផែនការសកម្មភាព ..... ៥៧

ជំហានទី៦ : ការត្រួតពិនិត្យឡើងវិញ ការធ្វើសវនកម្ម និងការឆ្លើយតប ..... ៥៩

សេចក្តីសន្និដ្ឋាន ..... ៦១

សេចក្តីបន្ថែម ៖ ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី (HSAP) និង ឧបករណ៍ប៉ាន់ប្រមាណ ដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល (RSAT) ..... ៦៣

សទ្ទានុក្រមពាក្យនិងបញ្ញត្តិ ..... ៦៨

ឯកសារយោង ..... ៦៩

ធនធាននានា ..... ៧១

## របៀបប្រើប្រាស់សៀវភៅណែនាំ

គោលបំណងនៃសៀវភៅនេះគឺផ្តល់ប្រភពសាមញ្ញនិងឧបករណ៍មូលដ្ឋានសម្រាប់អ្នកអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនិងរដ្ឋាភិបាល ដើម្បីបញ្ចូលក្នុងការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ (GIA) ឲ្យបានកាន់តែពេញលេញក្នុងវដ្តគម្រោងរបស់ខ្លួន។

ក្នុងការបញ្ចូលការវាយតម្លៃហេតុប៉ះពាល់យេនឌ័រក្នុងដំណើរការសាងសង់ទំនប់វារីអគ្គិសនី ក្រុមហ៊ុនមានឱកាសធ្វើឲ្យប្រសើរឡើងនូវស្ថានភាពចំពោះស្ត្រីក៏ដូចជាបុរស។ ការប្រើការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រនឹងជួយក្រុមហ៊ុនឲ្យរកឃើញ និងគ្រប់គ្រងហានិភ័យ ដោយចៀសផុតពីលទ្ធភាពដែលគម្រោងអភិវឌ្ឍន៍របស់ខ្លួនមានលក្ខណៈរើសអើងចំពោះស្ត្រី និងការធ្វើឲ្យស្ត្រីកាន់តែមានសំឡេងតិចទៅ។

អង្គគោលដៅដំបូងរបស់សៀវភៅណែនាំនេះមាន បុគ្គលិកក្រុមហ៊ុន បុគ្គលិកពិគ្រោះយោបល់និង ស្ថាប័នរដ្ឋដែលមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងទន្លេ ការវាយតម្លៃហេតុប៉ះពាល់ និង ការអភិវឌ្ឍទំនប់វារីអគ្គិសនី។

សៀវភៅណែនាំនេះនឹងជួយលោកអ្នក ស្វែងរក ស្វែងយល់ អាចស្មានបាន និង ឆ្លើយតប ទៅនឹងភាពផ្សេងគ្នាផ្នែក យេនឌ័រ ឱកាស និង សេចក្តីត្រូវការ ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី។ សៀវភៅនេះបានបញ្ចូលសំណួរណែនាំសម្រាប់បុគ្គលិកដែលធ្វើការទាក់ទងនឹងគម្រោងនិងផែនការអភិវឌ្ឍនិងគ្រប់គ្រងទំនប់វារីអគ្គិសនី។ ខ្លឹមសារទូទៅនៃសៀវភៅគឺអាចជួយក្រុមហ៊ុនឲ្យពិចារណាការអនុវត្តរបស់ខ្លួនលើសពីកម្រិតគម្រោងទៅទៀត ជាពិសេសនោះ គឺគោលនយោបាយប្រតិបត្តិនិងក្របខណ្ឌគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុនតាមរយៈការធ្វើឲ្យប្រសើរឡើងនូវសមភាពយេនឌ័រនិងសិទ្ធិស្ត្រី។

សៀវភៅមានលក្ខណៈជាប្រភពមួយដែលអាចបត់បែនបាន ត្រូវយកកន្លែងណា ត្រូវចោលកន្លែងណា តាមការចាំបាច់ ដោយមិនតម្រូវឲ្យយកជាគោលនយោបាយលម្អិតឬការណែនាំដែលត្រូវបំពេញតាំងពីដើមដល់ចប់នោះឡើយ។ វាមិនមែនជាសៀវភៅដែលធ្វើតាមក្របខណ្ឌតក្កភាពដែលមានជំហានសំខាន់៦ស្របគ្នានឹងរបៀបរៀបចំគម្រោងមួយដែលល្អនិងស្របតាមគោលការណ៍គ្រប់គ្រងដែលប្រើប្រាស់ដោយក្រុមហ៊ុនភាគច្រើននោះទេ។

ជំពូកចំនួន៥ដំបូងបង្ហាញពីប្រវត្តិនិងមូលហេតុថា ហេតុអ្វីបានជាយេនឌ័រមានសារៈសំខាន់ តើការប៉ាន់ប្រមាណផលប៉ះពាល់លើយេនឌ័រអាចផ្តល់ប្រយោជន៍អ្វីខ្លះដល់អ្នកអភិវឌ្ឍន៍វារីអគ្គិសនី និង ហេតុអ្វីបានជាការពិចារណាលើសេចក្តីត្រូវការនិងអត្ថប្រយោជន៍ផ្សេងគ្នារបស់បុរសនិងស្ត្រីជារឿងល្អ។

ជំពូកទី៦និយាយពីសៀវភៅណែនាំដំណើរការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនិងបង្ហាញពី ឧបករណ៍ បញ្ជីផ្ទៀងផ្ទាត់ និង សំណួរណែនាំ ដែលអាចជួយលោកអ្នកឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនៅក្នុងវដ្តការងាររបស់ខ្លួន។

នៅផ្នែកចុងក្រោយ គឺជំពូកឧបសម្ព័ន្ធបង្ហាញពីរបៀបដែលយេនឌ័រត្រូវបានបញ្ចូលក្នុងឧបករណ៍ប៉ាន់ប្រមាណលើនិរន្តរភាពទំនប់វារីអគ្គិសនីចំនួន២ ព្រមទាំង មានអនុសាសន៍ដើម្បីកែសម្រួលធ្វើឲ្យប្រសើរឡើង។

ប្រភពព័ត៌មាន ឯកសារយោង និង សទ្ទានុក្រម នៃពាក្យបច្ចេកទេសទាក់ទងនឹងយេនឌ័រ មាននៅផ្នែកខាងក្រោយនេះ។ ខាងក្រោមជាព័ត៌មានពិស្តារនៃសៀវភៅណែនាំ :

ការវាយតម្លៃហេតុប៉ះពាល់ការប៉ាន់ប្រមាណផលប៉ះពាល់លើយេនឌ័រនៅក្នុងវដ្តគម្រោង



សៀវភៅណែនាំនេះមានជំពូកដូចខាងក្រោម ៖

## ១. លំនាំដើម

ជំពូកដំបូងបង្ហាញពីបញ្ញត្តិរបស់ពាក្យយេនឌ័រនិងទំនប់វារីអគ្គិសនីនិងបរិបទរបស់ពាក្យទាំងពីរក្នុងឧស្សាហកម្មវារីអគ្គិសនី។

## ២. ហេតុអ្វីបានជាមានសៀវភៅណែនាំនេះនិងហេតុអ្វីបានជាមាននៅពេលនេះ?

ជំពូកនេះបង្ហាញថា តើសៀវភៅនេះបង្កើតឡើងសម្រាប់នរណា តើមានអ្វីខ្លះក្នុងសៀវភៅនេះ និង តើសៀវភៅនេះមានប្រយោជន៍ដូចម្តេចខ្លះក្នុងការអភិវឌ្ឍគម្រោងទំនប់វារីអគ្គិសនី។សៀវភៅនេះបង្ហាញផងដែរពីការពិនិត្យមើលស្ថានភាពយេនឌ័រនៅអាងទន្លេមេគង្គក្រោម។ វាជាការវិភាគបរិបទនៃសិទ្ធិនិងយេនឌ័ររបស់ស្ត្រីក្នុងបរិបទការធ្វើច្បាប់ និង គោលនយោបាយនៅព្រះរាជាណាចក្រកម្ពុជា ប្រទេសឡាវ និង ប្រទេសវៀតណាម ដោយផ្តោតលើយុត្តិធម៌ផ្នែកយេនឌ័រនៅតំបន់ទន្លេមេគង្គក្រោម។

## ៣. ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រជារឿងល្អ បរិបទនិងឱកាសដែលកំពុងមាន

ជំពូកនេះពិនិត្យមើលថា តើយេនឌ័រនិងសិទ្ធិរបស់ស្ត្រីត្រូវបានដោះស្រាយយ៉ាងដូចម្តេចទាក់ទងនឹងផ្នែកឯកជននិងដំណើរការឧស្សាហកម្មវារីអគ្គិសនី។ យើងនឹងពិនិត្យបរិបទទាក់ទងនឹងជនជាតិដើមភាគតិច ឬនិគមជនជាតិពន្ធុនានានៅតាមដងទន្លេមេគង្គនិងរបៀបដែលគំនិតផ្តួចផ្តើមនៃឧស្សាហកម្មវារីអគ្គិសនីអាចអង្គុយពិភាក្សាគ្នាលើវិធីសាស្ត្ររបស់ភាគីពាក់ព័ន្ធនានានិងឧស្សាហកម្មវារីអគ្គិសនី។

## ៤. ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ ឧបករណ៍ដែលសំខាន់សម្រាប់អ្នកអភិវឌ្ឍន៍

ជំពូកនេះបង្ហាញពីទិដ្ឋភាពលម្អិតនៃការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនិងវិធីដែលគេអាចបញ្ចូលវាយតម្លៃនេះទៅក្នុងដំណើរការគ្រប់គ្រងគម្រោងនិងវដ្តការងារ។ ជំពូកនេះក៏បង្ហាញពីឱកាសនានាក្នុងការប្រើការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន និងសង្គមដើម្បីជាឧទាហរណ៍ និង វិធីសាស្ត្រអនុវត្តល្អៗជាមូលដ្ឋាន។

## ៥. យេនឌ័រនៅតាមអាងទន្លេមេគង្គដំណាក់កាលមុនគម្រោង

ជំពូកនេះពិនិត្យពីសារៈសំខាន់នៃការសិក្សាមូលដ្ឋានយេនឌ័រដើម្បីធ្វើផែនការយុទ្ធសាស្ត្រ ដោយពិចារណាពីកត្តា បរិស្ថាន សង្គម និងសេដ្ឋកិច្ច។ យើងនឹងពិនិត្យមើលសារៈសំខាន់នៃការបង្កើតមូលដ្ឋានយេនឌ័រសម្រាប់ទន្លេ មុននឹងមានការសម្រេចជាចុងក្រោយថានឹងសាងសង់ទំនប់។ ការសិក្សានេះនឹងអនុញ្ញាតឲ្យមានការវាយតម្លៃពីជម្រើសនានាប្រើសម្រាប់ការប្រើទន្លេនិងទឹកទន្លេ ដោយគិតពីភាគីពាក់ព័ន្ធផ្សេងៗផ្អែកលើការវិភាគបែបស៊ីជម្រៅពីយេនឌ័រ និងការយោគយល់រួមគ្នា។ ការសិក្សានឹងធានាថា រាល់ការដោះដូរផលប្រយោជន៍គ្នាដែលបានពិភាក្សានោះជាផ្នែកមួយនៃការធ្វើសេចក្តីការសម្រេចចិត្ត និងពិចារណាពីផលប៉ះពាល់ផ្នែកយេនឌ័រនិងឱកាសនានា។

## ៦. ដំណើរការការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រៈការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រក្នុងដំណាក់កាលគម្រោង

ជំពូកនេះបង្ហាញពីដំណើរការការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រ។ យើងនឹងឃើញពីវិធីសាស្ត្រជាជំហានៗក្នុងការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រ ដោយផ្តោតលើវិធីសាស្ត្រដែលប្រើនេះក្នុងបរិបទនៃការបង្កើតគម្រោង។ ជំពូកនេះសម្រួលឧបករណ៍វិភាគយេនឌ័រសម្រាប់បរិបទទំនប់វារីអគ្គិសនីដែលរួមមាន ឧបករណ៍សម្រាប់ទាញយកនិងប៉ាន់ប្រមាណទិន្នន័យដោយចែកតាមភេទដើម្បីបង្កើតមូលដ្ឋានគម្រោងដោយមានបញ្ចូលយេនឌ័រ និង ដើម្បីឲ្យមានការយោគយល់កាន់តែខ្លាំងពីបរិបទយេនឌ័រនិងផលប៉ះពាល់របស់គម្រោង។ លើសពីនេះជំពូកក៏បង្ហាញពីសំណួរណែនាំនៅជំហាននីមួយៗដើម្បីធានាថាមានការយល់ច្បាស់លាស់ទិដ្ឋភាពសំខាន់នៃ ទំនាក់ទំនង តួនាទី ការទទួលខុសត្រូវ និង អំណាចរបស់យេនឌ័រ។ នៅខាងចុងជំពូក មាននិយាយពីការបង្កើតផែនការសកម្មភាពយេនឌ័រ និង ដំណើរការនៃ ការត្រួតពិនិត្យ សវនកម្ម ព្រមទាំងការធ្វើរបាយការណ៍ ចំពោះលទ្ធផលការងារនានា។

## សេចក្តីសន្និដ្ឋានឧបសម្ព័ន្ធ១ - HSAP និង RSAT : តើឧបករណ៍ប៉ាន់ប្រមាណឧស្សាហកម្មវារីអគ្គិសនីទាំងពីរនេះវាយតម្លៃយេនឌ័រយ៉ាងដូចម្តេច?

ជំពូកចុងក្រោយនេះពិនិត្យមើលទិដ្ឋភាពរួមពីរបៀបដែលយេនឌ័រត្រូវបានដោះស្រាយដោយឧបករណ៍វិភាគឧស្សាហកម្មនិងភាគីពាក់ព័ន្ធចំនួនពីរដែលយកមកប្រើក្នុងការសិក្សាទន្លេមេគង្គនាពេលសព្វថ្ងៃ នោះគឺ HSAP (ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គិសនី)និង RSAT(ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីលើអាងទន្លេទាំងមូល)។ ជំពូកនេះមានបញ្ចូលអនុសាសន៍ដើម្បីប្រើឧបករណ៍ប៉ាន់ប្រមាណទាំងនេះឲ្យបានកាន់តែប្រសើរក្នុងការដោះស្រាយបញ្ហាយេនឌ័រទាក់ទងនឹងទំនប់វារីអគ្គិសនី។



ចម្ការតាមដងទន្លេជាប្រភពចំណូលចម្បង
និងផ្តល់សុវត្ថិភាពម្ហូបអាហារសម្រាប់គ្រួសារ។
ជាទូទៅ ស្ត្រីតែងថែទាំចម្ការទាំងនេះ។
រូបថត ៖ លោក ធីម៉ូធី ហ៊ើរបឺត/អុកស្វាម អូស្ត្រាលី



# ១ លំនាំដើម

## ១.១. ផលប៉ះពាល់យេនឌ័រនៃវារីអគ្គិសនី

ការអភិវឌ្ឍទំនប់វារីអគ្គិសនីនៅតំបន់ទន្លេមេគង្គកំពុងកើនឡើងយ៉ាងឆាប់រហ័ស។ ប្រទេសថៃ និងប្រទេសវៀតណាមបានអភិវឌ្ឍធនធានវារីអគ្គិសនីរបស់ខ្លួនយ៉ាងខ្លាំង និងបានគិតគូរពីផលប្រយោជន៍ផ្សេងៗទាក់ទងនឹងការអភិវឌ្ឍក្នុងតំបន់។ ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ប្រទេសភូមាវិញក៏មានផែនការទាក់ទងនឹងការអភិវឌ្ឍលើដងទន្លេរបស់ខ្លួនដែរ។ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវបានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថានឹងយកការអភិវឌ្ឍទំនប់វារីអគ្គិសនីដើម្បីបង្កើតជា ធុងអាគុយសម្រាប់អាស៊ីអាគ្នេយ៍។ ការអភិវឌ្ឍដែលមានក្នុងផែនការជាច្រើនក្នុងតំបន់ទន្លេមេគង្គ គឺស្ថិតនៅដងទន្លេដែលឆ្លងព្រំដែនរបស់ប្រទេស។

នៅពេលមានគម្រោងថ្មីស្នើឡើងនិងបង្កើតឡើង គេហាក់មិនសូវគិតគូរពីសារៈសំខាន់នៃអភិបាលកិច្ចល្អនៃធនធានទន្លេ ការធ្វើផែនការឆ្លងព្រំដែនប្រទេសនិងថ្នាក់ជាតិនិងការវាយតម្លៃហេតុប៉ះពាល់នានា។

វារីអគ្គិសនីបានរួមចំណែកធ្វើឲ្យមានការអភិវឌ្ឍជាតិនៅប្រទេសជាច្រើនក្នុងសកលលោក។ ទោះបីវាជាបច្ចេកវិទ្យាជាចាស់បើប្រៀបធៀបនឹងបច្ចេកវិទ្យាជាថាមពលកកើតឡើងវិញក្តី វានៅមានតួនាទីសំខាន់ក្នុងប្រព័ន្ធថាមពលជាច្រើន។ ទោះជាយ៉ាងណាក្តី ឧស្សាហកម្មវារីអគ្គិសនីនិងប្រទេសក្នុងតំបន់ទន្លេមេគង្គក៏ទទួលស្គាល់ពីការសាងសង់ទំនប់វារីអគ្គិសនីដែលមានផលប៉ះពាល់អវិជ្ជមានទៅលើទន្លេនិងបរិស្ថាន។

ទាក់ទងនឹងការប៉ះពាល់បរិស្ថាន ទំនប់វារីអគ្គិសនីក៏បានប៉ះពាល់ផងដែរលើសហគមន៍ និងប្រជាជនដែលប្រើទន្លេនិងរស់នៅជុំវិញដងទន្លេ។ ទំនប់អាចធ្វើឲ្យការប្រើប្រាស់ធនធានធម្មជាតិរបស់ប្រជាជនមានការប្រែប្រួល ដូចជា ដី និង ទឹក តំបន់ដីសើម ព្រៃឈើ និង ធនធានក្នុងទឹក។ ទំនប់វារីអគ្គិសនី ជារឿយៗ ធ្វើឲ្យមានការផ្លាស់ទីលំនៅសហគមន៍ដោយបង្ខំហើយដែលបណ្តាលឲ្យមានបញ្ហាសង្គមនិងផ្លូវចិត្តធំធេងណាស់ចំពោះបុគ្គលម្នាក់ៗក៏ដូចជាចំពោះសហគមន៍ទាំងមូលដែរ។

ការប៉ះពាល់នេះមានចំពោះ បុរសនិងស្ត្រី ក្មេងស្រីនិង ក្មេងប្រុស មនុស្សក្មេងនិងមនុស្សចាស់ មនុស្សពិការ និងជនជាតិដើមភាគតិចផ្សេងៗ។ ផលប៉ះពាល់នេះបានធ្វើឲ្យខ្ទេចខ្ទាំចំណងទំនាក់ទំនងសហគមន៍និងជីវិតរស់នៅ។ សហគមន៍និងក្រុមគ្រួសារដែលមានតួនាទីយេនឌ័រនិងការទទួលខុសត្រូវនានាសុទ្ធតែត្រូវរងផលប៉ះពាល់។

ក្នុងសង្គមជាច្រើន ស្ត្រីជាអ្នកដែលទទួលអំរែកក្នុងការងារផ្ទះសំបែងនិងក្រុមគ្រួសារ ព្រមទាំងតួនាទីនិងកិច្ចការជាច្រើនទៀតក្នុងសហគមន៍។ ចំពោះសហគមន៍ដែលចំណងទាក់ទងរបស់ សង្គម, វប្បធម៌ និង សេដ្ឋកិច្ច មានលក្ខណៈស្មុគស្មាញជាមួយនឹង ដីធ្លី ទន្លេ និង ទីកន្លែង ការផ្លាស់ប្តូរដែលបណ្តាលមកពីទំនប់វារីអគ្គិសនីពិតជាមានទំហំធំធេងណាស់។ ជាពិសេសទៀតនោះ ការផ្លាស់ទីលំនៅគឺធ្វើឲ្យមានភាពក្រីក្រ ដោយសារថា វាបានធ្វើឲ្យបាត់បង់ធនធាន សេដ្ឋកិច្ច សង្គម និង វប្បធម៌ នៅពេលផ្លាស់ទីលំនៅនោះ (Koenig 2002 ត្រូវបានដកស្រង់ក្នុង Scudder 2005)។ ស្ទើរតែគ្រប់ករណី នៅពេលមានការផ្លាស់ប្តូរបណ្តាលមកពីទំនប់ គឺស្ត្រីជាជនដែលរងផលប៉ះពាលអវិជ្ជមានខ្លាំងជាងគេ។

ការសាងសង់ទំនប់និងការអភិវឌ្ឍវារីអគ្គិសនីជាចំណែកដ៏សំខាន់ដែលនាំមកនូវការរីកចម្រើនទូទាំងពិភពលោក។ ប៉ុន្តែ គេមិនត្រូវមើលរំលងផលប៉ះបាល់អវិជ្ជមានរបស់វាឡើយ ហើយ ជារឿយៗ ផលប៉ះពាល់ទាំងនេះមិនសូវគេធ្វើរបាយការណ៍ឬមិនសូវគេផ្តល់សារៈសំខាន់ក្នុងការប៉ាន់ប្រមាណពីតម្លៃនិងនិរន្តរភាពនៃគម្រោងទេ។

ផលប៉ះពាល់ទាំងនេះ ជាទូទៅ ជាប់ទាក់ទិននឹងការអភិវឌ្ឍទំនប់វារីអគ្គិសនីនៅទូទាំងពិភពលោក ហើយ វិធីសាស្ត្រជាដំណោះស្រាយក្នុងសៀវភៅណែនាំនេះគឺទាក់ទងនឹងបញ្ហានេះឯង។ ទោះយ៉ាងណាក្តី ដើម្បីលើកបញ្ហានៃផលប៉ះពាល់ និងបង្ហាញពីឱកាសសមភាពយេនឌ័រ សៀវភៅណែនាំនេះផ្តោតលើបរិបទយេនឌ័រលើការអភិវឌ្ឍវារីអគ្គិសនីក្នុងតំបន់ទន្លេមេគង្គ។

## ១.២. ភាពលម្អៀងផ្នែកយេនឌ័រក្នុងឧស្សាហកម្មវារីអគ្គិសនី

ដូចគ្នានឹងវិស័យវិស្វកម្មនិងហេដ្ឋារចនាសម្ព័ន្ធជាច្រើន តាមប្រវត្តិសាស្ត្រ វិស័យវារីអគ្គិសនីជាឧស្សាហកម្មដែលគ្រប់គ្រងដោយបុរស។ ដំណើរការជាច្រើនក្នុងការផលិតវារីអគ្គិសនី គិតតាំងពីវិស្វកម្មរហូតដល់ការផ្លាស់ទីលំនៅនោះសុទ្ធតែគ្រប់គ្រងដោយបុរសហើយលទ្ធផលដែលបានមកភាគច្រើនគឺមានប្រយោជន៍ដល់មនុស្សប្រុស។

គេសង្ឃឹមថានឹងមានការប្រែប្រួលពីបញ្ហានេះទោះបីការប្រែប្រួលនោះយឺតយ៉ាងណាក៏ដោយចុះ។ នាពេលបច្ចុប្បន្ន ស្ត្រីបានលេចមុខក្នុងបញ្ហាសង្គមនិងបរិស្ថាននៃអាជីវកម្មវារីអគ្គិសនី ឬ ក្នុងផ្នែកនិរន្តរភាព ឬ ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន។ ប៉ុន្តែ ជាទូទៅ ស្ត្រីនិងផលប្រយោជន៍របស់ស្ត្រីនៅតែគេមិនសូវឃើញមានក្នុងការសម្រេចចិត្តកម្រិតខ្ពស់ក្នុងគម្រោងទំនប់វារីអគ្គិសនីនិងក្នុងក្រុមហ៊ុនវារីអគ្គិសនី។

ឧទាហរណ៍ សមាគមវារីអគ្គិសនីអន្តរជាតិ (IHA) ដែលជាអង្គការកំពូលក្នុងវិស័យវារីអគ្គីសនី មានសមាជិកគណៈកម្មការនាយកចំនួន២២រូប តែ មានស្ត្រីចំនួនតែ៣រូបប៉ុណ្ណោះ។ ប្រធានសមាគម នាយកប្រតិបត្តិ និង នាយករង សុទ្ធតែជាបុរស។ នៅក្នុងក្រុមហ៊ុនជាសមាជិក បញ្ហានេះក៏ប្រហាក់ប្រហែលគ្នាដែរ។



អាងស្តុកទឹកទំនប់ណាំធៀន២និងតំបន់ព្រៃឈើដែល
ត្រូវលិចលង់, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
រូបថត ៖ ម៉ៃឃើល សាយមឹន/អុកស្វាម អូស្ត្រាលី



- សាជីវកម្មថាមពលទឹកជ្រោះ៣នៅប្រទេសចិនមានសមាជិកគណៈកម្មការនាយក៩រូបសុទ្ធតែជាបុរសទាំងអស់។[1]

- សមាជិកជាន់ខ្ពស់នៃគណៈកម្មការនាយកនិងនាយកប្រតិបត្តិរបស់ក្រុមហ៊ុនទំនប់វារីអគ្គិសនីតាស់ស្មាញ៉ារបស់ប្រទេសអូស្ត្រាលីមានតំណែងទាំងអស់១៧កន្លែង ក្នុងនោះ ១២តំណែងគ្រប់គ្រងដោយបុរស និង ៥តំណែងគ្រប់គ្រងដោយស្ត្រី។[2]

- ក្រុមហ៊ុន ស្តាតក្រាហ្វថ៍ របស់ប្រទេសណ័រវែសមានសមាជិកគណៈកម្មការនាយក បុរស៦នាក់ ស្ត្រី៦នាក់ ស្មើគ្នា ប៉ុន្តែក្រុមអ្នកគ្រប់គ្រងមានបុរស៦នាក់ស្ត្រី១នាក់ប៉ុណ្ណោះ។[3] រីឯ ក្រុមហ៊ុន ទំនប់វារីអគ្គិសនីបារាំង មានគណៈកម្មការនាយក បុរស១៤នាក់ និង ស្ត្រី៤នាក់ ហើយគណៈកម្មការប្រតិបត្តិមាន បុរស៨នាក់ និង ស្ត្រី១នាក់។[4]

ការមានស្ត្រីតំណាងនៅក្នុងរចនាសម្ព័ន្ធសាជីវកម្មជាជំហានមួយក្នុងការផ្តល់អំណាចដល់ស្ត្រី។ លើសពីរឿងតំណាងនេះទៀតនោះគឺមានគោលនយោបាយដែលលើកតម្កើងសិទ្ធិនិងណែនាំសេចក្តីសម្រេចជាយុទ្ធសាស្ត្រដោយផ្អែកលើការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រនិងឱកាសនានា នឹងមានន័យថា បុគ្គលិកគម្រោងមានបរិបទគោលនយោបាយច្បាស់លាស់ដើម្បីប្រតិបត្តិការងារ។ វាជាការចាំបាច់ដែលបុគ្គលិកទទួលបានការបណ្តុះបណ្តាល ត្រូវបានផ្តល់ធនធាន និង អាចប្រតិបត្តិគោលនយោបាយនៅកម្រិតគម្រោងមូលដ្ឋាន។ សៀវភៅណែនាំនេះផ្តល់តម្រុយដល់ក្រុមហ៊ុនវារីអគ្គិសនីដើម្បីធ្វើឲ្យទាំងបុរសទាំងស្ត្រីទទួលបានលទ្ធផលវិជ្ជមាន។

## ១.៣ បរិបទ : ហេតុអ្វីបានជាមានបញ្ហាយេនឌ័រ

តើវាពិតជាមានបញ្ហាឬដែលបុរសគ្រប់គ្រងផ្តាច់មុខក្នុងឧស្សាហកម្មនិងកម្រិតនៃការសម្រេចចិត្តក្នុងក្រុមហ៊ុនសាជីវកម្ម? កម្មការិនីមានចំនួន ៤០ភាគរយនៃកម្លាំងពលកម្មក្នុងពិភពលោក ប៉ុន្តែ ក្នុងវិស័យជាច្រើនដូចជា រ៉ែ សំណង់ និង ថាមពល ជាដើម ស្ត្រីមានចំនួនតិចតួចប៉ុណ្ណោះ ហើយ ស្ទើរតែគ្រប់វិស័យ គេកម្រឃើញស្ត្រីមានតំណែងជាអ្នកគ្រប់គ្រងដូចបុរសណាស់។ ស្ត្រីនៅតែជួបបញ្ហាជាច្រើនក្នុងការចូលរួមដោយពេញលេញ និងប្រកបដោយផ្លែផ្កាក្នុងទីផ្សារការងារ ក្នុងនោះ មានការរើសអើងនិងគំនិតចាស់គំរិលទាក់ទងតួនាទីយេនឌ័រ ហើយ ការចូលរួមរបស់ស្ត្រីទៀតសោតក៏មិនសូវគេឲ្យតម្លៃជានិច្ចកាលដែរ។ [IFC 2013, p. 2.]

អ្នកគ្រប់គ្រងក្រុមហ៊ុនសាជីវកម្មនិងក្របខណ្ឌគោលនយោបាយនឹងបញ្ជាក់ពីគម្រោងនានាដែលត្រូវបានបង្កើតឡើងនិងគ្រប់គ្រងមានលក្ខណៈយ៉ាងណា ហើយ ក្នុងករណីនេះ បើខ្វះការចូលរួមនិងមានតំណាងរបស់ស្ត្រីតិចតួចនោះ គេពិបាកនឹងនិយាយថាគម្រោងមួយបានពិចារណានិងយកចិត្តទុកដាក់ចំពោះសិទ្ធិស្ត្រីរួមទាំងសេចក្តីត្រូវការរបស់យេនឌ័រ និងឱកាសនានាបានពេញលេញណាស់។

តាមប្រវត្តិកន្លងមក គម្រោងទំនប់វារីអគ្គិសនីធ្វើឲ្យមានបញ្ហាធ្ងន់ធ្ងរថែមទៀតដល់ភាពលម្អៀងផ្នែកយេនឌ័រដែលកំពុងមានហើយបានជះឥទ្ធិពលអវិជ្ជមានជាដល់តួនាទីនិងឋានៈរបស់ស្ត្រីក្នុងគ្រួសារនិងសហគមន៍ចំពោះគម្រោងទាក់ទង នឹងប្រជាជនដែលរងផលប៉ះពាល់។ លទ្ធផលអវិជ្ជមានចំពោះជីវភាពរស់នៅរបស់ស្ត្រីនៅកម្រិតមូលដ្ឋាន និង ភាពក្រីក្រ ផលប៉ះពាល់លើសុខភាព និង អារម្មណ៍តក់ស្លុត ដែលកើតដោយសារការផ្លាស់ទីលំនៅនិងការដកហូតយកដីរបស់ពួកគាត់ដោយជាប់ទាក់ទងនឹងការសង់ទំនប់វារីអគ្គិសនី គឺមានការចងក្រងឯកសារទុកច្បាស់លាស់ដែលបង្ហាញពីការប៉ះពាល់អារម្មណ៍របស់ស្ត្រីជាខ្លាំង។(WCD 2000, p.114)

ប៉ុន្តែ ទំនប់វារីអគ្គិសនី ក៏ដូចគម្រោងហេដ្ឋារចនាសម្ព័ន្ធឯទៀតដែរអាចធ្វើឲ្យមានតួនាទីវិជ្ជមានក្នុងទំនាក់ទំនងយេនឌ័រ។ គណៈកម្មការពិភពលោកស្តីពីទំនប់បានកត់សម្គាល់ថា ៖

"... ដោយសារយេនឌ័រជាបញ្ញត្តិជាប់ទាក់ទងនឹងការសាងសង់ទំនប់ ការទទួលបានផលប្រយោជន៍ដោយស្ត្រីដែលកើតឡើងពីទំនប់គឺជារឿងចាំបាច់ ប៉ុន្តែ នៅមិនទាន់ជាលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ធ្វើឲ្យមានផលប៉ះពាល់លើយេនឌ័រដោយវិជ្ជមាននោះទេ" (WCD 2000, p.114-115)

WCD បានបញ្ជាក់ថា ប្រសិនបើទំនប់បង្កើតឡើងដោយគោរពសិទ្ធិនិងផលប្រយោជន៍ស្ត្រី រួមទាំងបុរសផង ហេដ្ឋារចនាសម្ព័ន្ធទឹកមានលទ្ធភាពអាចឲ្យស្ត្រីនិងបុរសសម្រេចផលប្រយោជន៍បានស្មើគ្នា។ ប្រសិនបើរឿងនេះប្រព្រឹត្តទៅបានត្រឹមត្រូវនោះ គម្រោងនានាអាចមានតួនាទីដែលនាំមកនូវការផ្លាប់ប្តូរក្នុងទំនាក់ទំនងយេនឌ័រ។

1. China Three Gorges Power Corporation 2002-2010, Corporation Information, Management Team, viewed 14 August 2013, http://www.ctgpc.com/information/information_b.php
2. Hydro Tasmania 2013, About us, viewed 14 August 2013, http://www.hydro.com.au/about-us/governance
3. Statkraft n.d., Group management, viewed 14 August 2013, http://www.statkraft.com/about-statkraft/organisation/group-management/
4. EDF 2013, Board of directors, viewed 14 August 2013, http://about-us.edf.com/governance/board-of-directors-43708.html



ការអប់រំពីការអភិរក្សត្រីនិងសហគមន៍នេសាទជារឿងសំខាន់
ក្នុងជីវភាពរស់នៅប្រកបដោយនិរន្តភាព, ប្រទេសឡាវ។
រូបថត ៖ ដេវី ហ្គេលា/អុកស្វាម អូស្ត្រាលី



## ២ ហេតុអ្វីបានជាសៀវភៅណែនាំនេះមានសារៈសំខាន់ហើយហេតុអ្វីត្រូវមានពេលនេះ?

### ២.១ តើអ្នកណាដែលគួរប្រើសៀវភៅណែនាំ

សៀវភៅណែនាំសរសេរឡើងដើម្បីលើកតម្កើងការពិចារណាឲ្យច្រើនឡើងលើយេនឌ័រក្នុងការអភិវឌ្ឍវារីអគ្គិសនី។ គោលបំណងសៀវភៅនឹងជួយបុគ្គលិកក្រុមហ៊ុនទំនប់វារីអគ្គិសនីក្នុងការងារពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់និងគ្រប់គ្រងហានិភ័យក្នុងការអភិវឌ្ឍវារីអគ្គិសនី។ ដូច្នេះគេគួរផ្តល់ដំណឹងការធ្វើសេចក្តីសម្រេចចិត្តនិងការអនុវត្តគម្រោងទំនប់វារីអគ្គិសនី ដើម្បីឲ្យមានការគិតគូរស្មើគ្នានូវ ផលប៉ះពាល់ សិទ្ធិ និង ឱកាសចំពោះស្ត្រីនិងបុរស។ សៀវភៅនេះបង្ហាញពីឧបករណ៍វាយតម្លៃដែលមានសារៈសំខាន់ចំពោះបុគ្គលិកគម្រោងក្នុងក្រុមហ៊ុនទំនប់វារីអគ្គិសនី និង ចំពោះបុគ្គលិករដ្ឋាភិបាលដែលទទួលខុសត្រូវក្នុងការបង្កើតគម្រោងនិងប្រតិបត្តិគម្រោង។

សៀវភៅនេះរៀបចំឡើងដើម្បីបង្ហាញឲ្យឃើញច្បាស់ពីផលប៉ះពាល់សង្គមនិងបរិស្ថាននិងដំណើរការគ្រប់គ្រង។ គោលបំណងគឺថាសៀវភៅនេះអាចប្រើដោយភាគីពាក់ព័ន្ធផ្សេងៗក្នុងក្រុមហ៊ុនទំនប់វារីអគ្គិសនី ពោលគឺមិនចំពោះតែបុគ្គលិកដែលធ្វើការទំនាក់ទំនងនឹងសហគមន៍ឬផ្នែកគ្រប់គ្រងបរិស្ថានឬសង្គមនោះឡើយ។

### ២.២ តើសៀវភៅណែនាំនេះមានសារៈប្រយោជន៍ដូចម្តេចខ្លះ?

សៀវភៅណែនាំនេះបង្ហាញហេតុផលថា ៖

- ហេតុអ្វីការបញ្ចូលការពិចារណាបន្ថែមទៀតលើផលប៉ះបាល់យេនឌ័រនឹងធ្វើឲ្យមានគម្រោងនិងលទ្ធផលប្រកបដោយនិរន្តរភាព
- តើការធ្វើការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនឹងធ្វើឲ្យគម្រោងកាន់តែប្រសើរឡើង
- ហេតុអ្វីការបញ្ចូលស្ត្រីឲ្យកាន់តែជ្រៅនិងឲ្យបានជាប់លាប់ក្នុងដំណើរការ ការវាយតម្លៃហេតុប៉ះពាល់ការធ្វើផែនការ និង ការធ្វើសេចក្តីសម្រេចចិត្ត នឹងនាំឲ្យមានគម្រោងកាន់តែប្រសើរឡើង។

សៀវភៅណែនាំនេះផ្តល់ការពិចារណា"ចំៗ"លើយេនឌ័រក្នុងការធ្វើផែនការនិងអភិបាលកិច្ចធនធានទឹក។ ហេតុផលមូលដ្ឋាននៃចំណុចនេះគឺការធានាថា ទាំងសំឡេងស្ត្រីទាំងសំឡេងបុរសត្រូវបានយកចិត្តទុកដាក់ ហើយ ផលប្រយោជន៍និងសិទ្ធិរបស់ពួកគេត្រូវបានពិចារណា ដែលនឹងចៀសផុតឬបន្ថយផលប៉ះពាល់អវិជ្ជមានលើស្ត្រី។ការចូលរួមដែលមានសារៈសំខាន់ក្នុងដំណើរការនានានិងការធ្វើសេចក្តីសម្រេចចិត្តគឺជាកត្តាសំខាន់ទាក់ទងនឹងបញ្ហានេះ។

នៅក្នុងករណីជាច្រើន ក្រោយពីការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនិងការធ្វើផែនការសកម្មភាពយេនឌ័រ គម្រោងនានាអាចមានការកែប្រែ។ ចំណុចនេះអាចជួយសម្រួលការបែងចែកធនធានបន្ថែមទៀតក្នុងការកាត់បន្ថយ ការសម្រួល ឬ ដំណើរការចែករំលែកផលប្រយោជន៍សំដៅឲ្យលទ្ធផលដល់ស្ត្រីជាពិសេស។ នៅក្នុងករណីខ្លះទៀតនោះបញ្ហានេះបង្កឲ្យគម្រោងនានាត្រូវផ្អាកឬឈប់ដំណើរការដោយសារមានការរកឃើញនានាក្នុងការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រ។ រាល់ជម្រើសទាំងនេះការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រត្រូវបានគេមើលឃើញថា ជាឧបករណ៍ប៉ាន់ប្រមាណការគ្រប់គ្រងហានិភ័យ។ នៅពេលប្រើឲ្យបានសព្វគ្រប់ទៅ ការប៉ាន់ប្រមាណនេះអាចជួយឲ្យគម្រោងរួមចំណែកក្នុងការធ្វើរបៀបវារៈដែលនាំឲ្យមានការផ្លាស់ប្តូរចំពោះសហគមន៍ដែលទទួលរងគ្រោះ ដែលនឹងបង្ហាញឲ្យឃើញពីលទ្ធផលប្រកបដោយនិរន្តរភាពថែមទៀត។

សៀវភៅនេះបង្ហាញពីសារៈសំខាន់និងអត្ថប្រយោជន៍នៃឧបករណ៍ប៉ាន់ប្រមាណជាច្រើនដែលប្រើរួចហើយដោយក្រុមហ៊ុនទំនប់វារីអគ្គិសនី និងស្ថាប័ននានារបស់រដ្ឋាភិបាល។ សៀវភៅនេះជាធនធានមួយសម្រាប់ក្រុមហ៊ុនពិគ្រោះយោបល់ដែលលទ្ធផលការងារអាចធ្វើឲ្យគម្រោងទទួលបានព្រឹត្តិការណ៍សំខាន់ក្នុងការយល់ព្រម។ ឧបករណ៍ប៉ាន់ប្រមាណជាច្រើនក្នុងចំណោមនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនិងមានការទទួលស្គាល់ច្រើន។ ឧបករណ៍ទាំងនេះត្រូវបានសម្រេចយកនិងលើកតម្កើងដោយអ្នកផ្តល់ថវិកាចំពោះគម្រោងទំនប់វារីអគ្គិសនី ហើយ ជាលទ្ធផលមានភស្តុតាងបញ្ជាក់ពីការប្រើប្រាស់និងតម្លៃក្នុងគម្រោងនានា។

សៀវភៅនេះក៏ពិនិត្យមើលផងដែរពីឧបករណ៍វិភាគថ្មីៗដែលបង្កើតឡើងដើម្បីវាស់និរន្តរភាពក្នុងគម្រោងទំនប់វារីអគ្គិសនីនិងរបៀបដែលគម្រោងទាំងនេះពិចារណាលើយេនឌ័រនិងធ្វើសំណូមពរដើម្បីធ្វើយ៉ាងណាឲ្យយេនឌ័រកាន់តែរឹងមាំឡើង។

សៀវភៅណែនាំនេះបង្ហាញពីចំណុចបន្ថែមនៃលក្ខណៈវិនិច្ឆ័យនិងសំណួរដែលផ្តោតលើ យេនឌ័រចំពោះឧបករណ៍ប៉ាន់ប្រមាណទាំងនេះដែលបង្ហាញពីបរិបទការអភិវឌ្ឍទំនប់វារីអគ្គិសនី។ យើងសង្ឃឹមថា សៀវភៅណែនាំនេះផ្តល់តម្លៃបន្ថែម ដល់ការធ្វើគម្រោងអភិវឌ្ឍន៍ និង ដល់ដំណើរការត្រួតពិនិត្យនិងការអនុវត្តតាមរបស់រដ្ឋាភិបាលនានា។

### ២.៣ ការធ្វើច្បាប់ជាតិនិងបរិបទគោលនយោបាយនៅតំបន់ទន្លេមេគង្គក្រោម

ការអភិវឌ្ឍទំនប់វារីអគ្គិសនីមានការរីកចម្រើនខ្លាំងក្លាណាស់នៅតំបន់ទន្លេមេគង្គក្រោម។ ស្របពេលនឹងការធ្វើឲ្យការអនុវត្តយេនឌ័ររបស់អ្នកអភិវឌ្ឍវិស័យឯកជន និងអ្នកផ្តល់ថវិកាកាន់តែប្រសើរឡើងជារឿងសំខាន់គោលនយោបាយ និងការធ្វើច្បាប់របស់រដ្ឋាភិបាលនឹងត្រូវបញ្ជាក់ពីការរំពឹងទុកចំពោះគម្រោងមួយ។ នៅផ្នែកខាងក្រោមយើងនឹងពិនិត្យបរិបទនេះ។

ប្រទេសកម្ពុជា ប្រទេសវៀតណាម និង ប្រទេសឡាវសុទ្ធតែមានការចែងក្នុង ច្បាប់រដ្ឋធម្មនុញ្ញ និង ក្របខណ្ឌគោលនយោបាយជាតិ ថាលើកតម្កើងយុត្តិធម៌យេនឌ័រនិងជំរុញសមភាពភេទនៅក្នុងការអភិវឌ្ឍជាតិ។ ជាមួយគ្នានេះដែរ ប្រទេសទាំងនេះបានប្តេជ្ញាអនុវត្តតាមអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិនិងសេចក្តីថ្លែងការសំខាន់ៗ ដែលបញ្ជាក់ពីកាតព្វកិច្ចរបស់រដ្ឋនីមួយៗ។ ទាក់ទងនឹងបញ្ហាទន្លេមេគង្គដែលហូរឆ្លងព្រំដែនប្រទេសវាមានសារៈសំខាន់ណាស់ដែលគេត្រូវពិចារណាលើអភិបាលកិច្ចរបស់រដ្ឋា

ភិបាល ការរំពឹងទុកក្នុងការគ្រប់គ្រង និង ការប្ដេជ្ញាចិត្ត ជាបន្ថែមទៀត។

ការពិភាក្សាខាងក្រោមនេះពិនិត្យលើបរិបទច្បាប់ និងគោលនយោបាយក្នុងការបញ្ចូលនិងវិភាគយេនឌ័រនៅកម្រិតជាតិ។ បរិបទនេះបង្ហាញការរំពឹងទុករបស់រដ្ឋាភិបាលចំពោះស្ថាប័នអនុវត្តច្បាប់នានានិងអ្នកអភិវឌ្ឍវិស័យឯកជនក្នុងការបញ្ចូលយេនឌ័រនិងលទ្ធផលដែលបានមក។ ផ្នែកដែលយើងសិក្សានេះគឺជាសេចក្ដីសង្ខេបការវិភាគដ៏វែងស្ដីពីបរិបទជាតិនៃប្រទេសនីមួយៗ (Simpson 2013)។[៥]

ស្របពេលដែលរដ្ឋាភិបាលប្រទេសទាំងបីបានប្ដេជ្ញាចិត្តចំពោះយេនឌ័រនិងសមភាពនៃឱកាសក្នុងការអភិវឌ្ឍដល់ប្រជាពលរដ្ឋរបស់ខ្លួននោះ បញ្ហាប្រឈមចាំបាច់គឺការអនុវត្តនិងការត្រួតពិនិត្យគោលនយោបាយនិងច្បាប់នានាក្នុងការអភិវឌ្ឍគម្រោងវារីអគ្គិសនី។ ចំណុចប្រសព្វគ្នារវាងកាតព្វកិច្ចនិងសេចក្ដីត្រូវការរបស់រដ្ឋ និង ការប្រតិបត្តិការងារនិងកាតព្វកិច្ចរបស់ក្រុមហ៊ុនម៉ៅការឯកជន គឺជាចំណុចរួមបំផុតមួយដែលផលប៉ះពាល់អវិជ្ជមានលើយេនឌ័រ (និង ផលប៉ះពាល់ដទៃទៀត) ទាក់ទងយ៉ាងខ្លាំងជាមួយសហគមន៍ដែលរងគ្រោះដោយការគម្រោង។ នេះជាបរិបទសម្រាប់អ្នកអភិវឌ្ឍវិស័យឯកជននៅតាមដងទន្លេមេគង្គ។

## សង្គមយេនឌ័រនិងទន្លេមេគង្គ

ដើម្បីនឹងប៉ាន់ប្រមាណពីរបៀបនិងមូលហេតុការធ្វើច្បាប់និងគោលនយោបាយជាតិប្រែប្រួលយ៉ាងដូចម្ដេចក្នុងប្រទេសនានាវាមានសារៈសំខាន់ដែលគេត្រូវយល់ពីផ្នត់គំនិតជាប្រពៃណីក្នុងប្រទេសនីមួយៗ។

គេអាចនិយាយបានថា ប្រទេសវៀតណាមនិងប្រទេសកម្ពុជាមានចំណុចរួមដូចគ្នា គឺប្រទេសទាំងពីរឲ្យតម្លៃបុរសជាធំ។ ចំណុចនេះមានន័យថា តាមប្រវត្តិសាស្ត្រ បុរសត្រូវបានគេចាត់ទុកជាមេគ្រួសារចំណែកឯស្ត្រីមានឋានៈទាបជាង ហើយ គេគិតថា ស្ត្រីគួរសន្សំកម្លាំងថែទាំស្វាមីនិងក្រុមគ្រួសារ។ ជាលទ្ធផល គេឃើញថា ស្ត្រី ទទួលបានចំណេះដឹងតិចតួច មានសិទ្ធិតិចតួច ហើយ ហាក់ដូចជាមិនសូវបានរួមចំណែកក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តអ្វីក្រៅក្នុងផ្ទះនោះទេ(ADB 2012; Tran 2001)។

នៅប្រទេសវៀតណាម អាកប្បកិរិយាទាំងនេះមានឫសគល់ចេញពីទ្រឹស្ដីចរិយាធម៌របស់ទស្សនវិទូ ខុង ជឺ នៅប្រទេសចិន។ នៅប្រទេសកម្ពុជាមានច្បាប់ស្រី និង ច្បាប់ប្រុស។

ផ្ទុយទៅវិញ ជនជាតិតៃ នៅប្រទេសឡាវ ដែលមាន ៦៧%នៃប្រជាជនឡាវនោះ ជាទូទៅ គោរពមាតាធិបតេយ្យ (ADB 2012)។ ចំណុចនេះមានន័យថា ស្ត្រីមានឋានៈខ្ពស់ជាងគេក្នុងគ្រួសារហើយជាអ្នកត្រូវទទួលកេរមរតកជាដីនិងទ្រព្យសម្បត្តិ (FAO 2012) ។ ទោះយ៉ាងណាក្ដី និគមជនជាជាតិពន្ធុភាគច្រើននៅប្រទេសឡាវអនុវត្តការឲ្យតម្លៃបុរសជាធំប្រហាក់ប្រហែលនឹងប្រទេសវៀតណាមនិងប្រទេសកម្ពុជាដែរ ហើយជនជាតិភាគតិចខ្លះទៀតកាន់ទំនៀមពហុពន្ធភាព (មានប្ដីឬប្រពន្ធច្រើន) និង ស្ត្រីរៀបការនៅវ័យក្មេង (FAO 2012) ពោលគឺ ប្រជាជនឡាវទាំងមូលជាប់ចំណាត់ថ្នាក់ទី១៣៩ក្នុងចំណោម១៨៦ប្រទេស យោងតាមតារាងវិសមភាពយេនឌ័ររបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិឆ្នាំ ២០១២[៦] (UNDP 2012)។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី១៣៨ ហើយ ប្រទេសវៀតណាមជាប់ចំណាត់ថ្នាក់ទី១២៧ (UNDP 2012)។

## ការធ្វើច្បាប់និងក្របខណ្ឌគោលនយោបាយជាតិ

រដ្ឋធម្មនុញ្ញទាំងបីប្រទេសលើកតម្កើងសិទ្ធិនៃពលរដ្ឋរបស់ខ្លួនថាមានភាពស្មើគ្នាចំពោះមុខច្បាប់។ ក្នុងនោះមានការនិយាយពីការលើកតម្កើងឋានៈស្ត្រីក្នុងគ្រួសារ។ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជានិងប្រទេសឡាវប្ដេជ្ញាធ្វើឲ្យប្រសើរឡើងនូវការអភិវឌ្ឍ និងសុខមាលភាពស្ត្រី ហើយប្រទេសវៀតណាមនិងប្រទេសកម្ពុជាបានហាមប្រាមដាច់ខាតមិនឲ្យមានការរើសអើងចំពោះស្ត្រី។ ប្រទេសវៀតណាម និងប្រទេសឡាវបានបញ្ជាក់ពីសិទ្ធិរបស់ស្ត្រីចំពោះសមភាពក្នុងផ្នែកសេដ្ឋកិច្ចនិងនយោបាយ។

ប្រទេសទាំងបីបានកំណត់យកយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងបរិបទអភិវឌ្ឍន៍ជាតិ ដោយឲ្យមានការទទួលខុសត្រូវលើការបញ្ជ្រាបនិងការរំពឹងទុកច្បាស់លាស់មួយចំនួនចំពោះក្រសួងសំខាន់នានាដែលជាប់ទាក់នឹងបញ្ហាទំនប់វារីអគ្គិសនី។ ឧទាហរណ៍, នៅប្រទេសកម្ពុជា ក្រសួង រ៉ែ និង ថាមពល មានក្រុមការងារនិងផែនការបញ្ជ្រាបយេនឌ័រនៅប្រទេសវៀតណាម ក្រសួងធនធានធម្មជាតិ និងបរិស្ថានមានផែនការសកម្មភាពស្ដីពីសមភាពយេនឌ័រនិងការលើកតម្កើងស្ត្រី ដែលរួមមានការប្ដេជ្ញាក្នុងការបញ្ជ្រាបយេនឌ័រក្នុងការធ្វើផែនការ និងការគ្រប់គ្រងធនធានទឹក។ ជាទូទៅ ការបកស្រាយវិធីសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រ និងការអនុវត្តនៃការបញ្ជ្រាបនេះខុសពីប្រទេសមួយទៅប្រទេសមួយ ហើយបញ្ហាដែលថាតើយន្តការទាំងនេះមានប្រសិទ្ធភាពបែបណាក្នុងបរិបទនៃការអភិវឌ្ឍវារីអគ្គិសនីនោះជាចំណុចដែលយើងត្រូវសិក្សា។[៧]

## ការអភិវឌ្ឍនិងសិទ្ធិស្ត្រី

ក្នុងចំណោមប្រទេសទាំងបី មានតែប្រទេសកម្ពុជាប៉ុណ្ណោះដែលមិនមានច្បាប់មួយដែលប្ដេជ្ញាថា នឹងការពារនិងលើកតម្កើងសមភាពយេនឌ័រ។ ប្រទេសវៀតណាមមានច្បាប់សមភាពយេនឌ័រ(២០០៦) ដែលមានខ្លឹមសារថា "ធានាថា មានសមភាពយេនឌ័រនៅគ្រប់វិស័យទាំងអស់នៃ នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គម និង គ្រួសារ គាំទ្រនិងបង្កើតលក្ខខណ្ឌដល់បុរសនិងស្ត្រីក្នុងការបញ្ចេញសមត្ថភាពរបស់ខ្លួន និង ផ្ដល់ឲ្យពួកគេនូវឱកាសស្មើភាពក្នុងការចូលរួមក្នុងដំណើរការអភិវឌ្ឍនិងទទួលផលពីការអភិវឌ្ឍ" ។ ទាក់ទងនឹងយុត្តិធម៌យេនឌ័រខ្លឹមសារចុងក្រោយនេះជាចំណុចទាក់ទងសំខាន់។ ប្រទេសឡាវមានច្បាប់ស្ដីពីការអភិវឌ្ឍនិងការពារស្ត្រី (ឆ្នាំ២០០៤) លើកតម្កើងសមភាពក្នុង "ស្វ័យអភិវឌ្ឍន៍" ដែលស្ត្រីនិងបុរស មានតម្លៃនិងឱកាសដូចគ្នាក្នុងវិស័យ នយោបាយ សេដ្ឋកិច្ច សង្គម និង វប្បធម៌ [កិច្ចការ]គ្រួសារ ការការពារនិងសន្តិសុខជាតិ និង ការបរទេស ..."។ ប្រទេសទាំងបីមានយុទ្ធសាស្ត្រជាតិនិងគម្រោងទាក់ទងនឹងការអភិវឌ្ឍស្ត្រី។ ប្រទេសវៀតណាមមាន យុទ្ធសាស្ត្រជាតិ

៥. របាយការណ៍នៃ ប្រទេសឡាវ, ប្រទេសវៀតណាម និង ប្រទេសកម្ពុជា អាចទាញយកចេញគេហទំព័រ www.oxfam.org.au/giamanual
៦. គណនាដោយផ្អែកលើតារាងបង្ហាញ ការផ្ដល់អំណាច, សុខភាពបន្តពូជ និង ការងារ។
៧. គណៈកម្មការទន្លេមេគង្គ សហការណ៍ជាមួយ GIZ កំពុងដោះស្រាយថា តើត្រូវជំរុញយ៉ាងដូចម្ដេចដើម្បីឲ្យមានការពិចារណាពីយេនឌ័រតាមការពិភាក្សានិងកម្មវិធីការងារនៃគំនិតផ្ដួចផ្ដើមស្ដីពីនិរន្តរភាពទំនប់វារីអគ្គិសនី និរន្តរភាព។

ស្តីពីសមភាពយេនឌ័រសម្រាប់ឆ្នាំ២០១១-២០២០។ ប្រទេសឡាវមាន យុទ្ធសាស្ត្រជាតិជាតិ ដើម្បីការលើកតម្កើងស្ត្រី (២០១១-២០១៥) (NSAW) ហើយ ប្រទេសកម្ពុជា មាន នារីរតនៈលើកទី៣ (២០០៩-២០១៣)[៨] ជាទូទៅ មានគោលដៅរួម ដូចជា ការធ្វើឲ្យប្រសើរឡើងនូវការអប់រំ សុខភាព ការងារ ការចូលរួមផ្នែកនយោបាយ និង ការលើកកម្ពស់ស្មារតីយេនឌ័រ ការបញ្ជ្រាបយេនឌ័រ ព្រមទាំង យន្តការ នៅក្នុងរដ្ឋាភិបាលនីមួយៗ។ ប្រទេសវៀតណាមមាន យុទ្ធសាស្ត្រយេនឌ័រដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (២០០៥) ដើម្បីធ្វើឲ្យប្រសើរឡើងនូវ "ការទទួលបាននិងការចូលរួមក្នុងការគ្រប់គ្រងធនធានសំខាន់ ដែលរួមមាន ទឹក ដី ហេដ្ឋារចនាសម្ព័ន្ធ សេវាឥណទាន និង សេវាសាធារណៈ នៅក្នុងវិស័យនេះ [ការអភិវឌ្ឍកសិកម្មនិងជនបទ]"។ លើសពីនេះយុទ្ធសាស្ត្រនេះបានលើកអនុសាសន៍ថា "ផ្តោតចម្បងលើយេនឌ័រ[និង] ពិនិត្យលើការបែងចែកតាមភេទ និង ឧបករណ៍ប៉ាន់ប្រមាណក្នុង គោលនយោបាយ ផែនការ កម្មវិធី និង កម្មវិធី អភិវឌ្ឍន៍នានា"។ ចំណុចនេះប្រហែលជាយុទ្ធសាស្ត្រដែលទាក់ទងផ្ទាល់ក្នុងការកំណត់សេចក្តីត្រូវការរបស់ស្ត្រីដែលរងផលប៉ះពាល់ដោយសារទំនប់វារីអគ្គិសនី។

## ការអភិវឌ្ឍ និងជនជាតិដើមភាគតិច និងនិគមជនជាតិពន្ធ

នៅប្រទេសឡាវ មាន គោលការណ៍ណែនាំស្តីពីការសងសំណង និងការដោះស្រាយលើគម្រោងអភិវឌ្ឍន៍ (២០០៥) តម្រូវឲ្យធ្វើ ផែនការអភិវឌ្ឍនិគមជនជាតិពន្ធនៅគ្រប់គម្រោងអភិវឌ្ឍន៍ដែលនិគមជនជាតិពន្ធទំនងនឹងទទួលរងផលប៉ះពាល់ដោយសារការអភិវឌ្ឍ។ គោលនយោបាយនិងការធ្វើច្បាប់ខ្លះក្នុងប្រទេសទាំងបីដែលដោះស្រាយចំពោះនិគមជនជាតិពន្ធផ្តោតលើការលុបបំបាត់ការរើសអើងនិងការធ្វើឲ្យប្រសើរឡើងជាទូទៅនូវសេវាកម្មនានានិងគាំទ្រនិគមជនជាតិពន្ធ។ ទាំងយុទ្ធសាស្ត្រកំណើនជាតិនិងការលុបបំបាត់ភាពក្រីក្រ របស់ប្រទេសឡាវ ទាំង ច្បាប់ស្តីពីសមភាពយេនឌ័រ (២០០៦) របស់ប្រទេសវៀតណាម សុទ្ធតែទទួលស្គាល់ពីការលំបាកដែលស្ត្រីនិគមជនជាតិពន្ធជួបប្រទះ។ ប៉ុន្តែ ជាទូទៅមានគោលនយោបាយនិងការធ្វើច្បាប់ជាក់លាក់មានកំណត់ណែនាំពីលទ្ធផលយេនឌ័រក្នុងបរិបទនៃផលប៉ះពាល់លើប្រជាជនជាជនជាតិដើមនៅក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនី។

## សិទ្ធិលើដីនិងធនធានធម្មជាតិ

សិទ្ធរបស់ស្ត្រីលើដី ទាំងការទទួលមរតកនិងភាពជាម្ចាស់ ត្រូវទទួលការការពារនៅប្រទេសទាំងបីដោយចែងក្នុងមាត្រានានានៃច្បាប់ ដី ទ្រព្យសម្បត្តិ ធនធាន។[៩] ប្រទេសទាំងបីទទួលស្គាល់ តាមផ្លូវច្បាប់របស់ខ្លួនថា ដីដែលទទួលបានគូស្វាមីភរិយា (ដោយរួមបញ្ចូលការផ្លាស់ប្តូរទីលំនៅថ្មី) ជារបស់ប្រពន្ធក៏ដូចជារបស់ស្វាមី ហើយបណ្ណកម្មសិទ្ធិត្រូវមានឈ្មោះទាំងពីរនាក់។

ប្រទេសកម្ពុជាមាន អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច(២០០៣) ជានាសិទ្ធិគ្រប់គ្រងផ្ទះសំបែងរបស់ស្ត្រីដើម្បីចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច[១០] ដែលគាំទ្រការទទួលបានរបស់ស្ត្រីដែលងាយរងគ្រោះក្នុងការប្រើប្រាស់ដីនិងធនធានធម្មជាតិ ដែលរបស់ទាំងនេះមានសារៈសំខាន់ជាពិសេសនៅក្នុងបរិបទនៃការដេកហូតយកដី ទឹក ទ្រព្យសម្បត្តិ និង ធនធាននានា ទាក់ទងនឹងគម្រោងទំនប់វារីអគ្គិសនី។

## ផែនការអភិវឌ្ឍជាតិ

បណ្តាប្រទេសទាំងបី យុទ្ធសាស្ត្រការធ្វើផែនការជាតិរបស់ប្រទេសឡាវបានបញ្ចូលដោយគ្របដណ្តប់លើបញ្ហាសមភាពយេនឌ័រច្រើនជាងគេ។ ផែនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិលើកទី៧ (២០១១-២០១៥) ដែលបញ្ចូលទំនប់វារីអគ្គិសនីជាចំណុចអាទិភាពនៃការអភិវឌ្ឍនោះ បង្ហាញពីសកម្មភាពជាច្រើនទាក់ទងនឹងការកសាងសមត្ថភាពរបស់ស្ត្រីក្នុងការពិភាក្សានយោបាយនិងការអភិវឌ្ឍសង្គមបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើផែនការនៅថ្នាក់ខេត្តខ័ណ្ឌនិងការបញ្ចូលការពិចារណាលើយេនឌ័រទៅក្នុងនោះ ជានាថា ស្ត្រីអាចទទួលបានសិទ្ធិរបស់គេ និង បង្កើនការស្រាវជ្រាវទាក់ទងនឹងយេនឌ័រឲ្យកាន់ស៊ីជម្រៅដើម្បីដោះស្រាយបញ្ហាទាំងឡាយខាងលើ។

យុទ្ធសាស្ត្រកំណើនជាតិនិងការលុបបំបាត់ភាពក្រីក្ររបស់ប្រទេសឡាវ ក៏បានធ្វើការសង្កត់ធ្ងន់លើទំនប់វារីអគ្គិសនីដែលជាមធ្យោបាយទាក់ទាញការវិនិយោគពីបរទេស និង មានផ្នែកនិយាយលម្អិតពី យុទ្ធសាស្ត្រយេនឌ័រដើម្បីកាត់បន្ថយភាពក្រីក្រ ដែលរួមមានបញ្ជាក់ពីសកម្មភាពច្បាស់លាស់ក្នុងការបញ្ជ្រាបយេនឌ័រនៅគ្រប់វិស័យ កសិកម្ម អប់រំ សុខភាព ការដឹកជញ្ជូន និង នយោបាយ។ ទោះយ៉ាងណាក្តី ផែនការអភិវឌ្ឍន៍ជាតិនានារបស់ប្រទេសវៀតណាមនិងប្រទេសកម្ពុជាមាននិយាយទូទៅពីបំណងប្រាថ្នាក្នុងការមានសមភាពយេនឌ័រ ប៉ុន្តែ មិនបានបញ្ចូលវិធីសាស្ត្រឬគោលដៅជាក់លាក់ដើម្បីធ្វើឲ្យសម្រេចបាននោះទេ។

## ការអភិវឌ្ឍវិស័យថាមពល

ដោយមានចក្ខុវិស័យទូលំទូលាយក្នុងការអភិវឌ្ឍវិស័យថាមពល (វារីអគ្គិសនី) ប្រទេសឡាវបានបង្ហាញជំហរយ៉ាងច្បាស់ក្នុងការប្រើប្រាស់ការវិនិយោគនិងការធ្វើគម្រោងដើម្បីសម្រេចលទ្ធផលផ្នែកយេនឌ័រនានា។

ចំណុចជាពិសេសនោះ គឺ យុទ្ធសាស្ត្រអភិវឌ្ឍថាមពលកកើតឡើងវិញ (២០១១) របស់ប្រទេសឡាវមានបញ្ចូលការធ្វើឲ្យកើនឡើងសមភាពយេនឌ័រជាវត្ថុបំណងដ៏ចម្បង ក៏ដូចជា "ការអភិវឌ្ឍដែលគិតគូរដល់និរន្តរភាពបរិស្ថាននិងសង្គមតាមរយៈការពង្រឹងការការពារគ្រប់គ្រាន់ដើម្បីធានា ... សហគមន៍មូលដ្ឋាននូវសុវត្ថិភាពស្បៀង និងធ្វើឲ្យពួកគាត់ទទួលបានដីគ្រប់គ្រាន់ដើម្បីបំពេញនិងអភិវឌ្ឍជីវភាពរស់នៅសម្រាប់រាល់ក្រុមជនជាតិដើមភាគតិច ដោយសង្កត់ធ្ងន់ជាពិសេសលើស្ត្រី"។ យុទ្ធសាស្ត្រនេះមិនបាននិយាយលម្អិតពីរបៀបថា តើត្រូវសម្រេចវត្ថុបំណងទាំងនេះ

---

៨. នារីរតនៈ ជា "ស្ត្រីជាត្បូងមានតម្លៃ" ជាផ្នែកមួយនៃសមភាពយេនឌ័រនិងផែនការយុទ្ធសាស្ត្រផ្តល់ដំណាចដល់ស្ត្រី របស់រាជរដ្ឋាភិបាលកម្ពុជា រៀបចំដោយដោយក្រសួងកិច្ចការនារី។

៩. ជាឧទាហរណ៍ មាត្រា៤៣នៃច្បាប់ភូមិបាល(២០០៣)របស់ប្រទេសឡាវចែងថា ប័ណ្ណចុះបញ្ជីដី ដែលជាទ្រព្យសម្បត្តិពីខាងមាតា ត្រូវមានឈ្មោះទាំងស្វាមីទាំងភរិយា។ នៅប្រទេសវៀតណាម មាត្រា២៧នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ(ឆ្នាំ១៩៨៦, ធ្វើវិសោធនកម្មឆ្នាំ២០០០)និយាយថា រាល់ដីទាំងអស់ដែលទទួលបានអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ជាទ្រព្យសម្បត្តិរួម ហើយ ទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយស្វាមីនិងភរិយាត្រូវចុះឈ្មោះទាំងស្វាមីទាំងភរិយា។ តម្រូវការនេះបញ្ជាក់ក្នុងមាត្រា៤៨នៃច្បាប់ភូមិបាល(២០០៣)ផងដែរ។

១០. សម្បទានដីសង្គមកិច្ចជាយន្តការដែលដីត្រូវបានផ្តល់ដល់សហគមន៍ដែលផ្លាស់ទីលំនៅដោយសារការអភិវឌ្ឍនៅប្រទេសកម្ពុជា។

យ៉ាងណានោះទេ ប៉ុន្តែ ***ការវាយតម្លៃហេតុប៉ះពាល់***សង្គម និងគោលការណ៍បច្ចេកទេស លើការសងសំណងនិងការតាំងទីលំនៅថ្មីក្នុងគម្រោងអភិវឌ្ឍ (២០០៥) បានបញ្ជាក់យ៉ាងច្បាស់ពីការរំពឹងទុកចំពោះការប្រមូលទិន្នន័យមានប៉ះពាល់ដល់យេនឌ័រ និងការផ្តល់សិទ្ធិតាំងទីលំនៅថ្មី។ គោលការណ៍ដែលកំពុងរៀបចំសម្រាប់ការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្ឃឹមថានឹងបន្តដោយមានការពិចារណាឲ្យបានជិតដល់ពីយេនឌ័រ។

ច្បាប់និងយុទ្ធសាស្ត្រទូលំទូលាយរបស់ប្រទេសវៀតណាមសម្រាប់ការធ្វើផែនការនិងការអភិវឌ្ឍថាមពលអគ្គិសនី និង ការវិនិយោគ ហាក់ដូចជាមិនឃើញនិយាយពីយេនឌ័រសោះ។ ការធ្វើផែនការថាមពលនិងអគ្គិសនីរបស់ប្រទេសកម្ពុជាក៏ហាក់ដូចជាខ្វះការសម្រេចចិត្តឬការបញ្ចូលការពិចារណាពីយេនឌ័របានច្បាស់លាស់។

## កិច្ចព្រមព្រៀងអន្តរជាតិសំខាន់ៗនិងរដ្ឋាភិបាលក្នុងតំបន់ទន្លេមេគង្គ

ប្រទេសវៀតណាម ប្រទេសកម្ពុជា និង ប្រទេសឡាវ បានចុះផ្តល់សច្ចាប័ន ឬ យល់ព្រមលើកិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធជាច្រើនដូចដែលមានក្នុងតារាងខាងក្រោម។

មាត្រានៅក្នុងកិច្ចព្រមព្រៀងណាដែលទំនងជាលើកតម្កើងយុត្តិធម៌យេនឌ័រការអភិវឌ្ឍទំនប់វារីអគ្គិសនីត្រូវបានរំលេចខាងក្រោម។ រាល់ការព្យាយាមការធ្វើគោលនយោបាយនៃប្រទេសទាំងបីមានពិភាក្សានៅខាងក្រោមជាបន្ទាប់។

## កិច្ចព្រមព្រៀងទាក់ទងនឹងយុត្តិធម៌យេនឌ័រក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនី

| | ប្រទេសវៀតណាម | ប្រទេសកម្ពុជា | ប្រទេសឡាវ |
|---|---|---|---|
| CEDAW: កតិកាសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី (អនុម័តនាថ្ងៃ១៨ខែធ្នូឆ្នាំ១៩៧៩) | ចុះហត្ថលេខាថ្ងៃទី២៩ ខែកក្កដាឆ្នាំ១៩៨០ ផ្តល់សច្ចាប័នថ្ងៃទី១៧ ខែកុម្ភៈឆ្នាំ១៩៨២ | ចុះហត្ថលេខាថ្ងៃទី១៧ខែតុលាឆ្នាំ១៩៨០ ផ្តល់សច្ចាប័នថ្ងៃទី១៥ខែតុលាឆ្នាំ១៩៩២ | ចុះហត្ថលេខាថ្ងៃទី១៧ខែកក្កដាឆ្នាំ១៩៨០ ផ្តល់សច្ចាប័នថ្ងៃទី១៤ខែសីហាឆ្នាំ១៩៨១ |
| CEDAW-OP: ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រីភេទ (អនុម័តនាថ្ងៃទី៦ខែតុលាឆ្នាំ១៩៩៩) | មិនទាន់បានចុះហត្ថលេខា | ចុះហត្ថលេខាថ្ងៃទី១១ខែវិច្ឆិកាឆ្នាំ២០០១ ផ្តល់សច្ចាប័នថ្ងៃទី១៣ខែតុលាឆ្នាំ២០១០ | មិនទាន់ចុះហត្ថលេខា |
| ICESCR: កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ (អនុម័តពីថ្ងៃពី១៦ខែធ្នូឆ្នាំ១៩៦៦) | ផ្តល់សច្ចាប័ននៅថ្ងៃទី២៤ ខែកញ្ញាឆ្នាំ១៩៨២ | ចុះហត្ថលេខាថ្ងៃទី១៧ ខែតុលាឆ្នាំ១៩៨០ យល់ព្រមថ្ងៃទី២៦ ខែឧសភាឆ្នាំ១៩៩២ | ចុះហត្ថលេខាថ្ងៃទី៧ ខែធ្នូឆ្នាំ២០០០ ផ្តល់សច្ចាប័នថ្ងៃទី១៣ ខែកុម្ភៈឆ្នាំ២០០៧ |
| ICESCR-OP: ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ (អនុម័តពីថ្ងៃពី១៦ខែធ្នូឆ្នាំ១៩៦៦) | មិនទាន់បានចុះហត្ថលេខា | មិនទាន់បានចុះហត្ថលេខា | មិនទាន់បានចុះហត្ថលេខា |
| ICCPR: កតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(អនុម័តថ្ងៃទី១៦ខែធ្នូឆ្នាំ១៩៦៦) | ផ្តល់សច្ចាប័ននៅថ្ងៃទី២៤ ខែកញ្ញាឆ្នាំ១៩៨២ | ចុះហត្ថលេខាថ្ងៃទី១៧ ខែតុលាឆ្នាំ១៩៨០ យល់ព្រមថ្ងៃទី២៦ ខែឧសភាឆ្នាំ១៩៩២ | ចុះហត្ថលេខាថ្ងៃទី៧ ខែធ្នូឆ្នាំ២០០០ ផ្តល់សច្ចាប័នថ្ងៃទី២៥ ខែកញ្ញាឆ្នាំ២០០៩ |
| ICCPR-OP: ពិធីសារបន្ថែមនៃកតិកញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(អនុម័តថ្ងៃទី១៦ខែធ្នូឆ្នាំ១៩៦៦) | មិនទាន់បានចុះហត្ថលេខា | ចុះហត្ថលេខាថ្ងៃទី២៧ ខែកញ្ញាឆ្នាំ២០០៤ | មិនទាន់បានចុះហត្ថលេខា |
| សេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិច | បោះឆ្នោតគាំទ្រនៅក្នុងសមាជអង្គការសហប្រជាជាតិ ថ្ងៃទី១៣ខែកញ្ញាឆ្នាំ២០០៧ | បោះឆ្នោតគាំទ្រនៅក្នុងសមាជអង្គការសហប្រជាជាតិ ថ្ងៃទី១៣ខែកញ្ញាឆ្នាំ២០០៧ | បោះឆ្នោតគាំទ្រនៅក្នុងសមាជអង្គការសហប្រជាជាតិ, ថ្ងៃទី១៣ខែកញ្ញាឆ្នាំ២០០៧ |

***កតិកាសញ្ញាស្តីពីការលុបចំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ*** តម្រូវឲ្យមានការលុបបំបាតរាល់ទម្រង់ប្រឆាំងនឹងស្ត្រីភេទ។ ដោយមានចែងក្នុងរដ្ឋធម្មនុញ ហើយ មិនមានច្បាប់ណាឬគោលនយោបាយណាដែលបង្ហាញក្នុងរបាយការណ៍នេះមានលក្ខណៈរើសអើងខ្លាំងនោះ វាចាំបាច់សម្រាប់ការបន្តអនុវត្តយ៉ាងសកម្មនូវសមភាពយេនឌ័រដើម្បីឲ្យសម្រេចក្នុងភាពជាក់ស្តែង។ ប្រទេសវៀតណាមនិងប្រទេសឡាវទាំងពីរមានច្បាប់ដែលផ្តោតលើយេនឌ័រដែលបោះជំហានឆ្ពោះទៅកាន់គោលដៅនេះ ប្រទេសកម្ពុជាហាក់ដូចជាមិនទាន់បោះជំហាននៅឡើយ។ មាត្រា១៤នៃកតិកាសញ្ញាខាងលើចែងពីសិទ្ធិរបស់ស្ត្រីក្នុងការចូលរួមដោយពេញលេញក្នុងការអភិវឌ្ឍហើយ គោលការណ៍បច្ចេកទេសស្តីពីការសងសំណង និងការតាំងទីលំនៅថ្មីក្នុងគម្រោងអភិវឌ្ឍ (២០០៥) របស់ប្រទេសឡាវ និង យុទ្ធសាស្ត្រយេនឌ័រសម្រាប់ការអភិវឌ្ឍកសិកម្មនិងជនបទ(២០០៥) ផ្តល់លក្ខណៈយ៉ាងល្អប្រសើរបំផុតក្នុងបរិបទនៃគម្រោងទំនប់វារីអគ្គិសនី។

***កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌*** ធានាថាក្នុងមាត្រា១ពីសិទ្ធិក្នុងការចិញ្ចឹមជីវិតហើយ មាត្រា៧ ចែងពីសិទ្ធិក្នុងការរស់នៅសមរម្យ។ វាមិនច្បាស់ថាលក្ខណៈនៃការធ្វើផែនការជាតិមានកម្រិតល្អយ៉ាងណាទាក់ទងនឹងការជ្រើសរើសដី ដើម្បីតាំងទីលំនៅថ្មីក្នុងប្រទេសនានាដែលប្រកាន់ខ្ជាប់កាតព្វកិច្ចនេះ។ ទោះយ៉ាងណាក្តី ការពិគ្រោះយោបល់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ រួមមានស្ត្រីផង ដែលត្រូវការជាចាំបាច់នូវឧបករណ៍នយោបាយនានាសម្រាប់ប្រទេសទាំងបីនោះគួររួមចំណែកដល់លទ្ធផលជាវិជ្ជមាន។

***កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ*** ចែងក្នុងមាត្រា៣ថា ការលើកតម្កើងនិងការអភិវឌ្ឍស្ត្រីជាអាទិភាព។ មាត្រា២៣ចែងថា រដ្ឋខិតខំដើម្បីធានាថា មានសមភាពយេនឌ័រក្នុងអាពាហ៍ពិពាហ៍។ មាត្រា២៥ចែងថា ប្រជាពលរដ្ឋទាំងអស់ទទួលបានការចូលរួមដោយស្មើភាពគ្នាក្នុងកិច្ចការសាធារណៈ និងទទួលបានសេវាសាធារណៈ។ មាត្រា២៦ចែងថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់។ សមភាពចំពោះមុខច្បាប់និងក្នុងអាពាហ៍ពិពាហ៍ត្រូវបានទទួលស្គាល់ដោយប្រទេសទាំងបី និង ការអភិវឌ្ឍស្ត្រីត្រូវបានបញ្ជាក់ ***ក្នុងកតិកាសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រីភេទ***។ ស្របគ្នានឹងប្រទេសទាំងបីបញ្ជាក់ពីគោលបំណងធ្វើឲ្យប្រសើរឡើងការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តជាសាធារណៈផែនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិលើកទី៧ (២០១១-២០១៥) របស់ប្រទេសឡាវបានបញ្ជាក់យ៉ាងច្បាស់ពីគោលបំណងបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើផែនការថ្នាក់ខេត្តនិងខណ្ឌនិងការពិភាក្សាផ្នែកនយោបាយ។

***សេចក្តីថ្លែងការណ៍ស្តីពី សិទ្ធិជនជាតិដើមរបស់អង្គការសហប្រជាជាតិ*** រដ្ឋធម្មនុញ្ញនៃប្រទេសទាំងបីលើកតម្កើងសមភាពជនជាតិដើមភាគតិច ដូចមានបញ្ជាក់ក្នុងមាត្រា១។ ទោះយ៉ាងជាណាក្តី ប្រទេសទាំងនេះមិនមានសេចក្តីចែងជាគោលនយោបាយជាក់លាក់ដូចខាងក្រោម ៖ ការការពារការដកហូតយកដីធ្លី និងធនធានរបស់ជនជាតិដើមភាគតិច ឬ ការតាំងទីលំនៅថ្មីដោយបង្ខំ (មាត្រា៨និងមាត្រា១០)។ សិទ្ធិដីធ្លីមានចែងក្នុងមាត្រា២៧-២៩ និងមាត្រា៣២ ឬ មាត្រា១៣ ១៨ និងមាត្រា១៩ ដែលតម្រូវឲ្យរដ្ឋនានាជួយជនជាតិដើមភាគតិចយល់និងចូលរួមក្នុងបញ្ហានយោបាយនិងច្បាប់ ជាពិសេសបញ្ហាដែលប៉ះពាល់ពួកគេ។

## ការអនុវត្តការងារ

ប្រទេសកម្ពុជា ប្រទេសឡាវ និង ប្រទេសវៀតណាម មានការប្តេជ្ញាចិត្តប្រហាក់ប្រហែលគ្នាលើសិទ្ធិនិងសមភាពស្ត្រីក្រោមសន្ធិសញ្ញាអន្តរជាតិ។ មានការលោយគ្នារវាងច្បាប់និងគោលនយោបាយ។ ប្រទេសឡាវបង្ហាញពីការភ្ជាប់ការអភិវឌ្ឍទំនប់វារីអគ្គិសនីទៅនឹងលទ្ធផលយេនឌ័រ។

គ្រប់ប្រទេសមានសេចក្តីចែងក្នុងក្របខណ្ឌគោលនយោបាយរបស់ខ្លួនដោយបង្កឲ្យមានឱកាស ដើម្បីសម្រេចយុត្តិធម៌យេនឌ័រក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនី។ ទោះជាយ៉ាងណាក្តី ការបំពេញចន្លោះប្រហោងក្នុងគោលនយោបាយចំពោះការពិចារណាលើយេនឌ័រនឹងមានសារៈសំខាន់ក៏ដូចគ្នានឹងការអនុវត្តយ៉ាងខ្ជាប់ខ្ជួននៃគោលនយោបាយនិងគោលការណ៍ណែនាំក្នុង ការរៀបចំគម្រោង ដំណើរការនៃការអនុវត្តនិងការតាមដាន។

គណៈកម្មការទន្លេមេគង្គដែលជាស្ថាប័នអន្តររដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះការប្រើនិងការគ្រប់គ្រងអាងទន្លេប្រកបដោយនិរន្តរភាពនៃ មានឱកាសធ្វើខ្លួនជាយានសម្រាប់រៀបចំវិធានទូទៅដើម្បីពង្រឹងការវាយតម្លៃយេនឌ័រ និងការពិចារណាលើយេនឌ័រកាន់តែខ្លាំងឡើង។ គណៈកម្មការនេះ ក៏ដូចរដ្ឋាភិបាលជាសមាជិករបស់ខ្លួន បានកំណត់យកយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយនៃអាណត្តិរបស់ខ្លួន។ ត្រង់ចំណុចនេះគណៈកម្មការបានបង្កើតគោលនយោបាយបណ្តុំព័ត៌មាន និង បញ្ជីត្រួតពិនិត្យ សម្រាប់ការបញ្ចូលយេនឌ័រ។ គំនិតផ្តួចផ្តើមស្តីពីទំនប់វារីអគ្គិសនីប្រកបដោយនិរន្តរភាព កំពុងធ្វើឲ្យការពិចារណាលើយេនឌ័រកាន់តែសកម្មឡើងក្នុងផ្នែកនៃការទទួលខុសត្រូវ និង ជាពិសេសអាចទាក់ទាញការវិនិយោគនិងសមិទ្ធផលក្នុងផ្នែកឯទៀតនៃគណៈកម្មការនេះ ដូចជា ជលផល បរិស្ថាននិង កសិកម្ម។ ខណៈពេលយើងកំពុងសរសេរនេះ បណ្តុំព័ត៌មានក្នុងការបញ្ជ្រាបយេនឌ័រក្នុងវិស័យទំនប់វារីអគ្គិសនីកំពុងត្រូវបានត្រួតពិនិត្យ។ ប៉ុន្តែ នៅផ្នែកឯទៀត ដូចជាការងារដើម្បីទទួលបានការរំពឹងទុករួមគ្នាចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមជាពិសេស បរិបទនៃការអភិវឌ្ឍឆ្លងព្រំដែនប្រទេស ផ្តល់ឱកាសមានប្រយោជន៍និងជាក់ស្តែងដើម្បីលើកតម្កើងតម្លៃនិងសារៈសំខាន់នៃវាយតម្លៃហេតុប៉ះពាល់យេនឌ័រសម្រាប់ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ។



ការប្រើឧបករណ៍នេសាទនៅប្រទេសឡាវ។
រូបថត ៖ សាយមឹន ប៊ូស



## ៣ ការវាយតម្លៃហេតុប៉ះពាល់ជារឿងល្អ បរិបទនិងឱកាសនានាដែលកំពុងមាន

នៅពេលដែលការវិភាគយេនឌ័រ និងការវាយតម្លៃហេតុប៉ះពាល់យេនឌ័រត្រូវបានប្រើក្នុងការធ្វើការសម្រេចចិត្ត វាអាចឲ្យក្រុមហ៊ុននិងគម្រោងរបស់លោកអ្នកចៀសផុតពីការបន្ថែមឬការបន្តការរើសអើង ហើយផ្ទុយទៅវិញ វាធ្វើឲ្យគម្រោងមួយអាចតួនាទីយ៉ាងសកម្មក្នុងការជួយឲ្យការផ្តល់សិទ្ធិដល់ស្ត្រីនិងសិទ្ធិស្ត្រីកើតមានឡើង។ វិធីសាស្ត្រដោះស្រាយដោយគិតគូរពីយេនឌ័រនៅគ្រប់កម្រិតក្នុងរចនាសម្ព័ន្ធទាំងមូល ការធ្វើនិងការគ្រប់គ្រងគម្រោង គឺជារឿងល្អសម្រាប់អាជីវកម្ម។ ប៉ុន្មានឆ្នាំថ្មីៗនេះក្រុមហ៊ុនមួយចំនួនដែលធ្វើការងារគ្រប់គ្រងទឹក និងការអភិវឌ្ឍទំនប់វារីអគ្គិសនីបានបង្កើនការផ្តោតអារម្មណ៍របស់ខ្លួនលើការយល់ដឹងពីយេនឌ័រ និង មួយចំនួនកំពុងខិតខំដាក់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំឲ្យក្លាយជាភ្នាក់ងារក្នុងការធ្វើឲ្យសម្រេចលទ្ធផលសង្គមជាវិជ្ជមាន។

ស្ថាប័ននានាក្នុងអង្គការសហប្រជាជាតិបានបង្កើតគម្រោងយេនឌ័រជាច្រើនដើម្បីប្រើ ក្នុងការបង្កើតគោលនយោបាយនិងគម្រោង និង ក្នុងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដែលរួមមាន ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី បានបង្កើត បណ្តុំព័ត៌មាន ការណែនាំផ្នែកគោលនយោបាយ និង ធនធាននានា ដើម្បីធានាថា យេនឌ័រត្រូវបានបញ្ចូលក្នុងការផ្តល់ការយល់ព្រមលើគម្រោងនិងលក្ខខណ្ឌអនុវត្តន៍។ សម្ព័ន្ធភាពស្ថាប័នក៏បានបង្កើតធនធានដែលមានបរិបទវិស័យជាក់លាក់ទាក់ទងនឹងឧស្សាហកម្មវារីអគ្គិសនី។[១១] ចំណុចដែលទាក់ទងបំផុតមានពិភាក្សាដូចខាងក្រោម ៖

### ៣.១ យេនឌ័រ ៖ រចនាសម្ព័ន្ធទឹក ការវាយតម្លៃទំនប់វារីអគ្គិសនី ភាពងាយរងគ្រោះ និង ផលប៉ះពាល់

**គណៈកម្មការពិភពលោកស្តីពីទំនប់ ៖** ទំនប់និងរបាយការណ៍អភិវឌ្ឍន៍ ក្នុងឆ្នាំ២០០០ គណៈកម្មការពិភពលោកស្តីពីទំនប់បានចេញរបាយការណ៍ចុងក្រោយដែលបានបង្ហាញវិធីសាស្ត្រដោះស្រាយថ្មីចំពោះការធ្វើការសម្រេចចិត្តលើហេដ្ឋារចនាសម្ព័ន្ធទឹក។ គណៈកម្មការពិភពលោកស្តីពីទំនប់ជាដំណើរការពហុភាគីពាក់ព័ន្ធដែលពិចារណាលើមូលដ្ឋានទិន្នន័យជាបទពិសោធន៍និងករណីសិក្សាជាច្រើនក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនី។ ក្របខណ្ឌការងារថ្មីរបស់គណៈកម្មការនេះបានបង្ហាញគុណតម្លៃចំនួន៥ខាងក្រោម ៖

១. សមភាព
២. ប្រសិទ្ធិភាព
៣. ការធ្វើការសម្រេចចិត្តដោយមានការចូលរួម
៤. និរន្តរភាព
៥. ការទទួលខុសត្រូវ

គណៈកម្មការក៏បានបង្ហាញអាទិភាពជាយុទ្ធសាស្ត្រចំនួន៧ដែលអាទិភាពនីមួយៗឈរលើគោលការណ៍គោលនយោបាយ។ អាទិភាពទាំង៧នោះគឺ ៖

i. ការធ្វើឲ្យមានការទទួលស្គាល់ជាសាធារណៈ
ii. ការប៉ាន់ប្រមាណជម្រើសដែលគ្រប់ជ្រុងជ្រោយ
iii. ការដោះស្រាយបញ្ហាទំនប់ដែលកំពុងមាន
iv. ការធ្វើឲ្យមាននិរន្តរភាពទន្លេនិងជីវភាព
v. ការទទួលស្គាល់ការផ្តល់សិទ្ធិនិងការបែងចែកផលប្រយោជន៍
vi. ការធានាថា មានការអនុវត្តដោយមានការទទួលខុសត្រូវ
vii. ការចែកទន្លេប្រើប្រាស់រួមគ្នាដើម្បី សន្តិភាព ការអភិវឌ្ឍ និង សុវត្ថិភាព

ដើម្បីអភិវឌ្ឍគុណតម្លៃទាំង៥ គណៈកម្មការបានស្នើនូវវិធីសាស្ត្រដោះស្រាយថ្មីដែលស្របតាមចំណុចនៃការសម្រេចចិត្តសំខាន់ៗនិងដំណើរការ ក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនីក្នុងនោះ មាន២ចំណុចស្ថិតក្នុងអភិបាលកិច្ចជាយុទ្ធសាស្ត្រនិងដំណាក់កាលធ្វើផែនការសម្រាប់ការធ្វើផែនការទឹកនិងថាមពល ៖ ការប៉ាន់ប្រមាណសេចក្តីត្រូវការសម្រាប់ទឹកនិងថាមពល និង ជម្រើសនានាសម្រាប់ពិចារណា។ ចំណុចចំនួន៣ទៀតទាក់ទងនឹងជម្រើសដែលបានកំណត់យកនិងផ្តោតលើដំណាក់កាលសំខាន់២ក្នុងការរៀបចំ ការអនុវត្ត និង ការប្រតិបត្តិគម្រោង។ តាមរយៈចំណុចទាំងនេះគណៈកម្មការបានបង្ហាញពីសារៈសំខាន់ក្នុងការកំណត់យកវិធីសាស្ត្រដោះស្រាយដែល ទទួលស្គាល់សិទ្ធិ និង ប៉ាន់ប្រមាណហានិភ័យក្នុងការផ្តល់មូលដ្ឋានសម្រាប់ការចចារលើលទ្ធផលនានាដែលកំពុងពិភាក្សាក្នុងរចនាសម្ព័ន្ធទឹក។

ម៉្យាងទៀតគណៈកម្មការបង្ហាញសារៈសំខាន់ក្នុងការពិចារណាពី យេនឌ័រក្នុងហានិភ័យ សង្គម វប្បធម៌ និង សេដ្ឋកិច្ច ក្នុងន័យទូលំទូលាយនិងតម្លៃ និងផលប្រយោជន៍ទាក់ទងនឹងការសាងសង់ទំនប់(WCD 2000)។

## ការឆ្លើយតបផ្នែកទំនប់វារីអគ្គិសនី

ស្របពេលដែលវិស័យវារីអគ្គិសនីទទួលគុណតម្លៃនិងអាទិភាពនានាដែលផ្តល់ជាអនុសាសន៍ដោយគណៈកម្មការពិភពលោកស្តីពីទំនប់ (HSAF 2011) ក្រុមហ៊ុននិងសមាគមឧស្សាហកម្មសំខាន់ៗនៃវិស័យនេះបានបដិសេធចំណុចនានានៃសិទ្ធិនិងក្របខណ្ឌហានិភ័យថា មិនមានលក្ខណៈជាក់ស្តែង។

ក្នុងផ្នែកណាមួយនោះ ក្នុងការឆ្លើយតបនឹងភាពប្រឈមនៃលក្ខណៈជាក់ស្តែងនេះ វិស័យវារីអគ្គិសនី បានផ្តួចផ្តើមគំនិតដំណើរការដោយខ្លួនឯង ឬ បានចូលរួមក្នុងគំនិតផ្តួចផ្តើមដទៃទៀតដើម្បីបង្កើតឧបករណ៍ប៉ាន់ប្រមាណរបស់ខ្លួនដើម្បីវាយតម្លៃនិរន្តរភាព។ នៅខាងក្រោមមានបង្ហាញពីឧបករណ៍ប៉ាន់ប្រមាណទាំងនេះហើយមានពិភាក្សាស៊ីជម្រៅថែមទៀតក្នុងផ្នែកឧបសម្ព័ន្ធ។

ភាគីពាក់ព័ន្ធដទៃទៀតក្នុងការអភិវឌ្ឍវិស័យវារីអគ្គិសនី ដូចជាសហគមន៍អឺរ៉ុប និង រដ្ឋាភិបាលអាល្លឺម៉ង់ ពិតជាបានប្រើអនុសាសន៍របស់គណៈកម្មការស្តីពីទំនប់ក្នុងការសម្រេចចិត្តរបស់ខ្លួនថាតើត្រូវគាំទ្រឬមិនគាំទ្រគម្រោងមួយ។

---

១១. ឧទាហរណ៍, ធនាគារពិភពលោកមើលការខុសត្រូវ កម្មវិធីជំនួយផ្នែកគ្រប់គ្រងវិស័យថាមពល ជាមូលនិធិជំនួយបច្ចេកទេសមានម្ចាស់ជំនួយច្រើន ។កម្មវិធីនេះមានបញ្ចូលគម្រោងយេនឌ័រមានប្រយោជន៍ដែលផ្តល់ការណែនាំនិងឧបករណ៍ប៉ាន់ប្រមាណយេនឌ័រសម្រាប់ក្រុមហ៊ុនថាមពលនានា។ សូមមើល ESMAP 2013, Gender: Social Inclusion in the Energy Sector: Online Resources, viewed 14 August 2013, http://www.esmap.org/node/2757



ទន្លេគឺជាជីវិត។ ការធ្វើចម្ការតាមដងទន្លេជាសកម្មភាព
ទ្រទ្រង់ជីវភាពនៅក្នុងតំបន់ទន្លេមេគង្គ។
រូបថត ៖ ម៉ាក ឌីស៊ី

## ពិធីសារការប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គិសនី

ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គិសនី (HSAP) ឆ្នាំ២០១១របស់សមាគមវារីអគ្គិសនីអន្តរជាតិទទួលស្គាល់យេនឌ័រថាជាបញ្ហាដែលប្រទាក់ក្រឡាគ្នាមានសារៈសំខាន់ក្នុងការវាស់វែងនិរន្តរភាព។

### ប្រធានបទនិរន្តរភាពនៃពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គិសនីបានស្នើយោបល់ថាយេនឌ័រមានសារៈសំខាន់

| ការប៉ាន់ប្រមាណនាដំណាក់កាលដំបូង | ការប៉ាន់ប្រមាណដំណាក់កាលរៀបចំ | ការប៉ាន់ប្រមាណដំណាក់កាលអនុវត្ត | ការប៉ាន់ប្រមាណដំណាក់កាលប្រតិបត្តិការ |
|---|---|---|---|
| បញ្ហាសង្គមនិងហានិភ័យ (ប្រធានបទ ៧) | | | |
| | ទំនាក់ទំនងនិងការពិគ្រោះយោបល់ | ទំនាក់ទំនងនិងការពិគ្រោះយោបល់ | ទំនាក់ទំនងនិងការពិគ្រោះយោបល់ |
| | ការវាយតម្លៃនិងការគ្រប់គ្រងហេតុប៉ះពាល់បរិស្ថាននិងសង្គម | | |
| | | ការគ្រប់គ្រងបញ្ហាសង្គមនិងបរិស្ថាន | ការគ្រប់គ្រងបញ្ហាសង្គមនិងបរិស្ថាន |
| | គម្រោងបានប៉ះពាល់សហគមន៍និងជីវភាពរស់នៅ | គម្រោងបានប៉ះពាល់សហគមន៍និងជីវភាពរស់នៅ | គម្រោងបានប៉ះពាល់សហគមន៍និងជីវភាពរស់នៅ |
| | ការតាំងទីលំនៅថ្មី | ការតាំងទីលំនៅថ្មី | ការតាំងទីលំនៅថ្មី |
| | លក្ខខណ្ឌការងារនិងការធ្វើការ | លក្ខខណ្ឌការងារនិងការធ្វើការ | លក្ខខណ្ឌការងារនិងការធ្វើការ |
| | សុខភាពសាធារណៈ | សុខភាពសាធារណៈ | សុខភាពសាធារណៈ |

**សម្រួលនិងស្រង់ចេញពី** (HSAP 2011)

ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គិសនីនេះត្រូវបានប្រើដើម្បីវាស់និរន្តរភាពក្នុងគម្រោងនីមួយៗឬបណ្តុំគម្រោង គឺថា វាមិនមែនរៀបចំឡើងសម្រាប់តែការប៉ាន់ប្រមាណនៅទូទាំងតំបន់ទន្លេមេគង្គនោះទេហើយពិធីសារនេះបង្ហាញបញ្ហាដែលជាប្រធានបទនិរន្តរភាពមួយចំនួនដែលក្នុងនោះ យេនឌ័រត្រូវបានគេពិចារណា។ ទោះជាយ៉ាងនេះក្តីបញ្ហានេះនៅមិនទាន់ហៅថា លើកកម្ពស់យេនឌ័រដែលជាបញ្ហាអាទិភាពទោលតែឯងសម្រាប់និរន្តរភាពឡើយ។ ផ្ទុយទៅវិញនោះ ពិធីសារនេះមានលក្ខណៈប្រហាក់ប្រហែលនឹង របៀបណែនាំ សម្រាប់អ្នកប្រើប្រាស់ពិធីសារដែលថា បញ្ហាសង្គមនានាត្រូវគិតយេនឌ័រទៅវិញ។ ពិធីសារនេះប្រើប្រព័ន្ធដាក់ពិន្ទុដើម្បីវាស់ការអនុវត្តនិរន្តរភាព ប៉ុន្តែ វាមិនមានមូលដ្ឋានច្បាស់លាស់ក្នុងសេចក្តីថ្លែងការណ៍ដែលគេដាក់ពិន្ទុឲ្យឬក្នុងវិធីសាស្ត្រប៉ាន់ប្រមាណសម្រាប់បែងចែកពិន្ទុ ដោយផ្អែកលើមូលដ្ឋាននៃចំណុចចន្លោះប្រហោងក្នុងការអនុវត្តយេនឌ័រនោះទេ។

### ឧបករណ៍ប៉ាន់ប្រមាណឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ

ឧបករណ៍ប៉ាន់ប្រមាណឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ (RSAT) ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ការប្រើប្រាស់នៅទូទាំងអាងទន្លេមេគង្គ (ដែលខុសពី HSAP) ក្នុងតំបន់ទន្លេមេគង្គ ហើយ បង្កើតជាវិធីសាស្ត្របញ្ច្រាបដើម្បីបញ្ចូលយេនឌ័រ។ RSAT ត្រូវបានបង្កើតឡើងដើម្បីសម្រួលការពិភាក្សាជាពហុភាគីពាក់ព័ន្ធដោយពិចារណាលើប្រធានបទនានានិងលក្ខណៈវិនិច្ឆ័យទាំងឡាយលើនិរន្តរភាព។ RSAT ផ្តោតជាទូទៅលើកិច្ចការជាពហុភាគីពាក់ព័ន្ធដែលនាំមានការជួបជុំគ្នារវាងអ្នកអភិវឌ្ឍ និង ខាងរដ្ឋាភិបាល ធនាគារ គណៈកម្មការទន្លេមេគង្គ គណៈកម្មការនានានៃអាងទន្លេមេគង្គ និង គណៈកម្មការទន្លេមេគង្គជាតិ។លក្ខណៈវិនិច្ឆ័យដែលប្រើដើម្បីបញ្ជាក់ពីការប៉ាន់ប្រមាណដោយសង្កត់ធ្ងន់លើយេនឌ័រ។ RSAT ត្រូវបានធ្វើបច្ចុប្បន្នកម្មជាច្រើនលើកច្រើនសារហើយបច្ចុប្បន្នកំពុងព្យាយាមដាក់បញ្ចូលសង្គមស៊ីវិលជាស្ថាប័នពាក់ព័ន្ធដែរ។ ប្រធានបទ RSAT មានភាពស៊ីគ្នាជាមួយ HSAP ។ ប៉ុន្តែវាផ្តោតខ្លាំងចំពោះបរិបទទន្លេមេគង្គ ឧទាហរណ៍ដូចជា ការផ្តោត ទៅលើការវាយតម្លៃលម្អិតលើធនធានជលផល។ លក្ខណៈវិនិច្ឆ័យដែលប្រើសំរាប់ផ្តល់ព័ត៌មានអំពីការវាយតម្លៃជាក់លាក់លើយេនឌ័រ។

ខុសពីគ្នាពី HSAP អ្នកប្រើប្រាស់ RSAT ត្រូវបានណែនាំឲ្យពិចារណាលើកភាពខុសគ្នានៃយេនឌ័រនិង "ការអនុវត្ត" យេនឌ័រ ក្នុងការដាក់ពិន្ទុឲ្យទៅតាមលក្ខណៈវិនិច្ឆ័យដែលមានស្រាប់ ។ RSAT ឈរលើនិយមន័យរបស់វិទ្យាស្ថានដទៃទៀត ដូចជា ធនាគារអភិវឌ្ឍអាស៊ី ជាដើមដែលបង្ហាញពីយេនឌ័រនិងបញ្ហាងាយរងគ្រោះរបស់ស្ត្រី ដូចមានក្នុងនិយមន័យពី "ការពិគ្រោះយោបល់ដែលមានអត្ថប្រយោជន៍" ជាដើម។[១២] មានការនិយាយស៊ីជម្រៅថែមទៀតពី RSAT ក្នុងឧបសម្ព័ន្ធ។

១២. ការពិគ្រោះយោបល់ដែលមានអត្ថប្រយោជន៍ជាដំណើរការដែល "(i) មាននៅក្នុងដំណាក់កាលដំបូងៗនៃវដ្តគម្រោង; (ii) ផ្តល់ព័ត៌មានដែលពាក់ព័ន្ធនិងមានភាពគ្រប់គ្រាន់ទាន់ពេលវេលាដែលជាព័ត៌មានងាយយល់ងាយទទួលយកបានចំពោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់ (iii)កើតឡើងក្នុងបរិយាកាសមិនមានការគំរាមកំហែងឬការបង្ខិតបង្ខំ និង (v) បង្កឲ្យមានការបញ្ចូលគំនិតយោបល់ពាក់ព័ន្ធនានារបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់និងភាគីពាក់ព័ន្ធដទៃទៀតក្នុងការសម្រេចចិត្ត ដូចជា គម្រោងកម្មវិធី, វិធានការកាត់បន្ថយបញ្ហា, ការបែងចែកឱកាសនិងអត្ថប្រយោជន៍នៃការអភិវឌ្ឍ និង បញ្ហាអនុវត្តនានា។ ការពិគ្រោះយោបល់នេះផ្តោតការពិចារណាលើសេចក្តីត្រូវការនៃក្រុមមនុស្សដែលបាត់បង់ផលប្រយោជន៍ឬងាយរងគ្រោះ ជាពិសេសនោះ គឺអ្នកដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ, អ្នកគ្មានដីធ្លី, មនុស្សចាស់ជរា, ក្រុមគ្រួសារដែលមានស្ត្រីជាមេគ្រួសារ, ស្ត្រីនិងកុមារ, ជនជាតិដើមភាគតិច និង អ្នកគ្មានបណ្ណកម្មសិទ្ធិដី"។ (ADB 2009, p. 26)

## យេនឌ័រនិងជនជាតិដើមភាគតិច

បញ្ហាសំខាន់ក្នុងបរិបទតំបន់ទន្លេមេគង្គនិងក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើនទៀត គឺថាតើទំនប់វារីអគ្គិសនីសាងសង់ដោយប្រើប្រាស់ធនធាននានា ដីនិងទឹក របស់ជនជាតិដើមភាគតិចយ៉ាងដូចម្តេច។ ការយល់ច្បាស់និងការចូលរួមក្នុងការប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រពីជនជាតិដើមភាគតិចគឺជាឱកាសសំខាន់ដើម្បីទទួលបានការយល់ព្រមពីសហគមន៍ចំពោះគម្រោងនិងការធានាថា គម្រោងដែលបង្កើតឡើងផ្តល់អត្ថប្រយោជន៍និងសិទ្ធិស្មើគ្នាចំពោះបុរសនិងស្ត្រី។ នៅក្នុងបរិបទនេះ ក្រុមហ៊ុនអាចចៀសផុតនិងកាត់បន្ថយហានិភ័យនៃការបង្កបញ្ហាបន្ថែមទៀតលើតួនាទីនិងទំនាក់ទំនងយេនឌ័រដែលមានលក្ខណៈអវិជ្ជមានកើតឡើងដោយសារគម្រោង។

ជនជាតិដើមភាគតិចជាប្រជាពលរដ្ឋក្រីក្រនិងនៅឆ្ងាយពីគេក្នុងពិភពលោក។ លើសពីនេះ ក្នុងសហគមន៍ខ្លះដែលជួបប្រទះការដកហូតយកដីធ្លីនិងធនធាននានាដោយបង្ខំនោះ ស្ត្រីជាជនជាតិដើមភាគតិចជួបប្រទះការរើសអើងជាបន្ថែមទៀត ហើយ ពួកគាត់ត្រូវធ្វើឲ្យបាត់បង់ឱកាសដើម្បីទទួលសិទ្ធិមនុស្សបានពេញលេញ។ ស្ត្រីជនជាតិដើមភាគតិចច្រើនតែ មានការអប់រំទាបទទួលសេវាសុខភាពបានតិច និង យកចិត្តទុកដាក់តិចតួចពីសង្គម។ ទាក់ទងនឹងការសង់ទំនប់វារីអគ្គិសនីដែលដកហូតយកធនធាននិងដីដូនតាពីជនជាតិដើមភាគតិចនិងប៉ះពាល់លើរចនាសម្ព័ន្ធសង្គមនោះ ជារឿយៗ មនុស្សប្រុសទេដែលពិភាក្សាការព្រមព្រៀងនិងការគ្រប់គ្រងចំណូលនិងអត្ថប្រយោជន៍ដទៃទៀតចំពោះគ្រួសារនិងសហគមន៍។

នៅក្នុងបរិបទនេះ គេឃើញមានក្រុមហ៊ុនជាច្រើនអាចជួយឲ្យគេចផុតពីផលប៉ះពាល់អវិជ្ជមាននានាបាន។ ការគោរពសិទ្ធិជនជាតិដើមភាគតិចក្នុងការផ្តល់ឬមិនផ្តល់ ការយល់ព្រមដោយសេរី ជាបឋម និងដោយបានជូនដំណឹង (FPIC) គឺជាសេចក្តី ថ្លែងការណ៍មួយជាក់លាក់ដែលបង្ហាញពីបំណងរបស់គម្រោងក្រុមហ៊ុន។ ក្រុមហ៊ុនទំនប់វារីអគ្គិសនីមិនត្រូវអនុគ្រោះ អត់ឱន ឬ រើសអើងចំពោះស្ត្រីភេទ ហើយ ត្រូវចៀសវាងផលប៉ះពាល់យេនឌ័រពីទំនប់វារីអគ្គិសនី ដោយធានាថាមានការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចក្នុងដំណើរការ FPIC។ រឿងនេះអាចប្រព្រឹត្តទៅបានដោយមានការទទួលស្គាល់និងគាំទ្រការខំប្រឹងប្រែងរបស់ស្ត្រីជនជាតិដើមភាគតិចក្នុងការធ្វើឲ្យមានការយល់ព្រមដោយភ្ជាប់ជាមួយនឹងសិទ្ធិរបស់សមាជិកសហគមន៍ទាំងអស់។ វាគួរតែស្ត្រីជនជាតិដើមភាគតិច (មិនមែនលើកទៅឲ្យអ្នកដទៃទេ) ដែលជាអ្នកសម្រេចចិត្តថា តើខ្លួនគួរចូលរួមក្នុងដំណើរការសម្រេចចិត្តដោយរបៀបណានិងនៅពេលណា ក៏ដូចគ្នានិងការចូលរួមរបស់ពួកគាត់ក្នុងដំណើរការ FPIC ដោយផ្អែកលើគោលការណ៍ សមភាព ការមិនមានការរើសអើង និង ភាពស្មើគ្នា។

សៀវភៅណែនាំនេះអាចប្រើដើម្បីជួយក្រុមហ៊ុននានាមានភាពប្រាកដថា ស្ត្រីនិងបុរសមានភាពស្មើគ្នាក្នុងការធ្វើការសម្រេចចិត្ត និង ថានៅពេលមានគម្រោងមួយចេញមក គម្រោងនេះមានការជ្រួតជ្រាបពីបញ្ហាយេនឌ័រក្នុងបរិបទដែលគម្រោងដំណើរការ។

## អង្គការសហប្រជាជាតិ,ធុរកិច្ចនិងសិទ្ធិមនុស្ស៖ បរិបទទំនប់វារីអគ្គិសនី

សិទ្ធិរបស់ស្ត្រីជាបញ្ហាស្នូលនៃក្របខណ្ឌសិទ្ធិមនុស្សអន្តរជាតិនិងត្រូវទទួលស្គាល់ក្នុងសេចក្តីថ្លែងការណ៍និងអនុសញ្ញានានា។ ចំណុច៦ពិនិត្យមើលពីរបៀបដែលរដ្ឋាភិបាលនៅតំបន់ទន្លេមេគង្គនានាបានគាំទ្រឧបករណ៍ទាំងនេះនិងពីរបៀបដែលរដ្ឋាភិបាលទាំងនេះសម្រេចបាន។នៅប៉ុន្មានឆ្នាំថ្មីៗនេះ តាមរយៈការគាំទ្ររបស់អង្គការសហប្រជាជាតិ មានការពិភាក្សាជិតដល់ជាមួយផ្នែកឯកជនដើម្បីកំណត់ថា តើឧបករណ៍សិទ្ធិមនុស្សអនុវត្តក្នុងវិស័យអាជីវកម្មយ៉ាងដូចម្តេច។ *ក្របខណ្ឌ ការពារ គោរព និង ដំណោះស្រាយលើបញ្ហាធុរកិច្ចនិងសិទ្ធិមនុស្ស* បញ្ជាក់ពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋាភិបាលនិងក្រុមហ៊ុនទាក់ទងនឹងការទប់ស្កាត់និងដោះស្រាយការរំលោភសិទ្ធិមនុស្សទាក់ទងនឹងអាជីវកម្ម។ ក្របខណ្ឌនេះទទួលបានការគាំទ្រពី រដ្ឋាភិបាល ក្រុមហ៊ុន និង សង្គមស៊ីវិល។ ក្របខណ្ឌនេះមានគោលគំនិត៣ដែលប្រទាក់ក្រឡាគ្នា :

រដ្ឋមានកាតព្វកិច្ចការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដោយភាគីទីបី រួមមាន ក្រុមហ៊ុន តាមរយៈ គោលនយោបាយ និយ័តកម្ម និងការដាក់ទោស។

ការទទួលខុសត្រូវនៃសាជីវកម្មចំពោះសិទ្ធិមនុស្សមានន័យថាក្រុមហ៊ុននានាត្រូវធ្វើការដោយប្រយ័ត្នប្រយែងដើម្បីចៀសវាងការរំលោភបំពានលើសិទ្ធិរបស់អ្នកដទៃនិងត្រូវដោះស្រាយផលប៉ះពាល់មិនល្អនៅក្នុងការងារដែលក្រុមហ៊ុននោះធ្វើ។

សេចក្តីត្រូវការដើម្បីទទួលបានដោយជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទាក់ទងនឹងអាជីវកម្មក្នុងដោះស្រាយទាំងតាមផ្លូវតុលាការនិងក្រៅតុលាការ។

### *គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស*

បង្កើតឡើងដើម្បីគាំទ្រក្របខណ្ឌ ការពារ គោរព និង ដំណោះស្រាយលើបញ្ហាអាជីវកម្មនិងសិទ្ធិមនុស្សដើម្បីពន្យល់ថា ការទទួលខុសត្រូវនៃសាជីវកម្មគោរពសិទ្ធិមនុស្សមានន័យថាក្រុមហ៊ុនត្រូវចៀសវាងធ្វើអ្វីដែលមានផលប៉ះពាល់មិនល្អផ្នែកសិទ្ធិមនុស្ស ដោយរួមបញ្ចូលទំនាក់ទងនានារបស់ក្រុមហ៊ុននោះផង។និយាយម្យ៉ាងទៀត ក្រុមហ៊ុន យ៉ាងហោចណាស់មិនត្រូវប៉ះពាល់ដល់សិទ្ធិមនុស្ស។

តាមការជាក់ស្តែង បញ្ហានេះតម្រូវឲ្យក្រុមហ៊ុននានាមានគោលនយោបាយសិទ្ធិមនុស្សដែលតម្រូវឲ្យពួកគេ គោរពសិទ្ធិមនុស្ស អនុវត្តសិទ្ធិមនុស្ស ដោយដំណើរការប្រយ័ត្នប្រយែងដែលពិចារណាយ៉ាងជិតដល់ពីបញ្ហាយេនឌ័រដើម្បីស្គាល់និងបង្ហាញថា ក្រុមហ៊ុនគោរពសិទ្ធិមនុស្ស (ដោយតម្រូវឲ្យមានការបង្ហាញនិងការប៉ាន់ប្រមាណផលប៉ះពាល់ ការបញ្ចូលការរកឃើញតាមការប៉ាន់ប្រមាណទូទាំងដំណើរការរបស់សាជីវកម្ម ព្រមទាំងតាមដាននិងផ្លាស់ប្តូរព័ត៌មានលើការអនុវត្តសិទ្ធិមនុស្ស) ហើយ ធ្វើការដើម្បីដោះស្រាយផលប៉ះពាល់មិនល្អដែលក្រុមហ៊ុនអាចបង្កឲ្យមានឡើងឬនាំឲ្យមាន ដូចជាយន្តការដោះស្រាយការមិនសុខចិត្តជាដើម។

## ៣.២ ទំនប់វារីអគ្គិសនីនិងយេនឌ័រ : ឱកាស

នៅសតវត្សរ៍ទី២១ ការអភិវឌ្ឍទំនប់វារីអគ្គិសនី ជារឿយៗ មានលក្ខណៈជា ការអភិវឌ្ឍបែបអន្តរាគមន៍។ នេះជាផ្លូវកាត់ក្នុងការពន្យល់លក្ខណៈសមហេតុសមផលរបស់គម្រោងដែលបង្ហាញការវិនិយោគលើទំនប់ជាឱកាសនាំមកនូវលទ្ធផលនៃការអភិវឌ្ឍទូលំទូលាយចំពោះប្រទេសជាតិឬអាងទន្លេ។ វាមានន័យថា គឺទំនប់ផ្ទាល់តែម្តងជាទំពស្រួចសម្រាប់ការអភិវឌ្ឍនិងការវិនិយោគទូលំទូលាយ ដូចជា ផ្លូវ សេវាកម្ម និង មន្ទីរពេទ្យជាដើម។ ប្រសិនបើការអភិវឌ្ឍនេះសម្រេចបាននោះ ការផ្តល់អំណាចដល់ស្ត្រីប្រាកដជាគោលបំណងសំខាន់មួយយ៉ាងប្រាកដ។

ការស្វែងយល់និងការយកចិត្តទុកដាក់លើយេនឌ័រជារឿងចាំបាច់សម្រាប់រដ្ឋាភិបាលជាច្រើនតាមរយៈការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះកិច្ចព្រមព្រៀងសិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋាភិបាលទាំងអស់នៃដងទន្លេមេគង្គក្រោមបានប្តេជ្ញាចិត្តធ្វើតាមយន្តការអនុវត្តសិទ្ធិមនុស្សសំខាន់ៗដែលទទួលស្គាល់និងលើកតម្កើងសិទ្ធិស្ត្រី។

ជាកំណើន គេឃើញថា ការគោរពសិទ្ធិមនុស្សជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនក៏ដូចជារបស់រដ្ឋាភិបាល។ និយាយឲ្យងាយស្តាប់ទៅការធ្វើឲ្យប្រសើរឡើងនូវលទ្ធផលយេនឌ័រក្នុងដំណើរការអភិវឌ្ឍនិងការប្រតិបត្តិទៅនៃទំនប់វារីអគ្គិសនីជាការអនុវត្តក្នុងអាជីវកម្មដ៏ល្អ។ រឿងនេះអាចសម្រេចបាននៅក្នុងការប្រតិបត្តិការគ្រប់គ្រងគម្រោងដែលកំពុងមាននិងអាចជួយក្រុមហ៊ុនឲ្យចៀសផុតពីហានិភ័យនិងថ្លៃចំណាយដែលមិនចង់បាន។

ឧស្សាហកម្មរ៉ែដោះស្រាយបញ្ហាប្រឈមដូចគ្នាជាច្រើន ដែលក្រុមហ៊ុនទំនប់វារីអគ្គិសនីជួបក្នុងទំហំនៃផលប៉ះពាល់និងសារៈសំខាន់នៃការចំណេញនិងរក្សាអាជ្ញាបណ្ណដើម្បីប្រតិបត្តិការងារ។

នៅឆ្នាំ២០០៩ ក្រុមហ៊ុនរ៉ែពហុជាតិ រីយ៉ូ ទិនតូ បានបង្កើតហេតុអ្វីក៏យេនឌ័រមានបញ្ហា ជាការណែនាំលើធនធានដើម្បីបញ្ចូលការពិចារណាយេនឌ័រទៅក្នុងការងារសហគមន៍នៅ រីយ៉ូ ទិនតូ។

ចំណុចនេះបញ្ចូលគោលការណ៍ណែនាំដល់បុគ្គលិករីយ៉ូលើគោលនយោបាយនិងតម្រូវការរបស់ក្រុមហ៊ុនរីយ៉ូស្តីពីឧបករណ៍និងឯកសារយោងចាំបាច់។ វាជាសេចក្តីថ្លែងការណ៍នៃសាជីវកម្មរបស់សារៈសំខាន់យេនឌ័រនៅក្នុងប្រតិបត្តិការនានារបស់ក្រុមហ៊ុន។

រីយ៉ូ ទិនតូ បញ្ជាក់ថា :

- "នៅ រីយ៉ូ ទិនតូ យើងមានការទទួលខុសត្រូវដើម្បីធានាថាទង្វើទាំងឡាយរបស់យើងមិនបង្កឲ្យអសមភាពដែលមានស្រាប់កាន់តែធ្ងន់ធ្ងរឡើងនៅក្នុងសហគមន៍ដែលយើងប្រតិបត្តិការងារ។ ការប្តេជ្ញាចិត្តរបស់ រីយ៉ូ ទិនតូ ចំពោះការអភិវឌ្ឍប្រកបដោយនិរន្តភាពនិងសិទ្ធិមនុស្សក៏តម្រូវផងដែរថា យើងត្រូវធ្វើដំណើរទៅកាន់ស្ថានភាពដែលយើងបានលើកតម្កើងគុណភាពជីវិតនិងលក្ខខណ្ឌសង្គមសេដ្ឋកិច្ចនៃសហគមន៍ដែលរងផលប៉ះពាល់និងរងគ្រោះ ចំពោះស្ត្រីនិងបុរស ក្មេងស្រីនិងក្មេងប្រុស នៅគ្រប់ទីកន្លែងទាំងអស់ដែលក្រុមហ៊ុនយើងមាននៅ"។

  (Rio Tinto 2009, ទំ. 22)
- "ក្រុមហ៊ុន រីយ៉ូ ទិនតូមានការទទួលខុសត្រូវដើម្បីធានាថាផលប៉ះពាល់មិនល្អនិងហានិភ័យសង្គមត្រូវបានកាត់បន្ថយឲ្យបានតិចបំផុត ហើយ មិនឲ្យមានបែងចែកផលមិនស្មើចំពោះក្រុមណាមួយនៃប្រជាជន។ មានភស្តុតាងច្បាស់លាស់ថា នៅក្នុងបរិបទមួយចំនួនស្ត្រីងាយរងគ្រោះដោយសារការអភិវឌ្ឍផ្នែករុករករ៉ែណាស់" (Rio Tinto 2009, p 81)
- "វាសំខាន់ដែលគេត្រូវទទួលស្គាល់ថា ភាពប្រឈមនានាដែលយើងជួបប្រទះក្នុងលក្ខណៈជាក្រុមហ៊ុនធ្វើការ ដើម្បីបញ្ចូលយេនឌ័រទៅក្នុងគម្រោងនិងកម្មវិធីអភិវឌ្ឍន៍ និងការអនុវត្ត នៅគ្រប់ដំណាក់កាលរុករករ៉ែទាំងអស់។ យើងត្រូវបន្តផ្តោតការយកចិត្តទុកដាក់លើការបញ្ចូលការពិចារណាយេនឌ័រទៅក្នុងដំណើរការការងារ ..." (Rio Tinto 2009, p. 72)

វិធីសាស្ត្រនេះដែលអនុម័តដោយក្រុមហ៊ុនរ៉ែ រីយ៉ូ ទិនតូ នេះផ្តល់គម្រូមួយសម្រាប់ក្រុមហ៊ុនទំនប់វារីអគ្គិសនីដើម្បីអនុវត្តវិធីសាស្ត្រទូលំទូលាយនិងប្រកាន់ភ្ជាប់នូវគោលនយោបាយក្នុងការបញ្ចូលយេនឌ័រ។ វិធីសាស្ត្រនេះអាចទាញយកបានពី http://www.riotinto.com/documents/reportspublications/rio_tinto_gender_guide.pdf



ស្ត្រីនៅក្នុងផ្សារត្រី, ខេត្តអាងយ៉ាង,
ប្រទេសវៀតណាម។
រូបថត ៖ ហ្គែរី លី/អុកស្វាម



# ៤ ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ : ឧបករណ៍ប៉ាន់ប្រមាណសំខាន់សម្រាប់អ្នកអភិវឌ្ឍ

## ៤.១ តើអ្វីជាការវាយតម្លៃផលប៉ះពាល់យេនឌ័រ?

ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រគឺជាដំណើរការដែលអនុញ្ញាតឲ្យអ្នកធ្វើការសម្រេចចិត្តនៅក្នុងគម្រោងយល់ពី ស្ថានភាពនិងបរិបទបច្ចុប្បន្នដែលត្រូវប៉ះពាល់ដោយសារគម្រោងនិងអ្វីដែលផ្លាស់ប្តូរព្រមទាំងលទ្ធផលនានាដែលអាចកើតឡើងដោយសារគម្រោងនេះ។ ការវាយតម្លៃនេះប្រើលក្ខណៈវិនិច្ឆ័យដើម្បីបញ្ជាក់ថា មានការយល់ដឹងពីផលប៉ះពាល់ដែលបានស្មានទុកនិងដែលកើតមានឡើង។

ការវាយតម្លៃហេតុផលប៉ះពាល់យេនឌ័រនឹងអនុញ្ញាតឲ្យអ្នកអភិវឌ្ឍគម្រោង (រួមទាំង រដ្ឋាភិបាល អ្នកផ្តល់ថវិកា និង ក្រុមហ៊ុន នានា) ពិចារណាទំនាក់ទំនងរវាងបុរសនិងស្ត្រី និង របៀបដែលគម្រោងនេះនឹងប៉ះពាល់ស្ត្រីនិងបុរស។ វាយតម្លៃហេតុនឹងធានាថា អំណាចរវាងបុរសនិងស្ត្រី ចំណុចជាច្រើននឹងមានបញ្ហាធ្ងន់ធ្ងរឡើងដោយសារគម្រោងនោះ ត្រូវបានយល់និង ថា មានសមភាពក្នុងលទ្ធផលដែលបានមក។ ដូច្នេះ ស្ត្រី ជាពិសេសដោយយោងលើភាពងាយរងគ្រោះព្រោះផលប៉ះពាល់របស់គម្រោង អាចមានស្ថានភាពល្អប្រសើរជាងមុនគម្រោង។

ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនឹងផ្តល់ព័ត៌មានលម្អិតនិងព័ត៌មានពីការដែលបុរស និងស្ត្រីទាក់ទងនិងមានទំនាក់ទំនងទៅវិញទៅមកជាមួយគ្នានៅគ្រប់ឋានៈសង្គមទាំងអស់ ហើយ អាចប្រើដើម្បីធានាថាសកម្មភាពនានាមិនធ្វើឲ្យខាតប្រយោជន៍បុរសឬស្ត្រីនោះទេ។ ការវិភាគយេនឌ័រនឹងធានាថា ការសម្រេចចិត្តក្នុងការអភិវឌ្ឍឈរលើមូលដ្ឋាននៃហេតុការណ៍នានាពីទំនាក់ទំនងរវាងបុរសនិងស្ត្រីនិងបរិបទនិងសេចក្តីត្រូវការផ្សេងគ្នារៀងខ្លួន។

ការប្រើការវាយតម្លៃហេតុប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រ អនុញ្ញាតឲ្យអ្នកអភិវឌ្ឍប៉ាន់ប្រមាណហានិភ័យនិងឱកាសរបស់បុរស និង ស្ត្រី និង ធ្វើការផ្លាស់ប្តូរ ការប្តេជ្ញាចិត្ត និង ការសម្រេចចិត្តចៀសវាងធ្វើឲ្យមានផលប៉ះពាល់ ព្រមទាំង លើកតម្កើងសមភាពយេនឌ័រ។

## ៤.២ ហេតុអ្វីបានជាធ្វើការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ?

*"ការពិចារណាលើបញ្ហាយេនឌ័រក្នុងការអនុវត្តគម្រោងទំនប់វារីអគ្គិសនីគឺមានសារៈសំខាន់ចំពោះនិរន្តភាពរបស់គម្រោង។ គម្រោងអភិវឌ្ឍទំនប់វារីអគ្គិសនីមានទំនងថានឹងអាចធ្វើឲ្យមានផលវិបាកផ្នែកបរិស្ថាន។ ទោះបីមានឥទ្ធិពលល្អឬមិនល្អ ឥទ្ធិពលនេះនឹងប៉ះពាល់ជីវិតគ្រប់ស្រទាប់ប្រជាជន ពោលគឺ ស្ត្រីនិងបុរសនៅគ្រប់វណ្ណៈសង្គមនិងជាតិសាសន៍ដែលកំពុងរស់នៅក្នុងតំបន់គម្រោង ... ឥទ្ធិពលមិនល្អនៃការអនុវត្តគម្រោងជះឥទ្ធិពល ជាពិសេសលើជីវិតរបស់ស្ត្រីនិងក្រុមដែលងាយរងគ្រោះនិងក្រុមជាតិពន្ធ ដែលបុរសហាក់ដូចជាទទួលផលប្រយោជន៍ច្រើនបំផុត"។*

*( Department of Electricity Development 2005, p. 1 )*

គោលដៅនៃការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនឹងខុសគ្នាអាស្រ័យលើបរិបទនិងការកំណត់ពេលវេលា។ ជាធម្មតា ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រត្រូវធ្វើឡើងរួមគ្នានឹងការសិក្សាលទ្ធភាពប្រព្រឹត្តទៅរបស់គម្រោងនិងការវាយតម្លៃហេតុគម្រោងដំណាក់កាលដំបូង។ ចំណុចនេះនឹងបញ្ជាក់ពីផែនការគ្រប់និងថវិកា។ តាមរបៀបនេះ លទ្ធផលដែលចេញមករួមមាន ៖

- ការយល់ដឹងរបស់អ្នកអភិវឌ្ឍគម្រោងពីរបៀបដែលគម្រោងនឹងមានផលប៉ះពាល់ផ្សេងគ្នាលើបុរសនិងស្ត្រី និង តាមរយៈការយល់ដឹងនេះ ...
- អ្នកអភិវឌ្ឍគម្រោងពង្រីកការពិចារណារបស់ខ្លួនលើផលប៉ះពាល់យេនឌ័រនិងការចូលរួមរបស់ស្ត្រីក្នុងដំណើរការសំខាន់ៗដើម្បីបញ្ជាក់ការសម្រេចចិត្តលើគម្រោងនាពេល អនាគត (រួមមាន ការប៉ាន់ប្រមាណហានិភ័យ, ទាក់ទងនឹង ការពិនិត្យមើលនិងការរៀបចំការវាយតម្លៃហេតុប៉ះពាល់ដទៃទៀត ដូចជា សម្រាប់ជនជាតិដើមភាគតិចឬទីដែលត្រូវមានការតាំងទីលំនៅថ្មី លើការបែងចែកថវិកា ការផ្តល់ធនធានការកំណត់ពេលវេលា ទំហំការងារ ជាដើម) និង តាមរយៈការពិចារណានេះ ...
- អ្នកអភិវឌ្ឍធានាថា ការសម្រេចចិត្តរបស់គម្រោងធ្វើឲ្យប្រសើរឡើងនូវសមភាពយេនឌ័រ
- ការប៉ាន់ប្រមាណនិងការវិភាគតម្លៃ/ផលប្រយោជន៍គឺឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយនិងពិតប្រាកដពីការដែលគម្រោងនឹងប៉ះពាល់ដល់ទំនាក់ទំនងយេនឌ័រនាពេលបច្ចុប្បន្ន និង អនាគត រួមមានការយល់ដឹងពីយេនឌ័ររបស់សហគមន៍ និង ប្រើសេវាប្រព័ន្ធអេកូដែលនឹងត្រូវប៉ះពាល់ដោយសារគម្រោង ហើយ កិច្ចការនេះនឹងជួយក្នុង ...
- សម្រួលឱកាសឲ្យមានការចូលរួមឲ្យបានច្រើនបំផុតចំពោះស្ត្រីនិងបុរសនៅក្នុងគម្រោង ហើយ ជួយឲ្យទទួលបានស្មើគ្នានូវផលប្រយោជន៍នានា។

អ្នកអភិវឌ្ឍគម្រោង ព្រមទាំង អ្នកផ្តល់ថវិកានិងដៃគូជារដ្ឋាភិបាលនឹងទទួលបានគុណតម្លៃក្នុងគម្រោងរបស់ខ្លួនដោយសារការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ។ ការពិចារណាលើយេនឌ័រនិងផលប៉ះពាល់នៃគម្រោង

លើយេនឌ័រ និង បន្ទាប់មក សម្របសម្រួលគម្រោងយ៉ាងណាឲ្យបានដោះស្រាយសមភាពយេនឌ័រនោះ ជាចំណុចសំខាន់ក្នុងការពិចារណានិរន្តរភាពនៃគម្រោងទំនប់វារីអគ្គិសនី។

ក្នុងការធានាថា គម្រោងប្រើការវាយតម្លៃហេតុប៉ះពាល់ និង បន្តឲ្យតម្លៃនិងពិនិត្យមើលទំនាក់ទំនងយេនឌ័រក្នុងការអភិវឌ្ឍរបស់គម្រោងនិងបរិបទនៃប្រតិបត្តិការងារ អ្នកស្នើគម្រោងនឹងអាចគ្រប់គ្រងហានិភ័យដែលកើតមានដល់គម្រោងរបស់ខ្លួន។ អ្នកគាំទ្រគម្រោងគួរពិចារណារបៀបដែលផលប៉ះពាល់អាចជួយប្រទះផ្សេងគ្នារវាងបុរសនិងស្ត្រីនិងរបៀបដែលផលប៉ះពាល់ទាំងនេះជះឥទ្ធិពលលើទំនាក់ទំនងសហគមន៍និងក្នុងក្រុមគ្រួសារនីមួយៗ។

ការសម្រេចបានលទ្ធផលវិជ្ជមានប្រកបដោយនិរន្តរភាពចំពោះស្ត្រីដែលជាផ្នែកមួយនៃវិធីសាស្ត្រអនុវត្តល្អនឹងតម្រូវឲ្យផ្តោតការពិចារណាលើការផ្តល់អំណាចដល់ស្ត្រី។

ប្រសិនបើគម្រោងនឹងផ្តល់ការផ្លាស់ប្តូរឬការផ្តល់អំណាចដល់ស្ត្រី វាមានសារៈសំខាន់ណាស់ដែលគេត្រូវទទួលស្គាល់ថា ស្ត្រីមិនគ្រាន់តែជាក្រុមមនុស្សមួយក្រុមក្នុងចំណោមក្រុមមនុស្សគ្មានអំណាចឬនៅឆ្ងាយពីគេក្នុងសង្គម ( ដូចជា ជនជាតិដើមភាគតិច អ្នកក្រនិង ជនពិការ ) នោះទេ ប៉ុន្តែ ស្ត្រីស្ថិតនៅគ្រប់ក្រុមមនុស្សទាំងនេះក្នុងសង្គម។ លើសពីនេះទៀត ក្រុមគ្រួសារជាចំណុចដែលធ្វើឲ្យស្ត្រីបាត់បង់អំណាច។

ដោយពិចារណាលើចំណុចនេះ យុទ្ធសាស្ត្រគ្រប់គ្រងដើម្បីដោះស្រាយគម្រោងដែលនាំឲ្យមានផលប៉ះពាល់នឹងមានឥទ្ធិពលលើទំនាក់ទំនងទៅវិញទៅមករវាងស្ត្រីនិងបុរស នៅគ្រប់ដំណាក់កាលនៃគម្រោង។ វានឹងមានភាពខុសគ្នាចំពោះក្រុមមនុស្សដែលមានវប្បធម៌និងភាសាផ្សេងគ្នា ភាពខុសគ្នាផ្នែកសង្គមសេដ្ឋកិច្ច និង ជាតិសាសន៍ថែមទៀត។ គម្រោងនឹងប៉ះពាល់សង្គម រចនាសម្ព័ន្ធសហគមន៍ ការងារនិងគ្រួសារ ហើយតាមរយៈចំណុចទាំងនេះ នឹងជះឥទ្ធិពលដល់ទំនាក់ទំនងរបស់ស្ត្រី និង បុរស។ ការពិចារណាគោលនយោបាយនិងសកម្មភាពគម្រោងដែលជះឥទ្ធិពលលើទំនាក់ទំនងក្នុងក្រុមគ្រួសារនិងការទទួលខុសត្រូវនានាគឺជារឿងសំខាន់។ លើសពីនេះ ការពិនិត្យលើការសម្រេចក្នុងការផ្តល់សំណងឬការបែងចែកផលប្រយោជន៍របស់គម្រោងអាចប៉ាន់ប្រមាណបានពីអំណាចនិងការគ្រប់គ្រងធនធាននិងទ្រព្យសម្បត្តិ ក៏ដូចជាឱកាសរបស់ស្ថាប័នរដ្ឋក្នុងការធ្វើឲ្យមានឥទ្ធិពលដល់ការផ្តល់អំណាចដល់ស្ត្រី។

- គម្រោងគួរពិចារណាណលើចំណុចទាំងនេះពេលកំពុងធ្វើ :
- យន្តការបណ្តឹងឬដំណើរការដោះស្រាយការកើតទុក្ខមិនសុខចិត្ត
- សិទ្ធិ ធនធាន ដី និង ទឹក ដែលកំពុងចរចារសម្រាប់សហគមន៍ដែលតាំងទីលំនៅថ្មី
- ការជំនួសធនធាននិងរចនាសម្ព័ន្ធន្ធដែលបាត់បង់ ដូចជា សាលារៀន មណ្ឌលសុខភាព និង ផ្សារ
- ការកំណត់ការប្រើប្រាស់សិទ្ធិដើម្បីសហគមន៍ដែលជីវភាពរស់នៅរបស់ពួកគេរងផលប៉ះពាល់ដោយសារគម្រោង
- ការពិគ្រោះយោបល់គម្រោងនិងដំណើរការធ្វើការសម្រេចចិត្តរបស់សហគមន៍
- ការរៀបចំគម្រោងនិងផែនការកាត់បន្ថយផលប៉ះពាល់( ដូចជា ចំពោះ ការតាំងទីលំនៅថ្មី ការគ្រប់គ្រងបរិស្ថាន )
- កិច្ចព្រមព្រៀងបែងចែកផលប្រយោជន៍គម្រោងអភិវឌ្ឍសហគមន៍។

## ៤.៣ តើពេលណាគេគួរធ្វើការវាយតម្លៃហេតុប៉ះពាល់ ?

ការវិភាគនិងការវាយតម្លៃហេតុផលប៉ះពាល់យេនឌ័រគួរត្រូវបញ្ចូលជាផ្នែកមួយក្នុងការនាំឲ្យភាគីពាក់ព័ន្ធចូលរួមក្នុងការធ្វើផែនការយុទ្ធសាស្ត្ររបស់អាងទន្លេមេគង្គ ដែលតាមរយៈកិច្ចការនេះនឹងមានជម្រើសនានាសម្រាប់គម្រោងអភិវឌ្ឍន៍លើទន្លេ។ ការចៀសពីផលប៉ះពាល់អវិជ្ជមានលើយេនឌ័រគួរជាលក្ខណៈវិនិច្ឆ័យមួយចាំបាច់ដើម្បីប៉ាន់ប្រមាណថាជម្រើសរបស់គម្រោងអាចធ្វើបាននិងមាននិរន្តរភាពឬអត់។

នៅក្នុងបរិបទដែលមានគម្រោងទំនប់វារីអគ្គិសនី ការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រនិងជំនាញការខាងផ្នែកយេនឌ័រជារឿងចាំបាច់នៅពេលក្នុងដំណាក់កាលដំបូងៗនៃការអភិវឌ្ឍរបស់គម្រោង។ មុនមានការសម្រេចចិត្តជាក់លាក់ ដើម្បីឲ្យការរៀបចំគម្រោងនិងផែនការគ្រប់គ្រងអាចយកមកសម្របសម្រួល ដោយឈរលើការយល់ដឹងពីយេនឌ័រ ហើយ ដើម្បីឲ្យការរៀបចំថវិកានិងការវិនិយោគបានល្អដោយផ្អែកលើការវិភាគយេនឌ័រ។ ការវិភាគផលប៉ះពាល់យេនឌ័រក្នុងការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន/សង្គមជាជម្រើសសំខាន់។

គំនូសតាងខាងក្រោមបង្ហាញចំណុចសំខាន់ៗក្នុងការចូលរួមរបស់ជំនាញការផ្នែកយេនឌ័រ របស់ស្ត្រី និង របស់ការប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រ អាចកើតនិងគួរមាននៅពេលបង្កើតគម្រោង។ ចំណុចនេះផ្តោតលើការដំណើរការវាយតម្លៃការអនុវត្តល្អ សង្គម និង បរិស្ថានជាគម្រូ។

# យេនឌ័រក្នុងការប៉ាន់ប្រមាណផលវាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន/សង្គមនិងដំណើរការគម្រោង



## ៤.៤ អ្វីជាការអនុវត្តល្អនៅពេលមានការវាយតម្លៃពីយេនឌ័រ?

ចំណុចចាប់ផ្តើមសំខាន់គឺអ្នកអភិវឌ្ឍនៃគម្រោងមើលងាយផលប៉ះពាល់លើយេនឌ័រថាជាបញ្ហាសិទ្ធិមនុស្ស។ ស្ត្រីនិងបុរសមានសិទ្ធិដូចគ្នា។ សិទ្ធិទាំងនេះកើតឡើងនៅក្នុងតួនាទីនិងការទទួលខុសត្រូវក្នុងផ្ទះនិងក្នុងសង្គម។ សិទ្ធិទាំងនេះអាចមានក្នុងទំនៀមទម្លាប់ប្រពៃណី។

ការវាយតម្លៃពីយេនឌ័រអាចជាការជួយស្ថាបនាដើម្បីធានាថាគ្មានបុរសឬស្ត្រីណាខាតបង់ផលប្រយោជន៍ដោយសារមោនអន្តរាគមន៍នៃការអភិវឌ្ឍឡើយ ហើយ គេគួរប្រាប់ពី គម្រោងកាត់បន្ថយផលប៉ះពាល់សំណង និង កម្មវិធីនានាទាក់ទងនឹងការបែងចែកផលប្រយោជន៍។

ការបង្កើតគម្រោងទំនប់វារីអគ្គិសនីតែងមានផលប៉ះពាល់ជានិច្ចលើយេនឌ័រ។ វាអាស្រ័យលើថា តើផលប៉ះពាល់ទាំងនេះអាចចៀសបាននិងអាចគ្រប់គ្រងបានយ៉ាងដូចម្តេច ទើបគេដឹងថា ផលប៉ះពាល់នេះគឺវិជ្ជមានឬក៏អវិជ្ជមាន។

នៅពេលដែលរឿងមួយចំនួនអាចស្មានទុកបាននោះផលប៉ះពាល់មួយចំនួន ជាធម្មតា នឹងមានលក្ខណៈពិសេសទៅតាមចំពោះបរិបទនៃគម្រោងនីមួយៗ។ ដើម្បីស្វែងយល់និងគ្រប់គ្រងផលប៉ះពាល់និងហានិភ័យលោកអ្នកត្រូវទទួលបាននិងសិក្សាទិន្នន័យដោយបែងចែកតាមភេទនិងត្រូវសួរសំណួរដែលត្រឹមត្រូវខាងក្រោម ៖

- តើគម្រោងនេះជាប់ទាក់ទងឬទេដល់ សហគមន៍ដែលរងផលប៉ះពាល់ និង ការប្រើប្រាស់ទន្លេ ព្រមទាំង មូលដ្ឋានធនធានធម្មជាតិ របស់ពួកគេ?
- តើគម្រោងនេះជះឥទ្ធិពលដល់ជីវិតរស់នៅប្រចាំថ្ងៃនៃស្រទាប់ប្រជាជននានាឬទេ?
- តើភាពខុសគ្នារវាងស្ត្រីនិងបុរសជួបប្រទះមានលក្ខណៈយ៉ាងដូចម្តេច ដោយគិតពីតួនាទីនិងការទទួលខុសត្រូវ ការទទួលបាននិងការគ្រប់គ្រងធនធាន សេចក្តីត្រូវការ និងផលប្រយោជន៍ ព្រមទាំង លទ្ធភាពចូលរួមធ្វើការសម្រេចចិត្ត។

## ៤.៥ ការជាប់ទាក់ទងនិងការចូលរួម

លក្ខណៈដែលជនទទួលរងផលប៉ះពាល់ មាន បុរស ស្ត្រី ក្មេង ចាស់ ក្នុងដំណើរការស្វែងយល់ និងវាយតម្លៃយេនឌ័រជាចំណុចសំខាន់ក្នុងការអនុវត្តការងារល្អ។ ការប្រមូលទិន្នន័យគួរធ្វើដោយបែងចែកតាមភេទនិងអនុវត្តដោយមានជាប់ទាក់ទងនឹងក្រុមមនុស្សផ្សេងៗគ្នា មានបុរសមានស្ត្រី។គេគួរបញ្ចូលក្រុមផ្សេងៗគ្នាទាំងនេះឲ្យបានល្អទៅក្នុងការរៀបចំនិងដំណើរការប្រមូលទិន្នន័យនិងការប៉ាន់ប្រមាណ។ គេគួរពិចារណាពីការប្រើភាសា និងការទទួលបានព័ត៌មាននិងឱកាស នៅដំណាក់កាលដំបូងនៃការរៀបចំផែនការសម្រាប់គម្រោង ដើម្បីឲ្យជនពិការ ភាពខុសគ្នាផ្នែកភាសា និង ភាពខុសគ្នាក្នុងការអប់រំ ទាំងអស់គ្នាមានឱកាសស្មើគ្នាដើម្បីចូលរួមនិងឲ្យគេស្តាប់ពីយោបល់របស់ខ្លួន។

### ចំណុចខាងក្រោមជាបញ្ជីត្រួតពិនិត្យដើម្បីបញ្ចូលការអនុវត្តការងារល្អ :

គេគួរពិចារណាដូចខាងក្រោម :

- ☐ ត្រូវធានាថា ការប្រជុំនិងដំណើរការការងារនានាផ្តល់ពេលសមរម្យដើម្បីឲ្យមានការចូលរួមរបស់បុរសនិងស្ត្រី
- ☐ ត្រូវធានាថា ការសម្ភាសនិងក្រុមមនុស្សដែលអញ្ជើញមកចូលរួមប្រជុំមានបុរសមានស្ត្រី ប៉ុន្តែ ស្ត្រីត្រូវបានសម្រួលឲ្យជួបដាច់ដោយឡែក
- ☐ ត្រូវធានាថា ភាសាដែលប្រើអាចឲ្យស្ត្រីងាយស្តាប់ងាយយល់ បញ្ចូលអ្នកសម្របសម្រួលជាស្ត្រី និងអ្នកបកប្រែជាស្ត្រីទៅក្នុងក្រុមដែលធ្វើគម្រោង
- ☐ ត្រូវធានា ថា ស្ត្រីមានក្នុងក្រុមដែលធ្វើគម្រោង និង ថា សមាជិកក្រុមដែលធ្វើគម្រោងមានសមត្ថភាពខ្ពស់ក្នុងការវិភាគយេនឌ័រ
- ☐ ត្រូវធានាថា មានការប្រមូលគំនិតយោបល់របស់មនុស្សក្មេងនិងចាស់ស្មើគ្នានៅក្នុងទិន្នន័យ
- ☐ ត្រូវសម្របសម្រួលនៅពេលផ្តល់ព័ត៌មានត្រឡប់ដោយជាក្រុមឲ្យ មានតែស្ត្រីដាច់ដោយឡែក និង មានបុរសស្ត្រីរួមគ្នា ហើយ ត្រូវធានាថា មានការត្រួតពិនិត្យទិន្នន័យដើម្បីឲ្យមានការយល់ដឹងរួមគ្នាលើការវិភាគ
- ☐ ត្រូវប្រាកដថា បានទាក់ទងស្ត្រីឲ្យចូលរួមក្នុងការត្រួតពិនិត្យនិងរបាយការណ៍ស្តីពីការរកឃើញនានា និងការវិភាគ ត្រូវឲ្យមានតំណាងក្រុមមនុស្សដែលមាន វប្បធម៌ ជាតិពន្ធុ ឬ សង្គមសេដ្ឋកិច្ច ផ្សេងគ្នា ពីក្នុងសហគមន៍នោះ
- ☐ បញ្ចូលស្ត្រីនិងបុរសពីប្រជាជនជាជនជាតិដើមភាគតិច ឬនិគមជនជាតិពន្ធុនៅក្នុងដំណើរការការងារនិងធានាថាអ្នកទាំងនោះបានបញ្ចូលមតិយោបល់គេស្មើគ្នា និង
- ☐ រកឧបាំងវប្បធម៌ដែលរាំងការចូលរួមរបស់ស្ត្រីហើយរកវិធីដោះស្រាយ។

ទំព័រ ១/១

នេះជាបញ្ជីត្រួតពិនិត្យគម្រូ។ តារាងបញ្ជីអាចទាញយកពី www.oxfam.org.au/giamanual





កសិករស្ទូងស្រូវ, ខេត្តវៀងចន្ទ ប្រទេសឡាវ។
រូបថត ៖ ដេវី ហ្គែលា/អុកស្វាម អូស្ត្រាលី

## ៥ យេនឌ័រក្នុងអាងទន្លេមេគង្គ : មុនគម្រោង

មុនមានទំនប់ គឺមានទន្លេ និង មានមនុស្សដែលប្រើទន្លេនោះ។ បុរសនិងស្ត្រីនឹងប្រើទន្លេក្នុងរបៀបផ្សេងគ្នា។ ពួកគេនឹងឲ្យតម្លៃ ទន្លេនិងធនធានរបស់វាផ្សេងៗគ្នា។ ពួកគេនឹងមានតួនាទីនិងការទទួលខុសត្រូវផ្សេងគ្នាទាក់ទងនឹងការទទួលបាននិងការគ្រប់គ្រងផ្សេងគ្នាលើធនធានរបស់ទន្លេ។ វាខុសគ្នាផងដែរក្នុងការដែលពួកគេទាក់ទងគ្នា ក្នុងក្រុមភាសាក្នុងសហគមន៍ និង តាមសហគមន៍ផ្សេងៗ។ ការយល់ពីបរិបទនេះគឺមានសារៈសំខាន់ចំពោះក្រសួងដែលទទួលខុសត្រូវ ការគ្រប់គ្រងទឹក ការគ្រប់គ្រងកសិកម្ម ដី និង ធនធាន មច្ឆជាតិ អ្នកធ្វើផែនការនានា។ល។

ការធ្វើផែនការអាងទន្លេមេគង្គជាយុទ្ធសាស្ត្រ រួមមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រនិងការប៉ាន់ប្រមាណផលវាយតម្លៃហេតុប៉ះពាល់ដែលកើតឡើងជាបណ្តុំអាចផ្តល់ឱកាសសំខាន់ដើម្បីធានាឲ្យមានទិន្នន័យដោយបែងចែកតាមភេទកាន់តែប្រសើរ និងការយល់ដឹងយេនឌ័ររបស់សហគមន៍ ជីវភាពរស់នៅ និង របៀបរស់នៅតាមដងទន្លេមេគង្គ។ នៅពេលរដ្ឋាភិបាលនិងអាជ្ញាធរនៃអាងទន្លេយកគំនិតយោបល់ផ្សេងៗមុនការសម្រេចចិត្តលើហេដ្ឋារចនាសម្ព័ន្ធនិងការវិនិយោគ វាច្បាស់ណាស់ថា គេអាចចៀសផុតពីផលប៉ះពាល់អវិជ្ជមាន ហើយ ឱកាសយេនឌ័រដែលនាំមកនូវការផ្លាស់ប្តូរនោះអាចកើតមានឡើង។

*"ការអភិវឌ្ឍក្នុងល្បឿនដ៏លឿននៅអាងទន្លេមេគង្គក្រោមបង្ហាញឲ្យឃើញពីការប្រឈមសំខាន់ចំពោះរដ្ឋាភិបាលនានាដែលទទួលខុសត្រូវការគ្រប់គ្រងអាងទន្លេថា ស្ថិតក្រោមសម្ពាធនៃសេចក្តីត្រូវការដែលចាំបាច់ជាច្រើន។ អាងទន្លេដែលមិនសូវអភិវឌ្ឍច្រើនមានកម្រិតក្រីក្រខ្ពស់និងការពឹងផ្អែកខ្ពស់លើធនធានទន្លេដើម្បីជីវភាពរស់នៅនៃប្រជាជននៅតាមអាងទន្លេទាំងនោះ។ ស្របពេលដែលទំនប់វារីអគ្គិសនីផ្តល់ឱកាសសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនោះ គេទទួលស្គាល់យ៉ាងទូលំទូលាយថា វាក៏នាំមកនូវហានិភ័យសង្គមនិងបរិស្ថានខ្លាំងក្លាណាស់ដែរ។*

*ការអភិវឌ្ឍប្រកបដោយនិរន្តរភាពទាមទារឲ្យពិចារណាលើបញ្ហារួមនិងការដោះដូរគ្នាក្នុងតម្លៃជាសេដ្ឋកិច្ច សង្គម និង បរិស្ថាន។ លំនឹងតម្លៃរវាងសហគមន៍ បរិស្ថាន និង សេដ្ឋកិច្ច ត្រូវសម្រេចឲ្យបាននិងត្រូវធានាឲ្យបានក្នុងលក្ខណៈច្បាស់លាស់និងមានការទទួលខុសត្រូវ ដោយទាញយកផលប្រយោជន៍នៃ ការពង្រីកចំណេះដឹង គំនិតយោបល់នានា និង គំនិតផ្តួចផ្តើមថ្មី"(RSAT 2010, p. 7)។*

### ដំណាក់កាលមុនគម្រោង : ការយល់ដឹងអំពីបរិបទ - ការប្រមូលទិន្នន័យនិងការអង្កេត យេនឌ័របឋម

ការអនុវត្តការងារល្អគឺថាអាងទន្លេមានផែនការគ្រប់គ្រងជាកម្រិតយុទ្ធសាស្ត្រ ដោយមានការយល់ដឹងឆ្លងព្រំដែន ប្រសិនបើទន្លេនោះហូរឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយទៀត។ ប៉ុន្តែ ផែនការជាច្រើនខ្វះការព្រមព្រៀងកម្រិតខ្ពស់បែបនេះ ឬ មានដែរតែក្រោយពីការសម្រេចចិត្តវិនិយោគនិងអភិវឌ្ឍន៍។ សម្រាប់ក្រុមហ៊ុនដែលចាប់អារម្មណ៍បង្កើតគម្រោង ឬ អ្នកដែលគេជួលឲ្យប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថានឬសង្គមសម្រាប់គម្រោង ដោយធានាថា អ្នកទាំងនេះបានយល់ដឹងពីយេនឌ័របានពេញលេញចំពោះ សហគមន៍ អ្នកប្រើប្រាស់ទន្លេ និង បរិបទទូទាំងអាងទន្លេជារឿងសំខាន់។ នៅពេលដែលមានការយល់ដឹងពីយេនឌ័រហើយ ការសម្រេចចិត្តនាពេលអនាគតលើការធ្វើផែនការនិងការគ្រប់គ្រងនឹងបង្ហាញពីការពិចារណាពីលទ្ធផលនិងទំនាក់ទំនងយេនឌ័រ។

ដោយបញ្ចូលការប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រទៅក្នុងវិធីអង្កេតមូលដ្ឋាននិងបច្ចេកទេសប្រមូលទិន្នន័យសម្រាប់ការគ្រប់គ្រងអាងទន្លេ វាអាចនាំឲ្យការយល់ដឹងពីយេនឌ័រនឹងត្រូវគេបញ្ចូលទៅក្នុងការសម្រេចចិត្តលើលទ្ធភាពប្រព្រឹត្តទៅរបស់គម្រោងនិងការធ្វើផែនការ។ នេះជាការអនុវត្តការងារល្អ។

ជំពូកនេះផ្តល់ការពិនិត្យលើសំណួរសំខាន់ៗមួយចំនួនគួរពិចារណាក្នុងការបង្កើតការអង្កេត យេនឌ័របឋមនៃអាងទន្លេនិងប្រជាជនដែលរស់នៅនោះ។

ជំពូកនេះបង្ហាញផងដែរ លើឱកាសធំៗក្នុងការពិចារណាយេនឌ័រក្នុងការសម្រេចចិត្តលើការធ្វើផែនការអនុវត្តការងារល្អ និង លើបរិបទនៃការធ្វើការសម្រេចចិត្ត។នៅផ្នែកចុងក្រោយ ជំពូកបង្ហាញពីបរិបទកម្រិតខ្ពស់ចំពោះផលប៉ះពាល់យេនឌ័របណ្តាលមកពីការផ្លាស់ប្តូរនៅអាងទន្លេហើយស្នើជាយោបល់លើចំណុចដែលគេអាចជួបនឹងផលប៉ះពាល់ទាំងនេះ។

## ប្រើការវាយតម្លៃហេតុប៉ះពាល់លើយេនឌ័រ ដើម្បីណែនាំការបង្កើតគម្រោងនិងការឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធ

ចូរពិចារណាសំណួរខាងក្រោមក្នុងការបង្កើតការយល់ដឹងពីទន្លេ និងបរិបទចំពោះផលប៉ះពាល់ដោយទំនប់វារីអគ្គិសនី :

- ☐ តើមានការយល់ដឹងច្បាស់លាស់ទេពីរបៀបដែលទន្លេនិងធនធានរបស់ត្រូវបានប្រើដោយសហគមន៍រស់នៅតាមដងទន្លេ? តើចំណុចនេះបញ្ចូលការយល់ដឹងពីតួនាទីនិងសកម្មភាពផ្សេងគ្នារបស់បុរសនិងស្ត្រីឬទេ?
- ☐ តើការប៉ាន់ប្រមាណការអង្កេតបឋមសិក្សានរណារស់នៅលីនិងនៅក្បែរទន្លេ ហើយ ប្រើប្រាស់ទន្លេ ដើម្បីជីវភាពរស់នៅរបស់ខ្លួនឬទេ? តើមានការយល់ដឹងពីការប្រើប្រាស់ផ្សេងគ្នាចំពោះទន្លេនិងធនធានរបស់វាដោយបុរសនិងស្ត្រីឬទេ? ចំណុចនេះគួរបញ្ចូលការពិចារណាលើសកម្មភាពសេដ្ឋកិច្ចផ្ទាល់រួមគ្នារបស់បុរសនិងរបស់ស្ត្រី (ឧទាហរណ៍ ការលាងចានឆ្នាំង ការដងទឹក ការដឹកជញ្ជូន ការលេងកម្សាន្ត) ក៏ដូចជាសកម្មភាពសង្គមនិងវប្បធម៌ (ដូចជា ពិធីសាសនាឬព្រលឹងដូនតានិងកន្លែងនានាដែលសំខាន់សម្រាប់សហគមន៍គោរពបូជា)។
- ☐ តើមានការប៉ាន់ប្រមាណ ការអង្កេតបឋមបញ្ចូលអ្នកប្រើប្រាស់ទន្លេនៅតាមរដូវផ្សេងឬទេ?
- ☐ តើការប៉ាន់ប្រមាណការអង្កេតបឋមពិចារណាពីអ្នកប្រើប្រាស់ទន្លេមកពីកន្លែងឆ្ងាយៗ ដូចជា សហគមន៍ដែលទៅទន្លេដើម្បីរកត្រីតាមរដូវ ក្រៅពីអ្នករស់នៅនឹងទន្លេឬទេ?
- ☐ តើចំណុចនេះបញ្ចូលការយល់ដឹងពីការទទួលខុសត្រូវនិងការប្រើប្រាស់និងធនធានរបស់ទន្លេដោយបុរសនិងស្ត្រីឬទេ? តើការប៉ាន់ប្រមាណការអង្កេតបឋមពិចារណាលើលក្ខខណ្ឌនិងស្ថានភាពផ្សេងគ្នានៅគ្រប់ទិដ្ឋភាពនៃសហគមន៍និងប្រព័ន្ធអេកូដែលរងផលប៉ះពាល់ឬទេ? គឺថា តើការប៉ាន់ប្រមាណការអង្កេតបឋមនេះបញ្ចូលសហគមន៍ឆ្លងព្រំដែនទន្លេនិងជីវភាពរបស់ពួកគាត់ឬទេ? ហើយត្រង់ចំណុចនេះគេមានទទួលទិន្នន័យដែលមានការបែងចែកតាមភេទឬទេ?

## នៅកម្រិតការធ្វើផែនការយុទ្ធសាស្ត្រសម្រាប់អាងទន្លេ វាមានសារៈសំខាន់ដើម្បីពិចារណាលើផលប៉ះពាល់យេនឌ័រ និងសេចក្តីត្រូវរបស់យេនឌ័រប្រើប្រាស់ដំណើរការនិងអន្តរាគមន៍ខាងក្រោម

**ការប៉ាន់ប្រមាណជម្រើស :** ការប៉ាន់ប្រមាណជម្រើសដោយមានពិចារណាសព្វគ្រប់របស់ផែនការអភិវឌ្ឍលើតម្រូវការទន្លេត្រូវពិចារណាការប្រើប្រាស់ទឹកសម្រាប់សុខភាពប្រព័ន្ធអេកូ សម្រាប់ជីវភាពរស់នៅ និងសកម្មភាពវប្បធម៌របស់សហគមន៍ ក៏ដូចជាពិចារណាពីសេវាអគ្គិសនីដែលអាចមានសម្រាប់ការប្រើប្រាស់នានា។ នៅដំណាក់កាលនេះ ជម្រើសក្រៅពីទំនប់ជាផ្នែកសំខាន់មួយនៃផែនការអភិវឌ្ឍ។ គេអាចធ្វើឲ្យប្រសើរឡើងនូវរចនាសម្ព័ន្ធដែលកំពុងមានដើម្បីផ្គត់ផ្គង់តម្រូវការថាមពលនិងទឹក។

**ការគ្រប់គ្រងលើតម្រូវការ :** ដោយពិចារណាលើផលប៉ះពាល់យេនឌ័រនិងឱកាសក្នុងការកាត់បន្ថយការប្រើប្រាស់ ប្រសិទ្ធភាពនៃការប្រើប្រាស់ឡើងវិញនិងថាមពលអាចជួយឲ្យសម្រេចបានផលប្រយោជន៍យុទ្ធសាស្ត្រយេនឌ័រ។

**ការគ្រប់គ្រងលើការផ្គត់ផ្គង់ :** ការពិចារណាលើជម្រើសដែលផ្តល់តម្រូវទឹកនិងថាមសម្រាប់អ្នកប្រើប្រាស់នានាជារឿងចាំបាច់។ ឧទាហរណ៍ តម្រូវការរបស់ភូមិនៅឆ្ងាយដាច់ស្រយាល ជាធម្មតា ត្រូវការថាមពលខ្នាតតូច កកើតឡើងវិញដែលប្រើបានទាំងអស់គ្នាក្នុងភូមិ ជាជាងប្រព័ន្ធថាមពលទំហំធំ។

**លំហូរបរិស្ថាន/លំហូរទឹកខាងក្រោម :** ពិនិត្យមើលតម្រូវការយេនឌ័រក្នុងការបញ្ជូននៃលំហូរបរិស្ថានដើម្បីស្វែងយល់ពី បម្រែបម្រួលលំហូរទឹកជារទឹក និង ការកំណត់ពេលបង្ហូរទឹកភ្ជាប់ទៅនឹងដំណើរការបរិស្ថាននិងទំនាក់ទំនងសហគមន៍នៅផ្លូវទឹកខាងក្រោមជាមួយទន្លេនិងដំបន់ដីលិចទឹកពិចារណាលើតួនាទីនិងការទទួលខុសត្រូវយេនឌ័រ និង បរិបទទឹកហូរឆ្លងព្រំដែនប្រទេស។

**ការតាំងទី និង ការរៀបចំ :** ពិចារណាលើផលប៉ះពាល់យេនឌ័រក្នុងការប៉ាន់ប្រមាណថា ជម្រើសនោះទៅរួចឬអត់ដើម្បីការតាំងទីរបស់ទំនប់និងការរៀបចំអាចជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រឯទៀតដើម្បីចៀសឬបន្ថយឲ្យបានតិចបំផុតនូវផលប៉ះពាល់លើយេនឌ័រដោយសារទំនប់វារីអគ្គិសនី។

**ការវាយតម្លៃហេតុប៉ះពាល់សង្គម :** ការរៀបចំនិងការអនុវត្តការប៉ាន់ប្រមាណសង្គមនៅលទ្ធផលប្រព្រឹត្តទៅរបស់គម្រោងដំណាក់កាលដំបូងជាចំណុចងាយ និងមានប្រសិទ្ធភាពបំផុត ដើម្បីឲ្យមានការចូលរួមពីស្ត្រី និងមានការពិចារណាពីផលប៉ះពាល់លើយេនឌ័រ។ បញ្ហាទាំងនេះជារឿយៗ នឹងមាននៅពេលមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន :** ដូចគ្នានឹងការវាយតម្លៃហេតុប៉ះពាល់សង្គម ការរៀបចំនិងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានផ្តល់ឱកាសសំខាន់ ដើម្បីស្តាប់គំនិតយោបល់របស់ស្ត្រី និងបង្ហាញតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ។ ពិចារណាផលប៉ះពាល់យេនឌ័រក្នុង ការវាយតម្លៃហេតុប៉ះពាល់សង្គម/បរិស្ថាន ជាចំណុចសំខាន់ ក៏ដូចជាសម្របសម្រួលឱកាសដ៏សំខាន់ដើម្បីឲ្យមានការចូលរួមរបស់ស្ត្រី។

**ទាំងការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន ទាំងការប៉ាន់ប្រមាណផលប៉ះពាល់សង្គម គួរពិចារណាផលប៉ះពាល់ទូទាំងអាងទន្លេ ដែលតំបន់ទន្លេមេគង្គអាច ជារឿយៗជាការឆ្លងកាត់ព្រំដែនប្រទេស។**

## យេនឌ័រក្នុងការធ្វើការសម្រេចចិត្ត

### តើអ្នកណាដែលកំពុងធ្វើការសម្រេចចិត្ត?

ការសម្រេចចិត្តនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍទន្លេនឹងធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវលើធនធានទឹក។ ក្នុងករណីខ្លះ អាជ្ញាធរអាងទន្លេអាចនឹងបង្កើតឡើងនិងឲ្យទទួលយកការទទួលខុសត្រូវទាំងនេះ ប៉ុន្តែ ក្នុងករណីច្រើនបំផុតរដ្ឋាភិបាលនឹងគ្រប់គ្រង ជាចុងក្រោយ លើសម្រេចចិត្តនានា។ គេឃើញភាគច្រើនបំផុតបញ្ហានេះនឹងបញ្ចូលក្រសួងធនធានទឹក បរិស្ថាននិងអភិវឌ្ឍន៍ជនបទ ឬ ធនធានធម្មជាតិ។ បញ្ជីត្រួតពិនិត្យនិងសៀវភៅណែនាំលើយេនឌ័រអាចផ្តល់ចំណុចចាប់ផ្តើមមានប្រយោជន៍សម្រាប់ភ្នាក់ងាររដ្ឋាភិបាលដើម្បីធានាថា យេនឌ័រមានបញ្ចូលក្នុងបរិបទខាងក្រោមក្នុងការធ្វើផែនការអាងទន្លេនិងការធ្វើការសម្រេចចិត្ត។

- ☐ ការយល់ពីបរិបទច្បាប់ជារឿងសំខាន់។ អ្វីដែលច្បាប់ និង បទបញ្ញាតិគ្របដណ្តប់លើការគ្រប់គ្រង និងការប្រើប្រាស់ និង ការដែលចំណុចទាំងនេះដូចគ្នាឬខុសគ្នាតាមព្រំដែនប្រទេសនោះគឺជាការពិចារណាសំខាន់មួយ។
- ☐ បរិបទច្បាប់នេះអនុញ្ញាតឲ្យអ្នកប្រើប្រាស់ឬអ្នកអភិវឌ្ឍរបស់ទន្លេមានភាពប្រាកដប្រជាលើធនធាន (ដូចជាលំហូរទឹក និង គុណភាពទឹក) ដើម្បីឲ្យពួកគេអាចរៀបចំផែនការតាមនេះ។ បើដូច្នេះ ការប្រែប្រួល ឬ ការដែលនឹងប្រែប្រួលចំពោះធនធានទាំងនោះនៅខ្សែទឹកខាងលើឬខាងក្រោម ភ្នាក់ងារ ឬអាជ្ញាធរបង្ហាញនូវហានិភ័យនានាចំពោះការអភិវឌ្ឍ ឬការវិនិយោគលើទន្លេ ឬ អ្នកដែលរស់នៅអាស្រ័យធនធានទន្លេ។ នេះជាបរិបទសម្រាប់ទំនប់វារីអគ្គិសនី។

**ប្រភេទនៃការសម្រេចចិត្តមានសារៈសំខាន់សម្រាប់អនាគតទន្លេនឹងបញ្ចូល ៖**

- ☐ តើអ្វីទៅជាស្ថានភាពទន្លេ និងអាងរបស់ទន្លេ (បរិស្ថាន សេដ្ឋកិច្ច សង្គម នយោបាយ)?
- ☐ តើវាស្ថិតក្រោមអាជ្ញាធរមួយឬវាហូរកាត់ព្រំដែនប្រទេស?
- ☐ តើការប្រើប្រាស់ទន្លេនិងធនធានរបស់វានៅបន្ត ហើយ
- ☐ តើអ្វីជាបរិបទសម្រាប់ការប្រើប្រាស់ (តើអ្នកប្រើប្រាស់ទន្លេនិងធនធានរបស់ទន្លេមានសិទ្ធិក្នុងការទទួលបានការប្រើប្រាស់ឬទេ)?
- ☐ អ្វីជាផែនការឬយុទ្ធសាស្រ្តកំពុងអនុវត្តក្នុងការណែនាំការប្រើប្រាស់ទន្លេនិងធនធានរបស់ទន្លេ?
- ☐ នៅថ្ងៃអនាគត តើធនធានធម្មជាតិ (ដូចជា ព្រៃលិចទឹកភ្លៀង មាត់ទន្លេ តំបន់ដីសើម វាលភក់ ឬ តួទន្លេ) ត្រូវបានបែងចែកជាតំបន់គ្រប់គ្រងឬទេ?
- ☐ តើត្រូវគ្រប់គ្រងធនធានទាំងនោះយ៉ាងដូចម្តេច? រួមមានទិដ្ឋភាពនានានៃការគ្រប់គ្រង ដូចជាការប្រើប្រាស់ធនធានរួម និង ការប្រើប្រាស់ជាឯកជនសម្រាប់អ្នកប្រើប្រាស់ខ្លះ (ដូចជា ការអភិវឌ្ឍ ការទាញយកការ ស្រោចស្រពដីស្រែ ចម្ការនិងការយកទៅចែកចាយបន្ត ការរុករករ៉ែ ទំនប់វារីអគ្គិសនី)
- ☐ សិទ្ធិទាំងឡាយក្នុងច្បាប់ៈ តើទន្លេនិងធនធានផ្សេងទឹកភ្លៀងត្រូវបានការពារយ៉ាងដូចម្តេចក្នុងច្បាប់? តើវាមានលក្ខណៈឯកជន តើវាអាចឲ្យសហគមន៍ប្រើប្រាស់ឬទេ តើអ្វីជាបទបញ្ញត្តិទាក់ទងនឹងការទទួលបានការប្រើប្រាស់ និងសិទ្ធិប្រើប្រាស់សម្រាប់សហគមន៍?
- ☐ ការប្រើប្រាស់និងសិទ្ធិទទួលបានការប្រើប្រាស់ ៖ តើអ្នកមានសិទ្ធទទួលបាន និងប្រើប្រាស់ធនធានទាំងនោះពីទន្លេ?

ទំព័រ ១/១

នេះជាបញ្ជីត្រួតពិនិត្យគម្រូ; តារាងនៃបញ្ជីនេះអាចទាញយកពី www.oxfam.org.au/giamanual

តារាងខាងក្រោមបង្ហាញពីបរិបទកម្រិតខ្ពស់ដែលការប្រែប្រួលទន្លេអាចជះឥទ្ធិពលដល់បុរសនិងស្ត្រីផ្សេងពីគ្នា។ ការប្រែប្រួលមួយចំនួនកើតឡើងដោយសារការអភិវឌ្ឍទំនប់វារីអគ្គិសនី មួយចំនួនបណ្តាលមកពីកត្តាងទៀតដែលជះឥទ្ធិពលដល់លទ្ធភាពប្រព្រឹត្តទៅនៃគម្រោងទំនប់វារីអគ្គិសនី។

## បរិបទសម្រាប់យេនឌ័រកើតឡើងពីការប្រែប្រួលដែលអាចកើតមានចំពោះទន្លេនិងអ្វីដែលមានន័យចំពោះទំនប់វារីអគ្គិសនី

| ការប្រែប្រួលចំពោះប្រព័ន្ធធម្មជាតិ | ផលប៉ះពាល់លើធនធាន | ផលប៉ះពាល់ចំពោះទំនប់វារីអគ្គិសនី | ការពិចារណាអំពីយេនឌ័រ |
|---|---|---|---|
| ការទាញយកចេញពីខ្សែទឹកខាងលើទន្លេ(ឧទាហរណ៍ ដោយទំនប់ផ្សេងទៀតសម្រាប់ការស្រោចស្រពសម្រាប់ការផ្គត់ផ្គង់ទឹក) | ទឹកមានចំនួនតិច | អាចប៉ះពាល់លទ្ធភាពប្រព្រឹត្តទៅរបស់គម្រោងឬលទ្ធភាពសេដ្ឋកិច្ចនៃទំនប់វារីអគ្គិសនីដែលបានគ្រោងទុក | អាចប៉ះពាល់ដល់ផលិតកម្មកសិកម្មរបស់ បុរស, ស្ត្រី និង សហគមន៍ |
| គុណភាពទឹកប៉ះពាល់នៅខ្សែទឹកខាងលើដោយសកម្មភាពឧស្សាហកម្មផ្សេងទៀត | គុណភាពទឹកថយចុះឬប្រែប្រួលដោយសារសកម្មភាពនៅខ្សែទឹកខាងលើ | អាចប៉ះពាល់ដល់ទួប៊ីននិងសកម្មភាពសេដ្ឋកិច្ច | អាចមានផលប៉ះពាល់ជាបណ្តុំ ដូចជា ចំពោះ ការប្រើប្រាស់ទឹករបស់គ្រួសារ ការមុជទឹក ការដុះលាង ការប្រើប្រាស់ទឹកសម្រាប់ចម្ការច្បារដំណាំ |
| ព្រៃឈើត្រូវកាប់សម្អាតចេញ | គុណភាពទឹកចុះថយ | អាចប៉ះពាល់ដល់ទួប៊ីននិងសកម្មភាពសេដ្ឋកិច្ច | ការប្រើប្រាស់ព្រៃសម្រាប់ឈើករុក្ខជាតិនិងសត្វអាចនឹងត្រូវប៉ះពាល់ |
| ទំនប់ឃាំងទឹកនិងបង្វែរសម្រាប់បង្កើតវារីអគ្គិសនី | ទន្លេប្រែប្រួល; លំហូរ ទឹកទន្លេឡើងចុះមិនតាមរដូវ ទឹកខ្សោះអុកស៊ីហ្សែន | អាចប៉ះពាល់ដល់ម៉ាស៊ីនបើកបិទទឹកនៅខ្សែទឹកខាងក្រោមប្រសិនបើលំហូរទឹកមិនអាចស្មានបាន | អាចប៉ះពាល់ដល់របៀបប្រើប្រាស់ទឹករបស់បុរសនិងស្ត្រីសម្រាប់ក្រុមគ្រួសារនិងការទទួលខុសត្រូវផ្នែកសេដ្ឋកិច្ច ជាពិសេស ប៉ះពាល់ដល់ស្ត្រីដែលប្រើទន្លេដើម្បី មុជទឹកដុសលាង, ការស្វែងរកម្ហូប |
| ទឹកដែលយកចេញពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតដើម្បីបង្កើតវារីអគ្គិសនី | លំហូរទឹកតិចក្នុងប្រព័ន្ធមួយ, លំហូរទឹកតាមរដូវ ឬ លំហូរទឹកខ្ពស់ហួតក្នុងប្រព័ន្ធផ្សេងទៀត | អាចកែសម្រួលទំនប់លើប្រព័ន្ធទទួលដែលមានលំហូរកើនឡើង អាចធ្វើឲ្យគម្រោងមិនអាចទៅរួច ប្រសិនបើនៅតែមានលំហូរទាប | ដូចគ្នានឹងខាងលើគឺប៉ះពាល់ដល់សកម្មភាពផលិតកម្ម។ លំហូរទឹកកើនឡើងឬថយចុះអាចប៉ះពាល់ដល់ភូមិករឬផ្ទះសំបែង |
| តំបន់ដីសើមខ្សែទឹកខាងក្រោមមិនបានទទួលទឹកជំនន់គ្រប់គ្រាន់ដើម្បីរក្សាជីវះចម្រុះ | តំបន់ដីសើមស្ងួតទៅៗ, តំបន់ព្រៃលិចទឹកអត់មាន"ទឹកចូលបំពេញ" ត្រីនិងប្រភេទសត្វរុក្ខជាតិទឹកដទៃទៀតត្រូវប៉ះពាល់/ងាប់ | | ឧស្សាហកម្មផលិតកម្មរបស់បុរសនិងស្ត្រីទាក់ទងនឹងតំបន់ដីសើមត្រូវប៉ះពាល់ ត្រីនិងផ្សារត្រីប្រែប្រួលជីវភាពត្រូវប៉ះពាល់ |
| ប្រព័ន្ធអេកូដីសណ្តរត្រូវប៉ះពាល់ធ្វើឲ្យប្រែប្រួលលំនឹងទឹកសាប/ទឹកប្រៃ | តំបន់នានាក្លាយជាមានដីប្រៃច្រើន/តិច។ កំណល្បាប់ដីសណ្តរនិងផ្នូកខ្សាច់ប្រែប្រួល | | ដូចគ្នានឹងខាងលើគឺប៉ះពាល់ដល់សកម្មភាពផលិតកម្ម។ អាចប៉ះពាល់ដល់ភូមិករឬផ្ទះសំបែង និង ការប្រកបរបរចិញ្ចឹមជីវិត |

## ការប្រើប្រាស់ទិន្នន័យដើម្បីបញ្ជាក់ពីការសម្រេចចិត្ត និងការគ្រប់គ្រងទន្លេនិងធនធានធម្មជាតិ

នៅពេលមានទិន្នន័យបានបែងចែកតាមភេទជាក់លាក់មាំហើយ តើទិន្នន័យទាំងនេះប្រើនៅក្នុងបញ្ហាអ្វីនិងប្រើបែបណា?

ការសិក្សាមូលដ្ឋាននេះផ្តល់ការយល់ដឹងពីការប្រើប្រាស់ទន្លេនិងធនធានរបស់ទន្លេផ្សេងគ្នាចំពោះ បុរស ស្ត្រី និង សហគមន៍។ វាផ្តល់ផងដែរនូវគំនិតបង្ហាញថាហេតុអ្វីបានជាវាដូចគ្នាឬខុសគ្នាតាមសហគន៍ផ្សេងៗ ក្នុងបរិបទផ្សេងៗ។ បរិបទខុសគ្នាទាំងនេះអាចមាន ៖

- ទីតាំងក្នុងទន្លេនិងប្រព័ន្ធអាង
- ការសិក្សាពីប្រជាជននៃសហគមន៍
- ឋានៈសេដ្ឋកិច្ចសង្គមនៃសហគមន៍
- ទំនាក់ទំនងផ្លូវការនិងមិនផ្លូវការដែលសហគមន៍ទាំងនោះដែលមានជាមួយទន្លេនិងធនធានរបស់ទន្លេ
- បញ្ហាច្បាប់នៃទំនាក់ទំនងទាំងនេះនិងការពឹងផ្អែកលើទន្លេ និងធនធានរបស់ទន្លេ
- ការដែលទំនាក់ទំនងនិងការពឹងផ្អែកលើទន្លេនិងធនធានរបស់ទន្លេប្រែប្រួលឬផ្លាស់ប្តូរតាមពេលវេលាតាមរដូវនិងពីមួយឆ្នាំទៅមួយឆ្នាំ
- ការដែលអ្នកប្រើប្រាស់ទន្លេនិងធនធានរបស់ទន្លេផ្សេងទៀតប៉ះពាល់ដល់ការប្រើប្រាស់និងការទទួលបានការប្រើប្រាស់ទន្លេរបស់សហគមន៍

ការសម្រេចចិត្តទាក់ទងនឹងអភិបាលកិច្ចនិងការគ្រប់គ្រងទន្លេគួរពិចារណាចំណុចទាំងនេះ។



## ៦ ដំណើរការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ

ជំពូកនេះនឹងរៀបរាប់អំពីដំណើរការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ។ ជំពូកនេះនឹងណែនាំជូននូវឧបករណ៍ជាឧទាហរណ៍និងបញ្ជីត្រួតពិនិត្យមួយចំនួន សម្រាប់ជួយដល់អ្នករៀបចំអភិវឌ្ឍន៍គម្រោងនិងភ្នាក់ងាររដ្ឋាភិបាល ក្នុងការប្រមូលទិន្នន័យបែងចែកតាមភេទ ព្រមទាំងជួយគូសបញ្ជាក់បង្ហាញរបៀបប្រើទិន្នន័យនេះសម្រាប់ផ្តល់ព័ត៌មានសម្រាប់ការសម្រេចចិត្តថ្នាក់គម្រោង ការរៀបចំផែនការគ្រប់គ្រងគម្រោង និងការអនុវត្តគម្រោង។ ដំណើរការនេះត្រូវបានរចនាបង្កើតឡើង ឲ្យមានភាពជាក់ទាក់ទងក្នុងវដ្តគម្រោងទាំងមូល ចាប់តាំងពីដំណាក់កាលដំបូងនៃការសិក្សាអំពីលទ្ធភាពប្រព្រឹត្តទៅរបស់គម្រោង រហូតដល់ដំណាក់កាលធ្វើផែនការគម្រោង ការអនុវត្តគម្រោង និងប្រតិបត្តិការគម្រោង។

ដំណើរការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនេះ ត្រូវបានរៀបចំក្នុងទម្រង់ជាការណែនាំមួយជំហានម្តងៗ។

**សៀវភៅនេះអាចផ្តល់ឲ្យបុគ្គលិកណែនាំវដ្តរបស់គំរោង ការប៉ាន់ប្រមាណ ធ្វើផែនការ និងត្រួតពិនិត្យ**



## ៦.១ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅក្នុងដំណាក់ការលទ្ធភាពប្រព្រឹត្តទៅរបស់គម្រោងដំណាក់កាលកសាងគម្រោង និងដំណាក់កាលធ្វើផែនការ

នៅពេលដែលគម្រោងមួយត្រូវបានបង្កើតឡើង និងទទួលបានការអនុញ្ញាតិឲ្យចាប់ផ្តើមដំណាក់កាលសិក្សាលទ្ធភាពប្រព្រឹត្តទៅរបស់គម្រោង និងដំណាក់កាលធ្វើផែនការ នេះជាពេលវេលាដ៏សំខាន់បំផុតមួយក្នុងការធានាថាការប៉ាន់ប្រមាណអំពីយេនឌ័រត្រូវបានធ្វើឡើងប្រកបដោយភាពពេញចិត្ត។ ការយល់ដឹងពាក់ព័ន្ធយេនឌ័រទាក់ទងផលប៉ះពាល់គម្រោងនៅដំណាក់កាលនេះ គេនឹងអាចធានាថា ការសម្រេចក្នុងពេលអនាគតអំពីការរចនា អំពីថវិកា និងអំពីប្រតិបត្តិការរបស់គម្រោងនឹងកើតចេញមកពីចំណុចចាប់ផ្តើមមួយដែលមានការយល់ជ្រួតជ្រាតអំពីបញ្ហាយេនឌ័រ។ ប្រការនេះនឹងធ្វើឲ្យហានិភ័យក្នុងគម្រោងនេះស្ថិតក្នុងកម្រិតទាបបំផុត។

### ការដោះស្រាយផលប៉ះពាល់យេនឌ័រនៅក្នុងគម្រោង

គោលបំណងគឺសម្រាប់ឲ្យមានការដាក់ដំណាក់កាលទាំងនេះ និងដាក់មតិយោបល់ក្នុងដំណាក់កាលទាំងនេះចូលទៅក្នុងផែនការគ្រប់គ្រងផ្សេងទៀត។ តែទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានសារៈសំខាន់ណាស់ដែលគម្រោងត្រូវរៀបចំឲ្យមានការយល់ដឹងបានល្អអំពីស្ថានភាពទំនាក់ទំនងយេនឌ័រនៅពេលបច្ចុប្បន្ន និងបរិបទយេនឌ័រ នៅក្នុងសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងតំបន់ដទៃទៀតដែលជាប់ពាក់ព័ន្ធនឹងគម្រោង។ ការយល់ដឹងពាក់ព័ន្ធនឹងយេនឌ័រនេះ អាចត្រូវគេយកមកប្រើ ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ធ្វើផែនការដោះស្រាយផលប៉ះពាល់ និងសម្រាប់ការសម្រេចបាននូវឱកាសសម្រាប់ការផ្លាស់ប្តូរយេនឌ័រ។

ផ្នែកបន្តនេះ នឹងណែនាំអំពីវិធីសាស្ត្រក្របខណ្ឌសាមញ្ញមួយក្នុងការយល់ដឹងអំពីផលប៉ះពាល់នៃគម្រោងទំនប់វារីអគ្គីសនីទៅលើយេនឌ័រ។ ផ្នែកនេះនឹងផ្តល់ជាអនុសាសន៍អំពីវិធីសាស្ត្រដែលត្រូវធ្វើជាជំហានៗ និងប្រើប្រាស់ឧបករណ៍និងក្របខណ្ឌមានស្រាប់ដែលអ្នកប្រឹក្សាយោបល់ និងក្រុមហ៊ុនមួយចំនួនបានគេប្រើរួចហើយនៅជុំវិញពិភពលោក នៅក្នុងវិស័យវារីអគ្គីសនី និងវិស័យពាក់ព័ន្ធផ្សេងទៀត។

ការជំរុញឲ្យក្រុមហ៊ុនមួយចំនួនប្រើប្រាស់សៀវភៅណែនាំនេះ គឺដោយសារតែឧបករណ៍ទាំងនេះត្រូវបានបង្កើតឡើងយ៉ាងល្អរួចរាល់ហើយ។ ចំណុចផ្សេងៗគ្នានៃឧបករណ៍ទាំងនេះ កំពុងត្រូវបានគេប្រើក្នុងតំបន់មេគង្គ និងក្នុងវិស័យផ្សេងៗទៀត ដូចជា វិស័យជលផល វិស័យកសិកម្ម ឬ វិស័យទឹក និងវិស័យអនាម័យ។ ខាងក្រោមនេះជាក្របខណ្ឌយេនឌ័រដែលត្រូវបានគេអនុម័តដោយមានការដាក់បញ្ចូលឧទាហរណ៍និងសំណួរណែនាំមួយចំនួនដែលមានភាពជាក់លាក់ សម្រាប់ការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីក្នុងតំបន់មេគង្គ។



ការពិភាក្សារបស់ស្ត្រីក្នុងអំឡុងពេលធ្វើការវាយតម្លៃហេតុប៉ះពាល់ ប្រទេសឡាវ
រូបថត៖ Lee Fitzroy/OxfamAUS

### ជំហានទី១ : ការប្រមូលទិន្នន័យ - ការបង្កើតទិន្នន័យបឋមជាក់លាក់ដែលអាចវិភាគយេនឌ័របាន

ត្រូវពិនិត្យដើម្បីមើលថាតើទិន្នន័យបឋមទាំងឡាយដែលមានកន្លងមកនៅក្នុងការប៉ាន់ប្រមាណអំពីលទ្ធភាពប្រព្រឹត្តទៅរបស់គម្រោងមានភាពរឹងមាំល្អសម្រាប់ឲ្យមានការយល់ដឹងអំពីបរិបទយេនឌ័រដែរឬទេ។ ប្រសិនបើមានភាពខ្វះខាតក្នុងការរៀបចំគម្រោង ដំណើរការប្រមូលទិន្នន័យដែលមានរៀបរាប់ក្នុងផ្នែកមុន ត្រូវយកមកប្រើ ឬ កែសម្រួល ឬធ្វើបច្ចុប្បន្នភាពឡើងវិញ។

នៅក្នុងបរិបទដែលការប៉ាន់ប្រមាណផ្នែកសង្គមនិងបរិស្ថានលម្អិតត្រូវបានពិនិត្យពិច័យរួច ហើយលក្ខខណ្ឌការងារត្រូវបានពង្រាងរួចហើយនោះ ការបញ្ចូលការវិភាគយេនឌ័រនិងជំនាញយេនឌ័រនឹងរឹតតែមានតម្លៃ។ ជំហានខាងក្រោមនេះ បង្ហាញអំពីឧបករណ៍ដែលត្រូវបានគេប្រើភាគច្រើន សម្រាប់ការប្រមូលនិងរៀបចំទិន្នន័យយេនឌ័រ ដើម្បីផ្តល់ព័ត៌មានសម្រាប់ការវិភាគនិងការធ្វើផែនការ នៅក្នុងដំណាក់កាលដំបូងនៃការរៀបចំគម្រោងនេះ។

ដើម្បីរៀបចំឲ្យមានការយល់ដឹងអំពីទិដ្ឋភាពបច្ចេកទេសនៃភាពអនុវត្តបានរបស់គម្រោងមួយ ការរៀបចំឲ្យមានទិន្នន័យបឋមអំពីទន្លេនិងប្រជាជនរស់នៅតាមដងទន្លេដែលរួមមានទិន្នន័យបែងចែកតាមភេទផងនោះ ការជូនដំណឹងអំពីការចូលរួមរបស់សហគមន៍និងការសម្រេចចិត្តក្នុងគម្រោង គឺជាប្រការចាំបាច់។

បន្ថែមទៅលើការយល់ដឹងអំពីបរិបទយេនឌ័រ កត្តាប្រជាសាស្ត្រជាច្រើនផ្សេងទៀតនៅក្នុងអាងទន្លេនិងតំបន់រងផលប៉ះពាល់ពីគម្រោងក៏គួរពិចារណាដែរ រួមមាន ក្រុមជនជាតិដើមនិងក្រុមប្រើប្រាស់ភាសាផ្សេងៗគ្នា ស្ថានភាពសេដ្ឋកិច្ចសង្គម ការអប់រំ អក្ខរភាព ទំនៀមទម្លាប់វប្បធម៌ និង ដំណើរការសម្រេចចិត្ត ការមិនសូវទទួលការយកចិត្តទុកដាក់ពីសង្គម ទំនៀមសង្គម និងអំពើហិង្សា ពិការភាព ព្រមទាំងភាពគព្វប្រសប់រវាងយេនឌ័រនិងទម្រង់ផ្សេងៗទៀតនៃភាពងាយរងគ្រោះ។

នៅពេលដែលគម្រោងត្រូវបានអនុញ្ញាតឲ្យដំណើរការសិក្សាអំពីលទ្ធភាពប្រព្រឹត្តទៅរបស់គម្រោង និងការវាយតម្លៃហេតុប៉ះពាល់កាន់តែទូលំទូលាយហើយនោះ គេគួរពិចារណាអំពីការរបៀបបញ្ចូលយេនឌ័រទៅក្នុងដំណើរការនិងទៅក្នុងការសម្រេចចិត្ត។

តារាងអំពីដំណើរការប៉ាន់ប្រមាណផលប៉ះពាល់សង្គម/បរិស្ថាន នៅទំព័រ២៥ ផ្តល់នូវការណែនាំអំពីឱកាសនៃដំណើរការសំខាន់ៗសម្រាប់ដាក់បញ្ចូលជំនាញផ្នែកយេនឌ័រនិងការប៉ាន់ប្រមាណយេនឌ័រ។

### ជំហានទី២ : ការយល់ដឹងអំពីបរិបទ

ការវិភាគបរិបទរួមសម្រាប់គម្រោងទំនប់វារីអគ្គិសនី នឹងជួយក្រុមហ៊ុន ព្រមទាំងអ្នកគាំទ្រហិរញ្ញវត្ថុនិង រដ្ឋាភិបាល ឲ្យបានយល់ដឹងអំពីសហគមន៍ដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារទំនប់ យល់ដឹងអំពីរបៀបដែលសហគមន៍ត្រូវបានរៀបចំបង្កើតឡើង របៀបដែលសហគមន៍ដំណើរការប្រព្រឹត្តទៅ និងរបៀបដែលសហគមន៍ទាំងឡាយមាន ទំនាក់ទំនងទៅវិញទៅមកជាមួយសហគមន៍ដទៃទៀត និង ទំនាក់ទំនងទៅវិញទៅមកជាមួយបរិស្ថានធម្មជាតិដែលនឹងត្រូវទទួលរងផលប៉ះពាល់ពីទំនប់។ ការអនុវត្តល្អមានន័យថា ត្រូវមានការយល់ដឹងច្បាស់អំពីតួនាទីការទទួលខុសត្រូវ និងទំនាក់ទំនងរវាងបុរស និងស្ត្រីនៅក្នុងសហគមន៍ដែលទទួលរងផលប៉ះពាល់និងក្រុមអ្នកប្រើប្រាស់ទឹក។

ការវិភាគបរិបទនេះ គឺពិចារណាអំពីតម្រូវការនិងផលប្រយោជន៍ជាក់ស្តែងរបស់ស្ត្រីនិងបុរស។ ទំព័រខាងក្រោមនេះ បង្ហាញនូវឧបករណ៍មួយចំនួនដែលនឹងជួយឲ្យក្រុមហ៊ុនយល់អំពីបរិបទដែលគម្រោងនឹងជះឥទ្ធិពលទៅលើសហគមន៍ទាំងនោះ។

#### តួនាទីស្ត្រីនិងតួនាទីបុរស ព្រមទាំងការបែងចែកការងារតាមយេនឌ័រ

ដំណើរការវាយតម្លៃហេតុប៉ះពាល់សង្គមបង្កើតជាការពណ៌នាអំពីសកម្មភាព ដែលជួយអ្នករៀបចំបង្កើតគម្រោងឲ្យមានការយល់ដឹងអំពីអ្វីដែលស្ត្រីនិងបុរសធ្វើ នៅក្នុងផ្ទះ ក្នុងភូមិ នៅលើទន្លេ និងនៅលើដីរបស់ពួកគេ។ ការពណ៌នាអំពីសកម្មភាពទាំងនេះ ជួយបកស្រាយពន្យល់អំពីសកម្មភាពក្នុងភូមិ ប្រចាំថ្ងៃ ប្រចាំរដូវ និងពេញមួយឆ្នាំ។ គេអាចប្រើវាជាឧបករណ៍សម្រាប់ប្រាស្រ័យទាក់ទងរវាងអ្នករៀបចំបង្កើតគម្រោងនិងសហគមន៍ទាំងឡាយបាន។ ដូចនេះហើយ វាជាការសំខាន់ពិសេសក្នុងការប្រមូលព័ត៌មានទូទៅយ៉ាងទូលំទូលាយអំពីសកម្មភាពរបស់បុរសនិងស្ត្រី។

ពេលធ្វើការស្ទង់មតិអំពីសកម្មភាព សូមពិចារណាចំណុចខាងក្រោម :

- ភាពខុសគ្នាតាមរដូវ
- ការកំណត់ពេលវេលា (ការងារមួយប្រើរយៈពេលប៉ុន្មានហើយការធ្វើដំណើរទៅធ្វើការ/ត្រឡប់មកពីធ្វើការនោះត្រូវចំណាយពេលប៉ុន្មាន)
- តួនាទីយេនឌ័រ តាមវ័យ (ក្មេងប្រុស/ស្រី ធ្វើអ្វី ស្ត្រី/បុរសធ្វើអ្វី, មនុស្សចាស់ ធ្វើអ្វី)
- សកម្មភាពនោះធ្វើនៅកន្លែងណា
- ពិការភាព (តើមានតួនាទីនិងការទទួលខុសត្រូវជាក់លាក់ណាខ្លះ ឬ ឧបសគ្គរាំងរាអ្វីខ្លះក្នុងការធ្វើការងារទាំងនោះសម្រាប់ជនពិការដែរឬទេ)
- ភាសានិងអក្ខរភាព៖ ចំណុចនេះអាចជាឧបសគ្គ ឬ កត្តារាំងមួយសម្រាប់សកម្មភាពមួយចំនួន ព្រមទាំងអាចជះឥទ្ធិពលដល់របៀបដែលក្រុមហ៊ុននិងរដ្ឋាភិបាលទាក់ទងជាមួយតំណាងសហគមន៍។ អ្នកណានិយាយភាសាណា ហើយត្រូវកំណត់ឲ្យបានថាក្រុមណាប្រើភាសាណា។

  ការប៉ាន់ប្រមាណអំពីសមត្ថភាពភាសារបស់ស្ត្រីនិងបុរសមានសារសំខាន់ណាស់ ដោយសារតែវាអាចផ្តល់រូបភាពយ៉ាងច្បាស់ថាអ្នកណាចេះអាននិងចេះសរសេរភាសាអ្វីខ្លះ។

## បញ្ជីត្រួតពិនិត្យដំណើរការសម្រាប់ដំណាក់កាលស្វែងយល់អំពីបរិបទ

- ☐ តើអ្នកមានរៀបចំការពិគ្រោះយោបល់ជាមួយស្ត្រីនិងបុរស( ដាច់ដោយឡែកពីគ្នា ឬ រួមគ្នា )នៅក្នុងរចនាសម្ព័ន្ធសហគមន៍ឬទេ ?
- ☐ តើអ្នកមានរកបានទិន្នន័យបែងចែកតាមភេទសម្រាប់សហគមន៍ដែរឬទេ ?
- ☐ តើអ្នកមានរកបានព័ត៌មាន ( និងកត់ត្រាទស្សនៈនិងការយល់ឃើញ ) របស់បុរសនិងស្ត្រី កុមារា និងកុមារីដែរឬទេ ?
- ☐ តើអ្នកមានបានចែករំលែកព័ត៌មានអំពីគម្រោងនេះជាមួយសហគមន៍ទាំងឡាយដែរឬទេ ? តើអ្នកមានបានផ្តល់ព័ត៌មានទាំងនេះ តាមទម្រង់ដែលបុរសនិងស្ត្រីអាចរកបានដោយស្មើភាពគ្នា និងសម្រាប់អ្នកចេះ/មិនចេះអានឬសរសេរដែរឬទេ ?
- ☐ តើអ្នកមានបានឆ្លើយតបទៅកាន់ក្រុមជនជាតិដើមភាគតិច ឬ ក្រុមនិគមជនផ្សេងគ្នា នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់សង្គម និងដំណើរការប្រមូលទិន្នន័យដែរឬទេ ?
- ☐ តើមានបានរកឃើញនូវឧបសគ្គរាំងដល់ការចូលរួមដែរឬទេ ហើយតើយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយឧបសគ្គទាំងនេះមានទទួលការយល់ព្រមជាមួយបុរសនិងស្ត្រីដែរឬទេ ហើយតើមានយុទ្ធសាស្ត្រសម្រាប់បុរសនិងស្ត្រីដែលមានតម្រូវការពិសេសដែរឬទេ ?
- ☐ តើអ្នកមានបានបញ្ចូលបញ្ហាស្ថាប័ន ( នៅថ្នាក់សហគមន៍ ថ្នាក់ផ្សារ ថ្នាក់រដ្ឋ ) ដែលមានការគិតគូរអំពីយេនឌ័រ និងទស្សនៈយេនឌ័រ របស់បុរសនិងស្ត្រីដែរឬទេ ?

ទំព័រ ១/១

## នៅពេលធ្វើការស្ទង់មតិអំពីសកម្មភាព សូមពិចារណាចំណុចដូចខាងក្រោម :

- ☐ ភាពខុសគ្នាតាមរដូវ
- ☐ ការកំណត់ពេលវេលា ( ការងារមួយប្រើរយៈពេលប៉ុន្មាន ហើយការធ្វើដំណើរទៅធ្វើការ/ត្រឡប់មកពីធ្វើការនោះត្រូវចំណាយពេលប៉ុន្មាន )
- ☐ តួនាទីយេនឌ័រ តាមវ័យ ( ក្មេងប្រុស/ស្រី ធ្វើអ្វី ស្ត្រី/បុរសធ្វើអ្វី មនុស្សចាស់ ធ្វើអ្វី )
- ☐ សកម្មភាពនោះធ្វើនៅកន្លែងណា
- ☐ ពិការភាព ( តើមានតួនាទីនិងការទទួលខុសត្រូវជាក់លាក់ណាខ្លះ ឬ ឧបសគ្គរាំងអ្វីខ្លះក្នុងការធ្វើការងារទាំងនោះសម្រាប់ជនពិការដែរឬទេ )
- ☐ ភាសានិងអក្ខរភាពៈ ( ចំណុចនេះអាចជាឧបសគ្គ ឬកត្តារាំងមួយសម្រាប់សកម្មភាពមួយចំនួន ព្រមទាំងអាចជះឥទ្ធិពលដល់របៀបដែលក្រុមហ៊ុននិងរដ្ឋាភិបាលទាក់ទងជាមួយតំណាងសហគមន៍។ អ្នកណានិយាយភាសាណា ហើយត្រូវកំណត់ឲ្យបានថាក្រុមណាប្រើភាសាណា។ ការប៉ាន់ប្រមាណអំពីសមត្ថភាពភាសារបស់ស្ត្រីនិងបុរសមានសារសំខាន់ណាស់ ដោយសារតែវាអាចផ្តល់រូបភាពយ៉ាងច្បាស់ថាអ្នកណាចេះអាននិងចេះសរសេរភាសាអ្វីខ្លះ )។

ទំព័រ ១/១

ទាំងនេះជាបញ្ជីត្រួតពិនិត្យសម្រាប់ជាគម្រូមួយចំនួនដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## ឧបករណ៍សម្រាប់ពណ៌នាសកម្មភាព

**គោលបំណង:** ឧបករណ៍នេះនឹងជួយឲ្យអ្នកយល់អំពីការងារផ្សេងគ្នាដែលបុរសនិងស្ត្រីធ្វើ ជួយឲ្យពិចារណាអំពីកន្លែងធ្វើការងារនិងពេលវេលាធ្វើការងារ ដើម្បីឲ្យរាល់ទម្រង់ការងារនិងសកម្មភាពទាំងអស់ (ទាំងសកម្មភាពទទួលបានប្រាក់កម្រៃនិងមិនទទួលបានប្រាក់កម្រៃ) ត្រូវបានវិភាគយ៉ាងច្បាស់។ត្រូវមានការយកចិត្តទុកដាក់ក្នុងការប្រមូលទិន្នន័យនិងក្នុងការពិចារណាអំពីភាពខុសគ្នាតាមរដូវហើយសូមកត់សម្គាល់ថានៅពេលធ្វើការប៉ាន់ប្រមាណនេះ ក៏ដូចនៅក្នុងករណីជាច្រើនទៀតដែរ គឺ អាចមានភាពមិនស្របគ្នាមួយចំនួនទាក់ទងនឹងការងាររបស់បុរសនិងស្ត្រីនៅរដូវផ្សេងគ្នា និងនៅពេលវេលាផ្សេងគ្នាក្នុងឆ្នាំទាំងមូល។

**សំណួរគន្លឹះ:** : តើបុរសនិងស្ត្រីធ្វើអ្វីក្នុងសហគមន៍របស់ពួកគាត់? តើពួកគាត់មានការទទួលខុសត្រូវអ្វីខ្លះនៅផ្ទះ? តើពួកគាត់ធ្វើអ្វីរួមគ្នាសម្រាប់សហគមន៍?

| **ការពណ៌នាសកម្មភាព:**<br>**ឈ្មោះភូមិ:** ........................ | | **កាលបរិច្ឆេទ:** .................. | | |
|---|---|---|---|---|
| សកម្មភាព | ស្ត្រី/កុមារី | បុរស/កុមារ | ទីកន្លែង | ពេលណា និងរយៈពេល |
| សកម្មភាពផលិតកម្ម | | | | |
| ការនេសាទ | | | | |
| ការលក់ត្រី | | | | |
| ដំណាំសម្រាប់លក់ | | | | |
| មើលថែទាំសត្វ | | | | |
| សកម្មភាពចិញ្ចឹម | | | | |
| មើលថែកូន | | | | |
| ដាំស្លសម្រាប់គ្រួសារ | | | | |
| ទៅដងរ/រែកទឹក | | | | |
| ការចិញ្ចឹមជីវិត/ការផលិតស្បៀង | | | | |
| ការថែទាំសុខភាពគ្រួសារ | | | | |
| ការងារសេហាគមន៍ | | | | |
| សកម្មភាពគ្រប់គ្រងសហគមន៍ | | | | |
| ការគ្រប់គ្រងសកម្មភាពសហគមន៍ | | | | |
| គោលនយោបាយសហគមន៍ | | | | |
| សកម្មភាពសហគមន៍តាមរដូវ | | | | |
| សកម្មភាពសាសនាឬជំនឿក្នុងសហគមន៍ | | | | |
| ការចូលរួមជាមួយអ្នកជិតខាង<br>និងអ្នកមកពីក្រៅសហគមន៍ | | | | |
| ពលកម្មក្នុងសហគមន៍ | | | | |
| ការអប់រំនិងសកម្មភាពផ្សេងៗ | | | | |
| សាលារៀនឬមហាវិទ្យាល័យ | | | | |
| ការបណ្ដុះបណ្ដាល | | | | |

**យកមកពី ក្របខណ្ឌវិភាគរបស់ Harvard**

ទំព័រ ១/១

ទាំងនេះជាឧបករណ៍ជាគម្រូមួយ ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## ឧបករណ៍សម្រាប់ពណ៌នាការប្រើប្រាស់និងការគ្រប់គ្រង

**គោលបំណង:** ឧបករណ៍នេះនឹងសម្រួលឲ្យមានការយល់ដឹងអំពីការអនុវត្តនាពេលបច្ចុប្បន្ន និងយល់ដឹងអំពីតួនាទីរបស់ស្ត្រីនិងបុរស ក្នុងការទទួលបានការប្រើប្រាស់ធនធាន។ ឧបករណ៍នេះនឹងផ្ដល់នូវព័ត៌មានទូទៅអំពីសហគមន៍ ប៉ុន្តែវាក៏ជួយបង្កើតទិន្នន័យបែងចែកតាមភេទដែរ។ វាក៏អាចឲ្យយើងមើលឃើញថាអ្នកណាខ្លះគ្រប់គ្រងលើធនធានទាំងនោះ នេះមានន័យថា តើអ្នកណាជាអ្នកធ្វើការសម្រេចចិត្តអំពីធនធានទាំងនោះនិងសម្រេចចិត្តអំពីការប្រើធនធានទាំងនោះ ហើយតើអ្នកណាមានសិទ្ធិតាមច្បាប់ និង/ឬ មានសិទ្ធិនៅផ្ទះ និង មានសិទ្ធិតាមការអនុវត្តក្នុងសហគមន៍។

**សំណួរគន្លឹះ:** តើអ្នកណាប្រើធនធានក្នុងសហគមន៍? អ្នកណាគ្រប់គ្រងការសម្រេចចិត្តលើធនធានធម្មជាតិនិងធនធានដែលកើតឡើងដោយប្រជាជន? តើអ្នកណាគ្រប់គ្រងផលប្រយោជន៍ (ដូចជាលុយ) ដែលបានមកពីការប្រើប្រាស់ ការលក់ ឬ ការទាញយកប្រយោជន៍ពីធនធានទាំងនោះ?

| ការពណ៌នាការប្រើប្រាស់និងការត្រួតពិនិត្យ | | | | |
|---|---|---|---|---|
| | ការប្រើប្រាស់ | | ការត្រួតពិនិត្យ | |
| | ស្ត្រី | បុរស | ស្ត្រី | បុរស |
| **ធនធានក្នុងសហគមន៍ និង/ឬ ក្នុងផ្ទះ** | | | | |
| ដីសម្រាប់ធ្វើកសិកម្មសម្រាប់ហូប | | | | |
| ដីសម្រាប់ដំណាំទុកលក់ | | | | |
| កម្លាំងពលកម្ម | | | | |
| ទូកនេសាទ និងឧបករណ៍នេសាទ | | | | |
| របស់ទ្រព្យក្នុងផ្ទះ ដូចជា សម្ភារៈ បច្ចេកវិទ្យា | | | | |
| របស់ទ្រព្យសម្រាប់ថែទាំសុខភាព | | | | |
| ការប្រើប្រាស់និងការអាចរកបាននូវធនធានទូទៅ៖<br>• ព្រៃ<br>• ទន្លេដីសើម | | | | |
| **ផលប្រយោជន៍បានមកពីការប្រើប្រាស់ធនធាន** | | | | |
| ចំណូលមកពីការលក់ដំណាំ | | | | |
| ចំណូលមកពីការលក់ត្រីនិងសត្វក្នុងទឹកផ្សេងទៀត | | | | |
| ចំណូលមកពីផលិតផលប្រមូលផលបាន | | | | |
| កម្មសិទ្ធិលើរបស់ទ្រព្យសម្បត្តិ | | | | |
| ឱកាសទទួលបានការអប់រំ | | | | |

ទំព័រ ១/១

ទាំងនេះជាឧបករណ៍ជាគម្រូមួយ ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## បញ្ជីតារាងសំណួរដែលអាចបញ្ចូលជាការណែនាំសម្រាប់ការប្រមូលទិន្នន័យនិងការវិភាគទិន្នន័យ

សំណួរដ៏សំខាន់ទាំងអស់នេះ គួរត្រូវបានអនុវត្តឲ្យបានស៊ីសង្វាក់គ្នាតាមគ្រប់សហគមន៍ ដោយសារថាសហគមន៍នីមួយៗនឹងមានទស្សនៈផ្សេងគ្នានិងមានស្ថានភាពផ្សេងគ្នា ហើយប្រការទាំងនេះនឹងមានបទពិសោធន៍ទាក់ទងផលប៉ះពាល់យេនឌ័រតាមលក្ខណៈ ដោយឡែកពីគ្នាដែរ។ ការធ្វើបែបនេះនឹងជួយអ្នកឲ្យយល់អំពីផលប៉ះពាល់ផ្សេងគ្នា ការចំណាយផ្សេងគ្នា ផលប្រយោជន៍ផ្សេងគ្នា ដែលអាចកើតចេញពីគម្រោងនេះ។ ចំណុចទាំងអស់នេះអាចត្រូវប្រើជាបញ្ជីត្រួតពិនិត្យមួយសម្រាប់ការប្រមូលទិន្នន័យ។ សំណួរទាំងឡាយត្រូវមានការកែសម្រួល ដើម្បីឲ្យត្រូវតាមបរិបទមូលដ្ឋាននីមួយៗ។

### សំណួរណែនាំ

- ☐ តើសហគមន៍ទាំងឡាយបានលើកឡើងអំពីអាទិភាពអ្វីខ្លះរបស់ពួកគេ?
- ☐ តើអាទិភាពទាំងនេះត្រូវបានកត់ត្រា និងត្រូវគេដឹងដោយវិធីណា?
- ☐ តើទំនាក់ទំនងទៅវិញទៅមកអ្វីខ្លះដែលសហគមន៍( ទាំងបុរសនិងស្ត្រី) មាន ជាមួយភូមិជិតខាង ជាមួយទីប្រជុំជនតាមមូលដ្ឋាន និងជាមួយទីផ្សារ?
- ☐ តើមានជម្រើសពលកម្មអ្វីខ្លះក្នុងភូមិនាពេលបច្ចុប្បន្ន? តើទំនប់នឹងជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះទៅលើកម្លាំងពលកម្មក្នុងសហគមន៍នាពេលបច្ចុប្បន្ន? តើនឹងមានផលប៉ះពាល់អ្វីខ្លះទៅលើកម្លាំងពលកម្មរបស់ស្ត្រីនិងបុរស? តើអ្នករកឃើញចំណុចទាំងអស់នេះដោយរបៀបណា?
- ☐ តើគម្រោងអាចផ្តល់អ្វីខ្លះដល់សហគមន៍ទទួលរងផលប៉ះពាល់? តើគេនឹងត្រូវការធនធានអ្វីខ្លះដើម្បីផ្តល់នូវលទ្ធផលនោះ?
- ☐ តើគេកំពុងគិតពិចារណាអំពីការផ្លាស់ប្តូរទីលំនៅដែរឬទេ (បើមាន ផែនការសកម្មភាពផ្លាស់ប្តូរទីលំនៅត្រូវបង្កើតឡើងសម្រាប់គម្រោងនេះ ហើយនេះជាដំណាក់កាលសំខាន់ណាស់ក្នុងការធានាឲ្យមានអ្នកជំនាញផ្នែកយេនឌ័រនិងមានធនធានដែលត្រូវការ)?
- ☐ តើមានជម្រើសអ្វីខ្លះសម្រាប់ការផ្តល់ការងារនៅក្នុងទំនប់នេះ? តើពេលវេលាសម្រាប់ផ្តល់ការងារមានលក្ខណៈយ៉ាងដូចម្តេច? គឺថា តើនឹងមានឱកាសការងារជាបន្តបន្ទាប់ ឬ នឹងមានការងារផ្តល់ឲ្យតែនៅក្នុងដំណាក់កាលសាងសង់?
- ☐ តើមានការជួយគាំទ្រដល់កម្មករយ៉ាងដូចម្តេច (ផ្តល់ជាផ្ទះសម្បែង ការធ្វើដំណើរពីសហគមន៍មូលដ្ឋាន ចំណីអាហារ)?
- ☐ តើមានការជួយគាំទ្រដល់សហគមន៍យ៉ាងដូចម្តេច( មណ្ឌលសុខភាព ការជួសជុលផ្លូវ សាលារៀន អ្នកផ្គត់ផ្គង់ទីផ្សារ វិធាននិងបទបញ្ញត្តិអំពីរបៀបដែលកម្មករនឹងទាក់ទងជាមួយសហគមន៍ និងកន្លែងដែលពួកគាត់នឹងបាន ឬ មិនបានទទួលបានការប្រើប្រាស់ធនធានផ្សេងៗ)?
- ☐ តើទំនប់នេះ (ការសាងសង់ ទីតាំងទំនប់ និងផលប៉ះពាល់ចំពោះទន្លេ និងទីជម្រាល ក្នុងពេលប្រតិបត្តិការ) នឹងប៉ះពាល់ដល់ការធ្វើកសិកម្មនៅតាមមូលដ្ឋានដែរឬទេ?
- ☐ តើតួនាទីបុរសនិងតួនាទីស្ត្រី តួនាទីក្មេងប្រុសនិង តួនាទីក្មេងស្រី ក្នុងការនេសាទនិងការប្រមូលផល នឹងទទួលរងផលប៉ះពាល់ដែរឬទេ?
- ☐ តើទ្រព្យរបស់ (ផ្ទះសម្បែង សហគមន៍) អ្វីខ្លះនឹងត្រូវទទួលរងផលប៉ះពាល់?
- ☐ តើដីណាខ្លះដែលគេត្រូវការសម្រាប់គម្រោងនេះ? តើមានជម្រើសអ្វីខ្លះ ហើយថាតើ សហគមន៍ត្រូវបានគេពន្យល់អំពីជម្រើសទាំងនេះដែរឬទេ?
- ☐ តើប្រតិបត្តិការរបស់ទំបន់នេះ នឹងជះឥទ្ធិពលអ្វីខ្លះទាក់ទងនឹងប្រព័ន្ធធម្មជាតិ ទាក់ទងនឹងការប្រើទន្លេនិងច្រាំងទន្លេ ទាក់ទងនឹងទំនាបលិចទឹក?
- ☐ តើមានការសន្មតយ៉ាងដូចម្តេចខ្លះចំពោះបុរសនិងស្ត្រី? តើអាចនឹងមានឧបសគ្គអ្វីខ្លះក្នុងការរារាំងមិនឲ្យសម្រេចបានលទ្ធផលវិជ្ជមានទាំងឡាយ?

### ទាក់ទងនឹងទន្លេមេគង្គ

- ☐ តើការនេសាទនឹងទទួលរងផលប៉ះពាល់យ៉ាងដូចម្តេចខ្លះដោយសារទំនប់នេះ?
- ☐ តើការប្រមូលផលរុក្ខជាតិក្នុងទឹកនិងសត្វក្នុងទឹក មានទទួលរងផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ (សូមគិតអំពី ក្នុងខ្សែទឹក ក្នុងវាលស្រែ ការប្រើដីសើម ការប្រើប្រាស់ទន្លេ?
- ☐ តើច្រាំងទន្លេនិង ការធ្វើកសិកម្មប្រដេញទឹក ទទួលរងផលប៉ះពាល់ដោយសារទំនប់យ៉ាងដូចម្តេចខ្លះ?
- ☐ តើការចិញ្ចឹមជីវិតដោយទាញយកផលចេញពីក្នុងទន្លេត្រូវរងផលប៉ះពាល់ពីទំនប់យ៉ាងដូចម្តេចខ្លះ (ការរុករករ៉ែដើម្បីចិញ្ចឹមជីវិត ការបូមខ្សាច់ និងការប្រមូលផលរុក្ខជាតិក្នុងទន្លេ ។ល។)?
- ☐ តើសកម្មភាពនៅផ្ទះមិនពាក់ព័ន្ធនឹងអាហារអ្វីខ្លះដែលទទួលរងផលប៉ះពាល់ពីទំនប់ (ការបោកសម្អាត ការងូតទឹក ទឹកផឹក)?
- ☐ តើការចិញ្ចឹមជីវិតមិនទាក់ទងនឹងការទាញផលពីទន្លេអ្វីខ្លះដែលទទួលរងផលប៉ះពាល់ពីទំនប់ (សេវាដឹកជញ្ជូន ការចិញ្ចឹមសត្វដែលត្រូវការទឹក)?
- ☐ តើការទទួលបានការប្រើប្រាស់ទឹកនិងការប្រើប្រាស់ព្រៃនឹងទទួលរងផលប៉ះពាល់ពីទំនប់យ៉ាងដូចម្តេចខ្លះ? តើការប៉ះពាល់នេះនឹងផ្លាស់ប្តូរតាមរដូវដែរឬទេ? តើនឹងមានរបបទឹកហូរដែរឬទេ?

ទំព័រ ១/១

ទាំងនេះជាបញ្ជីត្រួតពិនិត្យសម្រាប់ជាគម្រូមួយចំនួន ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## កត្តាដែលជះឥទ្ធិពលលើតួនាទីយេនឌ័រ ការបែងចែកការងារ និង ការប្រើប្រាស់និងគ្រប់គ្រងធនធាន

## សំណួរណែនាំដែលអាចបញ្ចូលជាការណែនាំសម្រាប់ការប្រមូលទិន្នន័យនិងការវិភាគទិន្នន័យ

សំណួរខាងក្រោមនេះ គួរត្រូវបានសួរឲ្យបានស៊ីសង្វាក់គ្នាតាមគ្រប់សហគមន៍ផ្សេងៗគ្នា ដោយសារថាសហគមន៍នីមួយៗនឹងផ្តល់នូវបរិបទនិងការឆ្លើយតបផ្សេងៗគ្នា។ ក្នុងការស្ទង់មតិថ្នាក់ភូមិដើម្បីកំណត់អំពីការពណ៌នាអំពីសកម្មភាព និង ការពណ៌នាអំពីការប្រើប្រាស់និងគ្រប់គ្រងនេះ ក៏ត្រូវពិចារណាអំពីកត្តាផ្សេងទៀតដែលកំណត់ ឬ ជះឥទ្ធិពលដល់ទំនាក់ទំនងនិងតួនាទីយេនឌ័រដែរ។

ភាពខុសគ្នារវាងការប្រើប្រាស់និងការគ្រប់គ្រងធនធានរបស់បុរសនិងស្ត្រី គឺជាការសញ្ញាបង្ហាញអំពីអតុល្យភាពអំណាចរវាងបុរសនិងស្ត្រី។

ដើម្បីធានាឲ្យមានការយល់ដឹងត្រឹមត្រូវអំពីតួនាទីនិងទំនាក់ទំនងយេនឌ័រនៅក្នុងសហគមន៍និងរវាងសហគមន៍ គេត្រូវការពិចារណាលើកត្តាកំណត់ផ្សេងៗទៀត រួមមាន៖

- □ តើសហគមន៍ត្រូវបានដាក់បញ្ចូលក្នុងសេដ្ឋកិច្ចទីផ្សារឬប្រាក់កាសត្រឹមកម្រិតណា? ហើយតើមានទំនាក់ទំនងទៅវិញទៅមករវាងសហគមន៍និងអ្នកដទៃដែរឬទេ? តើអ្នកណាមានការទទួលខុសត្រូវសម្រាប់សកម្មភាពអ្វីខ្លះ (គឺថាអ្នកណាយកទំនិញទៅផ្សារ? អ្នកណាចេញពីសហគមន៍ដើម្បីធ្វើការដែលទទួលបានប្រាក់ឈ្នួល?)
- □ តើជនជាតិអ្វីដែលមាននៅក្នុងសហគមន៍នេះ?
- □ តើមានភាពខុសគ្នារវាងសហគមន៍ជិតខាង ឬក្រុមប្រជាជនទូទៅយ៉ាងដូចម្តេច?
- □ តើសហគមន៍នេះជាសហគមន៍ជនជាតិដើមភាគតិច? ឬ មានបញ្ចូលក្រុមជនជាតិដើមប្រើភាសាចម្រុះដែរ?
- □ ដាក់ស្ថានភាពសេដ្ឋកិច្ចសង្គមដែលមាននៅក្នុងសហគមន៍ឲ្យដាច់ដោយឡែកពីគ្នា
- □ ការយល់ដឹងអំពីរចនាសម្ព័ន្ធក្នុងផ្ទះ រួមមានទាំងផ្ទះដែលមានស្ត្រីជាមេផ្ទះ មេម៉ាយ ក្រុម ឬ គ្រួសារដែលអាចមានមនុស្សច្រើនជំនាន់
- □ ការយល់ដឹងអំពីអាយុ និងការទទួលខុសត្រូវ
- □ ការគិតពិចារណាលើការទទួលបានការប្រើប្រាស់ទាក់ទងនឹងពិការភាព

ជាលទ្ធផលនៃការវិភាគនេះ យើងគួរមានការយល់ដឹងអំពីរចនាសម្ព័ន្ធនៅក្នុងផ្ទះ និងនៅក្នុងសហគមន៍។ តើអ្នកណាមានអំណាចអូសទាញ (Power) និង សមត្ថកិច្ច (authority)? ការយល់ដឹងអំពីទំនាក់ទំនង និងការយល់ដឹងអំពីអ្នកណាមានអំណាចអូសទាញនិងសមត្ថកិច្ច នៅក្នុងទំនាក់ទំនងទាំងនោះ គឺជាជំហានដ៏សំខាន់ក្នុងការយល់ដឹងអំពីផលប៉ះពាល់យេនឌ័រ។ ការវិភាគនឹងទទួលស្គាល់ថាមូលហេតុដើមនៃវិសមភាពយេនឌ័រកើតមានទាំងនៅក្នុងផ្ទះនិងក្នុងរចនាសម្ព័ន្ធសហគមន៍។

ទំព័រ ១/១

ទាំងនេះជាបញ្ជីត្រួតពិនិត្យសម្រាប់ជាគម្រូមួយចំនួន ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

ឧបករណ៍ស្តីពីការប្រើប្រាស់និងការគ្រប់គ្រងនេះ អាចប្រើសម្រាប់ពិចារណាថាតើអ្នកណាទទួលបានការប្រើប្រាស់និងគ្រប់គ្រងទៅលើផលប្រយោជន៍ដែលអាចកើតចេញមកពីគម្រោងទំនប់នេះ។ ការអនុវត្តល្អនឹងទទួលបានការព្រមព្រៀងក្នុងការចែករំលែកផលប្រយោជន៍ ដែលអាចរួមមានដូចជាការព្រមព្រៀងទៅលើភាគរយសម្រាប់ការចំណាយទៅលើមូលនិធិសហគមន៍ ពីប្រាក់ចំណូល ពីគម្រោងកែលម្អជីវភាព ពីឱកាសការងារ និងពីគម្រោងសម្រាប់កែលម្អសហគមន៍ជាច្រើនទៀត។

ជាការសំខាន់ក្នុងការទទួលស្គាល់ថាសំណងសម្រាប់ការបាត់បង់ទ្រព្យ ដីធ្លី និងសិទ្ធិផ្សេងៗដោយសារតែទំនប់នេះ គឺជាសកម្មភាពផ្តល់ត្រឡប់មកវិញជាលក្ខណៈស្តង់ដារសម្រាប់ផលប៉ះពាល់ទាំងឡាយ។ គេក៏ត្រូវធ្វើការបែងចែកផលប្រយោជន៍ បន្ថែមលើការផ្តល់នេះសំណងនេះទៀតផង។

ការទទួលបានដីធ្លី ការផ្លាស់ប្តូរគុណភាពទឹកនិងការរកទឹកបាន ព្រមទាំងការបំផ្លាញបរិស្ថាន ដែលកើតចេញពីទំនប់នេះ អាចធ្វើឲ្យចុះខ្សោយដល់សមត្ថភាពរបស់ស្ត្រីក្នុងការផ្គត់ផ្គង់ចំណីអាហារនិងទឹកស្អាតសម្រាប់គ្រួសាររបស់ពួកគាត់។ នេះមានន័យថា ការងាររបស់ស្ត្រីនឹងកាន់តែមានច្រើនឡើង។ ការជំនួសការទទួលបានការប្រើប្រាស់ធនធានទូទៅ (ដូចជាទឹកនិងច្រាំងទន្លេ) ដោយសេវាកម្មដែលតម្រូវឲ្យមានការបង់លុយ ក៏អាចបន្ថែមបន្ទុកនិងការចំណាយលើថវិការគ្រួសារដែរ។

ប្រសិនបើបុរសគ្រប់គ្រងការចំណាយដែលបានមកពីសំណង និងគ្រប់គ្រងលើមូលនិធិដែលបានមកពីចំណូលនោះ ស្ត្រីអាចនឹងត្រូវគេបដិសធមិនឲ្យមានការទទួលបានការប្រើប្រាស់និងការគ្រប់គ្រងទៅលើផលប្រយោជន៍ហិរញ្ញវត្ថុដែលនឹងបានមកពីទំនប់វារីអគ្គីសនីនេះឡើយ។ ប្រការនេះអាចនឹងនាំទៅរកការប៉ះពាល់ធ្ងន់ធ្ងរលើទំនាក់ទំនងយេនឌ័រ និងធ្វើឲ្យស្ត្រីកាន់តែពឹងផ្អែកផ្នែកសេដ្ឋកិច្ចនេះទៅលើបុរសច្រើនឡើង។ ដូច្នេះ ការប្រើទាំងឧបរកណ៍ពណ៌នាសកម្មភាព និង ឧបករណ៍ប្រើប្រាស់និងគ្រប់គ្រង នឹងជួយជំរុញឲ្យផែនការដែលបានបង្កើតឡើង មានការផ្តោតទៅលើការធានាឲ្យមានការចែករំលែកផលប្រយោជន៍និងសំណងដោយសារទំនប់វារីអគ្គីសនីដោយស្មើភាពគ្នារវាងបុរសនិងស្ត្រី។

## តួនាទីដែលអាចជះឥទ្ធិពលពីរដ្ឋ ពីទីផ្សារ និងពីស្ថាប័នសហគមន៍

ការយល់ដឹងអំពីស្ថាប័ននិងរចនាសម្ព័ន្ធនៃទំនាក់ទំនងសង្គម ផ្តល់នូវគ្រឹះសម្រាប់ពិចារណាថាតើគម្រោងទំនប់វារីអគ្គីសនី អាចជះឥទ្ធិពលទៅលើសហគមន៍និងទៅលើទំនាក់ទំនងយេនឌ័រយ៉ាងដូចម្តេចខ្លះ។ ជាការសំខាន់ណាស់ដែលត្រូវពិចារណាថាតើសហគមន៍មួយភប់ប្រសប់នឹងស្ថាប័ននិងដំណើរការផ្សេងៗរបស់រដ្ឋាភិបាលយ៉ាងដូចម្តេច។ លទ្ធភាពនិងឱកាសរបស់ស្ត្រីនិងបុរសនឹងមានភាពខុសប្លែកគ្នា សម្រាប់ការចូលរួមជាមួយដំណើរការនិងស្ថាប័នខាងក្រៅ ទោះជាស្ថាប័នរដ្ឋ ទីផ្សារ ឬ សេដ្ឋកិច្ចក៏ដោយ។ តើអ្នកណាតំណាងឲ្យផលប្រយោជន៍សហគមន៍និងការសម្រេចចិត្តរបស់សហគមន៍ជាមួយនឹងតួអង្គមកពីស្ថាប័ន? តើជាបុរស? ឬ ជាស្ត្រី? ឬ ជាក្រុមចម្រុះ?

ក្នុងបរិបទដែលដំណើរការរដ្ឋាភិបាលនិងគោលនយោបាយមានភាពទន់ខ្សោយ ឬមិនមានភាពស៊ីសង្វាក់គ្នានោះ អ្នករៀបចំអភិវឌ្ឍន៍គម្រោងគួរយកចិត្តទុកដាក់ជាពិសេស ដើម្បីឲ្យយល់អំពីវិធីដែលដំណើរការនិងគោលនយោបាយទាំងនោះ ភាភពប្រសព្វជាមួយសហគមន៍និងដំណើរការសង្គម។ ប្រការទាំងនេះអាចបង្កឲ្យមានវិសមភាពយេនឌ័រច្រើន ដែលអាចងាយស្រួលធ្វើឲ្យស្ថានភាពកាន់តែល្អក់កករដោយសារតែការដាក់គម្រោងថ្មីចូលទៅ។ ផ្ទុយទៅវិញ ប្រការទាំងនេះក៏ជាឱកាសសម្រាប់គម្រោងធ្វើឲ្យទទួលបានលទ្ធផលជាវិជ្ជមានអំពីយេនឌ័រ។

### សំណួរសំខាន់ៗសម្រាប់ណែនាំឲ្យមានការយល់ដឹងអំពីចំណុចនេះគួររួមបញ្ចូល:

- ☐ តើស្ថាប័នណាខ្លះដែលមានទាក់ទងនឹងតម្រូវការរបស់សហគមន៍? តើស្ថាប័នណាមានទំនាក់ទំនងនាពេលបច្ចុប្បន្នជាមួយសហគមន៍? តើអ្នកណាពាក់ព័ន្ធក្នុងការប្រើប្រាស់ ការទទួលបានការប្រើប្រាស់ និងការណែនាំទំនាក់ទំនងនេះ?
- ☐ តើផ្នែកណា ឬស្ថាប័នណារបស់រដ្ឋាភិបាលមានសមត្ថកិច្ចលើសកម្មភាពសហគមន៍? ឧទាហរណ៍ តុលាការ កងទ័ព ប៉ូលីស មន្ទីរកសិកម្មនិងជលផល មន្ទីរអភិវឌ្ឍន៍ជនបទ សហជីពស្ត្រីនិងយុវជន។
- ☐ តើរដ្ឋាភិបាលថ្នាក់ណាដែលសកម្មជាងគេក្នុងសហគមន៍ ឬ ក្នុងកម្រិតអាងទន្លេ ថ្នាក់ស្រុក ថ្នាក់ខេត្ត ឬ ថ្នាក់ជាតិ?
- ☐ តើគេប្រើលុយនិងគ្រប់គ្រងលុយដោយរបៀបណានក្នុងសហគមន៍នេះ? តើអ្នកណាគ្រប់គ្រងធនធនហិរញ្ញវត្ថុ ហើយតើអ្នកណាជាអ្នក "រក" លុយ? តើសហគមន៍មានប្រើស្ថាប័នធនាគារ ឬ ស្ថាប័នហិរញ្ញវត្ថុ ដែរឬទេ?
- ☐ តើសហគមន៍មានទំនាក់ទំនងជាមួយទីផ្សារ ដូចជាការលក់និងការទិញទំនិញកសិកម្ម ការរកទីផ្សារសម្រាប់លក់ត្រី ឬ ទំនិញកសិកម្មយ៉ាងដូចម្តេច? តើមានស្ថាប័នសហគមន៍អ្វីខ្លះ? ឧទាហរណ៍ សហគមន៍ សហករណ៍ អង្គការតាមសហគមន៍មូលដ្ឋាន គណៈកម្មការសហគមន៍នេសាទ និងក្រុមអ្នកប្រើប្រាស់ទឹក និង ប្រើប្រាស់ដី។

ទំព័រ ១/១

ទាំងនេះជាបញ្ជីត្រួតពិនិត្យសម្រាប់ជាគម្រូមួយចំនួន ដែលគម្រូនេះអាចទាញយកពីគេហទំព័រ
www.oxfam.org.au/giamanual

## ការអនុវត្តនូវឧបករណ៍វិភាគស្ថាប័ន

ការប្រើប្រាស់ការវិភាគស្ថាប័នជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សង្គម នឹងអាចឲ្យអ្នករៀបចំអភិវឌ្ឍន៍គម្រោង កំណត់រកឃើញរចនាសម្ព័ន្ធអំណាច វិធាន ការអនុវត្ត គោលនយោបាយ សកម្មភាព និងឥទ្ធិពលស្ថាប័ននានា។ ការវិភាគស្ថាប័ន នឹងបង្ហាញឲ្យឃើញអំពីវិធីដែលភ្នាក់ងារស្ថាប័នឬយន្តការផ្សេងគ្នា បង្កើតនិងជះឥទ្ធិពលលើទំនាក់ទំនងយេនឌ័រ និងបង្ហាញឲ្យឃើញពីវិធីដែលគេអាចរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការសម្រេចឲ្យបានសមភាពយេនឌ័រ ឬ ធ្វើឲ្យវិសមភាពយេនឌ័រកាន់តែមានភាពល្អក់កករ។ អ្នករៀបចំអភិវឌ្ឍន៍គម្រោង អាចប៉ាន់ប្រមាណ ថាតើទំនប់អាចរួមចំណែកក្នុងបរិបទនេះយ៉ាងដូចម្ដេច ហើយការធ្វើដូចនេះ អាចជាការផ្តល់ព័ត៌មានសម្រាប់ការសម្រេចចិត្តក្នុងគម្រោងដើម្បីធានាឲ្យមានការចៀសវាងឬកាត់បន្ថយវិសមភាពយេនឌ័របាន។

**គោលបំណង:** ឧបករណ៍នេះអាចប្រើសម្រាប់ស្វែងយល់អំពីស្ថាប័ន ដំណើរការ ឬ យន្តការសំខាន់ៗ ដែលជះឥទ្ធិពលដល់សហគមន៍និងទំនាក់ទំនងយេនឌ័រ។ ការពណ៌នាសកម្មភាព អាចប្រើជាជំនួយនិងជាបញ្ជីសំណួរ ដើម្បីធានាថាស្ថាប័នទាំងអស់ត្រូវបានគេរកឃើញនូវចំណុចដែលមានការទាក់ទងនឹងបុរស ស្ត្រី និងសហគមន៍។

**សំណួរគន្លឹះ:** តើមានសេវាកម្មអ្វីខ្លះដែលអ្នកទទួលបាន ដើម្បីជួយដល់អ្នកពីមួយថ្ងៃទៅមួយថ្ងៃ? អ្នកណាផ្តល់សេវាកម្មទាំងនោះ? តើមានមនុស្សឬស្ថាប័នណាដែលបានចូលរួមជាមួយអ្នកក្នុងការអនុវត្តសកម្មភាពទាំងនោះដែរឬទេ?តើអ្នកទទួលរងការប៉ះពាល់ដោយសារតែវិធានឬច្បាប់នៅពេលអ្នកធ្វើសកម្មភាពទាំងនោះដែរឬទេ? តើមានវិធាន និងច្បាប់អ្វីខ្លះ ហើយតើអ្នកដឹងដោយរបៀបណា? តើគេមានអនុវត្តវិធានឬច្បាប់ទាំងនោះឬទេ? តើស្ថាប័នទាំងនោះមានបណ្តាលឲ្យកើតមានវិសមភាពយេនឌ័រដែរឬទេ?

| ឧបករណ៍៖ ការវិភាគស្ថាប័ន | | | | | |
|---|---|---|---|---|---|
| ស្ថាប័ន | នាយកដ្ឋាន ឬ ភ្នាក់ងារ | គោលនយោបាយ ឬ យន្តការ | ទំនាក់ទំនងជាមួយសហគមន៍ | | |
| | | | បុរស | ស្ត្រី | សហគមន៍ |
| រដ្ឋ និង តំបន់ | | | | | |
| មន្ទីរកសិកម្ម | មន្ត្រីផ្សព្វផ្សាយកសិកម្ម | • គោលនយោបាយសម្រាប់តាមដាន<br>• ពូជស្រូវ បរេស | | | |
| មន្ទីរសុខាភិបាល | បុគ្គលិកមណ្ឌលសុខភាព, បុគ្គលិកមន្ទីរពេទ្យ | • យុទ្ធនាការសុខភាពសាធារណៈសម្រាប់ជម្ងឺគ្រុនចាញ់ | | | |
| មន្ទីរជលផល | ការស្រាវជ្រាវជលផល, បទបញ្ញត្តិជលផល | • អនុក្រឹត្យសហគមន៍នេសាទ<br>• តំបន់ការពារសត្វផ្សោត | | | |
| ក្រសួងធនធានធម្មជាតិនិងបរិស្ថាន | ផ្នែកវាយតម្លៃហេតុប៉ះពាល់សង្គម/បរិស្ថាន | ច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គោលការណ៍ណែនាំអំពីការចូលរួមជាសាធារណៈ | | | |
| គណៈកម្មាធិការទន្លេមេគង្គ | គណៈកម្មាធិការជាតិទន្លេមេគង្គ | • កម្មវិធីជលផលគម្រោងស្តីពីទំនប់វារីអគ្គីសនីប្រកបដោយនិរន្តរភាព<br>• នីតិវិធីសម្រាប់ជូនដំណឹង ការពិគ្រោះយោបល់និងការព្រមព្រៀងជាមុន | | | |
| ប៉ូលីស | | ការអនុវត្តច្បាប់ | | | |

ទំព័រ ១/២

| សហគមន៍ | | | | | |
|---|---|---|---|---|---|
| គណៈកម្មការសហគមន៍នេសាទ | នាយកដ្ឋានជលផល | • កិច្ចព្រមព្រៀងតំបន់ការពារ<br>• កម្មវិធីឃ្លាំមើល និងល្បាតការនេសាទខុសច្បាប់<br>• បទបញ្ញត្តិ នេសាទ និងការចូលនេសាទតាមរដូវ | | | |
| ក្រុមអ្នកប្រើប្រាស់ទឹក | ក្រសួងធនធានធម្មជាតិ និងបរិស្ថាន | • ការប្រើប្រាស់បង្គន់សហគមន៍ និងអនាម័យ<br>• ការទទួលបានទឹកស្អាតប្រើប្រាស់ ឬ ការប្រើប្រាស់អណ្តូងស្នប់ក្នុងភូមិ<br>• ក្រុមគ្រប់គ្រងអណ្តូងស្នប់ និង ប្រព័ន្ធស្រោចស្រព | | | |
| ស្ថាប័នសាសនា | វត្ត ព្រះសង្ឃ និង ដូនជី | • ការប្រើវត្តជាកន្លែងប្រជុំ<br>• សកម្មភាពសាសនាការប្រមូលផល ឬ សកម្មភាពតាមរដូវ | | | |
| សហករណ៍កសិករ | | • ធនាគារពូជ | | | |
| **ផ្សារ** | | | | | |
| សហជីពឥណទាន | | • អាត្រានៅថ្នាក់ភូមិ<br>• យន្តការឥណទានតាមទូរសព្ទចល័ត | | | |
| ធនាគារ | | • យន្តការខ្ចីបុលក្នុងសហគមន៍<br>• ការប្រាក់លើប្រាក់កម្ចី | | | |
| ក្រុមហ៊ុនជំនួញផ្នែកកសិកម្ម | | • កិច្ចព្រមព្រៀងជាមួយកសិករ | | | |
| ក្រុមហ៊ុនទំបន់វារីអគ្គីសនីផ្សេងទៀត | អ្នកធ្វើការផ្នែកទំនាក់ទំនងក្នុងសហគមន៍ | • ផែនការសកម្មភាពផ្លាស់ប្តូរទីលំនៅ<br>• គណៈកម្មការអាងទន្លេ<br>• វិធានគ្រប់គ្រប់ទីជម្រាល<br>• យន្តការដោះស្រាយបណ្តឹង/ទំនាស់ | | | |
| ក្រុមហ៊ុនរុករករ៉ែ | អ្នកធ្វើការផ្នែកទំនាក់ទំនងក្នុងសហគមន៍ | • យន្តការដោះស្រាយបណ្តឹងទំនាស់<br>• គណៈកម្មការមូលនិធិសហគមន៍ | | | |
| អ្នកឲ្យខ្ចីលុយ | | • សមាជិកសហគមន៍<br>• អ្នកឲ្យខ្ចីលុយពីក្រៅ | | | |



ទាំងនេះជាឧបករណ៍គម្រូ ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## ជំហានទី៣ : ការកំណត់បញ្ហាដែលកើតឡើងដោយសារទំនប់វារីអគ្គិសនី

ជាលទ្ធផលនៃការវិភាគបរិបទ អ្នករៀបចំគម្រោងគួរយល់ដឹងឲ្យបានច្បាស់អំពីសមត្ថភាពរបស់ស្ត្រីនិងសមត្ថភាពបុរសក្នុងការឆ្លើយតបនឹងការប្រែប្រួលដែលកើតចេញមកពីទំនប់នេះ។ ជាដំបូង ចេញពីការពិគ្រោះយោបល់និងការចូលរួមរបស់សហគមន៍ គេអាចបង្កើតបាននូវកម្រងនៃការសន្មតមួយចំនួនអំពីទ្រព្យ អំពីធនធាន ចំណុចខ្លាំង និងភាពងាយរងគ្រោះ របស់បុរស របស់ស្ត្រី និងរបស់សហគមន៍។ បន្ទាប់មកដំណើរការសារចុះឡើងម្តងហើយម្តងទៀតដែលមានការចូលរួមពីសហគមន៍ត្រូវរៀបចំឡើង ដោយមានការសម្របសម្រួលឲ្យបានសមរម្យដើម្បីឲ្យសហគមន៍ព្រមទាំងក្រុមបុរសនិងក្រុមស្ត្រីធ្វើការពិសោធន៍ទៅលើការសន្មតទាំងនោះ។

ជារឿយៗ ទំនប់វារីអគ្គិសនីមានទ្រង់ទ្រាយធំ ពីព្រោះវានឹងបណ្តាលឲ្យមានការប្រែប្រួលធម្មជាតិរបស់ប្រព័ន្ធទន្លេមួយ ហើយជារឿយៗផលប៉ះពាល់នឹងជះទៅលើសង្គមក្នុងទ្រង់ទ្រាយលើសពីតំបន់ដែលនៅជុំវិញទំនប់ឬអាងស្តុកទឹកនោះ។ ដូចដែលបានពិភាក្សានៅក្នុងផ្នែកផ្សេងនោះ គឺថាផលប៉ះពាល់មួយចំនួនអាចមានលក្ខណៈវិជ្ជមាន ក្នុងខណៈពេលដែលផលប៉ះពាល់មួយចំនួនផ្សេងទៀត នឹងមានការប៉ះពាល់ដោយផ្ទាល់និងជាបណ្តុំដល់សហគមន៍ទាំងឡាយណាដែលជីវិតនិងសុខមាលភាពរបស់ពួកគេពឹងផ្អែកទៅលើទន្លេនិងធនធានទីជម្រាលទន្លេ។

ការយល់ដឹងនិងការកាត់បន្ថយវិសាលភាពនៃបញ្ហាទាំងអស់នេះគឺជាកត្តាដ៏សំខាន់មួយក្នុងដំណើរការអនុញ្ញាតឲ្យមានការសាងសង់ទំនប់។ ការយល់ដឹងទូលំទូលាយអំពីបញ្ហាទាំងឡាយដែលមានការជាប់ទាក់ទងជាមួយនិងតួនាទីនិងទំនាក់ទំនងយេនឌ័រក្នុងសហគមន៍ទាំងឡាយដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងនេះគឺជាជំហានបន្ទាប់ក្នុងការធ្វើការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ។

ទោះបីជាយើងបង្កើតជាជំហានមួយដាច់ដោយឡែកតែឯងក្នុងជំហាននេះក៏ដោយ ក៏ដំណើរការនេះត្រូវធ្វើស្របជាមួយនឹងជំហានទី២ដែរ។

បញ្ហាទូទៅដែលកើតចេញមកពីគម្រោងទំនប់វារីអគ្គិសនីជាច្រើន ហើយដែលស្ត្រីនិងបុរសនឹងជួបប្រទះផ្សេងគ្នា រួមមាន:

- ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ ឬ ដោយស្ម័គ្រចិត្ត
- ការបាត់បង់ទ្រព្យសម្បត្តិ ដូចជាផ្ទះសម្បែង ដើមឈើហូបផ្លែ សួនបន្លែ ធនាគារស្រូវ អាគារសហគមន៍
- ការបាត់បង់ដីនិងធនធានសម្រាប់ផលិត
- ការផ្លាស់ប្តូរគុណភាពទឹក
- ការបំពុល (ខ្យល់ សំឡេង ទឹក ដី)
- ការបាត់បង់ផ្នែកជលផល: ទំនប់នឹងក្លាយជារបាំងក្នុងទន្លេដែលអាចបញ្ឈប់ការបម្លាស់ទីរបស់ត្រី ដែលជាកត្តានាំឲ្យបាត់បាត់ជម្រកត្រីដោយសារការលិចជម្រកតាមមាត់ពាម ការកាត់បន្ថយទឹកក្នុងទន្លេដោយសារតែការបង្វែរទឹកទៅស្ថានីយ៍អគ្គិសនីវិញ។
- បញ្ហាសុខភាព អាចកើតមានច្រើន រួមមាន ផលប៉ះពាល់ផ្នែកលើបរិស្ថាន ក៏ដូចជា បញ្ហាទាំងឡាយដែលកើតចេញពី កម្លាំងការងារដែលនឹងត្រូវចូលមកថ្មី ដូចជា ជម្ងឺឆ្លងតាមការរួមភេទជាដើម
- ហានិភ័យដោយការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សា
- ការបាត់បង់ជីវប្បធម៌ ទីតាំងវប្បធម៌ និងចំណងវប្បធម៌ទៅនឹងកន្លែងនោះ

នៅក្នុងទន្លេមេគង្គ ហានិភ័យនិងផលប៉ះពាល់ដោយសារទំនប់ក៏អាចកើតឡើងនៅក្នុងប្រទេសជិតខាងដែលនៅពីខ្សែទឹកខាងលើនិងខ្សែទឹកខាងក្រោមនៃទីតាំងទំនប់។ ហានិភ័យមួយចំនួនដែលមានភាពលេចធ្លោរួមមាន:

- ការផ្លាស់ប្តូររវ៉ូទឹកនិងបរិមាណទឹក និងការប៉ះពាល់ដល់ប្រព័ន្ធធម្មជាតិ ដូចជាទន្លេសាប ដីសណ្តរ ឬ កន្លែងនេសាទត្រីក្នុងប្រទេសថៃភាគខាងជើង
- ការផ្លាស់ប្តូរកករបាតទន្លេ និងការផ្លាស់ប្តូរលំហូរជីវជាតិតាមប្រព័ន្ធ និងការប៉ះពាល់ដល់តំបន់ដីសើម ដល់កសិកម្មនៅខ្សែទឹកខាងក្រោម និងប្រព័ន្ធអេកូឡូស៊ីតំបន់ដីសណ្តរ និងកសិកម្មនៅតំបន់ដីសណ្តរ
- មានឥទ្ធិពលរាំងដល់ការបម្លាស់ទីរបស់ត្រី និងការបង្កកំណើតរបស់ត្រី ដែលនៅចន្លោះ ទន្លេសាប និង ប្រព័ន្ធដៃទន្លេផ្នែកខាងលើផ្សេងៗទៀត។

នៅក្នុងដំណាក់កាលនេះ អ្នកត្រូវការយល់ដឹងអំពីកត្តាផ្សេងៗ ដែលជះឥទ្ធិពលទៅលើគម្រោង ព្រមទាំងទំនោរដែលនឹងប៉ះពាល់បរិបទគម្រោង ជាពិសេស គឺថាតើសហគមន៍នឹងទទួលរងផលប៉ះពាល់បែបណាខ្លះដោយសារគម្រោងនេះ។

ផលប៉ះពាល់ទាំងនេះត្រូវគេរំពឹងថានឹងកើតមានដល់សហគមន៍ នៅពេលចាប់ផ្តើមគម្រោង។ តាមវិធីនេះ គេអាចមើលឃើញថាសហគមន៍នឹងមានហានិភ័យកើតចេញពីគម្រោងដែលគេនឹងដាក់ដំណើរការ (WCD 2000)។ ការផ្លាស់ប្តូរ ដែលមកជាមួយគម្រោងនេះមានការប៉ះពាល់ដល់ទំនាក់ទំនងនិងតួនាទីក្នុងសង្គមនៅក្នុងសហគមន៍និងរវាងសហគមន៍នានា។ រចនាសម្ព័ន្ធសង្គមរបស់សហគមន៍ នឹងចុះខ្សោយដោយសារតែគម្រោងសម្រាប់សហគមន៍នៅតាមមាត់ពាមនៅតាមទន្លេមេគង្គវិញ គម្រោងនេះនឹងជះឥទ្ធិពលដោយផ្ទាល់លើយុទ្ធសាស្ត្រចិញ្ចឹមជីវិតនិងលើស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ។ ការផ្លាស់ប្តូរទីលំនៅ ជារឿយៗ បាននាំប្រជាជនចេញពីដីដូនតារបស់ខ្លួន និងបានធ្វើឲ្យបាត់បង់ចំណងវប្បធម៌ទៅលើទីតាំងនិងទ្រព្យសម្បត្តិទាំងនោះ។

តាមពិតទៅ ការពិនិត្យមើលទៅលើការជាប់ពាក់ព័ន្ធគ្នានៃការផ្លាស់ប្តូរដោយសារគម្រោងទាំងនេះនឹងជួយឲ្យរកឃើញអំពីវិធីដើម្បីចៀសវាង ឬ កាត់បន្ថយ ហានិភ័យដែលគេរំពឹងថានឹងកើតចេញមកពីគម្រោងនោះ។ ទង្វើនេះគួរបញ្ចូល ការពិចារណាអំពីផលប៉ះពាល់និងហានិភ័យដោយផ្ទាល់ និងដោយប្រយោល ដែលអាចកើតលើតំបន់ផ្សេងក្រៅតែពីតំបន់ដែលនៅជុំវិញទំនប់។

ការចូលរួមរបស់បុរសនិងស្ត្រីមកពីគ្រប់សហគមន៍ដែលទទួលរងផលប៉ះពាល់ គួរធ្វើឡើងដើម្បីធានាឲ្យមានការយល់ដឹងពេញលេញអំពីបញ្ហាឆ្លងផ្នែក ដែលកើតចេញមកពីគម្រោងនេះ។

- គួរផ្តល់ការពិចារណាអំពី របៀបដែលគម្រោងទំនប់វារីអគ្គិសនីទាក់ទងជាមួយ និងជះឥទ្ធិពលទៅលើ :
- ទំនាក់ទំនងយេនឌ័រនិងអំណាចក្នុងសហគមន៍
- តួនាទីនិងការទទួលខុសត្រូវយេនឌ័រ
- ការបែងចែកការងារផ្អែកលើយេនឌ័រ និងបន្ទុកការងាររបស់ស្ត្រី (ពិចារណាអំពីការងារដែលមានកម្រៃនិងគ្មានកម្រៃ)
- ការប្រើប្រាស់និងការគ្រប់គ្រងរបស់ស្ត្រីលើធនធាន ដោយរាប់បញ្ចូលទាំង ផលប្រយោជន៍ដែលអាចទទួលបានពីគម្រោងទំនប់វារីអគ្គិសនី (ការបែងចែកផលប្រយោជន៍)
- រចនាសម្ព័ន្ធនិងដំណើរការគ្រប់គ្រងក្នុងសហគមន៍ និងរបៀបដែលស្ត្រីចូលរួមឬអាចចូលរួមជាទូទៅ និងចូលរួមទាក់ទង នឹងការប៉ាន់ប្រមាណ និងការសម្រេចចិត្តទៅលើគម្រោងទំនប់វារីអគ្គិសនីនេះ
- សុខមាលភាពសហគមន៍ ការចិញ្ចឹមជីវិត និងសេវាកម្មដូចជាការអប់រំនិងសុខាភិបាល

## ឧបករណ៍: តារាងផលប៉ះពាល់និងបញ្ហា

| តារាងផលប៉ះពាល់និងបញ្ហា | | | | |
|---|---|---|---|---|
| បញ្ហា/ផលប៉ះពាល់ | បរិបទ | | | សកម្មភាព/ការឆ្លើយតប |
| | បុរស | ស្ត្រី | សហគមន៍ | |
| បរិស្ថាន | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| សង្គម | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| សេដ្ឋកិច្ច | | | | |
| | | | | |
| | | | | |
| | | | | |
| ផ្សេងៗ | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

ទំព័រ ១/១

ទាំងនេះជាឧបករណ៍គម្រូ ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## ភាពងាយរងគ្រោះខ្លាំងក្នុងទន្លេមេគង្គ[យេនឌ័រការចិញ្ចឹមជីវិត និង សុខភាពបរិស្ថានក្នុងទន្លេមេគង្គ]

ការប្រើប្រាស់បញ្ជីត្រួតពិនិត្យដើម្បីធ្វើការប៉ាន់ប្រមាណយេនឌ័រ អាចមានប្រយោជន៍សម្រាប់បុគ្គលិកគម្រោងក្នុងដំណើរផ្សេងៗរបស់គម្រោង។ ឧទាហរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំបង្កើតបញ្ជីត្រួតពិនិត្យផ្នែកយេនឌ័រផ្តោតតាមវិស័យដ៏មានប្រយោជន៍ខ្លាំងមែនទែនមួយ សម្រាប់ជួយដល់បុគ្គលិកនិងអ្នកប្រឹក្សាយោបល់ក្នុងការអនុលោមតាមគោលនយោបាយ និងគោលបំណងរបស់គេលើបញ្ហាយេនឌ័រ និងក្នុងការធានាថាគម្រោងរបស់ពួកគេ " មិនបង្កការលំបាក " និងបង្កើនឱកាសជាអតិបរមាសម្រាប់ឲ្យទទួលបានលទ្ធផលយេនឌ័រវិជ្ជមាន។ បញ្ជីត្រួតពិនិត្យខាងក្រោមនេះ បានប្រើប្រាស់គម្រូនេះ ដើម្បីគ្របដណ្តប់លើបរិបទភាពងាយរងគ្រោះសំខាន់ៗសម្រាប់គម្រោងវារីអគ្គីសនីក្នុងទន្លេមេគង្គ។

## ជលផល

ការស្រាវជ្រាវថ្មីមួយដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាបរបស់រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់អះអាងថា ***"សារៈសំខាន់ខ្លាំងនៃធនធានក្នុងទឹក ជាពិសេសត្រី សម្រាប់សុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភសម្រាប់ប្រជាជនកម្ពុជា។ ការស្រាវជ្រាវបានរកឃើញថាធនធានត្រីនិងធនធានក្នុងទឹកបានផ្តល់ជាតិសាច់៧៦%ជាតិប្រូតេអ៊ីន៣៧% ជាតិដែក៣៧% និងជាតិខ្លាញ់២៨% សម្រាប់ប្រជាជនកម្ពុជា។ ដូច្នេះ វិស័យជលផលជាប្រភពដ៏សំខាន់ក្នុងការផ្តល់ថាមពល ផ្តល់ជាតិប្រូតេអ៊ីន និងជាតិដែក សម្រាប់ប្រជាជនក្នុងប្រទេសកម្ពុជា។ ... ការកសាងទំនប់ក្នុងទន្លេនឹងមានផលប៉ះពាល់យ៉ាងខ្លាំងបំផុតលើអាហារូបត្ថម្ភ ...កុមារនិងស្ត្រីមានគភ៌ គឺជាក្រុមដែលងាយរងគ្រោះបំផុតចំពោះកង្វះប្រូតេអ៊ីនដោយសារតែពួកគេត្រូវការថាមពល ប្រូតេអ៊ីន និងជាតិដែក ក្នុងកម្រិតខ្ពស់ បើប្រៀបធៀបទៅនឹងរាងកាយរបស់ពួកគេ"។ (IFREDI 2013, p.1-2)***

នៅក្នុងទន្លេមេគង្គជលផលជាចំណុចសំខាន់សម្រាប់សុខមាលភាពសេដ្ឋកិច្ចនិងជីវភាពគ្រប់គ្រាន់ប្រចាំថ្ងៃ។ ការនេសាទមានសារៈសំខាន់ណាស់ខាងផ្នែកអាហារូបត្ថម្ភនិងសន្តិសុខស្បៀង។ នៅក្នុងប្រព័ន្ធទន្លេមេគង្គ ការបម្លាស់ទីមានសារៈសំខាន់ណាស់សម្រាប់វដ្តជីវិតត្រីជាច្រើនប្រភេទ។ ទំនប់នឹងទប់ស្កាត់ការបម្លាស់ទីនេះ ហើយប្រសិទ្ធភាពនៃច្រកសម្រាប់ត្រីផ្លាស់ទីដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងប្រភេទត្រីជាច្រើនប្រភេទនិងមានចំនួនដ៏ច្រើននេះ ត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់ថាជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមជាច្រើនដែលកើតឡើងដោយសារទំនប់នៅទន្លេមេគង្គនេះ ជាពិសេសនៅតួទន្លេមេនៃទន្លេមេគង្គមេ ហើយក៏ជាបញ្ហានៅទីតាំងសំខាន់ៗក្នុងប្រព័ន្ធដៃទន្លេជាច្រើនដូចជាប្រព័ន្ធទន្លេសេសានខាងក្រោមក្នុងភាគឦសាននៃប្រទេសកម្ពុជាជាដើម។ តើគម្រោងនេះនឹងមានឥទ្ធិពលទៅលើការប្រើប្រាស់និងការគ្រប់គ្រងរបស់សហគមន៍ក្នុងការប្រើប្រាស់ទឹកនិងធនធានក្នុងទឹកទាំងនោះដែរឬទេ? អ្នករៀបចំអភិវឌ្ឍន៍គម្រោង គួរពិចារណាទៅលើចំណុចអំពីតួនាទីនិងការទទួលខុសត្រូវយេនឌ័រ និងថាតើទំនប់ទាំងនោះនឹងជះឥទ្ធិពលទៅលើពួកគេយ៉ាងដូចម្តេចខ្លះ៖

- ☐ ការប្រើប្រាស់និងការគ្រប់គ្រងទឹកទន្លេសម្រាប់ការនេសាទ
- ☐ ការប្រើប្រាស់និងការគ្រប់គ្រងព្រៃលិចទឹកនិងដីសើមសម្រាប់ការនេសាទ
- ☐ តួនាទីនិងការទទួលខុសត្រូវក្នុងការកែច្នៃត្រី (ដូចជាការធ្វើប្រហុក[១៣])
- ☐ ការរកទីផ្សារលក់ត្រី
- ☐ ការចាប់ត្រី ការប្រមូលផលត្រីនិងសត្វក្នុងទឹកដទៃទៀត រួមមាននៅលើ ដីសើម ស្រែ និង ស្រះចិញ្ចឹមត្រី
- ☐ ការចិញ្ចឹមត្រី សត្វក្នុងទឹក
- ☐ អ្នកណាជាអ្នកគ្រប់គ្រងការប្រើប្រាស់ទ្រព្យសម្បត្តិរួមក្នុងផ្នែកជលផល
- ☐ ការសម្របតាមបរិស្ថានក្នុងតំបន់សម្រាប់ការចាប់ត្រី និងការបង្កាត់ពូជត្រី



ទាំងនេះជាបញ្ជីត្រួតពិនិត្យសម្រាប់ជាគម្រូមួយចំនួន ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

១៣. *"ប្រហុក" គឺជាប្រភពប្រូតេអ៊ីនយ៉ាងសំខាន់សម្រាប់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសសម្រាប់អ្នកក្រ។*

## កសិកម្ម

ផលិតកម្មកសិកម្មជាច្រើនទម្រង់បានគាំទ្រដល់ការចិញ្ចឹមជីវិតនៅតាមទីជនបទ។ ជាញឹកញាប់ទម្រង់ផលិតកម្មទាំងនេះត្រូវបានបំផ្លាញដល់ឫសគល់ ឬ ត្រូវបានផ្លាស់ប្ដូរដោយសារតែការដាក់ឲ្យមានទំនប់និងការប្រតិបត្តិការនៃទំនប់។ គេត្រូវមានការយល់ដឹងអំពីតួនាទីនិងការទទួលខុសត្រូវពាក់ព័ន្ធយេនឌ័រ ដើម្បីឲ្យមានការចៀសវាងឬកាត់បន្ថយផលប៉ះពាល់ពាក់ព័ន្ធនឹងយេនឌ័រ ដោយផ្ដោតសំខាន់ទៅលើរបៀបដែលគម្រោងជះឥទ្ធិពលដល់ការចូលរួមរបស់ស្ត្រី ដល់ការគ្រប់គ្រង ឬ ឥទ្ធិពលក្នុងផលិតកម្មកសិកម្ម។ ឧទាហរណ៍ គួរពិចារណាទៅលើ៖

- ☐ ការប្រើប្រាស់ដីមានជីជាតិនិងដីមានសុវត្ថិភាពសម្រាប់ការដាំដំណាំនៅតាមផ្ទះ
- ☐ ការប្រើប្រាស់ច្រាំងទន្លេពេលទឹកស្រកនៅរដូវប្រាំងសម្រាប់បង្កើតជាសួនបន្លែ
- ☐ ការប្រើប្រាស់ដីសម្រាប់ឲ្យសត្វស៊ីស្មៅ
- ☐ ការប្រើប្រាស់ដីសម្រាប់ដាំដុះ
- ☐ ការប្រើប្រាស់ដីសើមនិងទំនាបលិចទឹកសម្រាប់ផលិតកម្មនិងការប្រមូលផលកសិកម្ម
- ☐ ការប្រើប្រាស់ដីសម្រាប់ការធ្វើការដាំដុះលើដី ដាំដុះឆ្លាស់រដូវកាល ព្រមទាំងតួនាទីយេនឌ័រក្នុងការភ្ជួរដី ក្នុងការដាំដុះ ក្នុងការថែទាំសត្វ និងក្នុងការប្រមូលផលដំណាំ
- ☐ តួនាទីក្នុងការដាំដំណាំក្នុងផ្ទះ ដើមឈើហូបផ្លែ និងប្រភេទដំណាំបង្កាត់ពូជផ្សេងទៀត ព្រមទាំងការប្រមូលផល
- ☐ ការចិញ្ចឹមសត្វ
- ☐ ទំនៀមនិងរចនាសម្ព័ន្ធវប្បធម៌ ក្នុងការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីសម្រាប់ផលិតកម្មកសិកម្ម
- ☐ ការរកទីផ្សារ និងការលក់ផលិតផលកសិកម្ម

## តំបន់ទីជម្រាល

ទំនប់ទឹកទំនងជានឹងទាមទារឲ្យមានការបិទការចូលទៅកាន់និងការប្រើប្រាស់តំបន់ទីជម្រាលខាងលើទំនប់ គឺថាដើម្បី "ការពារ" ទីជម្រាលពីការកាប់ឈើ និងការទាញផលប្រយោជន៍ហួសប្រមាណ ដែលការធ្វើដូចនេះនឹងនាំឲ្យមានការហូរច្រោះដីជាតិ និង កុំឲ្យជះឥទ្ធិពលអវិជ្ជមានដល់គុណភាពទឹកនៅក្នុងអាងនិងរោងចក្រអគ្គីសនី។ តើមានការជះឥទ្ធិពលយ៉ាងដូចម្ដេចខ្លះទៅលើស្ត្រី បុរស និងសហគមន៍ ក្នុងការចូលទៅកាន់និងការប្រើប្រាស់ព្រៃ ធនធាន និងដី? គួរមានការពិចារណាទៅលើទំហំការងារដែលបានប្រាក់កម្រៃនិងដែលមិនមានប្រាក់កម្រៃ។ ឧទាហរណ៍ៈ

- ☐ ការប្រមូលចំណីអាហារចេញពីក្នុងព្រៃ
- ☐ ការបរបាញ់និងការចាប់សត្វចេញពីក្នុងព្រៃ
- ☐ ការប្រមូលផលិតផលកសិផលសម្រាប់លក់ សម្រាប់ប្រើប្រាស់ និងសម្រាប់ធ្វើជំនួញ
- ☐ ការប្រមូលអុស
- ☐ សកម្មភាពប្រពៃណី ឬ វប្បធម៌ដែលប្រើប្រាស់ដីព្រៃ ឬ តំបន់ជាក់លាក់ណាមួយក្នុងតំបន់អាងស្តុកទឹក
- ☐ ការធ្វើការកសិកម្មឆ្លាស់តាមរដូវកាល ដោយរាប់បញ្ចូលទាំងតួនាទីក្នុងការភ្ជួរដី ការដាំដុះ ការថែទាំ ការប្រមូលផលលើដីទាំងនោះ ព្រមទាំង
- ☐ ការប្រើប្រាស់តាមរដូវកាលទៅលើទីតាំង ដើមឈើ និងសរីរាង្គផ្សេងៗព្រមការ ការដាំបែបវិលជុំជាច្រើនឆ្នាំទៅលើដីដាំដុះ និងការប្រើដីសម្រាប់ផលិតផលព្រៃឈើ។

## អាងស្តុកទឹក

ជាធម្មតា ការដាក់ទំនប់លើប្រព័ន្ធទន្លេ គឺការបង្កើតឲ្យមានអាងស្តុកទឹកមួយដែលអាចធ្វើឲ្យលិចប្រព័ន្ធទន្លេទាំងស្រុង។ (យោងតាមរបបប្រតិបត្តិការ វាអាចបណ្ដាលឲ្យមានលំហូរមានការធ្លាក់ចុះនៅខាងក្រោមទំនប់ ឬ បណ្ដាលឲ្យមានការបាត់បង់សន្ទុះជំនន់តាមរដូវ ដោយសារតែកម្រិតនៃការរំដោះទឹកចេញ)។ នេះមានន័យថាបរិស្ថានក្នុងទឹកទាំងខាងលើទំនប់និងខាងក្រោមទំនប់នឹងមានការផ្លាស់ប្ដូរ នឹងមានការបាត់បង់ភាពចម្រុះដែលកើតមានក្នុងទន្លេតាមរដូវ ដោយសារតែភាពរាក់ ភាពឆាប់រហ័ស គំនរខ្សាច់ អាងជ្រៅៗ ទឹកជំនន់និងភាពរាំងស្ងួត ព្រៃលិចទឹកនិងដីសើមតាមរដូវ។ អាងស្តុកទឹកបង្កើតថ្មី នឹងផ្លាស់ប្ដូរលក្ខណៈជលធារ ហើយជារឿយៗនឹងបង្កើតឲ្យមានទឹកត្រជាក់ (ដោយសារតែជម្រៅរបស់វា) ឲ្យមានទឹកគ្មានអុកស៊ីហ្សែន ហើយលំហូរទឹកក៏នឹងទទួលរងផលប៉ះពាល់ដោយសារតែកាលវិភាគប្រតិបត្តិការរបស់ទំនប់នេះ។ ឧទាហរណ៍ ការស្តុកទឹកទុកសម្រាប់ផលិតអគ្គីសនី និងការរំដោះទឹកចេញ "ខុសរដូវ" ការបង្វែរទឹកទៅកន្លែងផលិតថាមពល ហើយបន្ទាប់មកផ្ទេរទឹកទៅក្នុងទន្លេឬទីជម្រាលផ្សេងទៀត (ដែលធ្វើឲ្យទឹកឡើងនៅក្នុងប្រព័ន្ធទាំងនោះ ព្រមទាំងបន្ថយទឹកនៅក្នុងទន្លេដើម)។ ដំណើរត្រីទៅខ្សែទឹកខាងលើនិងខ្សែទឹកខាងក្រោមនឹងត្រូវបង្អាក់ ខណៈពេលដែលបរិស្ថានទឹកជ្រៅ នៅនឹងថ្កល់ថ្មី ក្នុងអាងស្តុកទឹកនេះនឹងមិនមានភាពអំណោយផលសម្រាប់ប្រភេទសត្វក្នុងទឹកជាច្រើន។ ដូចបានបញ្ជាក់ខាងដើមរួចហើយថា ការផ្លាស់ប្ដូរទាំងអស់នេះអាចប៉ះពាល់ដល់កសិកម្ម ជលផល ព្រមទាំង ការទទួលបាននិងការប្រើប្រាស់បរិស្ថានទីជម្រាលជាច្រើន។ ការយល់ដឹងអំពីការប្រើប្រាស់ ការគ្រប់

ទំព័រ ២/៣

គ្រងនិងការទទួលខុសត្រូវផ្សេងៗគ្នាទៅលើទន្លេនិងធនធានទន្លេទាំងនោះ សម្រាប់ស្ត្រី បុរស និង សហគមន៍ អាចកំណត់បានដូចខាងក្រោម៖

- □ តើទំនប់នេះនឹងផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីតាមមាត់ជ្រលងធម្មជាតិយ៉ាងដូចម្តេចខ្លះ ហើយថាតើបុរសនិងស្ត្រីនឹងទាញយកប្រយោជន៍ពីប្រព័ន្ធអេកូឡូស៊ីទាំងនោះ យ៉ាងដូចម្តេច?
- □ តើស្ត្រីនិងបុរសទាំងឡាយនឹងត្រូវគេអនុញ្ញាតឲ្យចូលទៅកាន់តំបន់អាងស្តុកទឹកនោះដែរឬទេ ហើយថាតើពួកគេមានសិទ្ធិក្នុងការប្រើប្រាស់សត្វឬរុក្ខជាតិក្នុងទឹកទាំងនោះដែរឬទេ?
- □ តើបរិមាណទឹកនិងគុណភាពទឹក នឹងទទួលរងផលប៉ះពាល់បែបណា ហើយតើនិងមានផលប៉ះពាល់យ៉ាងដូចម្តេចទៅលើការប្រើប្រាស់ទន្លេនិងទឹកទន្លេបច្ចុប្បន្ននេះ?
- □ តើប្រជាជននឹងត្រូវគេបង្ខំឲ្យផ្លាស់ប្តូរទីលំនៅចេញពីតំបន់អាងស្តុកទឹកនេះឬទេ? ស្ត្រីនិងបុរសព្រមទាំងសហគមន៍ គួរទទួលបានការប្រឹក្សាយោបល់អំពីការប្រើប្រាស់និងការចូលទៅកាន់ដីទឹក និងដែនរបស់ពួកគេ។ ពួកគាត់មានសិទ្ធិក្នុងការផ្តល់ឬមិនផ្តល់ការយល់ព្រមដែលមានការជូនដំណឹងជាមុនអំពីធនធានរបស់ពួកគាត់។

## ខ្សែទឹកខាងក្រោម

បរិស្ថាននៅក្រោមខ្សែទឹកនិងផលប៉ះពាល់របស់ទំនប់ទៅលើប្រព័ន្ធធម្មជាតិនិងជីវភាពរស់នៅរបស់ប្រជាជន ជាទូទៅ ត្រូវបានគេព្រងើយកន្តើយមិនយកចិត្តទុកដាក់ និងត្រូវគេប៉ាន់ប្រមាណមិនបានជិតដល់ឡើយ។ ទំនប់នឹងរារាំងដល់ការបម្លាស់ទីដោយសេរីរបស់ត្រីនៅខាងលើនិងខាងក្រោមខ្សែទឹក ហើយទំនប់នេះក៏នឹងរារាំងដល់រុញច្រាន និងការបម្លាស់ទីនៃកករបាតទន្លេ និងជីជាតិរវាងតំបន់ខ្ពង់រាប និងដីសើមតាមខ្សែទឹក និង តំបន់ដីសណ្តរ។ ទំនប់នេះក៏នឹងបញ្ចេញទឹកចេញមក និងកាត់បន្ថយទឹក ឬ មិនមានសន្ទុះទឹកជំនន់ ដែលជាការហូរត្រឡប់នៃបឹងទន្លេសាប និង ការផ្តល់ទឹកជំនន់រដូវភ្លៀងទៅលើដីតំបន់ទាបឡើយ។ ទាំងអស់នេះជាទិដ្ឋភាពយ៉ាងសំខាន់សម្រាប់ការរស់នៅតាមទន្លេមេគង្គ ដែលក្នុងនោះមានតួនាទីនិងការទទួលខុសត្រូវពាក់ព័ន្ធនឹងយេនឌ័រ។យើងគួរមានការយល់ដឹងអំពីរបៀបដែលគម្រោងនឹងជះឥទ្ធិពលទៅលើបរិស្ថានតាមខ្សែទឹក ហើយការយល់នេះក៏ត្រូវរួមទាំងការយល់ដឹងអំពីការជះឥទ្ធិពលឆ្លងព្រំដែន និងទៅលើក្រុមដែលប្រើភាសាផ្សេងៗគ្នាដែរ។ ប្រការមួយចំនួនដែលគួរពិចារណា:

- □ តើការរៀបចំរចនាប្លង់នៃទំនប់នេះនិងកាលវិភាគសម្រាប់ប្រតិបត្តិការនឹងជះឥទ្ធិពលដល់លំហូរផ្នែកទឹកខាងក្រោមយ៉ាងណាខ្លះ? តើការជះឥទ្ធិពលនេះមានលក្ខណៈដូចម្តេចទៅតាមរដូវខុសគ្នា? តើការផ្លាស់ប្តូរទាំងនេះនឹងជះឥទ្ធិពលដល់ការប្រើប្រាស់និងការទទួលបានទឹក និងទន្លេសម្រាប់បុរស ស្ត្រី កុមារ មនុស្សចាស់ និងសហគមន៍ យ៉ាងដូចម្តេចខ្លះ? តើមានការពិចារណាអំពីថាតើការផ្លាស់ប្តូរទាំងនេះនឹងជះឥទ្ធិពលទៅលើតម្រូវរបស់ជនពិការ ឬមនុស្សដែលមានតម្រូវការពិសេសក្នុងការប្រើប្រាស់និងការគ្រប់គ្រងធនធាន និងព្រទ្យរបស់ទាំងនោះដែរឬទេ?
- □ តើប្រជាជននឹងបាត់ការប្រើប្រាស់ដី ឬ ធនធានផលិតកម្មដែរឬទេ?
- □ តើលំហូរទន្លេទំនងជាផ្លាស់ប្តូររបៀបដែលប្រជាជនប្រើប្រាស់និងចូលទៅកាន់ទឹកលេនៅពេលខុសគ្នាពេញមួយថ្ងៃ ឬ នៅពេលផ្សេងៗគ្នាក្នុងរដូវដែរឬទេ?
- □ តើការគ្រប់គ្រងទំនប់នឹងជះឥទ្ធិពលទៅលើការប្រែប្រួលលំហូរទឹកទន្លេយ៉ាងណាខ្លះ ហើយថាតើវានឹងមានជះឥទ្ធិពលទៅលើចំណុចប្រសព្វរវាងទន្លេ ជាមួយនិងច្រាំងទន្លេ និងដី សើម និងប្រព័ន្ធធម្មជាតិនិងផលិតកម្មដែលទាក់ទងនឹងចំណុចទាំងនេះយ៉ាងដូចម្តេច?
- □ តើរបបទឹកដែលមានការផ្លាស់ប្តូរនេះ ទំនងជានឹងបញ្ឈប់សកម្មភាពសង្គម ឬ វប្បធម៌ និងបញ្ឈប់ការប្រើប្រាស់បរិស្ថានធម្មជាតិ ឬ បរិស្ថានដែលបានសាងសង់ឡើងរួចហើយនោះ (ដូចជា ធ្វើឲ្យទន្លេមិនមានសុវត្ថិភាពក្នុងការដឹកជញ្ជូនដោយសារតែលំហូរខ្ពស់) ឬ លក្ខណៈមិនអាចទាយទុកមុននៃសភាពទន្លេនេះ នឹងបង្កគ្រោះថ្នាក់ចំពោះកុមារ ចំពោះមនុស្សចាស់ និងចំពោះស្ត្រីធ្វើការងារផ្ទះ ដោយសារតែការប្រើប្រាស់ទឹកទន្លេនេះដែរឬទេ?
- □ តើរបបទន្លេនេះនឹងបង្កគ្រោះថ្នាក់ដល់ការប្រើប្រាស់ច្រាំងទន្លេសម្រាប់ការដាំដុះ សម្រាប់ស្តុកឧបករណ៍នេសាទ ឬ ទូក ដែរឬទេ?
- □ តើប្រជាជននឹងបាត់ផ្ទះសម្បែង ដីកសិកម្ម ឬ ដីសហគមន៍ ដោយសារតែមានទំនប់ទឹកនេះ និងដោយសារតែប្រតិបត្តិការរបស់ទំនប់នេះ (ដូចជា តាមរយៈការបង្កើនលំហូរទឹកនៅខាងក្រោមស្ថានីយ៍ផលិតថាមពល) ដែរឬទេ?

ទំព័រ ៣/៣

ទាំងនេះជាបញ្ជីត្រួតពិនិត្យសម្រាប់ជាគម្រូមួយចំនួន ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## ជំហានទី៤: ការយល់ដឹងអំពីតម្រូវការ និង សេចក្តីប្រាថ្នារបស់ស្ត្រី (និងបុរស)

***"នៅទីណាដែលទំនប់ទាំងឡាយទទួលបានការកែលម្អស្តង់ដាររស់នៅក្នុងតំបន់ដែលទទួលឥទ្ធិពលនោះ ការកែលម្អនេះអាចមានផលវិជ្ជមានទៅលើសមធម៌យេនឌ័រ" [គណៈកម្មការទំនប់ ទំព័រ១១៦]***

បន្ទាប់ពីបានការប៉ាន់ប្រមាណជាបឋម បានប្រមូលទិន្នន័យបែងចែកតាមភេទ និងបានកំណត់រកឃើញបញ្ហាទាំងឡាយដែលគម្រោងនឹងធ្វើការណែនាំបង្ហាញតាមទស្សនៈយេនឌ័ររួមហើយ ពេលនេះជាឱកាសល្អក្នុងការចាប់ផ្តើមឲ្យបានច្បាស់លាស់បំផុតនូវដំណើរការមួយក្នុងការយល់ដឹងអំពីតម្រូវការនិងផលប្រយោជន៍របស់ស្ត្រី។ បន្ទាប់មក ត្រូវពិចារណាថាតើគម្រោងនេះអាចឆ្លើយតបនឹងតម្រូវការទាំងនេះយ៉ាងដូចម្តេច។

ប្រការនេះត្រូវមានការប៉ាន់ប្រមាណអំពីតម្រូវការរបស់ស្ត្រី និងសក្តានុពលដែលគម្រោងនេះមាន សម្រាប់ដោះស្រាយតម្រូវការរបស់ស្ត្រីនិងសហគមន៍ប្រកបដោយភាពវិជ្ជមាន។

តាមរយៈការប្រើប្រាស់ការប៉ាន់ប្រមាណយេនឌ័រ គម្រោងនេះនឹងប៉ាន់ប្រមាណដូចតទៅ:

- តើស្ត្រីត្រូវការអ្វីដើម្បីជួយពួកគាត់ទាក់ទងនឹងតួនាទីនិងការទទួលខុសត្រូវរបស់ពួកគាត់ (តម្រូវការយេនឌ័រជាក់ស្តែង)។
- តើស្ត្រីត្រូវការអ្វី ហើយតើត្រូវការការផ្លាស់ប្តូរបែបណាខ្លះក្នុងរចនាសម្ព័ន្ធនិងក្នុងស្ថាប័ន ដើម្បីសម្រេចបានសមភាពយេនឌ័រនៅក្នុងសហគមន៍(តើអ្វីជាផលប្រយោជន៍យេនឌ័រដែលមានលក្ខណៈជាយុទ្ធសាស្ត្រ?)។

តាមវិធីនេះ ទំនប់ទាំងឡាយមានសក្តានុពលក្នុងការដើរតួនាទីផ្លាស់ប្តូរមួយ នៅក្នុងទំនាក់ទំនងយេនឌ័រនិងទៅលើសមភាពស្ត្រី។ ប៉ុន្តែដើម្បីឲ្យជានាឲ្យមាននិរន្តរភាពនិងមានភាពសមស្របតាមបែបវប្បធម៌ ប្រការសំខាន់គឺត្រូវកំណត់នូវផលប្រយោជន៍និងតម្រូវការលក្ខណៈជាយុទ្ធសាស្ត្រ តាមរយៈវិធីសាស្ត្រមួយដែលមានលក្ខណៈពិគ្រោះយោបល់និងមានការចូលរួមដ៏ផុលផុសមួយ។ គម្រោងអាចធ្វើឲ្យមានធនធានសម្រាប់ជួយជំរុញឲ្យបានសម្រេចតាមសេចក្តីប្រាថ្នារបស់ប្រជាជនទទួលរងផលប៉ះពាល់ទាំងនោះ។ នៅពេលធ្វើការប៉ាន់ប្រមាណចំពោះការចំណាយសម្រាប់គម្រោងទាំងមូល ការចំណាយនេះអាចជាចំនួនដ៏តិចតួចមួយក៏ប៉ុន្តែ អាចមានការរួមចំណែកច្រើនក្នុងការសម្រេចបាននិងរក្សាបាននូវអាជ្ញាប័ណ្ណសង្គមក្នុងការប្រតិបត្តិការជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង។

គេមិនគួរទុកឲ្យតែអ្នកប្រឹក្សាយោបល់ ឬ តែអ្នកឯកទេស កំណត់ជាមុនអំពីអ្វីដែលជាតម្រូវការនិងជាការចង់បានរបស់ស្ត្រីនោះទេគឺ គម្រោងនេះគួរតែជួយសម្រួលដល់ដំណើរការនិងឱកាសដើម្បីឲ្យគេបានឮសំឡេងរបស់ស្ត្រីទន្ទឹមគ្នានឹងសំឡេងរបស់បុរសដែរ។ រឿងនេះគួរធ្វើឡើងក្នុងបរិបទមួយដែលមានការទទួលស្គាល់ក្រុមជាតិពន្ធុ ឬ ក្រុមជនជាតិដើមភាគតិចផ្សេងៗគ្នា ដើម្បីឲ្យសំឡេងរបស់បុរសស្ត្រីជនជាតិដើមភាគតិចត្រូវបានគេឮទន្ទឹមគ្នានឹងសំឡេងប្រជាជនដែលមិនមែនជាជនជាតិដើមភាគតិចដែរ។ គួរមានការយកចិត្តទុកដាក់ក្នុងការបង្កើតដំណាក់កាលនៃការប៉ាន់ប្រមាណនេះ ដើម្បីធានាថានិគមជនឬក្រុមប្រជាជនឯទៀតដែលអាចមានការលំបាកក្នុងការចូលទៅក្នុងការប្រជុំសហគមន៍ឬការប្រជុំសាធារណៈបានចូលរួមដោយសកម្មដែរ ដូចជា តាមរយៈការជួយសម្រួលឲ្យមានការប្រជុំនៅតាមគ្រួសារជាមួយគ្រួសារដែលមានមេផ្ទះជាស្ត្រី ឬ ជាមួយគ្រួសារដែលមានជនពិការរស់នៅជាមួយ។

### បញ្ជីតារាងសំណួរមូលដ្ឋានសម្រាប់ការចូលរួមរបស់ស្ត្រី

- ☐ តើអ្នកបានបកប្រែឯកសារទាំងឡាយជាភាសានិងទម្រង់ដែលស្ត្រីអាចរកយកមកទទួលព័ត៌មានបានដូចបុរសដែរឬទេ?
- ☐ តើអ្នកបានបង្កើតឱកាសប្រជុំដាច់ដោយឡែកជាមួយក្រុមស្ត្រីដែរឬទេ?
- ☐ តើអ្នកបានបង្កើតឱកាសប្រជុំសម្រាប់ស្ត្រីដែលមានស្ថានភាព អាយុ ជនជាតិផ្សេងគ្នាដែរឬទេ? ហើយតើអ្នកប្រាកដទេ ថាបានឮយោបល់របស់ស្ត្រីដែលមានស្ថានភាពសង្គមសេដ្ឋកិច្ច និងសាវតាជនជាតិទាំងអស់នោះ?
- ☐ តើមានផ្តល់អ្នកសម្របសម្រួលជាស្ត្រីដែរឬទេ?តើមានបានឲ្យស្ត្រីដែលមានសាវតាជនជាតិផ្សេងៗដែលមានសមត្ថភាពផ្នែកភាសានិងវប្បធម៌ចូលរួមដែរឬទេ?
- ☐ តើស្ត្រីបានចូលរួមក្នុងការប្រជុំសម្រេចចិត្តស្មើគ្នាដូចបុរសដែរឬទេ?
- ☐ តើស្ត្រីមានបានចូលរួមនៅ ក្នុងដំណើរការរាយការណ៍ត្រឡប់និងពិនិត្យឡើងវិញ នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬ ដំណើរការវាយតម្លៃហេតុប៉ះពាល់យេនឌ័រដែរឬទេ?

តើគេមានបានរៀបចំការប្រជុំតាមពេលវេលាផ្សេងៗគ្នានិងមានបានគិតអំពីពេលវេលាដែលប្រជាជនត្រូវរវល់តាមរដូវដើម្បីឲ្យមានការគោរពដល់ការទទួលខុសត្រូវលើការងារចម្រុះរបស់ស្ត្រីដែរឬទេ?

ទំព័រ ១/១

ទាំងនេះជាបញ្ជីត្រួតពិនិត្យសម្រាប់ជាគម្រូមួយចំនួន ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

ការប៉ាន់ប្រមាណអំពីតម្រូវការ នឹងពិនិត្យមើលលើតម្រូវការជាក់ស្តែងរបស់ស្ត្រី ប៉ុន្តែក៏ត្រូវពិនិត្យមើលស្ថានភាពនិងអំណាចរបស់ស្ត្រីនៅក្នុងសង្គមដែរ។ តម្រូវការជាក់ស្តែងជាតម្រូវការដែលអនុញ្ញាតឲ្យស្ត្រីអាចធ្វើបាននូវអ្វីដែលពួកគេកំពុងធ្វើនាពេលបច្ចុប្បន្ននេះ។ ការបំពេញតាមតម្រូវការជាក់ស្តែងនឹងរក្សាបាននូវស្ថានភាពបច្ចុប្បន្ននៃទំនាក់ទំនងយេនឌ័រ។

ផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រ នឹងកំណត់ឃើញថា អ្វីដែលនឹងជួយស្ត្រីឲ្យទទួលបានអំណាចនិងការគ្រប់គ្រងកាន់តែច្រើនជាងមុនទៅលើជីវិតរបស់ខ្លួននិងនៅក្នុងសង្គម។ ផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រ ត្រូវចាប់ចេញដំណើរ ពីចំណុចដែលស្ត្រីនៅក្នុងបរិបទជាច្រើនដែលស្ត្រីនឹងមានអំណាចតិចជាងបុរស ហើយស្ត្រីនឹងមានស្ថានភាពសង្គមទាបជាងបុរស។ ការប្រើប្រាស់វិធីសាស្ត្រយេនឌ័រយុទ្ធសាស្ត្រ គឺជាការទទួលស្គាល់សិទ្ធិស្ត្រីនិងផ្លាស់ប្តូរអតុល្យភាពអំណាចនៅក្នុងសង្គម និងគ្រួសារដែលបានរឹតបន្តឹងលើស្ត្រីមិនឲ្យទទួលបានសិទ្ធិរបស់ពួកគេ។

ការប៉ាន់ប្រមាណផលប្រយោជន៍ជាក់ស្តែងរួមជាមួយនឹងតម្រូវការជាយុទ្ធសាស្ត្ររបស់ស្ត្រី នឹងបណ្តាលឲ្យមានការពិចារណាអំពីការជះឥទ្ធិពលរបស់គម្រោងទៅលើស្ត្រី និងអំពីវិធីធ្វើឲ្យគម្រោងចៀសផុតពីការធ្វើឲ្យវិសមភាពកាន់តែមានភាពអាក្រក់ឡើងរវាងបុរសនិងស្ត្រី ព្រមទាំងអំពីការចូលរួមចំណែកក្នុងការផ្លាស់ប្តូរជាវិជ្ជមានទៅលើជីវិតរបស់ស្ត្រី។

ហេតុដូចនេះហើយ ការដែលក្រុមហ៊ុនមានការយល់ដឹងអំពីតម្រូវការជាក់ស្តែងនិងតម្រូវការជាយុទ្ធសាស្ត្ររបស់ស្ត្រី គឺជាប្រការដែលមានប្រយោជន៍មួយសម្រាប់ដំណើរការគម្រោង ដែលកំពុងធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ដែលកើតចេញពីគម្រោង និងការកាត់បន្ថយហានិភ័យ។

នៅពេលបញ្ចូលជាមួយឧបករណ៍ប៉ាន់ប្រមាណសំខាន់ផ្សេងទៀតដូចជាការពណ៌នាអំពីការប្រើប្រាស់និងគ្រប់គ្រងនោះ ការប៉ាន់ប្រមាណតម្រូវការយេនឌ័រនេះនឹងជួយឲ្យបុគ្គលិកគម្រោងរកឃើញឱកាសសម្រាប់ផ្តល់អន្តរាគមន៍បែបយុទ្ធសាស្ត្រ។ ឧទាហរណ៍ គេអាចប្រើសម្រាប់ការចរចានិងការប៉ាន់ប្រមាណអំពីយន្តការចែករំលែកផលប្រយោជន៍ដែលអាចទៅរួចមួយ ឬ សម្រាប់ការកំណត់រកឲ្យឃើញនូវជម្រើសផ្សេងៗក្នុងការផ្លាស់ប្តូរទីលំនៅដោយស្ម័គ្រចិត្ត និងរកឃើញគម្រោងសម្រាប់ស្តារជីវភាពរស់នៅ។

ការសម្រេចចិត្តជាច្រើនក្នុងគម្រោងដែលមានការចរចាររវាងក្រុមហ៊ុននិងសហគមន៍ទទួលរងផលប៉ះពាល់ដោយសារទំនប់នឹងទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ការប៉ាន់ប្រមាណតម្រូវការយេនឌ័រ។ តាមរយៈការធ្វើបែបនេះ ក្រុមហ៊ុននិងដៃគូរដ្ឋាភិបាល អាចសម្រេចបានផលប៉ះពាល់យេនឌ័រក្នុងលក្ខណៈវិជ្ជមាន។

## ឧបករណ៍ប៉ាន់ប្រមាណតម្រូវការនិងផលប្រយោជន៍បែបយុទ្ធសាស្ត្រ

**គោលបំណង:** ឧបករណ៍នេះនឹងជួយឲ្យអ្នកយល់អំពីតម្រូវការរបស់ស្ត្រី ដែលមាននាពេលបច្ចុប្បន្ននៅក្នុងបរិបទបច្ចុប្បន្ន។ ទន្ទឹមគ្នានេះដែរ សូមពិចារណាអំពីអ្វីនឹងត្រូវការផ្លាស់ប្តូរ ឬ អ្វីដែលអាចផ្លាស់ប្តូរ ដើម្បីធ្វើឲ្យរីកចម្រើនដល់ផលប្រយោជន៍ ស្ថានភាព និងអំណាចរបស់ស្ត្រីទាំងនៅក្នុងផ្ទះ ក្នុងសហគមន៍ ឬ ក្នុងសង្គម។

ព័ត៌មានដំបូងអាចទាញយកចេញពីឧបករណ៍ដទៃទៀតដូចជាការពណ៌នាសកម្មភាព និងការពណ៌នាការប្រើប្រាស់និងការគ្រប់គ្រង ប៉ុន្តែ បន្ទាប់មកគួរត្រូវមានការពិភាក្សានិងចម្រាញ់ ដោយផ្អែកលើមតិយោបល់ទាំងឡាយពីបុរសនិងស្ត្រី។ តម្រូវការនិងផលប្រយោជន៍បែបយុទ្ធសាស្ត្រជាច្រើន មានការសន្មតរួចជាស្រេចជាប់មកជាមួយ ដូចនេះ គួរមានការស្វែងរកនិងកំណត់និយមន័យបន្ថែមទៀត នៅកន្លែងដែលសហគមន៍ជាតិពន្ធុផ្សេងគ្នា ក្រុមភាសានិងវប្បធម៌ផ្សេងគ្នា មានវត្តមាននៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ពីគម្រោង។

**សំណួរគន្លឹះ:** តើបុរសនិងស្ត្រីត្រូវការអ្វីដើម្បីបន្តការរស់នៅបច្ចុប្បន្នឲ្យមានស្ថិរភាព? តើបុរសកំណត់អ្វីជាអាទិភាព? តើស្ត្រីកំណត់អ្វីជាអាទិភាព?

តើអ្វីត្រូវកំណត់ថាជាតម្រូវការរួម? តើមានអ្វីអាចជួយស្ត្រីឲ្យទទួលបានការគ្រប់គ្រងច្រើនជាងមុន និងទទួលបានផលប្រយោជន៍សម្រាប់រយៈពេលកាន់តែវែងជាងមុន? តើស្ត្រីលើកឡើងអំពីអ្វីដែលជាសេចក្តីប្រាថ្នារបស់ខ្លួនក្នុងពេលអនាគត?

ការប៉ាន់ប្រមាណតម្រូវការយេនឌ័រ អាចកត់ត្រានៅក្នុងតារាងសាមញ្ញមួយ។ ព័ត៌មាននេះគួរប្រមូលតាមរយៈការសន្ទនាជាមួយស្ត្រី ជាមួយបុរស និងជាក្រុមរួមគ្នា។ តារាងខាងក្រោមផ្តល់នូវឧទាហរណ៍មួយចំនួនអំពីប្រភេទតម្រូវការដែលគេអាចប៉ាន់ប្រមាណនិងសម្រេចបានក្នុងបរិបទទំនប់វារីអគ្គីសនី។

**ការប៉ាន់ប្រមាណតម្រូវការយេនឌ័រ**

| តម្រូវការយេនឌ័រជាក់ស្តែងសម្រាប់ស្ត្រី | តម្រូវការយេនឌ័របែបយុទ្ធសាស្ត្រសម្រាប់ស្ត្រី |
|---|---|
| • ការប្រើប្រាស់ច្រាំងទន្លេសម្រាប់ដាំដុះដំណាំ<br>• ការចូលព្រៃរកប្រមូលអនុផលព្រៃឈើ<br>• ការប្រើប្រាស់ទន្លេនិងទឹកស្អាត<br>• អុស<br>• សួនបន្លែនៅផ្ទះ<br>• ឧបករណ៍នេសាទ<br>• ធនធានសម្រាប់កែច្នៃត្រី<br>• គ្រាប់ពូជនិងរុក្ខជាតិសម្រាប់ផលិតកម្ម (ក្នុងការតាំងទីលំនៅថ្មី)<br><br>តម្រូវការទាក់ទងនឹងការគ្រប់គ្រងទន្លេនិងអភិបាលកិច្ច៖<br>• មានទីផ្សារសម្រាប់លក់ត្រី<br>• មានទូក/អាចដឹកជញ្ជូន<br>• ការបណ្តុះបណ្តាលជាក់លាក់ទាក់ទងនឹងការផ្លាស់ប្តូរដែលកើតចេញមកពីគម្រោង (ឧទា. ការធ្វើកសិកម្មដែលមានការផ្លាស់ប្តូរខុសពីមុន)<br>• ការងារមានប្រាក់កម្រៃ | • កិច្ចព្រមព្រៀងលើធនធានសហគមន៍ដែលបានបញ្ចូលស្ត្រីដោយស្មើភាព និងផ្តល់ឲ្យស្ត្រីទទួលបានការប្រើប្រាស់ដីផលិតកម្ម<br>• ការតំណាងនិងការរៀបចំរួមក្នុងគណៈកម្មការជលផល<br>• ការតំណាងនិងការរៀបចំរួមក្នុងការសម្រេចចិត្តក្នុងភូមិ<br>• សិទ្ធិក្នុងការនិយាយស្តី<br>• ជំនាញអំពីភាពជាអ្នកដឹកនាំ និងតួនាទីជាអ្នកដឹកនាំក្នុងគម្រោងឬសហគមន៍<br>• ឱកាសទទួលបានការអប់រំ<br>• ស្ត្រីទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី<br>• ប្រាស់កាស |

យកលំនាំតាម March, Smyth and Mukhopadhyay 1999, ទំ. ៦១



ទាំងនេះជាឧបករណ៍គម្រូ ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## ការពង្រឹងសិទ្ធិអំណាចស្ត្រី

***"តាមរយៈការមិនយល់ដឹងសោះអំពីយេនឌ័រនៅក្នុងដំណើរការធ្វើផែនការនោះ គម្រោងទំនប់ធំៗតែងតែធ្វើឡើងនៅលើអគុល្យភាពនៃទំនាក់ទំនងយេនឌ័រដែលមានស្រាប់។ សម្រាប់សហគមន៍ដែលទទួលរងផលប៉ះពាល់ ទំនប់ទាំងនោះបានកាន់តែធ្វើឲ្យមានគម្លាតយេនឌ័រធំឡើងអាចតាមរយៈការចូលរួមចំណែកមិនមានសមាមាត្រសម្រាប់ការចំណាយផ្សេងៗសម្រាប់ស្ត្រី ឬ តាមរយៈការបែងចែកដោយគ្មានសមធម៌ទៅលើផលប្រយោជន៍ដែលបានបង្កើតឡើង" (WCD 2000, ទំ ១១៤)។*** យើងបានយល់ស្របថាគម្រោងនឹងមានផលប៉ះពាល់លើយេនឌ័រ។ផលប៉ះពាល់ទាំងនេះមានសក្តានុពលវិជ្ជមាន ប៉ុន្តែដូចដែលគណៈកម្មាធិការពិភពលោកស្តីពីទំនប់ និងអ្នកប្រាជ្ញផ្សេងទៀត [Scudder, T. The Future of Large Dams, 2005], បានគូសបញ្ជាក់យ៉ាងច្បាស់ថា ជាញឹកញាប់មែនទែនដែលគម្រោងទំនប់វារីអគ្គីសនីនឹងធ្វើឲ្យគម្លាតយេនឌ័រកាន់តែមានភាពអាក្រក់ឡើងទៅវិញ។

ដើម្បីឲ្យគម្រោងចៀសវាងប្រការនេះបាន សំខាន់ត្រូវមានការវិភាគអំពីការឆ្លើយតបយ៉ាងណាចំពោះតម្រូវការនិងផលប្រយោជន៍របស់ស្ត្រី និងថាតើការអភិវឌ្ឍន៍នឹងមានឥទ្ធិពលយ៉ាងណាដល់ទំនាក់ទំនងយេនឌ័រក្នុងតំបន់ទទួលរងផលប៉ះពាល់និងតំបន់ដែលជះឥទ្ធិពលពីគម្រោងដែរឬទេ។

ឧបករណ៍មានប្រយោជន៍សម្រាប់ដំណើរការនេះគឺក្របខណ្ឌពង្រឹងសិទ្ធិអំណាចស្ត្រី ដែលជាឧបករណ៍សម្រាប់ប៉ាន់ប្រមាណស្ថានភាពនិងតម្រូវការរបស់ស្ត្រី ប្រៀបធៀបនឹងស្ថានភាពនិងតម្រូវការរបស់បុរស។ ការប៉ាន់ប្រមាណនេះផ្តល់ឲ្យមានការយល់ដឹងអំពីទំនាក់ទំនងលើកន្លែងដែលបុរសនិងស្ត្រីត្រូវការវិធានការអភិវឌ្ឍន៍មួយចំនួន។ ឧបករណ៍ដែលគេប្រើញឹកញាប់ក្នុងការប៉ាន់ប្រមាណអំពីភាពក្រីក្រមួយនេះ អនុញ្ញាតឲ្យអ្នកអភិវឌ្ឍន៍គម្រោងប៉ាន់ប្រមាណថាតើគម្រោងនឹងមានលទ្ធផលវិជ្ជមានសម្រាប់ស្ត្រី បើប្រៀបធៀបនឹងបុរសដែរឬទេ ហើយត្រូវធ្វើយ៉ាងណា។

ក្របខណ្ឌពង្រឹងសិទ្ធិអំណាចស្ត្រី លើកឡើងថាមានប្រភេទ ឬកម្រិតចំនួនបី ដែលគម្រោងមួយអាចប៉ាន់ប្រមាណទៅលើ :

១. **កម្រិតអវិជ្ជមាន:** ចំណុចដែលគម្រោងនេះនឹងជះឥទ្ធិពលអវិជ្ជមានលើស្ត្រី

២. **កម្រិតអព្យាក្រឹត្យ:** ចំណុចដែលគម្រោងនេះនឹងជះឥទ្ធិពលលើស្ត្រីនិងបុរសស្មើគ្នា

៣. **កម្រិតវិជ្ជមាន:** ចំណុចដែលគម្រោងនេះនឹងជះឥទ្ធិពលវិជ្ជមានលើតម្រូវការនិងផលប្រយោជន៍លើស្ត្រី ព្រមទាំងនឹងកែលម្អស្ថានភាពរបស់ស្ត្រីប្រៀបនឹងស្ថានភាពបុរស

ក្របខណ្ឌពង្រឹងសិទ្ធិអំណាចស្ត្រី ផ្អែកទៅលើវិធីសាស្ត្រដែលមានដាក់មាត្រដ្ឋានសម្រាប់ប៉ាន់ប្រមាណសមភាពនិងសម្រាប់វាស់ស្ទង់ការពង្រឹងសិទ្ធិអំណាច។ ការប៉ាន់ប្រមាណលើមាត្រដ្ឋានប្រាំកម្រិតស្តីពីការពង្រឹងសិទ្ធិអំណាច ដោយចាប់ផ្តើមពីកម្រិតទាបបំផុត (ឬមានការផ្លាស់ប្តូរតិចតួច)នេះ ត្រូវគេប្រើសម្រាប់ប៉ាន់ប្រមាណស្ថានភាពសមភាពរបស់ស្ត្រីដែលជាលទ្ធផលរបស់គម្រោង។ កម្រិតនៃការពង្រឹងសិទ្ធិអំណាចទាំងប្រាំគឺ :

i. **សុខមាលភាព:** ស្ត្រីនឹងទទួលបានសំណងជាសម្ភារៈ ឬផលប្រយោជន៍ពីគម្រោង

ii. **ការទទួលបានការប្រើប្រាស់:** ស្ត្រីទទួលបានស្ថានភាពផ្នែកផ្លូវច្បាប់ ការកែទម្រង់ការទទួលបានសិទ្ធិប្រើប្រាស់ធនធានផលិតកម្ម និងកត្តាដែលជះឥទ្ធិពលដល់ផលិតកម្ម ដូចជាកម្លាំងពលកម្ម សមភាព និងធនធានស្មើបុរស

iii. **ការធ្វើឲ្យមានការយល់ដឹង:** មានការយល់ដឹងអំពីភាពខុសគ្នារវាងតួនាទីភេទនិងតួនាទីយេនឌ័រ គឺថាស្ត្រីនិងបុរសមានសមភាពទាក់ទងនឹងការបែងចែកកម្លាំងពលកម្មយេនឌ័រ ហើយការមានប្រៀបត្រូវដកចេញ។

iv **ការចូលរួមឬការប្រមូលគៀងគរ:** ស្ត្រីត្រូវមានការចូលរួមដោយស្មើភាពក្នុងការសម្រេចចិត្តកម្រិតគម្រោងក្នុងការរចនាគម្រោង ការប៉ាន់ប្រមាណ យន្តការគម្រោង និងដំណើរការគ្រប់គ្រង។

v **ការគ្រប់គ្រង:** ស្ត្រីត្រូវមានការចូលរួមដោយស្មើភាពក្នុងការសម្រេចចិត្ត ហើយការចូលរួមនេះជះឥទ្ធិពលដល់គុណភាពនៃការគ្រប់គ្រងលើតួនាទី និងការទទួលខុសត្រូវយេនឌ័រផ្សេងទៀត។

នៅក្នុងគម្រោងទំនប់វារីអគ្គីសនីជាច្រើន លទ្ធផលសម្រាប់ស្ត្រីហាក់ដូចជានៅត្រឹមកម្រិតសុខមាលភាព ដែល "ផលិតផល" មើលឃើញជាក់ស្តែង ត្រូវបានគេផ្តល់ទៅឲ្យស្ត្រី (និង បុរស) ដូចជា ផ្ទះថ្មី ទីតាំងផ្សារថ្មី គ្រាប់ពូជសម្រាប់បង្កើតសួនបន្លែនៅ ផ្ទះឡើងវិញបន្ទាប់ពីមានការផ្លាស់ប្តូរទីលំនៅដោយស្ម័គ្រចិត្តរួចមក។ ប៉ុន្តែសម្រាប់កន្លែងដែលមានការបញ្ចូលយេនឌ័របានល្អប្រសើរ ការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើផែនការគម្រោងព្រមទាំងការសម្រេចចិត្តមានលក្ខណៈជាប្រព័ន្ធនិងប្រកបដោយអត្ថន័យនេះ វាជាឱកាសកាន់តែប្រសើរដើម្បីសម្រេចបាននូវលទ្ធផលដែលមានលក្ខណៈធ្វើឲ្យមានការផ្លាស់ប្តូរកាន់តែប្រសើរ។ នេះមានន័យថាគម្រោងនេះបានដោះស្រាយផលប្រយោជន៍បែបយុទ្ធសាស្ត្រសម្រាប់ស្ត្រី។

## ឧបករណ៍ពង្រឹងសិទ្ធិអំណាចស្ត្រី

**គោលបំណង:** គោលបំណងរបស់ឧបករណ៍នេះគឺសម្រាប់កត់ត្រានូវសកម្មភាពនិងកម្មវិធីណាខ្លះដែលគម្រោងនេះបានបង្កើត និងហេតុអ្វីបានជាបង្កើត។ ឧបករណ៍នេះ ជំរុញឲ្យបុគ្គលិកគម្រោងធ្វើការប៉ាន់ប្រមាណជាក់ស្តែង ថាហេតុអ្វីបានជាគំនិតផ្តួចផ្តើមជាគម្រោងទាំងនោះមានសារៈសំខាន់ និងឲ្យបុគ្គលិកគម្រោងគិតឲ្យបានពេញលេញអំពីការពង្រឹងគំនិតផ្តួចផ្តើមជាគម្រោងទាំងនោះ ដើម្បីឲ្យមានការរួមចំណែកជាវិជ្ជមានដល់ការពង្រឹងសិទ្ធិអំណាចស្ត្រី។

**សំណួរគន្លឹះ:** តើមានការពិគ្រោះយោបល់ជាមួយស្ត្រីអំពីការបង្កើតគម្រោងនិងសកម្មភាពទាំងនោះដែរឬទេ? តើស្ត្រីមានបានចូលរួមនៅក្នុងការសម្រេចចិត្តដែលផ្អែកលើព័ត៌មានពេញលេញនិងប្រកបដោយជម្រើសដែរឬទេ? តើស្ត្រីមានបានចូលរួមក្នុងដំណើរការធ្វើផែនការសម្រាប់សកម្មភាពនោះឬទេ? តើបុគ្គលិកគម្រោងមានពិចារណាអំពីរបៀបគាំទ្រសកម្មភាពជាបឋមពីពេលមួយទៅពេលមួយ ដើម្បីពង្រឹងសិទ្ធិអំណាចស្ត្រីដែលរងផលប៉ះពាល់ពីគម្រោងឲ្យកាន់តែខ្លាំងក្លាថែមទៀតដែរឬទេ?

តារាងខាងក្រោមនេះផ្តល់នូវឧទាហរណ៍មួយអំពីការអនុម័តវិធីសាស្ត្រក្របខណ្ឌពង្រឹងសិទ្ធិអំណាចស្ត្រីនេះ នៅក្នុងបរិបទទំនប់វារីអគ្គិសនី។ ឧទាហរណ៍ទាំងនេះគួរតែពង្រីកនិងសម្របទៅតាមបរិបទក្នុងតំបន់នោះ។

| ឧបករណ៍ការវិភាគសម្រាប់ការពង្រឹងសិទ្ធិអំណាចស្ត្រី | | | | | | |
|---|---|---|---|---|---|---|
| | | កម្រិតនៃការបារម្ភចំពោះសុខមាលភាពស្ត្រី | | | | |
| ផ្នែក | ការឆ្លើយតប ឬ សកម្មភាពគម្រោង | សុខមាលភាព | ការទទួលបានការប្រើប្រាស់ | ការធ្វើឲ្យមានការយល់ដឹង | ការចូលរួមឬ ការប្រមូលគៀងគរ | ការគ្រប់គ្រង |
| **ការងារ/សកម្មភាពសេដ្ឋកិច្ច** | | | | | | |
| សួនបន្លែនៅផ្ទះ | ពូជដែលផ្តល់ដោយក្រុមហ៊ុនសម្រាប់គ្រួសារផ្លាស់ប្តូរទីលំនៅ | | | | | |
| វារីវប្បកម្មតាមគ្រួសារ | កូនត្រីដែលក្រុមហ៊ុនផ្តល់ឲ្យ | | | | | |
| សហករណ៍កសិករស្ត្រីត្រូវបានបង្កើត | មូលនិធិហិរញ្ញវត្ថុ | | | | | |
| ស្ត្រីមានតំណាងស្មើគ្នានៅក្នុងគណៈកម្មការភូមិ | ស្ត្រីអាចទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ពេលវេលារបស់គាត់ធ្វើការជាមួយរដ្ឋាភិបាលដើម្បីធានាឲ្យមានតំណាងស្មើគ្នាសម្រាប់បុរសនិងស្ត្រី | | | | | |
| **ការអប់រំ** | | | | | | |
| សាលារៀនត្រូវបានសាងសង់ | មានកំណត់ក្នុងផែនការផ្លាស់ទីលំនៅ,ថវិកា | | | | | |
| ស្ពានត្រូវបានសាងសង់ | មានកំណត់ក្នុងផែនការផ្លាស់ទីលំនៅ, ថវិកា | | | | | |
| រថយន្តក្រុង | ផ្គត់ផ្គង់ដោយក្រុមហ៊ុន | | | | | |

ទំព័រ ១/២

| | | | | | | |
|---|---|---|---|---|---|---|
| គ្រូនិយាយភាសាអ្នកស្រុក និងរស់នៅក្នុងភូមិជាស្ត្រី | ផ្ទះគ្រូត្រូវបានសាងសង់ជាមួយសាលា ធ្វើការជាមួយរដ្ឋបាលថ្នាក់ខេត្តដើម្បីធានាឲ្យមានការគាំទ្រពីគ្រូ | | | | | |
| **ធនធាន** | | | | | | |
| សិទ្ធិដីធ្លី | ធ្វើការជាមួយរដ្ឋាភិបាលដើម្បីធានាឲ្យទទួលបានកម្មសិទ្ធិ ដោយមានដាក់ឈ្មោះស្ត្រីនិងបុរស | | | | | |
| សិទ្ធិទឹក | បានផ្តល់ធនធានសម្រាប់បង្កើតក្រុមស្ត្រីប្រើប្រាស់ទឹក បានកំណត់អាទិភាពស្ត្រី | | | | | |
| សិទ្ធិចូលព្រៃនិងប្រើប្រាស់ព្រៃ | បានរៀបចំឲ្យសហគមន៍អាចចូលនិងប្រើប្រាស់ព្រៃតាមទីជម្រាល បានបង្កើតគណៈកម្មការព្រៃសហគមន៍ ដោយមានទាំងបុរសនិងស្ត្រី | | | | | |
| **សេវាសម្រាប់គ្រួសារ** | | | | | | |
| ការតភ្ជាប់អគ្គីសនី | បានផ្គត់ផ្គង់ថាមពលដល់គ្រប់ផ្ទះនៅក្នុងសហគមន៍ដើមនិងអ្នកផ្លាស់ទីលំនៅ | | | | | |
| ដើងរ៉ូប៊ីណេទឹក | បានអភិវឌ្ឍគម្រោងដោយផ្អែកលើអាទិភាពស្ត្រី | | | | | |
| ការសាងសង់ផ្ទះ | ការរចនានិងការសម្រេចចិត្តមានការចូលរួមពីស្ត្រី | | | | | |
| ប្រព័ន្ធស្រោចស្រព | មានស្ត្រីនិងបុរសចូលរួមក្នុងការកំណត់ប្រេកហូរ ប្រេកចាប់ផ្តើមនិងសិទ្ធិ/ការប្រើប្រាស់ | | | | | |

ទំព័រ ២/២

ទាំងនេះជាឧបករណ៍គម្រូ ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## ជំហានទី៥ : យុទ្ធសាស្ត្រយេនឌ័រ និង ផែនការសកម្មភាព

មានការផ្តល់អនុសាសន៍ថាគួររៀបចំបង្កើតផែនការសកម្មភាព និងយុទ្ធសាស្ត្រយេនឌ័រដាច់ដោយឡែក។ គម្រោងជាច្រើនអាចបញ្ចូលទិន្នន័យនិងការឆ្លើយតបយេនឌ័រទៅក្នុងផែនការគ្រប់គ្រងផលប៉ះពាល់សង្គម។ ការវិភាគនិងការយល់ដឹងពាក់ព័ន្ធយេនឌ័រ គួរត្រូវបញ្ចូលទៅក្នុងផែនការគ្រប់គ្រងដែរ ប្រសិនបើមានការបញ្ជ្រាបយេនឌ័រក្នុងគម្រោងទាំងមូល។ នៅកន្លែងដែលមិនមានការវិនិយោគក្នុងការបញ្ជ្រាបយេនឌ័រ ឬ ការចាប់ផ្តើមវិធីសាស្ត្របញ្ជ្រាបនេះមិនពេញលេញទេនោះ គេផ្តល់អនុសាសន៍ថាគួរមានការរៀបចំបង្កើតផែនការគ្រប់គ្រងយេនឌ័រនេះដាច់ដោយឡែកតែឯង ដែលមានកំណត់អំពីវិស័យគោលនយោបាយនិងគ្រប់គ្រងដែលត្រូវកំណត់អាទិភាព ត្រូវអនុវត្ត ត្រូវផ្តល់ធនធាន និងត្រូវតាមដានឃ្លាំមើល។

ការប៉ាន់ប្រមាណដែលបានធ្វើក្នុងជំហាន ២-៤ នឹងបង្ហាញអំពីផលប៉ះពាល់សំខាន់ៗទៅលើសមភាពបុរសនិងស្ត្រី និង/ឬ ឱកាសរបស់បុរសនិងស្ត្រី ហើយ ការពិចារណាអំពីអនុសាសន៍សម្រាប់ចៀសវាងឬកាត់បន្ថយការប៉ះពាល់ជាអប្បបរមា គឺជាការចាំបាច់។ មានជម្រើសជាច្រើនសម្រាប់បញ្ហានេះ គឺមានចាប់តាំងពី ការប៉ាន់ប្រមាណអំពីសំណងគ្រប់គ្រាន់សម្រាប់ផលប៉ះពាល់ ទាំងស្រុង រហូតដល់ការបញ្ឈប់គម្រោងទាំងស្រុង ប្រសិនបើផលប៉ះពាល់ឬហានិភ័យមានកម្រិតធំធេងពេក។ គម្រោងភាគច្រើននឹងមានសមត្ថភាពក្នុងរចនាឡើងវិញដើម្បីចៀសវាង ឬ កាត់បន្ថយផលប៉ះពាល់យេនឌ័រអវិជ្ជមាន ហើយប្រការទាំងនេះច្រើនត្រូវគេអនុវត្តរួមជាមួយនឹងការផ្តល់សំណង និងការចរចារបែងចែកផលប្រយោជន៍។ ការកែប្រែមួយក្នុងគម្រោង ដែលផ្អែកលើលទ្ធផលនិងអនុសាសន៍ចេញពីការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ គួរត្រូវធ្វើដោយមានការពិគ្រោះយោបល់ជាមួយក្រុមភាគីពាក់ព័ន្ធ ដោយមានការចូលរួមពីស្ត្រីដែរ។

តាមរយៈការរៀបចំបង្កើត**ផែនការសកម្មភាពយេនឌ័រ**ជាក់លាក់តាមគម្រោង ដោយប្រើព័ត៌មានពីការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនោះ គម្រោងនឹងមានផែនទីបង្ហាញផ្លូវច្បាស់លាស់ អមជាមួយអន្តរាគមន៍ជាក់លាក់ អាចវាស់វែងបាន និងផ្តោតចំគោលដៅ ដោយក្នុងនោះរួមមានទាំងសូចនាករ សម្រាប់ដោះស្រាយផលប៉ះពាល់អាចទាយទុកមុន ឬ ផលប៉ះពាល់ដែលអាចកើតដោយមិនបានគិតទុកជាមុន ទៅលើទំនាក់ទំនងយេនឌ័រ និងសិទ្ធិស្ត្រី។

ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនិងផែនការសកម្មភាពយេនឌ័រ គឺជាការណែនាំសម្រាប់អ្នកធ្វើការសម្រេចចិត្តនៅក្នុងគម្រោង។ ឯកសារទាំងនេះនឹងមានរួមបញ្ចូលយុទ្ធសាស្ត្រគ្រប់គ្រងយេនឌ័រ ដែលអ្នករៀបចំបង្កើតគម្រោងនិងប្រតិបត្តិករគម្រោងអាចប្រើសម្រាប់ណែនាំដល់ការអនុវត្តគម្រោង។ ឯកសារទាំងនេះក៏ជាឧបករណ៍ដ៏មានប្រយោជន៍សម្រាប់រាយការណ៍ជូនដល់អង្គភាព កែលម្អគុណភាពគ្រប់គ្រង ឬ អង្គភាពពិនិត្យមើលការអនុលោមតាម ហើយជារឿយៗ គឺជាតម្រូវការរបស់ហិរញ្ញិកទៀតផង។ ផែនការសកម្មភាពយេនឌ័រ គួរមានបញ្ចូលការប្តេជ្ញាផ្តល់ថវិកា និងធនធាន ព្រមទាំងមានតារាងពេលវេលាច្បាស់លាស់។ អង្គភាពមួយចំនួននឹងត្រូវការរៀបចំឲ្យមានផែនការសកម្មភាពយេនឌ័រ ដើម្បីឆ្លុះបញ្ចាំងអំពីដំណើរការនិងលទ្ធផលផ្សេងៗរបស់គម្រោង ដែលនៅក្នុងការរចនាបង្កើត គួរធានាថា គេមិនបានភ្លេច ឬ មិនបានផ្តល់អាទិភាពដល់យេនឌ័រ។[១៤]

ជាចំណែកមួយនៃផែនការសកម្មភាព ក្រុមហ៊ុនគួររៀបចំឲ្យមាន**យុទ្ធសាស្ត្រយល់ដឹងអំពីហានិភ័យយេនឌ័រនិងការអនុលោម។** នេះជាការវិនិយោគប្រកបដោយគុណសម្បត្តិមួយ ដោយសារតែគេអាចប្រើវាបាននៅពេញវដ្តគម្រោង។ គេក៏អាចទាញយកប្រយោជន៍ពីយុទ្ធសាស្ត្រនេះដើម្បីជាព័ត៌មានសម្រាប់ការសម្រេចចិត្តក្នុងពេលអនាគត ហើយការបញ្ចូលបញ្ជីសំណួរត្រួតពិនិត្យ អាចជួយអ្នកគ្រប់គ្រងមកពីអង្គភាពផ្សេងគ្នារកឃើញឱកាសនិងតម្រូវការសម្រាប់បញ្ចូលយេនឌ័រទៅក្នុងដំណើរការជំនួញរបស់ខ្លួន។ បញ្ជីសំណួរត្រួតពិនិត្យ ក៏អាចត្រូវគេប្រើក្នុងអំឡុងពេល តាមដាន វាយតម្លៃ ការប៉ាន់ប្រមាណអំពីនិរន្តរភាព ឬ ដំណើរការសវនកម្មការទទួលខុសត្រូវសង្គម ជាទៀងទាត់ដែរ។ គួរមានការយកចិត្តទុកដាក់ដើម្បីធានាថាបញ្ជីសំណួរត្រួតពិនិត្យ ត្រូវប្រើសម្រាប់វាស់វែងលទ្ធផល និងសកម្មភាព ព្រមទាំងត្រូវប្រើសម្រាប់ពិនិត្យបញ្ជាក់ការប្តេជ្ញាចិត្តដែលបានលើកឡើងតាមរយៈការវិភាគជាក់លាក់ដែលគេបានធ្វើឡើងសម្រាប់ទំនាក់ទំនងយេនឌ័រ សម្រាប់តម្រូវការស្ត្រី និងសម្រាប់សិទ្ធិស្ត្រី។

---

១៤. ឧទាហរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ី ប្រើវិធីសាស្ត្រមួយដែលបានបញ្ចូលផែនការសកម្មភាពយេនឌ័រទៅក្នុងឯកសារគម្រោងផ្សេងៗទៀត។ ក្នុងនោះរួមមាន "... ក្រុមគោលដៅច្បាស់លាស់ ចំនួនកូតា ចំណុចសំខាន់ក្នុងការរចនាយេនឌ័រ និងសូចនាករបំពេញការងារបែបបរិមាណវិស័យ ដើម្បីធានាឲ្យមានការចូលរួមនិងផលប្រយោជន៍សម្រាប់ស្ត្រី។ ទិដ្ឋភាពសំខាន់ៗនៃផែនការសកម្មភាពយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងការធានាគម្រោង ដើម្បីលើកទឹកចិត្តឲ្យមានការជំនឿចិត្តពីភ្នាក់ងារអនុវត្តគម្រោងនិងដៃគូគម្រោងផ្សេងទៀត"។ (ADB 2013)

## អ្វីដែលធ្វើឲ្យផែនការសកម្មភាពយេនឌ័រនិងយុទ្ធសាស្ត្រមានប្រសិទ្ធភាព? បញ្ជីត្រួតពិនិត្យ

**ការវិភាគសង្គមនិងយេនឌ័រដែលមានគុណភាព:**

- □ ការវាយតម្លៃហេតុប៉ះពាល់លើសិទ្ធិមនុស្ស និងសង្គមគួរធ្វើឡើងដោយមានរួមបញ្ចូលការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ។
- □ បញ្ហារាំងក្នុងការចូលរួមរបស់ស្ត្រីនិងបុរសត្រូវបានរកឃើញ។
- □ ផលប្រយោជន៍ដែលអាចមានសម្រាប់រយៈពេលខ្លីនិងសម្រាប់រយៈពេលវែងសម្រាប់ស្ត្រីនិងបុរស ត្រូវបានរកឃើញ។
- □ សកម្មភាពគម្រោងត្រូវបានរៀបចំបង្កើតឡើងដើម្បីជំរុញការចូលរួមរបស់ស្ត្រីនិងដើម្បីឲ្យទទួលបានផលប្រយោជន៍សម្រាប់បុរសនិងស្ត្រី។

**កសាងផែនការសកម្មភាពយេនឌ័រ និង ផែនការអនុវត្ត:**

- □ ផែនការសកម្មភាពយេនឌ័រនិងយុទ្ធសាស្ត្រនេះ ផ្តល់នូវទិសដៅច្បាស់លាស់សម្រាប់បុគ្គលិកគម្រោងឲ្យបានដឹងអំពីការរំពឹងទុកអំពីឱកាស និងអំពីស្តង់ដារអប្បបរមា។ ប្រាក់លើកទឹកចិត្ត និងរង្វាន់ត្រូវតម្រឹមទៅតាមលទ្ធផលយេនឌ័រ។
- □ ផែនការសកម្មភាពយេនឌ័រ គួរអាចទាញយកជាសាធារណៈដោយដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងគម្រោង និងត្រូវតាមដានដោយជាប់លាប់និងម៉ឺងម៉ាត់។
- □ ផែនការអនុវត្តផែនការសកម្មភាពយេនឌ័រ ផ្តល់នូវការប្តេជ្ញាចិត្តអនុវត្តសកម្មភាពគម្រោងនិងគោលដៅ ត្រូវមានថវិកាសម្រាប់អនុវត្ត និងកំណត់ឲ្យមានការទទួលខុសត្រូវរវាងមណ្ឌលពាណិជ្ជកម្មពាក់ព័ន្ធគម្រោង ផ្នែកផ្សេងនៃគម្រោង និងទីភ្នាក់ងារអនុវត្តគម្រោង។
- □ សកម្មភាពគម្រោងត្រូវកសាងឡើងដោយមានការចូលរួមពាក់ព័ន្ធយ៉ាងសកម្មពីបុរសនិងស្ត្រី ព្រមទាំងទទួលបានព័ត៌មានអំពីផែនការនិងអាទិភាពរបស់បុរស របស់ស្ត្រី និងរបស់សហគមន៍
- □ ការតាមដាននិងការត្រួតពិនិត្យផែនការសកម្មភាពយេនឌ័រឡើងវិញ គួរបញ្ចូលការប៉ាន់ប្រមាណអំពីលទ្ធផល គឺមិនមែនបញ្ចូលតែសកម្មភាពប៉ុណ្ណោះទេ។

**គោលដៅមានភាពជាក់ស្តែងនិងការតាមដានទៀងទាត់:**

- □ គួរកំណត់រកឲ្យឃើញនូវឱកាសសម្រាប់ជាប្រយោជន៍ស្មើគ្នារវាងបុរសនិងស្ត្រី។ ជាដំបូង ចំណុចនេះត្រូវអភិវឌ្ឍនៅក្នុងរចនាសម្ព័ន្ធនិងដំណើរការដែលមានស្រាប់ ហើយនិងកំណត់ឲ្យឃើញនូវឱកាសសម្រាប់ការផ្លាស់ប្តូររយៈពេលវែង។
- □ កំណត់ឲ្យបាននូវគោលដៅដែលសហគមន៍មានការយល់ដឹងនិងមានការចូលរួមចំណែក ដោយរាប់បញ្ចូលទាំងគោលដៅជាក់លាក់មួយចំនួនសម្រាប់បុរស ស្ត្រី និងក្រុមតូចៗក្នុងសហគមន៍។
- □ ការតាមដានជាប្រចាំទៅលើគោលដៅនិងសកម្មភាពពាក់ព័ន្ធនឹងយេនឌ័រ។

**ការកសាងសមត្ថភាពយេនឌ័រនិងជំនាញឯកទេសយេនឌ័រនៅក្នុងក្រុមគម្រោងនិងនៅក្នុងចំណោមភ្នាក់ងារអនុវត្តរបស់រដ្ឋាភិបាលអ្នកម៉ៅការឯកជន និងអង្គការមិនមែនរដ្ឋាភិបាល**

- □ ផ្តល់ការបណ្តុះបណ្តាលជាផ្លូវការស្តីពីគោលនយោបាយសាជីវកម្ម (នៅកន្លែងដែលមានសាជីវកម្ម) និងស្តីពីការយល់ដឹងអំពីយេនឌ័រឲ្យបានជាទូទៅ។ ត្រូវបញ្ចូលការបណ្តុះបណ្តាលស្តីពីការប៉ាន់ប្រមាណនិងលទ្ធផលអំពីផលប៉ះពាល់យេនឌ័រព្រមទាំងរបៀបប្រើលទ្ធផលទាំងនោះ នៅក្នុងវដ្តអាជីវកម្មនិងការគ្រប់គ្រងគម្រោង
- □ ធានាថាមានការគាំទ្រជាបន្តបន្ទាប់ ព្រមទាំងផ្តល់ការបង្ហាត់បង្ហាញដល់បុគ្គលិកគម្រោង ដល់ភាគីរដ្ឋាភិបាល ដល់អ្នកម៉ៅការឯកជន និងអ្នកអនុវត្តគម្រោងជាអង្គការមិនមែនរដ្ឋាភិបាលនានា
- □ ធានាឲ្យមានជំនាញផ្នែកយេនឌ័រនៅក្នុងក្រុមគម្រោង ហើយធានាថាបុគ្គលិកគម្រោងទាំងនេះមានអាណត្តិ និងអាជ្ញាធរ សម្រាប់បំពេញការងារសម្រាប់ផែនការសកម្មភាពយេនឌ័រក្នុងតំបន់គ្រប់គ្រងផ្សេងៗទៀត
- □ រង្វាន់លើកទឹកចិត្តដល់ការបំពេញការងារយេនឌ័របានល្អ ត្រូវដាក់ចូលក្នុងកញ្ចប់ការងារសម្រាប់បុគ្គលិកគម្រោង។

**យកលំនាំតាម** Hunt, Thomas and Lateef 2007ទំ. ៥១។

ទំព័រ១/១

ទាំងនេះជាបញ្ជីត្រួតពិនិត្យសម្រាប់ជាគម្រូមួយចំនួន ដែលគម្រូនេះអាចទាញយកពីគេហទំព័រ www.oxfam.org.au/giamanual

## ជំហានទី៦ : ការត្រួតពិនិត្យឡើងវិញ ការធ្វើសវនកម្ម និងការឆ្លើយតប

ជំពូកនេះពិនិត្យអំពីសារៈសំខាន់នៃការតាមដាននិងការរាយការណ៍ អំពីការផ្តោតលើសារៈសំខាន់នៃដំណើរការបែបចូលរួមដើម្បីធានាថាលទ្ធផលដែលបានដាក់ជាផែនការនិងលទ្ធផលទាយទុកមុនបានសម្រេចតាមការគ្រោងទុក ហើយសម្រាប់កន្លែងណាដែលមិនត្រូវគន្លង ត្រូវមានការកែសម្រួលនិងមានការវិនិយោគដើម្បីធានាថាគម្រោងមួយនោះត្រូវនាំត្រឡប់មកត្រូវតាមគន្លងនៃលទ្ធផលដែលបានព្រមព្រៀងគ្នា ឬ តាមការចរចារឡើងវិញ ព្រមទាំង តាមដានទៅលើផលប៉ះពាល់យេនឌ័រដែលកើតឡើងដោយមិនបានរំពឹងទុក។ ក្នុងការធ្វើតាមបែបមានការចូលរួមនិងប្រកបដោយតម្លាភាព អ្នករៀបចំគម្រោង/ប្រតិបត្តិករគម្រោង ទំនងជានឹងទទួលបានលទ្ធផលវិជ្ជមានជាអតិបរមាពីបុរសនិងស្ត្រី នៅគ្រប់តំបន់ដែលរងការប៉ះពាល់ដោយសារគម្រោង។

**ការប៉ាន់ប្រមាណគម្រោងដោយប្រើសវនកម្មយេនឌ័រ**

បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានទៅលើការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ និងមានការព្រមព្រៀងលើផែនការសកម្មភាពយេនឌ័រជាមួយក្រុមបុរស ក្រុមស្ត្រី និងក្រុមសហគមន៍រួចហើយ គេត្រូវការតាមដាននិងត្រួតពិនិត្យឡើងវិញទៅលើផលប៉ះពាល់និងលទ្ធផលជាក់ស្តែង។

ឧបករណ៍ដ៏មានតម្លៃមួយសម្រាប់ការប៉ាន់ប្រមាណផែនការនិងយុទ្ធសាស្ត្រទាំងនោះ គឺការធ្វើសវនកម្មយេនឌ័រ។ គេអាចធ្វើបានតាមទម្រង់ពីរ ដែលអាចធ្វើឡើងដាច់ដោយឡែកតែឯង ឬតាមដំណើរការជាប់ពាក់ព័ន្ធគ្នា។

១. **សវនកម្មឯករាជ្យដោយអ្នកឯកទេសយេនឌ័រ:** ដំណើរការនេះអាចធ្វើឡើងជាផ្នែកមួយនៃការរាយការណ៍ប្រចាំឆ្នាំ ឬ ការរាយការណ៍តាមការសម្រេចព្រឹត្តិការណ៍គោលណាមួយ។ ជម្រើសមួយទៀតគឺត្រូវផ្តួចផ្តើមបង្កើតវាជាផ្នែកមួយនៃដំណើរពិនិត្យដ៏ត្រឹមត្រូវ មុនពេលនាំគម្រោងឆ្លងកាត់ការសម្រេចចិត្តអំពីព្រឹត្តិការណ៍គោលជាក់លាក់ណាមួយនោះ។ ការធ្វើបែបនោះនឹងផ្តល់ទំនុកចិត្តដល់អ្នកគ្រប់គ្រងគម្រោងនិងហិរញ្ញិកគម្រោង ថាហានិភ័យយេនឌ័រត្រូវបានគេប៉ាន់ប្រមាណរួចហើយ និងថា មានយុទ្ធសាស្ត្រនិងធនធានសមរម្យរួចជាស្រេច សម្រាប់ចៀសវាង កាត់បន្ថយលុបបំបាត់និងផ្តល់សំណងសម្រាប់ហានិភ័យ។

២. **សវនកម្មយេនឌ័រតាមបែបចូលរួម:** ការធ្វើបែបនេះ ត្រូវដឹកនាំនិងគ្រប់គ្រងដោយស្ត្រីទទួលរងផលប៉ះពាល់ពីគម្រោង។ ការធ្វើបែបនេះគួរសម្របសម្រួលដោយក្រុមហ៊ុន ប៉ុន្តែ ត្រូវចាត់ចែងដោយឯករាជ្យមិនមានការបង្ខិតបង្ខំឬការត្រួតត្រាណាមួយឡើយ។ តាមពិតទៅ ការធ្វើវាជាផ្នែកមួយដ៏សំខាន់នៃការធ្វើសវនកម្មឯករាជ្យនេះ គឺជាយុទ្ធសាស្ត្រដ៏មានប្រយោជន៍មួយ។ ក៏ប៉ុន្តែ គេក៏អាចសម្របសម្រួលជាដំណើរការដាច់ដោយឡែកតែឯងបាន នៅទីណាដែលស្ត្រីសហគមន៍បានទទួលឧបករណ៍និងការបណ្តុះបណ្តាលដើម្បីធ្វើសវនកម្មនេះដោយខ្លួនឯង។ ការធ្វើបែបនេះអាចជាសសរស្តម្ភដ៏សំខាន់មួយក្នុងសហគមន៍/ក្នុងទំនាក់ទំនងក្រុមហ៊ុន ព្រមទាំងអាចជួយផ្តល់ព័ត៌មានសម្រាប់ការពិភាក្សា និងសម្រាប់ការកំណត់រកបញ្ហាទៀតផង។

**ការធ្វើសវនកម្ម បម្រើឲ្យគោលបំណងមួយចំនួន:**

- ពិនិត្យមើលផលប៉ះពាល់ជាក់ស្តែង
- វាស់ស្ទង់កម្រិតនៃភាពត្រឹមត្រូវនៃផលប៉ះពាល់និងលទ្ធផលដែលបានគិតទុកជាមុន
- ផ្តល់ដំណើរការមានរចនាសម្ព័ន្ធមួយ ដើម្បីស្តាប់មតិយោបល់ពីស្ត្រីនិងបុរសដែលទទួលរងផលប៉ះពាល់ និងដើម្បីបានយល់ដឹងអំពីបទពិសោធន៍ចេញពីទស្សនៈផ្សេងៗរបស់ពួកគាត់
- វាស់ស្ទង់ប្រសិទ្ធភាពនៃវិធានការកាត់បន្ថយផលប៉ះពាល់ និងប៉ាន់ប្រមាណអំពីកម្រិតនៃភាពគ្រប់គ្រាន់ទាក់ទងនឹងសំណង ដែលជាចំណុចសំខាន់ជាពិសេស នៅក្នុងបរិបទសហគមន៍ដែលបានផ្លាស់ទីលំនៅ និងកម្មវិធីកែលម្អជីវភាព។
- ការពិសោធន៍ប្រសិទ្ធភាពនិងប្រសិទ្ធផលនៃយន្តការចែករំលែកផលប្រយោជន៍ ជាពិសេសទៅលើសមភាពនិងការពង្រឹងសិទ្ធិអំណាចស្ត្រី
- កំណត់រកឲ្យឃើញដំណើរការសម្រាប់ចែករំលែកផលប្រយោជន៍និងយន្តការដោះស្រាយទំនាស់ ទាក់ទងនឹងផលប្រយោជន៍របស់បុរសនិងស្ត្រី

## តើគួរធ្វើសវនកម្មនៅពេលណា?

គម្រោងទំនប់វារីអគ្គីសនីមានពេលវេលាវែងចាប់ពីការចាប់ផ្តើមរហូតដល់ពេលប្រតិបត្តិការចុងក្រោយ។ ក្នុងខណៈពេលដែលវាត្រូវការពេលវេលាច្រើនឆ្នាំមុនពេលចាប់ផ្តើមអនុវត្តនោះ ផលប៉ះពាល់អាចចាប់ផ្តើមមានតាំងពីដំណាក់កាលដំបូងបំផុតនៃសកម្មភាពលើទីតាំង។ ក៏ប៉ុន្តែលទ្ធផលនិងផលប៉ះពាល់ប្រហែលជាមិនផុសឡើងភ្លាមៗនោះទេ ហើយគេទំនងជាត្រូវការការតាមដានជានិច្ចក្នុងការប៉ាន់ប្រមាណអំពីប្រសិទ្ធភាពឲ្យបានត្រឹមត្រូវ។ នៅក្នុងបរិបទនេះ លទ្ធផលនិងផលប៉ះពាល់សម្រាប់យេនឌ័រ គួរត្រូវបានតាមដានពេញវដ្តគម្រោង និងក្រោយពេលចាប់ផ្តើមប្រតិបត្តិការ។[១៥]

ចំណុចងាយរងគ្រោះសំខាន់ៗសម្រាប់ផលប៉ះពាល់យេនឌ័រកើតមាននៅពេល:

- មានការដកហូតយកដីធ្លី និងមានការចរចារអំពីការបន្ធូរបន្ថយ ឬអំពីសំណង
- មានការរុះរើផ្លាស់ប្តូរទីលំនៅ
- អ្នកម៉ៅការ និងបុគ្គលិកសំណង់ ចូលមកក្នុងទីតាំង និងស្នាក់នៅក្នុងតំបន់នោះ។

១៥. ក្នុងបរិបទនៃលក្ខខណ្ឌតម្រូវផ្នែកគោលនយោបាយ តាមរយៈ IFI។ ការធ្វើសវនកម្មអាចជាការពិនិត្យដ៏មានប្រយោជន៍ ក្រោយថ្ងៃបញ្ចប់គម្រោង ឬ ការបញ្ចេញសាច់ប្រាក់កម្ចីពេញលេញ។

នៅពេលផែនការសកម្មភាពយេនឌ័រត្រូវគេចរចារនិងព្រមព្រៀងជាមួយសហគមន៍ហើយ ប្រការសំខាន់គឺត្រូវពិចារណាថាតើមានគេយកចិត្តទុកដាក់គ្រប់គ្រាន់សម្រាប់បរិបទទាំងនោះដែរឬទេ។

នៅពេលសហគមន៍ត្រូវផ្លាស់ប្តូរទីតាំងដោយសារទំនប់ កម្មវិធីកែលម្អជីវភាព ឬ កម្មវិធីស្តារជីវភាព គឺជាអន្តរាគមន៍សាមញ្ញបំផុតមួយចំនួន ដើម្បីបន្ធូរបន្ថយផលប៉ះពាល់។ ចំណុចនេះគួរតែជាការផ្តោតជាពិសេស នៅក្នុងដំណើរការតាមដាននិងសវនកម្ម។ ការធ្វើសវនកម្មបែបចូលរួមឬ បែបគ្រប់គ្រងដោយសហគមន៍ គឺជាឧបករណ៍ដ៏សំខាន់ក្នុងការជួយឲ្យយល់ដឹងអំពីរបៀបតាមដានប្រៀបទៅនឹងលទ្ធផលដែលបានព្រមព្រៀងជាមួយគ្នាដែលគេបានដាក់ចូលទៅក្នុងផែនការសកម្មភាពយេនឌ័រ។ ការធ្វើសវនកម្មអាចធ្វើឡើងដោយសុទ្ធតែមានប្រយោជន៍នៅគ្រប់ដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍន៍គម្រោង។ ការធ្វើសវនកម្មយេនឌ័រ បង្ហាញនូវឱកាសមួយសម្រាប់អ្នករៀបចំបង្កើតគម្រោងឲ្យបានពិនិត្យទៅលើលទ្ធផលដែលទទួលបានសម្រាប់បុរសនិងស្ត្រី។ការធ្វើសវនកម្មឡើងវិញនឹងជួយអ្នកគ្រប់គ្រងគម្រោងឲ្យអាចតាមដានការរីកចម្រើននិងការផ្លាស់ប្តូរ ព្រមទាំងរកឃើញគម្លាតជាលក្ខណៈប្រព័ន្ធ ក៏ដូចជារកឃើញឱកាសទទួលបានលទ្ធផលប្រកបដោយនិរន្តរភាព។

## ការប្រើប្រាស់សេវាកម្មដើម្បីកែលម្អការបំពេញការងារ

សវនកម្មនឹងតម្រូវឲ្យមានការប៉ាន់ប្រមាណមួយជិតស្និទ្ធទៅនឹងលក្ខខណ្ឌការសង្កេតបឋមសម្រាប់ស្ត្រីនិងបុរស ព្រមទាំងពិនិត្យមើលការផ្លាស់ប្តូរយេនឌ័រក្នុងចំណោមប្រជាជនផ្សេងៗគ្នា និងក្រុមតូចៗផ្សេងៗគ្នាក្នុងសហគមន៍។ នៅក្នុងបរិបទវារីអគ្គីសនីនៅទន្លេមេគង្គ រួមជាមួយនឹងផលប៉ះពាល់លើស្ត្រីនិងបុរសនោះ ខាងក្រោមនេះគឺជាក្រុមសូចនាការសំខាន់ៗមួយចំនួនដែលគួរពិចារណាក្នុងការធ្វើសវនកម្មយេនឌ័រៈ

គួរពិនិត្យចំណុចទាំងនេះសម្រាប់សហគមន៍ដើមជាទីដែលមានការបម្លាស់ទីចូលមក ជាពិសេសសម្រាប់សហគមន៍ទើប"បង្កើត" ថ្មីៗ ជាទីដែលមនុស្សបានផ្លាស់ទៅរស់នៅក្នុងទីតាំងភូមិថ្មី ។

- ការប្រើប្រាស់និងការគ្រប់គ្រងច្រាំងទន្លេ ដីកសិកម្មនិងដីព្រៃ ព្រមទាំងធនធានជាសត្វ
- ការប្រើប្រាស់ទឹក ធនធានទន្លេនិងសរីរាង្គក្នុងទឹក សុខភាពនិងចំនួនប្រភេទរស់នៅក្នុងទឹកទន្លេ និងធនធានទឹក
- គុណភាពទឹក
- ការចូលទៅកាន់និងការប្រើប្រាស់ដែលអាចដឹងមុន
- ការទទួលបានសេវាកម្មថ្មីៗរួមមាន អគ្គីសនី ផ្សារ សេវាសុខភាពទឹក ការអប់រំ (សាលារៀននិងការបណ្តុះបណ្តាល) ជាពិសេសពិនិត្យមើលថាតើប្រជាជនអាចរកបាននិងប្រើប្រាស់ដោយរបៀបណាដើម្បីជាប្រយោជន៍បែបយុទ្ធសាស្ត្រសម្រាប់ស្ត្រី ប្រៀបធៀបនឹងតម្រូវការជាក់ស្តែង
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា តើគេប្រើយ៉ាងដូចម្តេច អ្នកណាជាអ្នកប្រើ និងប្រើក្នុងគោលបំណងអ្វី? អ្នកណាត្រួតពិនិត្យការប្រើប្រាស់នោះ?
- ឱកាសការងារនិងលក្ខខណ្ឌការងារ ដូចជាការធ្វើការបន្ថែមម៉ោង នៅពេលបច្ចុប្បន្ន និងរំពឹងទុកទៅថ្ងៃអនាគត។
- ស្ថាប័នសុខាភិបាល ដូចជា រួមបញ្ចូលទាំងសុខភាពមាតា និងកុមារ ការរីករាលដាលនៃជម្ងឺឆ្លងតាមការរួមភេទ ដោយប្រៀបធៀបជាមួយនឹងទិន្នន័យអង្កេតបឋម
- ការបម្លាស់ទីរបស់ប្រជាជន ដូចជា តាមរដូវ និងជាទូទៅ
- អំពើហិង្សាយេនឌ័រ
- សុខភាពសាធារណៈ និងសុខមាលភាពសហគមន៍ ដូចជា តើគម្រោងជះឥទ្ធិពលដោយរបៀបណា?
- ការបំពុល និងការរំខាន ដូចជា ខ្យល់ ទឹក សំឡេង ដីកសិកម្ម និងដាំដំណាំ។

## សេចក្តីសន្និដ្ឋាន

ឱកាសសំខាន់ៗពិតជាមានសម្រាប់ក្រុមហ៊ុនទំនប់វារីអគ្គីសនីក្នុងការប្រើប្រាស់ការប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រនៅក្នុងវដ្តអាជីវកម្មរបស់ពួកគេ។ សៀវភៅណែនាំនេះ ផ្តល់នូវឧបករណ៍សាមញ្ញមួយចំនួនសម្រាប់ជួយក្រុមហ៊ុនឲ្យមានការអនុវត្តតាមលក្ខណៈស្តង់ដារទៅលើការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនៅក្នុងប្រតិបត្តិការរបស់ខ្លួន។ មានការស្នើឡើងថា គេអាចធ្វើបែបនេះបានត្រឹមត្រូវតាមតក្កភាពបំផុត គឺនៅពេលវាជាចំណែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សិទ្ធិមនុស្សនិងសង្គម និងដំណើរពិនិត្យដ៏ត្រឹមត្រូវបំផុត។

តាមរយៈការធ្វើបែបនេះ ក្រុមហ៊ុនអាចជួយបង្កើនសំឡេងអំពីទស្សនៈរបស់ស្ត្រី អំពីតម្រូវការនិងផលប្រយោជន៍របស់ស្ត្រី។

ក្នុងការប្រើការវាយតម្លៃហេតុប៉ះពាល់យេនឌ័រ ដើម្បីផ្តល់ព័ត៌មានសម្រាប់វិធីសាស្ត្រគ្រប់គ្រងនិងការសម្រេចចិត្តលើធនធាន ក្រុមហ៊ុនអាចរៀបចំគម្រោងឲ្យកាន់តែមានការឆ្លើយតបទៅនឹងតម្រូវការនិងផលប្រយោជន៍ស្ត្រី។ ជាលទ្ធផល ក្រុមហ៊ុនអាចកាត់បន្ថយហានិភ័យនិងក៏អាចកំណត់រកឃើញលទ្ធផលដែលកាន់តែមាននិរន្តរភាពសម្រាប់មនុស្សដែលទទួលរងផលប៉ះពាល់ពីគម្រោងនេះបានកាន់តែច្រើនថែមទៀត។ ក្រុមហ៊ុនអាចប្រើប្រាស់ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រនេះ ដើម្បីបង្ហាញអំពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសិទ្ធិស្ត្រី សមភាពយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី ហើយដែលទង្វើនេះនឹងបង្កើតឲ្យបានជាការអនុវត្តអាជីវកម្មនិងការទទួលខុសត្រូវសាជីវកម្មប្រកបដោយនិរន្តរភាព។

ដើម្បីឲ្យក្រុមហ៊ុនទំនប់វារីអគ្គីសនីអាចចៀសវាងនិងបន្ធូរបន្ថយផលប៉ះពាល់យេនឌ័រពីគម្រោងរបស់ខ្លួន ខាងក្រោមជាការផ្តល់អនុសាសន៍អំពីការវាយតម្លៃហេតុប៉ះពាល់យេនឌ័រៈ

- ត្រូវផ្អែកទៅលើការយល់ច្បាស់ទៅលើទិន្នន័យសង្កេតបឋមនៃប្រព័ន្ធទន្លេ និងប្រជាជន មុនពេលគម្រោងចាប់ផ្តើម ហើយទិន្នន័យនោះត្រូវមានទិន្នន័យបែងចែកតាមភេទផងដែរ។
- ត្រូវយល់អំពីតម្រូវការនិងផលប្រយោជន៍យេនឌ័ររបស់បុរសនិងស្ត្រីនៅក្នុងសហគមន៍ទទួលរងផលប៉ះពាល់ពីគម្រោង
- ត្រូវមានការយល់លម្អិតអំពីផលប៉ះពាល់យេនឌ័រនៅពេលណែនាំអំពីគម្រោងនេះទៅដល់សហគមន៍ទទួលរងផលប៉ះពាល់ ព្រមទាំងបង្ហាញអំពីវិធីចៀសវាងនិងកាត់បន្ថយផលប៉ះពាល់ទាំងនោះ
- ត្រូវរកឲ្យឃើញឱកាសក្នុងការជំរុញអភិវឌ្ឍតម្រូវការជាក់ស្តែងរបស់ស្ត្រី ទន្ទឹមនឹងតម្រូវការរបស់បុរស ហើយនិងត្រូវលើកកម្ពស់ផលប្រយោជន៍បែបយុទ្ធសាស្ត្ររបស់ស្ត្រីទៀតផង
- នៅពេលពិភាក្សាជាមួយស្ត្រី ត្រូវកំណត់រកឲ្យឃើញនូវឱកាសរបស់គម្រោងក្នុងការរួមចំណែកដល់សមភាពយេនឌ័រនិងការពង្រឹងសិទ្ធិអំណាចស្ត្រី។ ការវាយតម្លៃហេតុប៉ះពាល់យេនឌ័រគួរផ្តល់ព័ត៌មានសម្រាប់ការរៀបចំផែនការសកម្មភាពនិងយុទ្ធសាស្ត្រយេនឌ័រ ដែលត្រូវបង្កើតឡើងតាមរយៈការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធនិងដោយមានការចូលរួមពីស្ត្រីនិងបុរសដែលទទួលរងផលប៉ះពាល់។ ទង្វើនេះនឹងផ្តល់ព័ត៌មានដល់ដំណើរការសំខាន់ៗដូចជាការកំណត់វិសាលភាព និងការចរចារអំពីកិច្ចព្រមព្រៀងចែករំលែកផលប្រយោជន៍ កញ្ចប់សំណង ព្រមទាំងមូលនិធិនិងគម្រោងធនធានសហគមន៍។ តាមពិតទៅ ការធានាឲ្យផែនការយេនឌ័រត្រូវបានបញ្ជ្រាបទៅក្នុងផែនការគ្រប់គ្រងនិងដំណើរការតាមដានផ្សេងៗ មានន័យថា ការអនុវត្តទំនងជានឹងផ្តល់នូវលទ្ធផលប្រកបដោយនិរន្តរភាពសម្រាប់គម្រោង និងសម្រាប់ស្ត្រីនិងបុរសដែលទទួលរងផលប៉ះពាល់ពីគម្រោង។



នុយ សុជាតា (ឈ្មោះត្រូវបានដូរដើម្បីការពារអត្តសញ្ញាណ) សម្លឹងមើលទន្លេមេគង្គក្បែរតំបន់ទំនប់សម្បូរ ដែលត្រូវបានស្នើជាគម្រោងឡើង ក្នុងប្រទេសកម្ពុជា។ ភូមិរបស់គាត់នឹងទទួលរងផលប៉ះពាល់ប្រសិនបើទំនប់នឹងចាប់ដំណើរការ
រូបថត៖ John Sones/OxfamAUS



## សេចក្តីបន្ថែម : ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី HSAP និង ឧបករណ៍ប៉ាន់ប្រមាណល្បឿនពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ RSAT: តើឧបករណ៍ក្នុងវិស័យឧស្សាហកម្មវារីអគ្គីសនីទាំងនេះបញ្ចូលយេនឌ័រយ៉ាងដូចម្តេច?

ជំពូកនេះពិនិត្យមើលថាតើឧបករណ៍ប៉ាន់ប្រមាណអំពីនិរន្តរភាពវារីអគ្គីសនី គឺពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី (HSAP) និង ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល(RSAT) បញ្ចូលយេនឌ័រដោយវិធីណា។ ឥឡូវនេះ ឧបករណ៍ថ្មីទាំងពីរនេះត្រូវគេប្រើក្នុងវិស័យសាធារណៈហើយ ហើយកំពុងតែត្រូវបានក្រុមហ៊ុននិងភាគីពាក់ព័ន្ធនឹងរដ្ឋាភិបាលជាច្រើនក្នុងតំបន់ទន្លេមេគង្គយកមកពិចារណា។

### ក្រុមគោលដៅ និង ភាពខុសគ្នា

ឧបករណ៍ទាំងពីរនេះមានភាពស្រដៀងគ្នា ក៏ប៉ុន្តែវាក៏មានភាពខុសប្លែកសំខាន់ៗមួយចំនួនដែរ ទាក់ទងនឹងចំណុចផ្តោតលើរបៀបប្រតិបត្តិការ។

ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី ត្រូវបានសរសេរឡើងសម្រាប់គោលដៅចម្បងជាឧស្សាហកម្មវារីអគ្គីសនី។ ពិធីសារនេះផ្តោតទៅលើការប៉ាន់ប្រមាណគម្រោងមួយៗ ឬ ចំណែករបស់គម្រោង (ដូចជាកន្លែងទឹកធ្លាក់)។ ពិធីសារនេះប៉ាន់ប្រមាណគម្រោងដោយពិនិត្យមើលលើការពិចារណាអំពីនិរន្តរភាពសម្រាប់គម្រោងទំនប់វារីអគ្គីសនី ហើយពិធីសារនេះជួយឲ្យមានការបង្កើតការពណ៌នាអំពីនិរន្តរភាពសម្រាប់គម្រោងនោះ។ ពិធីសារនេះ រួមមានឧបករណ៍ប៉ាន់ប្រមាណដាច់ដោយឡែកដែលគេរចនាឡើងសម្រាប់ការអនុវត្តការអភិវឌ្ឍគម្រោងនៅដំណាក់កាលផ្សេងៗគ្នា ដូចជា ដំណាក់កាលដំបូង ដំណាក់កាលរៀបចំ ដំណាក់កាលអនុវត្តនិងដំណាក់កាលប្រតិបត្តិការ។

ផ្ទុយទៅវិញ ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល (RSAT) ត្រូវបានបង្កើតឡើងសម្រាប់ប៉ាន់ប្រមាណនិរន្តរភាពនៅលើវិមាត្រអាងទន្លេ គឺមិនពិចារណាអំពីគម្រោងនីមួយៗនោះទេ។ គេបង្កើតឡើងក្នុងវិធីសាស្រ្ត ការគ្រប់គ្រងធនធានទឹកសមាហរណកម្ម (IWRM) សម្រាប់ការអភិវឌ្ឍ ហើយត្រូវបានបង្កើតឡើងតាមរយៈកិច្ចសហការដោយគណៈកម្មធិការទន្លេមេគង្គ មូលនិធិសត្វព្រៃពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី។ មានការតម្រឹមដ៏ស៊ីសង្វាក់គ្នាអំពីប្រធានបទនិងវិធីសាស្រ្តដាក់ពិន្ទុរវាងក្របខណ្ឌទាំងពីរនេះ ប៉ុន្តែ ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល (RSAT) មានភាពជាក់លាក់ជាង ចំពោះបញ្ហានិរន្តរភាពនៅក្នុងបរិបទទន្លេមេគង្គ (ប្រសិនបើនេះជាបរិបទសម្រាប់ការអភិវឌ្ឍ) ដោយមានការផ្តោតទៅលើការប៉ាន់ប្រមាណឆ្លងព្រំដែន និងសង្កត់ធ្ងន់ទៅលើវិស័យដូចជាជលផល ជាប្រធានបទក្នុងកម្រិតខ្ពស់។

នៅក្នុងការចាប់ផ្តើមដំបូង ឧបករណ៍ទាំងពីរត្រូវគេប្រើជាមធ្យោបាយសម្រាប់លើកទឹកចិត្តឲ្យមានការពិភាក្សាក្នុងចំណោមភាគីពាក់ព័ន្ធនិងបង្កើតឲ្យមានការយល់ដឹងអំពីគម្រោងជាក់លាក់និងអាងទន្លេមួយចំនួនដោយធ្វើការពិចារណាទៅលើវិសាលភាពដ៏ទូលាយនៃប្រធានបទជាច្រើនទាក់ទងនឹងនិរន្តរភាព។ ឧបករណ៍ទាំងពីរនេះប្រើលក្ខខណ្ឌវិនិច្ឆ័យមួយសំណុំ និងណែនាំ "ការដាក់ពិន្ទុអំពីនិរន្តរភាព" ទៅលើប្រធានបទនានា តាមរយៈការបង្ហាញអំពីការរំពឹងទុកសម្រាប់ការអនុវត្តល្អនិងការអនុវត្តល្អបំផុត ឬ ការបំពេញការងារដ៏អន់ថយ។ មកទល់នឹងពេលបច្ចុប្បន្ននេះ ភាគច្រើន អ្នកដែលប្រើឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល (RSAT) គឺ ដៃគូរដ្ឋាភិបាល ខណៈពេលដែល ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី (HSAP) កំពុងត្រូវពិចារណាភាគច្រើនដោយក្រុមហ៊ុនជាសមាជិករបស់សមាគមវារីអគ្គីសនីអន្តរជាតិ។

## ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី (HSAP)

### តើពិធីសារនេះជាអ្វី? វាដំណើរការយ៉ាងដូចម្តេច? ហេតុអ្វីបានជាគេបង្កើតវាឡើង?

វេទិកាប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី ត្រូវបានផ្តួចផ្តើមឡើងក្រោមកិច្ចសហការមួយរបស់ សមាគមវារីអគ្គីសនីអន្តរជាតិ មូលនិធិសត្វព្រៃពិភពលោក និង អង្គការអភិរក្សធម្មជាតិ។ ជាមួយនឹងសមាជិកចំនួន ១៣ ចេញមកពីវិស័យផ្សេងៗគ្នា និងក្រុមភាគីពាក់ព័ន្ធផ្សេងៗគ្នា[១៦] ព្រមទាំងអ្នកសម្របសម្រួលនិងប្រធានមួយរូប វេទិកានេះប្រតិបត្តិការក្នុងរូបភាពជាគម្រោងផ្តួចផ្តើមអ្នកពាក់ព័ន្ធចម្រុះ។ វេទិកានេះត្រូវរងការរិះគន់ ដោយសារតែមិនបានបញ្ចូលសមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាលមកពីប្រទេសកំពុងអភិវឌ្ឍន៍ ប្រជាជនទទួលរងផលប៉ះពាល់គម្រោង ឬ សមាជិកមកពីអង្គភាពឯកទេស ដូចជាអង្គភាពពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីលំនៅដោយមិនស្ម័គ្រចិត្ត។

លទ្ធផលបឋមចេញពីការចរចាក្នុងវេទិកានោះ គឺពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី។ ពិធិសារនេះអនុម័តវិធីសាស្រ្តបញ្ជ្រាបមួយដើម្បីបញ្ចូលយេនឌ័រ ដូចជាការបញ្ចូលវិស័យសំខាន់ដទៃទៀតទាក់ទងនឹងនិរន្តរភាពសម្រាប់គម្រោងទំនប់វារីអគ្គីសនី ដូចជា ការប្រែប្រួលអាកាសធាតុនិងសិទ្ធិមនុស្ស។ ផ្នែកខាងក្រោមនេះនឹងពន្យល់អំពីវិធីសាស្រ្តនេះ និងកំណត់រកគម្លាត ព្រមទាំងរកវិធីដើម្បីកែលម្អ។

លទ្ធផលដ៏មានប្រយោជន៍នៃដំណើរការវេទិកានេះ បានទទួលការចាប់អារម្មណ៍ដាក់នៅលើគេហទំព័ររបស់សមាគមវារីអគ្គីសនីអន្តរជាតិត្រង់ផ្នែកមូលដ្ឋានចំណេះដឹង ពិធីសារអំពីនិរន្តរភាព (IHA 2011a)។ ប៉ុន្តែ អ្វីដែលសំខាន់នោះគឺថា វិស័យសំខាន់ៗមួយចំនួននៅមិនមានការឯកភាពគ្នាក្នុង ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនីនេះនៅឡើយ គឺចំណុចទាក់ទងនឹងការរំពឹងទុកជុំវិញការកំណត់អំពីអ្វីដែលជា "ការអនុវត្តល្អជាមូលដ្ឋាន" សម្រាប់ការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត ដោយសេរីនិងមានការយល់ព្រមជាមុននោះ។

ពិធីសារនេះ ជាក្របខណ្ឌប៉ាន់ប្រមាណដែលប្រើបាននៅដំណាក់កាលផ្សេងគ្នាក្នុងគម្រោង។ ពិធីសារនេះអាចផ្តល់នូវការពណ៌នាអំពីនិរន្តរភាពសម្រាប់គម្រោងដោយផ្អែកទៅលើការបំពេញការងាររបស់គម្រោងនិងលទ្ធផលមកពីគ្រប់បញ្ហាទាក់ទងនឹងនិរន្តរភាព។ គេហៅថា "ប្រធានបទអំពីនិរន្តរភាព" ក្នុងពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី(HSAP)។

សំណុំប្រធានបទអំពីនិរន្តរភាពសម្រាប់ពិធីសារនេះ ត្រូវបាន

---

១៦. សមាជិកវេទិកាត្រូវបានអញ្ជើញមកពីគ្រប់ភាគីពាក់ព័ន្ធដូចខាងក្រោម៖ រដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ រដ្ឋាភិបាលប្រទេសអភិវឌ្ឍន៍ ឧស្សាហកម្មវារីអគ្គីសនី អង្គការមិនមែនរដ្ឋាភិបាលផ្នែកសង្គមនិងបរិស្ថាន និងវិស័យហិរញ្ញវត្ថុ។ អ្នកនិពន្ធសៀវភៅណែនាំនេះតំណាងឲ្យអង្គការអុកស្វាមនៅក្នុងវេទិកានេះ។

បង្ហាញទាំងស្រុងនៅទំព័រ ៤១។ ទស្សនៈអំពីបរិស្ថាន សង្គម បច្ចេកទេស សេដ្ឋកិច្ច/ហិរញ្ញវត្ថុ និងការប្រឆាំងបញ្ចូលគ្នា មាននៅក្នុងប្រធានបទពិធីសារជាក់លាក់បន្ថែមទៀត។ ប្រធានបទទាំងអស់នេះត្រូវបានកំណត់ឡើងដោយប្រើវិធីសាស្ត្រសាមញ្ញមួយ ដែលមានដាក់បញ្ចូលសេចក្តីថ្លែងការណ៍អំពីការពណ៌នានិងគោលបំណង សេចក្តីថ្លែងការណ៍អំពីការដាក់ពិន្ទុក្នុងកម្រិតទាំងប្រាំ គឺ "៥" តំណាងឲ្យ ការអនុវត្តល្អបំផុត "៣" តំណាងឲ្យការអនុវត្តល្អ និង "១" តំណាងឲ្យការមិនបំពេញការងារ ឬ ការងារអន់។ សេចក្តីថ្លែងការណ៍អំពីការដាក់ពិន្ទុ បានទទួលព័ត៌មានពីលក្ខខណ្ឌវិនិច្ឆ័យជាក់លាក់តាមប្រធានបទនោះ នៅក្នុងដំណាក់កាលអភិវឌ្ឍន៍គម្រោងនោះ។ ជាចុងក្រោយ ការណែនាំអំពីការប៉ាន់ប្រមាណនេះត្រូវបានគេផ្តល់មក ដោយមានការបង្ហាញសម្រាប់អ្នកប៉ាន់ប្រមាណនិងក្រុមហ៊ុនអំពីនិយមន័យគន្លឹះសម្រាប់អ្នកប្រើប្រាស់ ឧទាហរណ៍ និងបញ្ញត្តិមួយចំនួន ដែលមានយោងនៅក្នុងប្រធានបទនិងលក្ខខណ្ឌវិនិច្ឆ័យ។ ការផ្តល់ឲ្យខាងលើនេះគួរអាចណែនាំអ្នកប៉ាន់ប្រមាណឲ្យធ្វើការវិនិច្ឆ័យលើការដាក់ពិន្ទុ។

ពិធីសារនេះ ត្រូវបានរៀបចំឡើងជាបណ្តុំឧបករណ៍ដាច់ដោយឡែកតែឯងសម្រាប់ការប្រើប្រាស់នៅដំណាក់កាលផ្សេងៗនៃការអភិវឌ្ឍន៍ទន្លេនិងគម្រោង : ដំណាក់កាលដំបូង (មុនពេលមានគម្រោង) បន្ទាប់មកដំណាក់កាលត្រៀមរៀបចំ ដំណាក់កាលអនុវត្តគម្រោង និងដំណាក់កាលប្រតិបត្តិការ។ ឧបករណ៍តម្រង់ទិសគម្រោងបីចុងក្រោយនេះ មានប្រព័ន្ធដាក់ពិន្ទុដែលគេកម្រិតមកសម្រាប់ប៉ាន់ប្រមាណការអនុវត្តការងារធៀបនឹងសេចក្តីថ្លែងការណ៍អំពីការអនុវត្តល្អ ដល់ការអនុវត្តល្អបំផុតនៅក្នុងវិស័យឧស្សាហកម្មនេះ។

ដំណើរការការធ្វើការប៉ាន់ប្រមាណ ទាមទារឲ្យមានការវាស់វែងធៀបនឹងភស្តុតាងជាក់ស្តែងនិងឯកសារជាក់ស្តែង។ ការដាក់ពិន្ទុឆ្លុះបញ្ចាំងទៅលើមូលដ្ឋាននៃភស្តុតាង ហើយការដាក់ពិន្ទុនេះគួរផ្អែកលើហេតុការណ៍ពិត អាចធ្វើឡើងវិញដូចគ្នា មិនលំអៀង និង អាចផ្ទៀងផ្ទាត់បាន។ ទោះបីជាមានបញ្ហាក្នុងការបង្កើតការអនុវត្តឧបករណ៍នេះក៏ដោយ ក៏ឧបករណ៍នេះទទួលស្គាល់សុពលភាពនៃភស្តុតាងតាមពាក្យសម្តីដែលទទួលបានមកពីប្រជាជនទទួលរងផលប៉ះពាល់ពីគម្រោងដែរ ជាសំខាន់គឺសម្រាប់ព័ត៌មានទាក់ទងនឹងយេនឌ័រ។ មានវិស័យសម្រាប់ធ្វើលក្ខណវិនិច្ឆ័យនេះចំនួនប្រាំមួយ គឺៈ ការប៉ាន់ប្រមាណ ការគ្រប់គ្រង ការចូលរួមពីភាគីពាក់ព័ន្ធ ការគាំទ្រភាគីពាក់ព័ន្ធ ការអនុលោមតាម និងលទ្ធផល។

ដូចបានពិភាក្សារួចមកហើយ ពិធីសារនេះត្រូវបានរៀបចំឡើងជាឧបករណ៍មួយសម្រាប់ឧស្សាហកម្មនេះប៉ាន់ប្រមាណគម្រោងដើម្បីឲ្យមាននិរន្តរភាព។ មុននេះ គណៈកម្មការពិភពលោកស្តីពីទំនប់ បានបង្កើតក្របខណ្ឌថ្មីមួយសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹក តាមការផ្តល់អនុសាសន៍អំពីវិធីសាស្ត្រអំពីសិទ្ធិ ហានិភ័យ និងលទ្ធផលចេញពីការចរចារ ក៏ប៉ុន្តែសមាគមវារីអគ្គីសនីអន្តរជាតិ និងភាគីពាក់ព័ន្ធសំខាន់មួយចំនួនផ្សេងទៀតបានឆ្លើយតបមកវិញចំពោះក្របខណ្ឌនេះ ដោយបានអះអាងថា វាមិនបានផ្តល់នូវឧបករណ៍អនុវត្តជាក់ស្តែងមួយសម្រាប់អ្នករៀបចំអភិវឌ្ឍន៍គម្រោងទេ។[១៧] ដោយសារតែបរិបទនៃឧបករណ៍អនុវត្តជាក់ស្តែងនេះហើយ បានជាវេទិកាបានបង្កើតពិធីសារនេះ។

## វិធីសាស្ត្ររបស់ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី ចំពោះយេនឌ័រ

ពិធីសារនេះដោះស្រាយបញ្ហាយេនឌ័រដោយវិធីណាពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី បានអនុម័តតាមវិធីសាស្ត្រកាត់ទទឹងសម្រាប់យេនឌ័រ។ យេនឌ័ររួមជាមួយនឹង ការប្រែប្រួលអាកាសធាតុ អំពើពុករលួយ និងយន្តការដោះស្រាយទំនាស់ ការគ្រប់គ្រងធនធានទឹកចម្រុះ បញ្ហាឆ្លងព្រំដែន និង តម្លាភាព ជាបញ្ហាមួយចំនួនក្នុងចំណោម "បញ្ហាដែលមានការចាប់អារម្មណ៍ខ្លាំង" ដែលពិធីសារនេះបានរកឃើញ។ ទោះបីជាបញ្ហាទាំងនេះមានការចាប់អារម្មណ៍ខ្លាំងយ៉ាងណាក៏ដោយ ក៏បញ្ហាទាំងនេះមិនត្រូវបានគេកំណត់ថាជាប្រធានបទអំពីនិរន្តរភាពឡើយ ប៉ុន្តែ ពិធីសារនេះបានបញ្ចូលការពិចារណាលើបញ្ហាទាំងនេះក្នុងវិស័យផ្សេងៗពាសពេញក្នុងក្របខណ្ឌនេះ។ សេចក្តីសង្ខេបអំពីកន្លែងដែលមានលើកឡើងទាក់ទងនឹងយេនឌ័រនៅក្នុងពិធីសារនេះ មានបង្ហាញនៅទំព័រ ១៩។

អត្ថន័យនៅក្នុងការអនុវត្តជាក់ស្តែងគឺថា យេនឌ័រនេះអាច "បាត់បង់" យ៉ាងងាយនៅក្នុងដំណើរការពិចារណាអំពីអ្វីដែលសំខាន់នៅពេលកំណត់ពិន្ទុសម្រាប់ការអនុវត្តការងារ។ ប្រការដែលថាតើបញ្ហាកាត់ទទឹងនៅក្នុងពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនីនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងដូចម្តេចនៅក្នុងការសម្រេចចិត្តដាក់ពិន្ទុនេះ មិនមានភាពច្បាស់លាស់នៅទេ។ ប្រសិនបើបញ្ហាកាត់ទទឹងនេះមិនត្រូវបានឆ្លុះបញ្ចាំងក្នុងសេចក្តីថ្លែងការណ៍អំពីការដាក់ពិន្ទុ ប៉ុន្តែមានតែនៅក្នុងកំណត់ចំណាំសេចក្តីណែនាំ ដូចក្នុងករណីយេនឌ័រដែរនោះ មានន័យថា មិនទាន់មានមូលដ្ឋានច្បាស់លាស់សម្រាប់អ្នកប៉ាន់ប្រមាណក្នុងការបញ្ចូលយេនឌ័រទៅក្នុងការសម្រេចចិត្តក្នុងការដាក់ពិន្ទុនៅឡើយទេ។ ប្រការនេះធ្វើឲ្យមានការលើកសំណួរចោទឡើងទាក់ទងនឹងវិធីសាស្ត្រថា តើបញ្ហាកាត់ទទឹងទាំងឡាយនេះត្រូវបានគេប៉ាន់ប្រមាណនិងឆ្លុះបញ្ចាំងជាពិន្ទុយ៉ាងដូចម្តេច ប្រសិនបើមិនមានបញ្ជាក់ច្បាស់នៅក្នុងសេចក្តី ថ្លែងការណ៍អំពីការដាក់ពិន្ទុនោះ។

ឧទាហរណ៍ ក្នុងប្រធានបទ P5 អំពី ការវាយតម្លៃនិងការគ្រប់គ្រងហេតុប៉ះពាល់បរិស្ថាននិងសង្គមនៅក្នុងដំណាក់កាលត្រៀមរៀបចំ យើងមិនឃើញមានការលើកឡើងដោះស្រាយបញ្ហាយេនឌ័របន្តិចណាទាល់តែសោះនៅក្នុងការពណ៌នាអំពីប្រធានបទនិងគោលបំណង ហើយក៏មិនមានឃើញចែងនៅក្នុងសេចក្តីថ្លែងអំពីការដាក់ពិន្ទុក្នុងកម្រិតណាមួយសោះឡើយ។ កន្លែងដែលយើងរកឃើញថាមានចែងអំពីយេនឌ័រនេះ គឺនៅក្នុងកំណត់ចំណាំការណែនាំសម្រាប់ប្រធានបទនោះ ដែលនេះជាឧទាហរណ៍នៃភស្តុតាងមួយក្នុងចំណោមឧទាហរណ៍ជាច្រើនសម្រាប់អ្នកប៉ាន់ប្រមាណយកមកពិចារណា។

"បញ្ហាសង្គមសំខាន់ៗរួមមាន សហគមន៍ទទួលរងផលប៉ះពាល់ពីគម្រោងប្រជាជនជនជាតិដើមភាគតិច និគមជនភាគតិច ការតាំងទីលំនៅថ្មី បេតិកភណ្ឌវប្បធម៌ (ទាំងជាលក្ខណៈរូបវន្តនិងអរូបវន្ត) និងសុខភាពសាធារណៈ។ បញ្ហាទាំងនេះត្រូវវិភាគដោយគិតអំពីសូចនាករសេដ្ឋកិច្ចសង្គម (ដោយគិតទាំង កម្រិតស្តង់ដារជីវភាព ការចិញ្ចឹមជីវិត និងស្ថិតិសុខភាព) និង យេនឌ័រដែរ។ ផលប៉ះពាល់សង្គមពីគម្រោងដែលលាតសន្ធឹងហួសពីព្រំដែនកំណត់របស់គម្រោង ត្រូវមានការប៉ាន់ប្រមាណ និងបញ្ចូលទៅក្នុងផែនការគ្រប់គ្រងដែរ (IHA 2011a, ទំ. ៦០)។

១៧. អង្គការអុកស្វាមគាំទ្រក្របខណ្ឌគណៈកម្មការពិភពលោកស្តីពីទំនប់ជាឧបករណ៍សំខាន់មួយសម្រាប់សម្រេចបានការអភិវឌ្ឍទន្លេប្រកបដោយនិរន្តរភាព ស្របពេលដែលមានការការពារបរិស្ថាននិងធ្វើឲ្យមានការរីកចម្រើនដល់សិទ្ធិ ឬ សហគមន៍តាមទន្លេ។ អង្គការអុកស្វាមចូលរួមក្នុងដំណើរការពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី ក្នុងគោលបំណងធានាឲ្យមានការឆ្លុះបញ្ចាំងវិធីសាស្ត្ររបស់គណៈកម្មការពិភពលោកស្តីពីទំនប់នៅក្នុងពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី។ ចំណុចមិនមានការឯកភាពគ្នាក្នុងពិធីសារនេះ ជាការបង្ហាញអំពីចំណុចដែលមិនបានសម្រេចតាមគោលបំណង។ ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី បានរកឃើញចំណុចទាំងនេះជាវិស័យអាទិភាពសម្រាប់ការត្រួតពិនិត្យឡើងវិញនិងការកែសម្រួលឡើងវិញក្នុងពេលអនាគត។

ការអនុវត្ត ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី៖ របៀបវាស់វែងការប៉ាន់ប្រមាណយេនឌ័រ តើអ្នកប៉ាន់ប្រមាណត្រូវប៉ាន់ប្រមាណនិងវាស់វែងផលប៉ះពាល់គម្រោងលើស្ត្រីនិងបុរសដោយរបៀបណា

ពិធីសារនេះគឺជាឯកសារសាធារណៈ អាចទាញយកដោយសេរី ប៉ុន្តែស្ថិតនៅក្រោមការត្រួតត្រាដោយលក្ខខណ្ឌសម្រាប់ប្រើប្រាស់។ ការប្រើប្រាស់ជាផ្លូវការត្រូវកំណត់ដោយអាជ្ញាប័ណ្ណចេញពីសមាគមវារីអគ្គីសនីអន្តរជាតិ និងគណៈកម្មការអភិបាលកិច្ចសម្រាប់ការប៉ាន់ប្រមាណពិធីសារជាផ្លូវការ។ សំណុំលក្ខខណ្ឌទាំងនេះ ជាការណែនាំសម្រាប់ការប្រើប្រាស់ពិធីសារនេះ និងអំពីការអះអាងណាខ្លះដែលអាចផ្អែកទៅលើការប្រើប្រាស់ជាផ្លូវការ។ គេអាចប្រើវាបានសម្រាប់ការប៉ាន់ប្រមាណមិនផ្លូវការដែលមកទល់ពេលបច្ចុប្បន្ននេះ ចំណាប់អារម្មណ៍ភាគច្រើនចេញមកពីការប៉ាន់ប្រមាណដោយខ្លួនឯងដែលប្រតិបត្តិករវារីអគ្គីសនីនិងអ្នករៀបចំអភិវឌ្ឍន៍គម្រោងប្រើប្រាស់ជាការរៀនសូត្រប៉ុណ្ណោះ។

ការប្រើប្រាស់អ្នកប៉ាន់ប្រមាណដែលមានការទទួលស្គាល់គឺជាតម្រូវការចាំបាច់ពីសមាគមវារីអគ្គីសនីអន្តរជាតិ ដើម្បីធ្វើ ការងារប៉ាន់ប្រមាណពិធីសារនេះជាផ្លូវការ។ សមាគមវារីអគ្គីសនីអន្តរជាតិ បានសន្មត់តួនាទីរបស់អង្គភាពគ្រប់គ្រងក្នុងការពិនិត្យលើពិធីសារនេះ ខណៈពេលដែលការងារអភិបាលកិច្ចស្ថិតក្នុងដៃរបស់ក្រុមប្រឹក្សាប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី បង្កើតឡើងដោយគណៈកម្មការអភិបាលកិច្ចកណ្ដាលជាមួយនឹងសភាផ្នែកផ្សេងៗទៀត។

## ចំណុចខ្វះខាតក្នុងការទទួលបានជាសាធារណៈនិងតម្លាភាព

ទោះបីជាពិធីសារនេះអាចឲ្យគេរកបានជាសាធារណៈនិងបើកចំហរក្នុងការពិនិត្យពិច័យអំពីរបៀបនិងកន្លែងលើកឡើងនិងមិនលើកឡើងអំពីផលប៉ះពាល់និងឱកាសយេនឌ័រក៏ដោយ ក៏ការទទួលស្គាល់អ្នកប៉ាន់ប្រមាណនិងការធ្វើការប៉ាន់ប្រមាណមានលក្ខណៈបិទបាំងច្រើន។ សមាគមវារីអគ្គីសនីអន្តរជាតិបានបញ្ជាក់ថា គ្រប់ការប៉ាន់ប្រមាណទាំងអស់ ត្រូវប្រើវិធីសាស្ត្រនិងសម្ភារៈមានលក្ខណៈស្តង់ដារ ដែលរចនាបង្កើតឡើងសម្រាប់ភាពជាដៃគូធ្វើការលើបញ្ហានិរន្តរភាព ប៉ុន្តែ ឯកសារទាំងនេះមិនអាចទាញយកជាសាធារណៈនោះទេ។ លក្ខខណ្ឌតម្រូវ ការបណ្តុះបណ្តាលតារាងប៉ាន់ប្រមាណ និងតារាងដាក់ពិន្ទុសម្រាប់អ្នកប៉ាន់ប្រមាណក៏មិនអាចទាញយកជាសាធារណៈនោះដែរ។ ខណៈពេលដែលមានវិន័យនិងវិស័យជំនាញជាច្រើនដែលគេត្រូវការដើម្បីបង្កើតជាក្រុមប៉ាន់ប្រមាណនោះ ការធានាឲ្យមានសមត្ថភាពគ្រប់គ្រាន់របស់អ្នកប៉ាន់ប្រមាណដែលទទួលបានការបណ្តុះបណ្តាលផ្នែកវិភាគយេនឌ័រនិងប៉ាន់ប្រមាណយេនឌ័រ គួរជាវិធីគន្លឹះមួយដែលពិធីសារអាចជួយលើកកម្ពស់ការអនុវត្តយេនឌ័រកាន់តែប្រសើរនៅក្នុងវិស័យវារីអគ្គីសនីនេះ។

## ឧបសគ្គ

ការប៉ាន់ប្រមាណអំពីនិរន្តរភាពត្រូវបានធ្វើឡើងដោយប្រើជ្យាក្រាមពីងពាងដើម្បីតំណាងឲ្យពិន្ទុ។ ដោយសារតែយេនឌ័រមិនត្រូវបានយកមកពិចារណាក្នុងសេចក្តីថ្លែងការណ៍ក្នុងការដាក់ពិន្ទុនោះ យើងមិនឃើញមានការពិចារណាអំពីតំណាងអំពីយេនឌ័រថាជាកត្តាសំខាន់ សម្រាប់បញ្ហានិរន្តរភាពនៅក្នុងឧបករណ៍ប្រាស្រ័យទាក់ទងដ៏សំខាន់នេះទេ។

អ្នកប៉ាន់ប្រមាណដាក់ពិន្ទុដោយប្រើវិធីសាស្ត្រតារាងម៉ាទ្រិចដោយមានការពន្យល់ហេតុផលប្រៀបធៀបនឹងការពិចារណាអំពីភស្តុតាង។ ដូចបានរៀបរាប់ពីមុនហើយ ការអនុវត្តការងារឬវិធីសាស្ត្រពាក់ព័ន្ធយេនឌ័រមិនមែនជាលក្ខខណ្ឌតម្រូវដែលចែងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍អំពីការដាក់ពិន្ទុនៅក្នុងពិធីសារនេះទេ ដូច្នេះ វាមានចន្លោះប្រហោងក្នុងការអនុវត្តយេនឌ័រ ហើយវាមិនអាចឆ្លុះបញ្ចាំងក្នុងការសម្រេចក្នុងការដាក់ពិន្ទុនោះទេ។

មិនមានទិសដៅសម្រាប់ការពិចារណាអំពីបញ្ហាដែលមានចំណាប់អារម្មណ៍ខ្លាំងនិងកាត់ទទឹងនេះនៅក្នុងការរាយការណ៍និងការដាក់ពិន្ទុសម្រាប់បញ្ហានិរន្តរភាពនេះទេ។

### អនុសាសន៍សម្រាប់ ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី

- ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី គួរមានការពិនិត្យនិងសរសេរឡើងវិញ ដើម្បីដាក់បញ្ចូលយេនឌ័រនិងសិទ្ធិស្ត្រីជាសំខាន់និងទូលំទូលាយ ដោយរួមបញ្ចូលទាំងការប៉ាន់ប្រមាណអំពីប្រសិទ្ធភាពនៃវិធីសាស្ត្រកាត់ទទឹងទាក់ទងនឹងយេនឌ័រ (ព្រមទាំងវិស័យទាក់ទងនឹងនិរន្តរភាពសំខាន់ៗផ្សេងទៀតផង)។
- ក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ននៃពិធីសារនេះ យើងអាចសម្រេចបានយ៉ាងប្រសើរបំផុត តាមរយៈ
  - ការលើកយេនឌ័រឲ្យទៅជាប្រធានបទមួយ ហើយការធ្វើបែបនេះនឹងធានាថាការអនុវត្តការងារពាក់ព័ន្ធយេនឌ័រត្រូវបានវាស់វែងនិងរាយការណ៍ក្នុងនាមជាវិស័យនិរន្តរភាពដ៏សំខាន់មួយ
  - ការបញ្ចូលការពិចារណាអំពីយេនឌ័រឲ្យកាន់តែមានលក្ខណៈស៊ីសង្វាក់គ្នានៅពាសពេញសេចក្តីណែនាំអំពីការប៉ាន់ប្រមាណនេះ
  - ដាក់បញ្ចូលយេនឌ័រនិងការពង្រឹងសិទ្ធិអំណាចស្ត្រីទៅក្នុងសេចក្តីថ្លែងការណ៍អំពីការដាក់ពិន្ទុសម្រាប់ការអនុវត្តល្អជាមូលដ្ឋាន ហើយបន្ទាប់មក ត្រូវមានការឆ្លុះបញ្ចាំងការអនុវត្តការងារឲ្យបានកាន់តែប្រសើរនៅក្នុងការសម្រេចចិត្តដាក់ពិន្ទុ។
- អ្នកប៉ាន់ប្រមាណដែលទទួលស្គាល់ដោយពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនីនេះ គួរមានសមត្ថភាពក្នុងការវិភាគយេនឌ័រ និងការប៉ាន់ប្រមាណផលវាយតម្លៃហេតុប៉ះពាល់យេនឌ័រ និង/ឬ ក្រុមអ្នកប៉ាន់ប្រមាណគួរតម្រូវយ៉ាងហោចណាស់ឲ្យមានសមាជិកម្នាក់ដែលមានសមត្ថភាពនិងជំនាញនេះ។
- ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី គួរពិនិត្យមើលដើម្បីបញ្ចូលការវាយតម្លៃហេតុប៉ះពាល់យេនឌ័រឲ្យឃើញច្បាស់នៅក្នុងការរំពឹងទុកសម្រាប់ ការអនុវត្តល្អទាក់ទងនឹង "ការប៉ាន់ប្រមាណ" និង "ការគ្រប់គ្រង" ក្នុងការដាក់ពិន្ទុជាបន្តបន្ទាប់។
- ត្រូវធានាថាការវាយតម្លៃហេតុប៉ះពាល់យេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងការបណ្តុះបណ្តាលនិងការប៉ាន់ប្រមាណសមត្ថភាពសម្រាប់អ្នកប៉ាន់ប្រមាណពិធីសារនេះ។
- ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនី គួរតែជាឧបករណ៍ធនធានបើកចំហរទាំងស្រុងមួយ រួមទាំងការដាក់សេចក្តីណែនាំសម្រាប់អ្នកប៉ាន់ប្រមាណពិធីសារ និងឧបករណ៍សម្រាប់ប៉ាន់ប្រមាណទាំងនេះ ឲ្យអាចទាញយកជាសាធារណៈផង។
- នៅពេលដែលឧបករណ៍ទាំងអស់នេះត្រូវបានដាក់ឲក្រុបានជាសាធារណៈហើយ គេគួរដំណើរការ ត្រួតពិនិត្យឡើងវិញទាក់ទងនឹងបញ្ហាយេនឌ័រក្នុងឧបករណ៍ទាំងនោះនេះ ក្នុងការបណ្តុះបណ្តាលនិងក្នុងលក្ខណៈវិនិច្ឆ័យជ្រើសរើសអ្នកប៉ាន់ប្រមាណ និងក្រុមប៉ាន់ប្រមាណ។

## ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល (RSAT)

### តើឧបករណ៍នេះជាអ្វី? វាដំណើរការយ៉ាងដូចម្តេច? ហេតុអ្វីបានជាគេបង្កើតវាឡើង?

ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល (RSAT) បានកំណត់ចេញប្រធានបទចំនួន១០ អំពីនិរន្តរភាព និងប្រធានបទរងចំនួន២៧។ ប្រធានបទរងនីមួយៗមានលក្ខខណ្ឌវិនិច្ឆ័យដូចគ្នាចំនួនបួន ដែលត្រូវតែប៉ាន់ប្រមាណនៅគ្រប់ប្រធានបទទាំងអស់។ លក្ខណៈវិនិច្ឆ័យទាំងបួននេះ ផ្តល់នូវក្របខណ្ឌមួយសម្រាប់ការប៉ាន់ប្រមាណប្រធានបទទាំងនេះដោយប្រៀបទៅនឹងវិស័យទទួលខុសត្រូវសំខាន់ៗចំនួនបួនសម្រាប់ការគ្រប់គ្រងធនធានទឹកសមាហរណកម្ម (IWRM) និងការអភិវឌ្ឍវារីអគ្គិសនី។ ប្រធានបទនីមួយៗមានសេចក្តីថ្លែងការណ៍អំពីការអនុវត្តការងារមួយចំនួន ដែលមានបង្ហាញនៅក្នុងការរំពឹងទុកនិងចំណុចផ្តោតនៃប្រធានបទ ដើម្បីធ្វើឲ្យមានតុល្យភាពរវាងទិដ្ឋភាពការគ្រប់គ្រងធនធានទឹកសមាហរណកម្ម (IWRM) និងទិដ្ឋភាពវារីអគ្គិសនី។

**លក្ខណៈវិនិច្ឆ័យទាំងបួន គឺ:**

១. **ការធ្វើផែនការនិងការគ្រប់គ្រងអាងទន្លេ:** ដែលពិនិត្យលើវិស័យនិងផលប្រយោជន៍ផ្សេងៗពាក់ព័ន្ធក្នុងទន្លេ និងពិនិត្យលើរបៀបតំណាងនិងរបៀបពិចារណានៅក្នុងការធ្វើផែនការនិងគ្រប់គ្រងអាងទន្លេ ព្រមទាំង ពិនិត្យលើគុណភាពទិន្នន័យអង្កេតបឋមគ្រប់វិស័យក្នុងអាងទាំងមូល។

២. **ការធ្វើផែនការនិងបទបញ្ញាក្នុងវិស័យថាមពល/អគ្គីសនី:** ដែលពិនិត្យលើគោលនយោបាយ និងការធ្វើផែនការសម្រាប់ផ្នែកថាមពល និង អគ្គីសនី ក្នុងអាង ដោយផ្តោតលើវារីអគ្គីសនី។ ផ្នែកនេះក៏ពិចារណាអំពីរបៀបរៀបចំបង្កើតផែនការវារីអគ្គីសនីនិងផែនការប្រើប្រាស់ទឹកដែរ។

៣. **គម្រោងទំនប់វារីអគ្គីសនី:** ពិនិត្យលើផែនការមួយៗនិងផែនការរួម លើសកម្មភាពស្រាវជ្រាវនិងការគ្រប់គ្រងរបស់អ្នកអភិវឌ្ឍន៍និងប្រតិបត្តិករវារីអគ្គីសនីទាំងអស់ក្នុងអាងទន្លេ។ ផ្នែកនេះក៏ពិចារណាអំពីរបៀបសម្របសម្រួលកត្តាទាំងនេះ ព្រមទាំងអំពីរបៀបពិចារណាទៅលើអ្នកប្រើប្រាស់ទឹកផ្សេងទៀត និងរបៀបចូលរួមរបស់អ្នកប្រើប្រាស់ទឹកផ្សេងទៀតនៅក្នុងអាងទន្លេនេះ។ ផ្នែកនេះពិចារណាអំពីគម្រោងនៅគ្រប់ដំណាក់កាលទាំងអស់នៃការអភិវឌ្ឍនិងប្រតិបត្តិការ។

៤. **និយ័តកម្មនិងអភិបាលកិច្ច:** ពិចារណាអំពីក្របខណ្ឌនិយ័តកម្មនិងក្របខណ្ឌផែនការសម្រាប់ការគ្រប់គ្រងវារីអគ្គីសនីនិងធនធានទឹក។ ផ្នែកនេះពិនិត្យគ្រប់កម្រិត គឺចាប់ពីកម្រិតមូលដ្ឋានដល់កម្រិតអន្តរជាតិ និងពិនិត្យអំពីរបៀបនៃការពង្រឹងនិងអនុវត្តក្នុងការងារជាក់ស្តែង (RSAT 2013)។

### វិធីសាស្ត្ររបស់ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនី សម្រាប់អាងទន្លេទាំងមូល (RSAT) ចំពោះយេនឌ័រ - របៀបដោះស្រាយបញ្ហាយេនឌ័រ តាមក្របខណ្ឌឧបករណ៍ប៉ាន់ប្រមាណ ដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល(RSAT)

នៅក្នុងពង្រាងចុងក្រោយនៃឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័ស អំពីនិរន្តរភាពនៃវារីអគ្គិសនី សម្រាប់អាងទន្លេទាំងមូល(RSAT) នេះ[១៩] ការវិភាគយេនឌ័រ និងការយល់ដឹងអំពីយេនឌ័រ ត្រូវគេរំពឹងថាមាននៅក្នុងវិស័យសំខាន់ពីរៈ

i. នៅក្នុងលក្ខខណ្ឌវិនិច្ឆ័យក្នុងប្រធានបទរងទាំងបួន។ ឧទាហរណ៍ ប្រធានបទរង ៤.២ ការបែងចែកផលប្រយោជន៍ពីថ្នាក់ជាតិទៅថ្នាក់មូលដ្ឋាន ៥.៣ សុវត្ថិភាពស្បៀងនិងការកាត់បន្ថយភាពក្រីក្រ និង ៥.៤ ជនជាតិដើមភាគតិចនិងនិគមជនជាតិពន្ធុ។ ចំណុចទាំងអស់នេះកំណត់សារៈសំខាន់ណាស់ ក្នុងការពិចារណាអំពីយេនឌ័រនិងផលប្រយោជនស្ត្រីនៅក្នុងដំណើរការឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូលនេះ។

ii. នៅក្នុងកំណត់សម្គាល់សេចក្តីណែនាំនិងនិយមន័យនៃប្រធានបទ។ ឧទាហរណ៍ កំណត់សម្គាល់សេចក្តីណែនាំនិងនិយមន័យសម្រាប់ ប្រធានបទ៥ បញ្ហាសង្គមនិងការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ កំណត់អំពីសារៈសំខាន់នៃទិន្នន័យបែងចែកតាមភេទដោយមានការប្រមូលទិន្នន័យផ្នែកសង្គម។ ហើយនៅក្នុងការពិចារណាអំពីហានិភ័យសង្គមនិងការកំណត់អំពីការពិគ្រោះយោបល់ប្រកបដោយជោគជ័យនោះ ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល (RSAT) នេះបានកំណត់អំពីសារៈសំខាន់នៃដំណើរដាក់បញ្ចូលយេនឌ័រនិងឆ្លើយតបយេនឌ័រ។

ឯកសារណែនាំការប៉ាន់ប្រមាណឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូល (RSAT) ដែលផ្តល់ព័ត៌មានអំពីការរំពឹងទុកនិងដំណើរការសម្រាប់ការធ្វើការប៉ាន់ប្រមាណឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេនេះមិនតម្រូវឲ្យមានទិន្នន័យយេនឌ័រ ឬ ឯកទេសយេនឌ័រទេ។

### ការអនុវត្តឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនី

**សម្រាប់អាងទន្លេទាំងមូល :** របៀបវាស់វែងការប៉ាន់ប្រមាណយេនឌ័រ តើអ្នកប៉ាន់ប្រមាណត្រូវប៉ាន់ប្រមាណនិងវាស់វែងផលប៉ះពាល់គម្រោងលើស្ត្រីនិងបុរសដោយរបៀបណាចំណុចសំខាន់នៃការប៉ាន់ប្រមាណឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេទាំងមូលនេះមានលក្ខណៈស្រដៀងទៅនឹង ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនីដែរ គឺការប្រមូលភស្តុតាងនិងទិន្នន័យ។ តាមពិតទៅគេអាចប្រមូលនិងពិចារណាលើទិន្នន័យយេនឌ័រ និង ទិន្នន័យបែងចែកតាមភេទ នៅក្នុងការប៉ាន់ប្រមាណ ប៉ុន្តែ នៅក្នុងការប៉ាន់ប្រមាណនេះ គេមិនតម្រូវឲ្យត្រូវតែធ្វើនោះទេ។ ក៏ប៉ុន្តែ សេចក្តីថ្លែងការណ៍អំពីការអនុវត្តការងារ ដែលបានកំណត់ការពិចារណាអំពីយេនឌ័រនោះ តម្រូវឲ្យអ្នកប៉ាន់

---

១៨. ខណៈពេលដែលមានភាពខុសប្លែកគ្នាមួយចំនួន ដែលមានលក្ខណៈជាក់លាក់សម្រាប់បរិបទទន្លេមេគង្គទាក់ទងនឹងការអភិវឌ្ឍក្នុងឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេនេះ គេក៏ឃើញមានការតម្រឹមដោយចេតនាមួយក្នុងប្រធានបទឧបករណ៍ប៉ាន់ប្រមាណលឿនពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេនេះ ឲ្យស្របនឹង ពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គិសនីដែរ។

១៩. នៅពេលកំពុងសរសេរនោះ ឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេឆ្នាំ២០១០ បានដាក់ចេញជាសាធារណៈរួចហើយ។ ឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ ត្រូវបានផលិតឡើងជាឯកសារធនធានបើកចំហរមួយ ដោយកំពុងមានការរៀបចំពង្រាងថ្មីៗជាន្តបន្ទាប់ ប៉ុន្តែ ពង្រាងឆ្នាំ២០១៣ ដែលមានដាក់បញ្ចូលយេនឌ័រច្រើនជាងឯកសារក្នុងឆ្នាំ២០១០នោះ មិនទាន់ត្រូវបានបញ្ចេញជាសាធារណៈនៅឡើយទេ។ ដូច្នេះការវិភាគនិងអនុវត្តក្នុងនេះត្រូវផ្អែកលើពង្រាងឆ្នាំ២០១៣នេះ ប្រសិនបើមិនមានការបញ្ជាក់ក្រៅពីនេះ។ ឯកសារនេះត្រូវដាក់ប្រកពក្នុងខែសីហា ឆ្នាំ២០១៣។

ប្រមាណប្រមូលទិន្នន័យយេនឌ័រ។ ដូចក្នុងប្រធានបទដែលបានលើកឡើងមុននោះ យើងអាចកំណត់ថា នេះជាចន្លោះប្រហោងក្នុងអំឡុងពេលធ្វើការប៉ាន់ប្រមាណ។ ស្រដៀងគ្នានឹងពិធីសារប៉ាន់ប្រមាណនិរន្តរភាពវារីអគ្គីសនីដែរ ជំនាញយេនឌ័រមិនត្រូវបានតម្រូវឲ្យមានជាផ្នែកមួយនៃដំណើរការប៉ាន់ប្រមាណនិងការចូលរួមរបស់ស្ត្រីនោះទេ ហើយការចូលរួមរបស់ស្ត្រីក្នុងក្រុមភាគីពាក់ព័ន្ធផ្សេងៗគ្នានោះ ក៏មិនបានតម្រូវឲ្យមានដែរ។

ដំណើរការធ្វើការប៉ាន់ប្រមាណ បង្ហាញនូវឱកាសសម្រាប់ការប៉ាន់ប្រមាណយេនឌ័រនិងការដាក់បញ្ចូលយេនឌ័រ។ ការជ្រើសរើសអ្នកសម្របសម្រួលសម្រាប់ ឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេនេះ ត្រូវបានកំណត់ថាជាការសំខាន់ខ្លាំង ប៉ុន្តែមិនមានការបញ្ជាក់អំពីឯកទេសយេនឌ័រជាលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកសម្របសម្រួលឡើយ។ ស្រដៀងគ្នានេះដែរ ការធ្វើទស្សនកិច្ចទៅទីតាំងអាងទន្លេ ត្រូវបានកំណត់ថាជាឱកាសដ៏សំខាន់ក្នុងការទទួលបានការយល់ដឹងពី មូលដ្ឋានជាក់ស្តែងអំពីអាងទន្លេ និងការកំណត់រកឲ្យឃើញបញ្ហាសំខាន់ៗ ប៉ុន្តែ មិនមានការកំណត់អំពីការពិចារណាយេនឌ័រក្នុងការពន្យល់បរិបទសម្រាប់ការជ្រើសរើសទីតាំងនិងបញ្ហាឡើយ។

ប្រសិនបើកត្តាទាំងនេះត្រូវបានយកមកប្រើប្រាស់ដោយចៃដន្យនោះ វានឹងក្លាយជាលទ្ធភាពពិតប្រាកដមួយដែលការប៉ាន់ប្រមាណឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេនេះអាចពិចារណាយេនឌ័រក្នុងការពិភាក្សានិងក្នុងការប៉ាន់ប្រមាណរហ័សប្រកបដោយអត្ថន័យ។ ប៉ុន្តែ ដោយសារតែវាជាការចៃដន្យច្រើនជាងការយកចិត្តទុកដាក់ដោយចេតនានោះ ឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេនេះ ក៏អាចបាត់បង់ឱកាសដ៏សំខាន់ក្នុងការពិចារណាយេនឌ័រ ព្រមទាំងបទពិសោធន៍ តម្រូវការ និងផលប្រយោជន៍របស់ស្ត្រីដែរ។

### អនុសាសន៍សម្រាប់ឧបករណ៍ប៉ាន់ប្រមាណដោយឆាប់រហ័សអំពីនិរន្តរភាពនៃវារីអគ្គិសនីសម្រាប់អាងទន្លេ (RSAT)

- លើកឡើងដោះស្រាយទិដ្ឋភាពនៃឧបករណ៍ប៉ាន់ប្រមាណឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ ត្រង់ចំណុចដែលមិនមានការកំណត់ច្បាស់អំពីយេនឌ័រ ដោយសារវានឹងអាចធ្វើឲ្យចុះខ្សោយដល់ការបញ្ចូលយេនឌ័រនៅក្នុងវិស័យផ្សេងៗទៀតនៃឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ នេះ។ ឧទាហរណ៍ ការពិចារណាយេនឌ័រអាចត្រូវបានគេបញ្ចូលកាន់តែច្បាស់នៅក្នុងគោលកាណ៍គន្លឹះសម្រាប់ការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) និងវារីអគ្គីសនី ដែលបានសម្រួលដល់ឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ។ ជាងនេះទៅទៀត ការកំណត់ច្បាស់លាស់អំពីយេនឌ័រ គួរបញ្ចូលទៅក្នុងគោលការណ៍ដូចតទៅ:
    i. ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការការពារសិទ្ធិនិងសិទ្ធិទទួលបាន
    ii. ការចែករំលែកផលប្រយោជន៍និងការចំណាយសម្រាប់ការអភិវឌ្ឍដោយស្មើភាពគ្នា
    iii. ការដោះស្រាយភាពក្រីក្រ និងសុវត្ថិភាពស្បៀងក្នុងអាងទន្លេសម្រាប់ទំនប់វារីអគ្គីសនី
- ពិចារណាអំពីការពង្រឹងប្រធានបទទី៥ អំពី បញ្ហាសង្គមនិងការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ ដោយបញ្ចូលប្រធានបទរងថ្មីមួយអំពីយេនឌ័រនិងតម្រូវការរបស់ស្ត្រី ព្រមទាំងកំណត់ឲ្យច្បាស់អំពីយេនឌ័រនៅក្នុងសេចក្តីថ្លែងការណ៍អំពីការអនុវត្តការងារនិងគោលបំណងសម្រាប់ប្រធានបទទី៥នេះ។ ប្រធានបទរង ៥.៣ អំពីសុវត្ថិភាពស្បៀងនិងការកាត់បន្ថយភាពក្រីក្រនិង ៥.៤ ជនជាតិដើមភាគតិចនិងនិគមជនភាគតិច បង្ហាញអំពីវិធីសាស្ត្រដ៏រឹងមាំមួយក្នុងការពិចារណាអំពីផលប៉ះពាល់យេនឌ័រនិងការពិគ្រោះយោបល់ជាមួយបុរសនិងស្ត្រី។
- ពង្រឹងវិធីសាស្ត្របញ្ជ្រាប : ដាក់បញ្ចូលវិធីសាស្ត្រដែលកាន់តែមានលក្ខណៈជាប្រព័ន្ធនិងស៊ីសង្វាក់គ្នាបន្ថែមទៀត ដោយបញ្ចូលយ៉ាងច្បាស់អំពីយេនឌ័រទៅក្នុងការពិពណ៌នាអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការធ្វើការអាងទន្លេនិងគម្រោងទំនប់វារីអគ្គីសនី។ វិធីសាស្ត្រដែលបានអនុម័តនៅក្នុងប្រធានបទរង ៤.២ ការចែករំលែកផលប្រយោជន៍ពីថ្នាក់ជាតិទៅថ្នាក់មូលដ្ឋាន ក្នុងប្រធានបទទី៤: ការបែងចែកការចំណាយនិងផលប្រយោជន៍ពីទំនប់វារីអគ្គិសនីដោយសមភាព ជាការបង្ហាញអំពីគម្រូល្អមួយ។ "ការធ្វើផែនការអាងទន្លេ ទាំងមូល គួរបញ្ចូលបញ្ញត្តិអំពីការបែងចែកការចំណាយនិងផលប្រយោជន៍វារីអគ្គិសនីគ្រប់វិស័យនិងគ្រប់សហគមន៍នៅក្នុងអាងតូចៗផ្សេងទៀត។ ត្រូវមានផែនការជាក់លាក់សម្រាប់ស្ត្រី ក្រុមជនជាតិ និងក្រុមតូចៗដើម្បីទទួលបានផលប្រយោជន៍" (RSAT 2013 ទំព័រ ២១)។
- ឯកសារណែនាំអំពីការប៉ាន់ប្រមាណឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ ផ្តល់ឱកាសមួយចំនួនសម្រាប់ការពិចារណាបញ្ហាយេនឌ័រនិងផលប៉ះពាល់យេនឌ័រក្នុងដំណើរការឧបករណ៍ប៉ាន់ប្រមាណឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ នេះឲ្យបានកាន់តែប្រសើរ ដូចជា:
    - ធានាថាការពិចារណាអំពីយេនឌ័រត្រូវបានបញ្ចូលក្នុងការត្រៀមរៀបចំដោយក្រុមប៉ាន់ប្រមាណ ជាផ្នែកមួយនៃការស្រាវជ្រាវបឋមលើឯកសារដែលមានស្រាប់
    - កំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធជាស្ត្រីនិងអ្នកឯកទេសយេនឌ័រជាផ្នែកសំខាន់ក្នុងការវិភាគអំពីភាគីពាក់ព័ន្ធ និងការជ្រើសរើសអ្នកចូលរួមសម្រាប់ការប៉ាន់ប្រមាណ
    - ធានាឲ្យមានជំនាញយេនឌ័រ ជាសមត្ថភាពសំខាន់សម្រាប់អ្នកសម្របសម្រួល
    - កំណត់រកឱកាសដើម្បីបង្ហាញអំពីការយល់ដឹងផ្នែកយេនឌ័រក្នុងពេលធ្វើទស្សនកិច្ចនៅទីតាំង សម្រាប់ការប៉ាន់ប្រមាណ
    - ធ្វើឲ្យការទទួលបានទិន្នន័យយេនឌ័រនិងទិន្នន័យបែងចែកតាមភេទជាការរំពឹងទុកស្តង់ដាមួយ នៅក្នុងកំណត់ត្រាផ្តល់យោបល់
- ពិចារណាបញ្ចូលឧបករណ៍មួយចំនួនចេញពីសៀវភៅណែនាំនេះ ដូចជា ការពណ៌នាអំពីការប្រើប្រាស់និងការគ្រប់គ្រង ទៅក្នុងសេចក្តីណែនាំឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ។
- បន្ទាប់ពីសម្រេចចុងក្រោយនិងប្រើប្រាស់ឧបករណ៍ប៉ាន់ប្រមាណឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ នេះ ចំនួនពីរបីឆ្នាំ ត្រូវពិនិត្យឡើងវិញអំពីប្រសិទ្ធភាពរបស់ឧបករណ៍ប៉ាន់ប្រមាណ ឆាប់រហ័សពីនិរន្តរភាពវារីអគ្គិសនីទូទាំងអាងទន្លេ នេះ ដោយពិចារណាលើបញ្ហាយេនឌ័រ។

## សទ្ទានុក្រមពាក្យនិងបញ្ញត្តិ

### យេនឌ័រ

តួនាទីនិងការទទួលខុសត្រូវផ្សេងគ្នារបស់ស្ត្រីនិងបុរស។ តួនាទីនិងការទទួលខុសត្រូវនេះ ត្រូវបានចេះដឹងតាំងពីបឋមវ័យនិងពេញមួយជីវិត ពីមនុស្សនៅជុំវិញខ្លួនយើង គឺមិនមែនចេះមកពី "ធម្មជាតិ" នោះទេ។ តួនាទីនិងការទទួលខុសត្រូវនេះ មានភាពខុសគ្នាតាមវប្បធម៌និងតំបន់ ហើយមានការផ្លាស់ប្តូរតាមពេលវេលា។

### យេនឌ័រនិងភេទ

ភេទ សំដៅទៅលើភាពខុសគ្នាផ្នែកជីវសាស្ត្ររវាងបុរសនិងស្ត្រី យេនឌ័រ សំដៅទៅលើតួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនង របស់ស្ត្រីនិងបុរស ព្រមទាំងភាពខុសគ្នាផ្នែកសង្គមដែលកើតឡើងលើបុរសនិងស្ត្រីក្នុងសង្គមនិងរវាងសង្គមផ្សេងគ្នា។

### ការមិនយល់ដឹងអំពីយេនឌ័រ

ការខកខានមិនបានពិចារណាភាពខុសគ្នារវាងតម្រូវការបុរសនិងស្ត្រី ទៅលើ តម្រូវការ ផលប្រយោជន៍ ព្រមទាំង ការទទួលបានការប្រើប្រាស់ធនធាន អំណាច និងស្ថានភាពសង្គម។

### សមភាពយេនឌ័រ

សិទ្ធិ ស្ថានភាព ឱកាស និងលទ្ធផលស្មើភាពគ្នាសម្រាប់បុរសនិងស្ត្រី

### សមធម៌យេនឌ័រ

គឺជាការទទួលបានការប្រព្រឹត្តមកលើខ្លួនប្រកបដោយភាពយុត្តិធម៌សម្រាប់ស្ត្រីនិងបុរស។ ជារឿយៗ គេត្រូវការយុទ្ធសាស្ត្រនិងវិធានការពិសេស ដើម្បីផ្តល់សំណងដល់ការដែលស្ត្រីមិនបានទទួលប្រយោជន៍ផ្នែកសង្គមនិងប្រវត្តិសាស្ត្រ។ ការរើសអើងបែបវិជ្ជមាន អាចជាតម្រូវការសម្រាប់ជួយស្ត្រីទទួលបានឱកាសស្មើភាពគ្នា។ ដើម្បីទទួលបានសមធម៌ ត្រូវធ្វើឲ្យសមភាពកើតឡើងជាមុនសិន។

### ការបញ្ជ្រាបយេនឌ័រ

ដំណើរការដែលធានាថាការងារដែលធ្វើតាមគ្រប់វិធីទាំងអស់ត្រូវរួមចំណែកជួយឲ្យស្ត្រីទទួលបានចំណែកធនធាននិងអំណាចស្មើភាពគ្នា។ គ្រប់យ៉ាងដែលក្រុមហ៊ុនឬអង្គភាពធ្វើ រាប់បញ្ចូលទាំង ការធ្វើគោលនយោបាយ ការរៀបចំរបៀបវារៈ ការធ្វើផែនការ ការគ្រប់គ្រងធនធានមនុស្សការគ្រប់គ្រងកម្មវិធី ការគ្រប់គ្រងព័ត៌មាន និងការបែងចែកធនធានត្រូវទទួលបានព័ត៌មានតាមរយៈការវិភាគយេនឌ័រ។

### អព្យាក្រឹត្យយេនឌ័រ

ទាក់ទងនឹងមនុស្សឬសហគមន៍ ហើយ មិនកំណត់ដាក់លាក់លើបុរសឬស្ត្រីនោះទេ។ អាចប្រឈមនឹងការមើលរំលងចំណុចខុសគ្នាដែលមានភាពសំខាន់។

### ទំនាក់ទំនងយេនឌ័រ

ទំនាក់ទំនងទាំងនេះ គឺជាទំនាក់ទំនងសង្គមរវាងស្ត្រីនិងបុរស ព្រមទាំងមានការពាក់ព័ន្ធនឹងការបែងចែកអំណាចរបស់ភេទទាំងពីរនេះ។ ទំនាក់ទំនងយេនឌ័រ កំណត់អំពីរបៀបបែងចែកការទទួលខុសត្រូវនិងការរំពឹងទុករបស់សង្គម និងរបៀបនៃការឲ្យតម្លៃភេទនីមួយៗ។ ទំនាក់ទំនងយេនឌ័រ មានភាពផ្សេងគ្នាទៅតាមពេលវេលានិងទីកន្លែង និងខុសគ្នាទៅតាមក្រុមមនុស្សផ្សេងគ្នាដែរ។ នេះមានន័យថា ទំនាក់ទំនងយេនឌ័រមានភាពផ្សេងគ្នា ដោយយោងតាមទំនាក់ទំនងសង្គមផ្នែកផ្សេងទៀត ដូចជា វណ្ណៈ ពូជសាសន៍ ជនជាតិ ពិការភាព អាយុ និង វប្បធម៌ (យកលំនាំចេញពីការិយាល័យស្ត្រី និងសាកលវិទ្យាល័យអាជីឡេត ២០០៥)។

### ការផ្លាស់ប្តូរយេនឌ័រ

គឺនៅពេលគេចាត់ទុកយេនឌ័រថាជាចំណុចស្នូលក្នុងការលើកកម្ពស់សមភាព និងក្នុងការសម្រេចបានលទ្ធផលអភិវឌ្ឍន៍វិជ្ជមាន។ ការផ្លាស់ប្តូរយេនឌ័រ ចាប់ផ្តើមលើការងារផ្លាស់ប្តូរទំនាក់ទំនងយេនឌ័រដែលមិនទាន់មានសមភាព ដើម្បីលើកកម្ពស់ការចែករំលែកអំណាច លើកកម្ពស់ការគ្រប់គ្រងធនធាន លើកកម្ពស់ការធ្វើការសម្រេចចិត្ត និងលើកកម្ពស់ការគាំទ្រដល់ការពង្រឹងសិទ្ធិអំណាចស្ត្រី។

### ចំណុចប្រសព្វ

នៅកន្លែងដែលមានការប៉ាន់ប្រមាណយេនឌ័រ រួមជាមួយកត្តាផ្សេងទៀតដែលជះឥទ្ធិពលដល់ទំនាក់ទំនងអំណាចនិងភាពងាយរងគ្រោះ រួមមាន វណ្ណៈ ពូជសាសន៍ សាសនា ជនជាតិ និង ពិការភាព។ ចំណុចនេះមានសារៈសំខាន់ជាពិសេស នៅពេលពិនិត្យមើលបញ្ហាកំណត់អត្តសញ្ញាណនិងបញ្ហាអំណាច ដើម្បីឲ្យបានយល់ដឹងអំពីថាតើការផ្លាស់ប្តូរនឹងជះឥទ្ធិពលយ៉ាងណាខ្លះចំពោះអ្នកដែលត្រូវគេផាត់ចេញពីសង្គម។

### ការពង្រឹងសិទ្ធិអំណាចស្ត្រី

ដំណើរការ "ពីក្រោមទៅលើ" នៃការផ្លាស់ប្តូរទំនាក់ទំនងអំណាចរវាងបុរសនិងស្ត្រី។ កត្តានេះអាចសម្រេចបានតាមរយៈបុគ្គល ឬ ក្រុមមនុស្ស ជាពិសេសស្ត្រី តាមរយៈការដឹងអំពីស្ថានភាពអន់ទាបនិងអំណាចតិចតួចរបស់ស្ត្រី ឬ តាមរយៈឧបសគ្គនិងឱកាសតិចតួច និងកសាងសមត្ថភាពឬជួយសម្រួលក្នុងការជំនះនិងផ្លាស់ប្តូរ។

### សិទ្ធិស្ត្រី

សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៨ បានចែងអំពីសិទ្ធិមនុស្សរបស់ស្ត្រីនិងបុរសទាំងអស់។ ប៉ុន្តែ ប្រពៃណី បុរេនិច្ឆ័យ ផលប្រយោជន៍សង្គមសេដ្ឋកិច្ចនិងនយោបាយ បានប្រមូលផ្តុំដើម្បីដកស្ត្រីចេញពីសិទ្ធិទាំងអស់នេះ។ ដូចនេះ សិទ្ធិមនុស្សរបស់ស្ត្រីត្រូវទទួលបានការពិចារណាដាច់ដោយឡែកនិងទទួលបានការយកចិត្តទុកដាក់ជាពិសេស។

(យកលំនាំពី Kilsby, D 2013 បញ្ញត្តិនិងនិយមន័យយេនឌ័រ ឯកសារផ្ទៃក្នុងអង្គការអុកស្វាម)

## ឯកសារយោង


ធនាគារអភិវឌ្ឍន៍អាស៊ី (អេឌីប៊ី) ២០០៦ បញ្ជីត្រួតពិនិត្យយេនឌ័រកសិកម្ម ទំ. ៧ ចូលមើលខែតុលាឆ្នាំ២០១៣ http://www.adb.org/Documents/Manuals/Gender_Checklists/Agriculture/default.asp?p=genchck

អេឌីប៊ី ២០០៩ សេចក្តីថ្លែងការណ៍គោលនយោបាយការពារ, ទំ.៣៣ ចូលមើលខែមេសាឆ្នាំ២០១៣, http://www.adb.org/sites/default/files/pub/2009/Safeguard-Policy-Statement-June2009.pdf

អេឌីប៊ី ២០១២ "កម្ពុជា : ការវិភាគយេនឌ័រក្នុងប្រទេស" ចូលមើលថ្ងៃទី២៤ខែឧសភាឆ្នាំ ២០១៣ http://www.adb.org/documents/cambodia-country-gender-analysis

អេឌីប៊ី ២០១៣ ផែនការសកម្មភាពយេនឌ័រគម្រោង ចូលមើលថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ http://www.adb.orងg/themes/gender/project-action-plans

នាយកដ្ឋានអភិវឌ្ឍន៍អគ្គិសនី ២០០៥ ការដោះស្រាយបញ្ហាយេនឌ័រ : សៀវភៅណែនាំ ទំ.១ ចូលមើលថ្ងៃទី៨ ខែសីហាឆ្នាំ២០១៣ http://www.doed.gov.np/documents/Manual-for-Addressing-Gender-Issues.pdf

អង្គការហ្វាវ ២០១២ទិន្នន័យអំពីយេនឌ័រនិងសិទ្ធិដីធ្លី:សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ចូលមើលថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៣ http://www.fao.org/gender/landrights/report/en/

ហ៊ីល ខ. ២០០៩ ស្ត្រី សហគមន៍ និង ការរុករករ៉ែ ៖ ផលប៉ះពាល់យេនឌ័រនៃការរុករករ៉ែនិងការប៉ាន់ប្រមាណផលប៉ះពាល់តួនាទីយេនឌ័រ អុកស្វាម អូស្ត្រាលី ក្រុងមេលប៊ន។

ហាន់ ជ ថូម៉ាស ហ និង ឡាធិហ្វ ស ២០០៧ ផែនការសកម្មភាពយេនឌ័រ និង លទ្ធផលសមភាពយេនឌ័រ : ការប៉ាន់ប្រមាណយេនឌ័រឆាប់រហ័សនៃគម្រោងអេឌីប៊ី របាយការណ៍សំយោគ អេឌីប៊ី ក្រុងម៉ានីល ខែកញ្ញា ឆ្នាំ២០០៧។

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ២០១៣ ការវិនិយោគលើការងាររបស់ស្ត្រី : ល្អសម្រាប់អាជីវកម្ម ល្អសម្រាប់ការអភិវឌ្ឍ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក្រុងវ៉ាស៊ីនតោនឌីស៊ី IFReDI ២០១៣ គោលនយោបាយ IFReDI សង្ខេប រដ្ឋបាលជលផល រាជធានីភ្នំពេញ ទំ.២-៣។

សមាគមវារីអគ្គិសនី (IHA) ២០១១a ពិធីសារប៉ាន់ប្រមាណនិរន្តភាពវារីអគ្គិសនី--ឯកសារ : ពិធីសារប៉ាន់ប្រមាណនិរន្តភាពវារីអគ្គិសនី ឯកសារមូលដ្ឋាន ឯកសារឧបករណ៍ប៉ាន់ប្រមាណដំណាក់កាលដំបូង ឧបករណ៍ប៉ាន់ប្រមាណការរៀបចំ ឧបករណ៍ប៉ានប្រមាណការអនុវត្ត និង ឧបករណ៍ប៉ាន់ប្រមាណការប្រតិបត្តិការងារ ចូលមើលថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ http://www.hydrosustainability.org/Document-Library.aspx សមាគមវារីអគ្គិសនីអន្តរជាតិ (IHA)២០១៣b ពិធីសារប៉ាន់ប្រមាណនិរន្តភាពវារីអគ្គិសនី--ការប៉ាន់ប្រមាណពិធីសារ ចូលមើលថ្ងៃទី៩ខែសីហាឆ្នាំ២០១៣ http://www.hydrosustainability.org/Protocol-Assessments.aspx

ឃីលស៍បាយ ដ ២០១៣ បច្ចេកសព្ទនិងនិយមន័យយេនឌ័រ ឯកសារការងារផ្ទៃក្នុង អុកស្វាម អូស្ត្រាលី ក្រុងមេលប៊ន។

ខឺនីក, ឌ និង ឌីអារា ត ២០០២ "ឥទ្ធិពលនៃការតាំងទីលំនៅថ្មីលើធនធានទ្រព្យសម្បត្តិរួម" ដកស្រង់ក្នុង ស្កុតឌ័រ ធ ២០០៥ អនាគតទំនប់ធំៗ ការដោះស្រាយជាមួយនឹងតម្លៃ សង្គម បរិស្ថាន ស្ថាប័ន និង នយោបាយ អ៊ីរស្តែន រាជធានីឡុងដុង។

ម៉ាល់ហោត្រា អ ស៊ូល័រ ស និង ប៊ីនឌ័រ ស ២០០២ វាស់ការផ្តល់ដំណាចរបស់ស្ត្រីជាអថេរក្នុងការអភិវឌ្ឍអន្តរជាតិ ធនាគារពិភពលោក ក្រុងវ៉ាស៊ីនតោន ឌីស៊ី។

ម៉ាច ស ស្មីត អាយ និង មុខោបាធ្យាយ ម ១៩៩៩ ការណែនាំលើក្របខណ្ឌវិភាគយេនឌ័រ អុកស្វាម ចក្រភពអង់គ្លេសអក់ស្វ័ត។

មេហតា ល និង ស្រីវិណាសាន ប ២០០០ ការធ្វើឲ្យមានលំនឹងសេចក្តីទុក្ខនិងផលចំណេញ : អត្ថបទទស្សនៈស្តីពីយេនឌ័រនិងទំនប់ធំៗ គណៈកម្មការពិភពលោកស្តីពីទន្លេ អគ្គលេខាធិការដ្ឋានគណៈកម្មការពិភពលោកស្តីពីទន្លេ។

គណៈកម្មការទន្លេមេគង្គ ២០១០ ឧបករណ៍ប៉ាន់ប្រមាណយ៉ាងឆាប់រហ័សអំពីនិរន្តភាពនៃវារីអគ្គិសនីលើអាងទន្លេទាំងមូល (RSAT)ចូលមើលថ្ងៃទី១៣ខែសីហាឆ្នាំ២០១៣, http://www.mrcmekong.org/assets/Publications/Reports/RSAT-Revision-3-for-printingOCT-3-2010-Corrected-FINAL.PDF

ម៉ូស៊ឺរ យ ១៩៩៣ ការធ្វើផែនការនិងការអភិវឌ្ឍ : ទ្រឹស្តីការអនុវត្ត និង ការហ្វឹកហាត់ រូតលេតជ៍ រាជធានីឡុងដុង ការិយាល័យស្ត្រីនិងសកលវិទ្យាល័យអាដឺលេត ២០០៥ ការប៉ាន់ប្រមាណផលប៉ះពាល់លើយេនឌ័រ : ការអនុវត្តគម្រូរបស់ប្រទេសហុលឡង់ ចូលមើលថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣ http://www.officeforwomen.sa.gov.au/__data/assets/pdf_file/0013/445/Gender-Analysis-NETHERLANDS.pdf

ត្រួតពិនិត្យ អូវ៉ែរហូល យ អែនឌ័រសឹន ម.ប ខ្លោត យ អស្ទីន ជ ១៩៨៥ សៀវភៅករណីសិក្សា : តួនាទីយេនឌ័រក្នុងគម្រោងអភិវឌ្ឍន៍ រោងពុម្ព កុមារិយ័ន ក្រុងវ៉ាស៊ីនតោន ឌីស៊ី។

អុកស្វាម ២០១៣ សៀវភៅណែនាំការគ្រប់គ្រងកម្មវិធី អុកស្វាម អូស្ត្រាលី ក្រុងមេលប៊ន។

រីយ៉ូ ទិនតូ ហេតុអ្វីយេនឌ័រមានបញ្ហា រីយ៉ូ ទិនតូ ចំកាត់ក្រុងមេលប៊ន។

RSAT ២០១០ គំនិតផ្តួចផ្តើមរួមស្តីពីឧបករណ៍ប៉ាន់ប្រមាណយ៉ាងឆាប់រហ័សអំពីនិរន្តភាពនៃវារីអគ្គិសនីលើអាងទន្លេទាំងមូលគណៈកម្មការទន្លេមេគង្គ អេឌីប៊ី ដាប់ប៊្លូប៊្លូអេហ្វ រដ្ឋធានីវៀងចន្ទ។

អ៊ែសាត ២០១៣ គំនិតផ្តួចផ្តើមរួមស្តីពីឧបករណ៍ប៉ាន់ប្រមាណយ៉ាងឆាប់រហ័សអំពីនិរន្តភាពនៃវារីអគ្គិសនីលើអាងទន្លេទាំងមូល គណៈកម្មការទន្លេមេគង្គ, អេឌីប៊ី ដាប់ប៊្លូប៊្លូអេហ្វ រដ្ឋធានីវៀងចន្ទ។ (នឹងបោះពុម្ពផ្សាយ)

ស្កាដ្ឌ័រ ថ ២០០៥ អនាគតទន្លេធំៗ : ការដោះស្រាយជាមួយតម្លៃ សង្គម បរិស្ថាន ស្ថាប័ន និង នយោបាយ អ៊ីរស្តែន រាជធានីឡុងដុង។

ស៊ីមសឺន វ ២០១៣ យុត្តិធម៌យេនឌ័រក្នុងវារីអគ្គិសនី " របាយការណ៍សំយោគការពិនិត្យលើនយោបាយនិងនីតិកម្ម អុកស្វាម អូស្ត្រាលី រដ្ឋធានីមេលប៊ន។

ត្រឹង ត ក ២០០១. ការកែទម្រង់ដីនិងនិងសិទ្ធិទ្រព្យសម្បត្តិស្ត្រីនៅប្រទេសវៀតណាម។ មជ្ឈមណ្ឌលសម្រាប់យេនឌ័រ បរិស្ថាន និង ការអភិវឌ្ឍប្រកបដោយនិរន្តភាព រដ្ឋធានីហាណូយ ចូលមើលថ្ងៃ១៧ ខែឧសភា ឆ្នាំ២០១៣ http://www.pdfio.com/k-1783628.html.

អង្គការសហប្រជាជាតិ ២០០៨ ការពារ គោរព និង ដោះស្រាយៈ ក្របខណ្ឌច្បាប់សម្រាប់អាជីវកម្មនិងសិទ្ធិមនុស្ស របាយការណ៍នៃអ្នកតំណាងពិសេសអគ្គលេខាធិការលើបញ្ហាសិទ្ធិមនុស្សនិងសាជីវកម្មឆ្លងប្រទេសនិងសហគ្រាសអាជីវកម្មផ្សេងទៀត A/HRC/8/5 ខែមេសា ឆ្នាំ ២០០៨។

អង្គការសហប្រជាជាតិ ២០១០ យេនឌ័រនិងសិទ្ធិជនជាតិដើមភាគតិច ចូលមើលថ្ងៃទី១៣ខែសីហាឆ្នាំ២០១៣ http://www.un.org/esa/socdev/unpfii/documents/Briefing%20Notes%20Gender%20and%20Indigenous%20Women.pdf

អង្គការសហប្រជាជាតិ ២០១១ គោលការណ៍ណែនាំស្តីពីអាជីវកម្មនិងសិទ្ធិមនុស្ស ចូលមើលថ្ងៃទី២០ខែសីហាឆ្នាំ២០១៣ www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (យូអិនឌីភី) ២០១២ សន្ទស្សន៍វិសមភាពយេនឌ័រ ចូលមើលថ្ងៃទី២០ខែឧសភាឆ្នាំ២០១៣ http://data.un.org/DocumentData.aspx?q=HDI and id=332

ធនាគារពិភពលោក ២០០៧, ឧបករណ៍សម្រាប់ការវិភាគការកែទម្រង់គោលនយោបាយ ស្ថាប័ន នយោបាយ និង សង្គម ៖ សៀវភៅធនធានសម្រាប់អ្នកអនុវត្តការអភិវឌ្ឍ ចូលមើលឆ្នាំ២០០៧ http://siteresources.worldbank.org/EXTTOPPSISOU/Resources/1424002-1185304794278/TIPs_Sourcebook_English.pdf

ធនាគារពិភពលោក ២០១៣ ការពិនិត្យមើលវារីអគ្គិសនី ចូលមើលថ្ងៃទី១៥សីហាឆ្នាំ២០១៣ http://www.worldbank.org/en/topic/hydropower/overview

គណៈកម្មការពិភពលោកស្តីពីទន្លេ (WEA) ២០០០ ទំនប់ និងការអភិវឌ្ឍ - ក្របខណ្ឌច្បាប់ថ្មីសម្រាប់ការសម្រេចចិត្តក្នុងហេដ្ឋារចនាសម្ព័ន្ធ អ៊ីស្តែន រាជធានីឡុងដុង។

## ធនធាននានា

របាយការណ៍នេះ យោងលើក្របខណ្ឌដែលមានស្រាប់ខាងក្រោមនិងស្នើជាវិធីសាស្ត្រដែលក្របខណ្ឌទាំងនេះអាចប្រើបានរបៀបណាខ្លះក្នុងបរិបទវារីអគ្គិសនី។

បញ្ជីពេញលេញនៃក្របខណ្ឌទាំងនេះមានក្នុង ហីល(២០០៩) ការវាយតម្លៃយេនឌ័រក្នុងការរុករករ៉ែ ចំណែក ចំណុចខ្លាំងចំណុចខ្សោយ និងបរិបទដើម្បីប្រើនោះ មាននិយាយក្នុងអត្ថបទ ម៉ាច ស្មីត និង មុក្ខោបាធ្យាយ បោះពុម្ពផ្សាយដោយ អុកស្វាម ការណែនាំចំពោះក្របខណ្ឌវិភាគយេនឌ័រ (១៩៩៩)។

### ក្របខណ្ឌសម្រាប់ការវិភាគហាវីត

ក្របខណ្ឌវិភាគហាវីតពិនិត្យមើលការបែងចែកយេនឌ័រក្នុងការងារ និង បង្ហាញការងារនិងធនធានរបស់បុរសនិងស្ត្រីក្នុងសហគមន៍។ ក្របខណ្ឌនេះឆ្លុះបញ្ចាំងពីវិធីសាស្ត្រមានប្រសិទ្ធភាពក្នុងការបញ្ចូលស្ត្រីទៅក្នុងការអភិវឌ្ឍនិងបង្ហាញពីករណីសេដ្ឋកិច្ចដែលលៃធនធានសម្រាប់ស្ត្រីក៏ដូចជាសម្រាប់បុរស។

### ក្របខណ្ឌម៉ូស័រ

ក្របខណ្ឌម៉ូស័របង្កើតឡើងដោយលោកស្រី យ៉ែរ៉ូលីន ម៉ូស័រ នាដើមឆ្នាំ១៩៨០ ជាវិធីនៃការធ្វើផែនការនិងវិភាគយេនឌ័រនៅក្នុងវិធីសាស្ត្រផ្តល់អំណាចរបស់ស្ត្រី។ លោកស្រី ម៉ូស័រ បានទាមទារឲ្យមានការបញ្ចូលការធ្វើផែនការយេនឌ័រនៅគ្រប់ការងារអភិវឌ្ឍន៍ទាំងអស់ក្នុងគោលដៅរំដោះស្ត្រីចេញពីការបន្ទាបបន្ថោក និង ការទទួលបាន សមភាព ភាពស្មើមុខស្មើមាត់ និង ការផ្តល់អំណាច។

### ក្របខណ្ឌការផ្តល់អំណាចស្ត្រី (ឡុងវី)

ក្របខណ្ឌការផ្តល់អំណាចស្ត្រីបង្កើតឡើងដោយលោកស្រីសារ៉ា លូភីខាល ឡុងវី ក្នុងបរិបទនៃវិធីសាស្តផ្តល់អំណាចចោទសួរ និងចោទសួរលើការផ្តល់អំណាចអ្វី ដល់ស្ត្រីនិងសមភាពពេលអនុវត្តជាក់ស្តែង លោកស្រីវាយតម្លៃយ៉ាងជ្រៅលើទំហំនៃអន្តរាគមន៍ការអភិវឌ្ឍដែលគាំទ្រការផ្តល់អំណាចនេះ។

### អន្តរភាគភាព

ដោយបង្កើតឡើងមិនសម្រាប់ក្របខណ្ឌវិភាគសម្រាប់ការយេនឌ័រ បញ្ញត្តិកម្មរបស់លោកស្រីលើ "(អន្តរភាគភាព) intersectionality"[២០] គឺជាឧបករណ៍ប៉ាន់ប្រមាណតម្លៃមានសារៈសំខាន់ក្នុងការវិភាគយេនឌ័រ ពីព្រោះ វាវិភាគអន្តរភាគនៃទម្រង់ទាំងឡាយនៃការរើសអើងនិងការដកសិទ្ធិស្ត្រីភេទ។ វិធីសាស្ត្រនេះពិនិត្យលើទំនាក់ទំនងទៅវិញទៅមកនៃផ្នែកផ្សេងៗនៃការរើសអើងនិងការបន្ទាបបន្ថោកដែលចងក្រងជារចនាសម្ព័ន្ធឋានៈរបស់ស្ត្រីនិងបុរស។

២០. សូមមើល គ្រេន-ស, ឃ ១៩៩១, "ធ្វើផែនទីជនទទួលការយកចិត្តទុកដាក់តិចតួច ៖ អន្តរភាគភាព, នយោបាយអត្តសញ្ញាណ និង អំពើព្រៃផ្សៃ ចំពោះស្ត្រីដែលមិនមែនស្បែកស", ទស្សនាវដ្តីស្តែនហ្វត, លេខ៤៣, ទំ.១២៤១-៩៩; និង គ្រេន-ស, ឃ ២០០០, អត្ថបទគោលសម្រាប់ការប្រជុំក្រុមអ្នកជំនាញលើទិដ្ឋភាពនៃការរើសអើងពូជសាសន៍ទាក់ទងនឹងយេនឌ័រ, រៀបចំនៅរដ្ឋធានីហ្សាគ្រេប, ប្រទេសក្រូអាត, ថ្ងៃទី២១-២៤ ២០០០។

Australian Government
Department of Foreign Affairs and Trade

Australian Aid—managed by the Challenge Program on Water and Food on behalf of DFAT

Australian Aid

CGIAR Challenge Program on WATER & FOOD
Andes • Ganges • Limpopo • Mekong • Nile • Volta

OXFAM